# ប្រវត្តិសាស្ត្រកម្ពុជា

## អាណាចក្រភ្នំ ( ស.វ ទី១ ដល់ ទី៦ )

បណ្ឌិត ម.ត្រាណេ



ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
ភ្នំពេញ ព.ស ២៥៤៦ គ.ស ២០០២

www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

សៀវភៅ **អាណាចក្រនគរភ្នំ** នេះដែលជាការបោះជំហានថ្មីមួយទៀត ប្រកបដោយផលផ្លែ គួរឱ្យមោទនៈ នៅលើមាគ៌ាស្រាវជ្រាវមួយដ៏វែងឆ្ងាយ នឹងពុំអាចធ្វើឡើងបាន បើសិនជាគ្មានការចូលរួមវិភាគទានដ៏ក្លៀវក្លា ពីសំណាក់លោក បណ្ឌិត **ដារ៉ា ឆ័ត្ររិយ៉** និង លោក **ខួន ទាវ៉ន់ចន្ធី** ដែលជានាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

ដូច្នេះខ្ញុំបាទ សូមថ្លែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះប្រិយមិត្តទាំងពីរនាក់ខាងលើនេះ ដែលរមែងតែងតែដាក់តម្លៃលើវិស័យវប្បធម៌ជាតិយ៉ាងខ្ពស់ជានិច្ចជាកាល ។ សូមលោកទាំងពីរ ប្រកបតែសេចក្តីសុខសប្បាយ ជានិច្ចនិរន្តរ៍ ក្នុងដំណើរជីវិតរបស់លោក ។

ខ្ញុំសង្ឃឹមថា ស្នាដៃនេះ ពិតជានឹងក្លាយទៅជាឧបករណ៍ស្រាវជ្រាវមួយយ៉ាងសំខាន់ ចំពោះខេមរជន ក្នុងការស្វែងយល់អំពីព្រលឹងជាតិ និងអត្តសញ្ញាណជាតិរបស់ខ្លួន ពីព្រោះជាការចាំបាច់ណាស់ ដែលយើងត្រូវតែកែលំអទំព័រប្រវត្តិសាស្ត្រជាតិយើង ឱ្យកាន់តែមានភាពសុក្រិតឡើងជាលំដាប់ ដោយពឹងពាក់លើទិន្នន័យមូលដ្ឋានថ្មីៗ ដែលមានលក្ខណៈជាវិទ្យាសាស្ត្រដែលអ្នកស្រាវជ្រាវពុំធ្លាប់មានពីមុនមក ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ មេសា ឆ្នាំ ២០០២

បណ្ឌិត **មីសែល ត្រាណេ**

www.elibraryofcambodia.org

# ភាគទី១ : រូបភាពឯកសារ





www.elibraryofcambodia.org

# ភាគទី១ ៖ អត្ថបទ

www.elibraryofcambodia.org

*" នៅចំកណ្តាលតំបន់ដែលមាន វត្តារកម្មឥណ្ឌា ឥណ្ឌូចិនខាងត្បូងបានក្លាយបន្តិចម្តងៗជារដ្ឋមួយដ៏មានឥទ្ធិពលយ៉ាងខ្លាំងក្លាជាងគេ គឺរដ្ឋភ្នំ ។ ពីសតវត្សរ៍ទី២ ដល់សតវត្សរ៍ទី៦ នៃ គ.ស ព្រះរាជាណាចក្រនេះមានទីតាំងជាគោល១ នៅកម្ពុជាភាគខាងត្បូង និង នៅកូសាំងស៊ីន ( កម្ពុជាក្រោម ឬវៀតណាមខាងត្បូង បច្ចុប្បន្ន ) ហើយបានលាតសន្ធឹងដោយសន្សឹមៗនូវអានុភាពរបស់ខ្លួន ដល់ប្រទេសសៀម និងម៉ាឡេស៊ី ព្រមទាំងឆ្នេរសមុទ្រដ៏ឆ្ងាយនៃកោះជ្វា និង ភូមា ។ ប្រជាពលរដ្ឋមន-ខ្មែរ ( របស់នគរភ្នំ ) រក្សានូវស្នាមផ្តិតនៃវប្បធម៌ឥណ្ឌាយ៉ាងជ្រៅ ។ គឺនៅក្នុងពុម្ពនគរភ្នំនេះហើយ ដែលលក្ខណៈ អាស៊ី និង ទន់ឥណ្ឌាការលាយឡំចូលគ្នា ដើម្បីបង្កើតឡើងនូវ អារ្យធម៌ដ៏វិសេសវិសាលមួយ ដែលជនជាតិខ្មែរ " នាសម័យអង្គរ " ជាអ្នកទទួលមរតក " ដូនតា " បានលើកភាពរុងរឿងថ្កុំថ្កើងនេះផុតកំពូល "*

*( ឯកសារអង្គរ. មនុស្ស និង ថ្ម. ទំព័រ ១៧. ដោយ បែរណារភីលិបគ្រោលីយេ )*

# សេចក្តីសម្គាល់

ក្នុងការស្រាវជ្រាវ ដើម្បីចងក្រងសៀវភៅ " **ប្រវត្តិសាស្ត្រ អាណាចក្រភ្នំ** " ពីសតវត្សរ៍ទី១ ដល់ទី៦នៃ គ.ស នេះយើងពុំបានយកចិត្តទុកដាក់នឹងបញ្ហាដែលទាក់ទិនទៅនឹងការបង្កើតរដ្ឋមន ឈ្មោះទ្វារវតី ឬ តូឡូប៉ូទី នៃឯកសារចិននៅចុងសតវត្សរ៍ទី៦ ដើមសតវត្សរ៍ទី៧ នៃគ.ស នៅលើទឹកដីថៃបច្ចុប្បន្ន ដែលដើមឡើយជាទឹកដីរបស់ នគរភ្នំនោះទេ ។

ចំពោះយើងសមិទ្ធិផលសង្គមខាងលើនេះដែលជាព្រឹត្តិការណ៍មួយថ្មីថ្មោងសម្រាប់ ទំព័រប្រវត្តិសាស្ត្រ នៃភូមិភាគឥណ្ឌូចិនបច្ចុប្បន្ននេះ បានប្រព្រឹត្តិឡើងក្រោយពីការបែកបាក់នៃអាណាចក្រភ្នំដែលជាក្សត្ររដ្ឋនៅចុងសតវត្សរ៍ ទី៦ នៃគ.ស ។

គប្បីត្រូវដឹងថា ជនជាតិមននិងជនជាតិខ្មែរដែលស្ថិតនៅក្នុងអម្បូរភាសាមន-ខ្មែរ ដើមឡើយជាជនជាតិរួមឈាមជ័រពូជសាសន៍ជាមួយ ដូចវត្តមាននៃប្រភេទ



www.elibraryofcambodia.org

ឈាម (Hᴇ) ក្នុងរាងកាយរបស់ពួកគេជាសក្តិភាពស្រាប់ ។ម្យ៉ាងទៀតគួររំលឹកឡើងវិញផងដែរថា : ក្នុងចំណោម កុលសម្ព័ន្ធ មន-ខ្មែរ ជាច្រើនដែលបានតពូជពង្ស ពីសម័យបុរេប្រវត្តិសាស្ត្រនៅក្នុងទ្វីបឥណ្ឌូចិននេះមានតែកុលសម្ព័ន្ធ ខ្មែរ និង កុលសម្ព័ន្ធមនទេដែលបានក្លាយទៅជារដ្ឋ ឬ អាណាចក្រក្រោមឥទ្ធិពលនៃវប្បធម៌ អារ្យធម៌ ក្លិង្គនាដើមសម័យប្រវត្តិសាស្ត្រ ។

ម្យ៉ាងទៀត, យើងក៏អាចបញ្ជាក់ផងដែរថាក្នុងចំណោមបដិមាសាស្ត្រ នៃនគរភ្នំ គឺសិល្បៈបែបតាមិលេ បល្លវៈ ដែលមានអាយុចំណាស់ច្រើនជាងសិល្បៈផ្សេងៗទៀត ហើយចម្លាក់បុរាណទាំងនោះត្រូវបានគេរកឃើញ នៅខេត្តតាំងអ៉ា នៃប្រទេសថៃបច្ចុប្បន្ន។ នេះជាចំណុចចាប់ផ្តើមនៃកាលប្រវត្តិ នៃប្រវត្តិសិល្បៈ ឬប្រវត្តិសាស្ត្រកម្ពុជាដែលគេពុំសូវចាប់អារម្មណ៍ព្រោះខ្វះគំនិតសំយោគក្នុងការស្រាវជ្រាវ ។

បញ្ហាប្រវត្តិសិល្បៈខ្មែរ គឺជាបញ្ហាចម្បងមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា។ មុនការស្រាវជ្រាវរបស់យើង អ្នកស្រាវជ្រាវមួយចំនួនបានភ្លេចថា នាគ្រាបឋមនៃប្រវត្តិសាស្ត្រខ្មែរ តំបន់នានានៃឈូងសមុទ្រសៀមបច្ចុប្បន្នស្ថិតក្នុងបរិវេណ នៃដែនដីរបស់នគរភ្នំ ហើយស្ថានភាពនេះមិនបានប្រែប្រួលប៉ុន្មានរហូតដល់សតវត្សរ៍ទី១២ ដើមសតវត្សរ៍ទី១៣ នៃ គ.ស ។ មានភស្តុតាងខ្លះសម្រាប់ការសន្និដ្ឋាននេះ ដែលថាខេត្តនគរស្រីធម្មរាជ ជ័យ៉ា, កញ្ចនៈបូរី ។ល។ គឺជាអតីតទឹកដីខ្មែរ នាសម័យមុនអង្គរ និងអង្គរ ។ ការរំលឹកឡើងវិញនូវទំព័រប្រវត្តិសាស្ត្រចាស់ មិនគួរជាការភ្ញាក់ផ្អើលទេដោយមូលហេតុខាងលើ ។

ដោយឡែកសូមជម្រាបថា តាមការស្រាវជ្រាវថ្មីរបស់លោក សាស្ត្រាចារ្យ អ៊ីហ្សីហ្សាវ៉ា យើងអាចដឹងថា អវសានរបស់ អាណាចក្រនគរភ្នំពុំត្រូវបានបញ្ចប់នៅឆ្នាំ ៥៥០ នៃ គ.ស ដូចដែលអ្នកប្រវត្តិសាស្ត្រវិទូបានអះអាងពីមុននោះទេ ក៏ប៉ុន្តែ



www.elibraryofcambodia.org

ក្រោយពីឆ្នាំ៦២៧ នៃ គ.ស ។ នេះសឱ្យឃើញថា ការរួមបញ្ចូលអាណាចក្រភ្នំ និង ចេនឡាឱ្យទៅជាធ្លុងមួយនាសម័យមុនអង្គរ ដើម្បីមូលហេតុជាតិត្រូវបានធ្វើឡើង ដោយសន្សឹម១ ហើយបានប្រើពេលវេលាដ៏វែងអន្លាយ ដែលគេស្មានមិនដល់ពីមុនមក ។

ទិន្នន័យស្ថាបត្យកម្ម ក៏បង្ហាញឱ្យយើងដឹងថា រវាងឆ្នាំ៥៥០ ដល់ឆ្នាំ៦០០ នៃ គ.ស មានការដុះដាល នៃរចនាបថ ថលាបរិវ៌ត នៅខេត្តចម្ប៉ាសាក់, ក្រចេះ ស្ទឹងត្រែង និង ខេត្តច័ន្ទបូរណ៍ ( ច័ន្ទបុ៊ូន ) នៃប្រទេសថៃបច្ចុប្បន្ន ។ គឺរចនាបថសិល្បៈ ជាពិសេសក្បាច់ផ្តែរនេះហើយ ដែលបានផ្តល់កំណើតឱ្យរចនាបថសម្បូរណ៍ព្រៃគុក នៃព្រះរាជធានីឥសានបុរៈ ឬ សម្បូរណ៍ព្រៃគុកយើងនេះ ។ ទិន្នន័យទាំងនេះបង្ហាញយ៉ាងច្បាស់លាស់អំពីសារៈសំខាន់សម្រាប់យើងក្នុងការស្រាវជ្រាវអំពីវប្បធម៌ អារ្យធម៌សម័យនគរភ្នំ ដែលនឹងត្រូវបញ្ចប់នៅឆ្នាំ៦២៧ នៃ គ.ស ។ ហើយអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះមក ព្រះរាជាណាចក្រកម្ពុជាបុរាណទាំងស្រុងស្ថិតនៅក្រោមការត្រួតត្រាដឹកនាំដោយព្រះមហាក្សត្រចេនឡា ។

ជាអវសានសូមជម្រាបថាតាមគំហើញថ្មីដែលបានមកពីការស្រាវជ្រាវរបស់យើងគេអាចឃើញថា អ្វីដែលលោកសាស្ត្រាចារ្យ ហ្វ្រូលីយេ និង ប៉័រសើលីយេ មានប្រសាសន៍អំពីទំហំទឹកដីនគរភ្នំ មានលក្ខណៈត្រឹមត្រូវ សមស្របនឹងព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រពិត ក៏ប៉ុន្តែគប្បីត្រូវបញ្ជាក់បន្ថែមទៀតថា វប្បធម៌ឥណ្ឌា គ្រាន់តែបានគ្របដណ្តប់លើមូលដ្ឋានវប្បធម៌ខ្មែរ-មន ចាស់តែប៉ុណ្ណោះដែលមានវឌ្ឍនភាពខ្ពង់ខ្ពស់រួចមកហើយដូចជារូបភាពនៃសៀវភៅនេះជាសក្ខីភាពស្រាប់ ដែលបង្ហាញនូវការចាក់ឫស នៃវប្បធម៌ឥណ្ឌា និងលក្ខណៈសំយោគនៃវប្បធម៌ អារ្យធម៌ខ្មែរ ចាប់តាំងពីដើមសតវត្សរ៍ទី១ នៃ គ.ស មកម្ល៉េះ ។



www.elibraryofcambodia.org

អ្វីដែលបានជម្រាបអាចបញ្ជាក់នូវតួនាទីជាប្រវត្តិសាស្ត្រដែលទីក្រុងអង្គរបុរីធ្លាប់មានតាំងពីមុនមក ។ តែទោះបីយ៉ាងណាក៏ដោយយើងជឿជាក់ថា **វ្យាធបុរៈ** " ទីក្រុងនៃ **ទ្រមាត់ផ្ការ** " ពុំមែនជារាជធានីតែមួយគត់របស់នគរភ្នំនោះទេ ពោលគឺនៅមានរាជធានីជាច្រើនទៀត ដែលស្ថិតនៅតាមឆ្នេរសមុទ្រ ឬនៅតំបន់ផ្សេងទៀត ដែលស្ថិតនៅតាមឆ្នេរសមុទ្រ ឬនៅតំបន់ផ្សេងទៀតដែលស្ថិតនៅជិតជ្រលងភ្នំ ។

ផ្អែកលើការស្រាវជ្រាវផ្នែកបុរាណវិទ្យាថ្មីៗនេះ ក៏បានបញ្ជាក់ឱ្យយើងដឹងទៀតថា តាមពិតនគរភ្នំ គឺជារដ្ឋចម្រុះ ឬ ក្សត្រប្រទេស ។ បើនិយាយម្យ៉ាងទៀតនគរភ្នំ គឺជាលទ្ធផលផ្សំផ្គុំនៃរដ្ឋ តូច ធំ ទាំងឡាយ ដែលមានរបបនយោបាយ និង វប្បធម៌ដូចគ្នា ។

ដោយសារជាតិនៃរចនាសម្ព័ន្ធសង្គមនេះហើយ បានជាយើងឃើញនៅពេលដែលអំណាចកណ្តាលចុះទន់ខ្សោយ ដោយប្រការណាមួយនៅពេលនោះ ក៏មានការបំបែករដ្ឋពីសំណាក់នគរចំណុះខ្លះ ជាមូលហេតុដែលនាំមកនូវចម្បាំង និង ភាពវឹកវរក្នុងអាណាចក្រកម្ពុជា ។

ដើម្បីឱ្យមិត្តអ្នកអានកាន់តែយល់អំពីអាណាចក្រភ្នំ យើងសូមធ្វើសេចក្តីសំយោគ នៃប្រភពឯកសារប្រវត្តិសាស្ត្រជាច្រើនវិស័យ ដែលត្រូវរួមបញ្ចូលក្នុងការស្រាវជ្រាវនេះ និងលទ្ធផលនៃការរកឃើញនូវបុរាណវត្ថុជាច្រើន ដែលគេពុំធ្លាប់ឃើញពីមុនមក ។ ដូច្នេះយើងនឹងផ្តោតការយកចិត្តទុកដាក់របស់យើងទៅលើស្ថានីយ៍ប្រវត្តិសាស្ត្រជាច្រើន ដូចជា ស្ថានីយ៍ អង្គរបុរី អូរកែវ ចម្ប៉ាសាក់ អ៊ូថង និងស្ថានីយ៍ប្រវត្តិសាស្ត្រមួយចំនួនទៀត ដែលស្ថិតនៅតាមឆ្នេរសមុទ្រសៀម គឺដើមឡើយម៉ែកដីនេះ បានស្ថិតនៅក្នុងបរិវេណរបស់ទឹកដីនគរភ្នំ និង ចេនឡា ។

សូមរំលឹកថា នៅទីនេះយើងមិនវិភាគពីបញ្ហាវប្បធម៌មន នៃអាណាចក្រ



www.elibraryofcambodia.org

ទ្វារវតីទេ ពីព្រោះនគរនេះបានត្រូវបដិសន្ធិឡើងនៅសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ពោលគឺក្រោយពីការបែកបាក់នៃនគរភ្នំ ។

## ឯកសារមូលដ្ឋាន ស្តីពីនគរភ្នំ

នគរភ្នំជាព្រះរាជាណាចក្រខ្មែរមុនដំបូងបង្អស់ ដែលបានបង្កើតឡើងដោយឥទ្ធិពលនៃវប្បធម៌ឥណ្ឌា ឬឥណ្ឌូបនីយកម្ម នាដើមសតវត្សរ៍ទី ១ នៃគ្រិស្តសករាជ ។

ការសិក្សាអំពីនគរភ្នំ ត្រូវអាស្រ័យលើប្រភពឯកសារចិន ដែលបានសរសេរនៅសតវត្សរ៍ទី៣ នៃគ្រិស្តសករាជ ដូចជាសៀវភៅ " សាគ គូ ពេរី " នាឆ្នាំ២៨៥ នៃគ្រិស្តសករាជជាដើម ។ សូមជម្រាបថា ប្រភពឯកសារចិនដែលចាស់ជាងគេ គឺបានត្រូវកត់ត្រាឡើងដោយរាជវង្សហានខាងកើត " ១០០ឆ្នាំមុនគ្រិស្តសករាជ ១០០ឆ្នាំនៃគ្រិស្តសករាជ " ហើយក៏មានការពិពណ៌នាអំពីរដ្ឋខ្មែរដំបូងនេះដែរ ។

សូមជម្រាបថា មួយភាគធំនៃឯកសារខាងលើដែលត្រូវបានចងក្រងឡើងដោយលោក **កាំង ថៃ** និង **ជូ យីង** នៅពេលដែលគាត់បានអញ្ជើញមកធ្វើបេសកកម្មនៅនគរភ្នំ ត្រូវបានបាត់បង់ទៅហើយ ។ ប៉ុន្តែអ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រចិនបុរាណបានដកស្រង់ព្រឹត្តិការណ៍ខ្លះៗសំខាន់ៗ ដែលជាហេតុនាំឱ្យយើងអាចតាមដានដោយជាក់លាក់ នូវដំណើរការនៃប្រវត្តិសាស្ត្រកម្ពុជា តាំងពីដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជតរៀងមក ។

ប្រភពឯកសារចិនទាំងនោះ បានប្រាប់ឱ្យយើងដឹងអំពីកំណើតនៃ **នគរភ្នំ** " ឬ ហ្វូណន " បើយើងហៅតាមចិនដែលជាលទ្ធផលក្នុងការរៀបអភិសេក រវាងតាព្រាហ្មណ៍ម្នាក់ជាតិកលិង្គ ត្រកូល **កៅណ្ឌិន្យ** ដែលមកពីស្រុកឥណ្ឌាខាងត្បូង ជាមួយនាង **លីវយី** ឬ **នាងនាគ** ដែលជាអ្នកស្រុក ។ គឺការរួមសង្វាស់រវាងគូស្វាមីភរិយាដំបូងនេះ



www.elibraryofcambodia.org

ហើយ ដែលបានឱ្យកំណើតទៅជាសន្តតិវង្ស ឬព្រះរាជវង្សានុវង្សខ្មែរនៅនាសម័យក្រោយៗទាំងអស់ ។ ទន្ទឹមនឹងនេះ យើងក៏អាចជ្រាបថា ស្ពានមេត្រីភាពតាមផ្លូវពាណិជ្ជកម្មនិងការទូតរវាង នគរភ្នំ និងចក្រភពចិន បានធ្វើឡើងរវាងឆ្នាំ២៣១ នៃគ្រិស្តសករាជ ។ មិនតែប៉ុណ្ណោះកំណត់ហេតុចិនក៏បានបញ្ជាក់ឱ្យយើងដឹងពីទីតាំងរបស់នគរភ្នំ និងពត៌មានជាច្រើនទៀត ទាក់ទិននឹងប្រពៃណីខ្មែរបុរាណដែលនឹងពិភាក្សានៅបន្តិចទៀតនេះ ។

ក្រៅពីប្រភពឯកសារចិន យើងនៅមានប្រភពឯកសារមួយយ៉ាងទៀត គឺសិលាចារឹកខ្មែរនិងចាម ដែលជាមូលដ្ឋាននៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។ ការសិក្សាវិភាគនូវអត្ថបទសិលាចារឹកមានសារសំខាន់ជាអនេក ដោយហេតុថាវាអាចបញ្ជាក់នូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ដែលបានកត់ត្រាទុកឯកសារចិន ឬបំពេញនូវកង្វះខាតនានា ជាប្រយោជន៍ដល់ការស្វែងយល់អំពី អរិយធម៌ វប្បធម៌ខ្មែរបុរាណ ។

លើសពីនេះទៀត ផ្ទាំងសិលាចារឹកខ្មែរទាំងឡាយ ក៏ជាមុខសញ្ញាសម្រាប់បញ្ជាក់ឱ្យយើងដឹងអំពីអតីតបង្គោលសីមា របស់ព្រះរាជាណាចក្រកម្ពុជា នាសម័យបុរាណដែរ ដោយហេតុថាជាការពិតហោស់ ដែលកន្លែងណាមានសិលាចារឹកខ្មែរកន្លែងនោះគឺជាទឹកដីខ្មែរ ។ម្យ៉ាងទៀត វត្តមានរបស់សិលាចារឹកខ្មែរដែលសរសេរជាភាសាសំស្ក្រឹត បាលី ឬ ខ្មែរ ក៏ជានិមិត្តរូបនូវអ្វីមួយដែលយើងអាចចាត់ទុកថាជាឯកសារផ្នែកវប្បធម៌ដែរ ពីព្រោះអ្វីៗដែលបានចារឡើងនោះ ត្រូវបានធ្វើឡើងសម្រាប់ជនជាតិខ្មែរផងដែរ ឧទាហរណ៍មួយដ៏ជាក់ស្តែង គឺយើងមិនអាចបញ្ចូលនូវសិលាចារឹកទាំងអស់ដែលឃើញនៅប្រទេសថៃ ថាជាសំណង់វប្បធម៌ និង អរិយធម៌បានជាដាច់ខាត ដោយហេតុថា សិលាចារឹករបស់ជនជាតិថៃដែលចាស់ជាងគេបង្អស់ បានចារឡើងនៅសតវត្សរ៍ទី១៣ នៃគ្រិស្តសករាជ ត្រូវបានសរសេរជាភាសាថៃ តែប្រើតួអក្សរ



www.elibraryofcambodia.org

ខ្មែរ។ ទាំងនេះសឱ្យឃើញថា មុនការបង្កើតតួអក្សរថៃតាមលំនាំអក្សរខ្មែរនៅសតវត្សរ៍ទី ១៣-១៤នៃគ្រិស្តសករាជ នៅខេត្តសុខោទ័យ ជនជាតិថៃជាជនជាតិអន្តោប្រវេសន៍ ហើយជនជាតិនេះពុំទាន់មានអក្សរនៅឡើយទេ ។ យើងចង់និយាយនៅត្រង់នេះថា ជនជាតិថៃនាសម័យនោះ ស្ថិតក្នុងស្ថានភាពមួយមិនខុសពី បងប្អូនខ្មែរលើ ឬ ភ្នង សព្វថ្ងៃប៉ុន្មានទេ ឬក៏ជនជាតិខ្មែរនាសម័យមុនប្រវត្តិសាស្ត្រ ។ ក្នុងករណីនេះហើយដែល ខ្មែរយើងនៅខេត្តសៀមរាប កាលបើបានឃើញរូបចម្លាក់កងទ័ពសៀម ឬ ថៃនៅតាមប្រាសាទអង្គរវត្ត រមែងតែភ្ញាក់អោត់ថា " ភ្នំចិន " ។ តាមពិតពាក្យពីរម៉ាត់ខាងលើ នេះដែលនិយាយពីជំនាន់មួយទៅជំនាន់មួយទៀតមិនដាច់ សំដៅទៅជនជាតិនាសម័យនោះ គ្មានន័យបន្ទាបបន្ថោកទេ គឺគ្រាន់តែជាពាក្យមួយដែលគេប្រើដើម្បីប្រៀបធៀប កម្រិតវប្បធម៌ ឬក៏ពូជសាសន៍តែប៉ុណ្ណោះទេ ។ សូមកុំភ្លេចថា ជាទស្សនៈរបស់យើង ពាក្យភ្នំចិន ក៏ដូចពាក្យភ្នំខ្មែរដែរ ដែលពាក្យនេះសំដៅពួកខ្មែរដែលរស់នៅតាមព្រៃភ្នំ ឬខ្ពង់រាប ឬមួយជាខ្មែរដើមដែលបានរួមឈាមជ័រជាមួយខ្មែរតែប៉ុណ្ណោះ ។

ម្យ៉ាងទៀត ក្នុងការស្រាវជ្រាវរបស់យើងនេះ យើងនឹងផ្តោតលើការចាប់អារម្មណ៍ទៅលើវត្ថុបុរាណ ដែលជាភស្តុតាងនៃខឿនអារ្យធម៌ វប្បធម៌ខ្មែរបុរាណ និងដែលគេបានជួបប្រទះរកឃើញ មិនគ្រាន់តែនៅក្នុងខ័ណ្ឌសីមា នៃកម្ពុជាបច្ចុប្បន្ននោះទេ ដែលត្រូវបានព្រឹត្តិការណ៍នយោបាយបង្រួញឱ្យតូច ក៏ប៉ុន្តែមាននៅឯស្រុកលាវ យួន ឬ វៀតណាមខាងត្បូង និងស្រុកសៀម ឬ ថៃ ថែមទៀតផង ដែលដើមឡើយជា អតីតទឹកដីនៃព្រះរាជាណាចក្រនគរភ្នំ ឬ ចេនឡា ។

យើងមានជំនឿយ៉ាងមាំថា ធ្វើយ៉ាងនេះ យើងពិតជានឹងបានសម្រេចនូវវត្ថុបំណងដ៏ពិសិដ្ឋរបស់យើងពុំខាន គឺការស្រាវជ្រាវរាវរកភាពពិត ឬសារជាតិពិតរបស់



www.elibraryofcambodia.org

ប្រវត្តិសាស្ត្រកម្ពុជា ដែលគេបានបំភ្លេចដោយអយុត្តិធម៌បំផុត ។

សរុបសេចក្តីមក មូលដ្ឋានរបស់ប្រវត្តិសាស្ត្រកម្ពុជា មានឯកសារជាលាយលក្ខណ៍អក្សរ គឺកំណត់ហេតុចិន និងសិលាចារឹកខ្មែរ ក៏ប៉ុន្តែការចងប្រវត្តិសាស្ត្រនេះ ក៏ត្រូវពឹងផ្អែកទៅលើវត្ថុបុរាណ ដែលបានមកពីកំណាយស្ថានីយ៍ប្រវត្តិសាស្ត្រផ្សេងៗដែរ ហើយអត្ថប្រយោជន៍របស់ប្រភពឯកសារខាងលើនោះ គឺការផ្តល់ចំពោះយើងនូវព្រឹត្តិការណ៍សំខាន់ៗ ទាក់ទងពីភូមិសាស្ត្រ នយោបាយ សេដ្ឋកិច្ច អក្សរសិល្ប៍ អក្សរសាស្ត្រ សាសនា ។ល។ គួរបញ្ជាក់ថា នាសម័យរុងរឿងនៃនគរភ្នំ ព្រះរាជាណាចក្រថៃ "សៀម" និង លាវ ហើយនិងវៀតណាមខាងត្បូងពុំទាន់មានវត្តមាននៅក្នុងភូមិភាគឥណ្ឌូចិនកណ្តាលនៅឡើយទេ ហើយបណ្តាទឹកដីនៃប្រទេសទាំងនេះ ស្ថិតក្នុងបរិវេណរបស់នគរខ្មែរ និង មន ។ កំណើតនៃប្រទេសទាំងបីនេះ បានចាប់បដិសន្ធិឡើងនៅក្នុងព្រំប្រទល់នគរភ្នំទាំងអស់គឺជាព្រឹត្តិការណ៍ថ្មីក្នុងភូមិភាគឥណ្ឌូចិននាសតវត្សរ៍ទី១៣ សម្រាប់ជនជាតិថៃ លាវ និងនៅសតវត្សរ៍ទី១៧ សម្រាប់ប្រទេសវៀតណាមខាងត្បូង ។ រីឯនគរមនវិញ ដែលជាអ្នកស្ថិតនៅក្នុងអម្បូរជាមួយខ្មែរ គឺរដ្ឋនេះហើយដែលបានកកើតឡើងនៅសតវត្សរ៍ទី៧ ក្រោយពីការបាក់បែកនៃនគរភ្នំ ដូចយើងបានពោលរួចមកហើយ ។

នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលគេត្រូវតែដឹងក្នុងការស្រាវជ្រាវរកឫសគល់វប្បធម៌ខ្មែរ បើពុំដូច្នោះទេ ការសិក្សានិងការធ្វើវិភាគអំពី ប្រវត្តិសាស្ត្រកម្ពុជានឹងពុំអាចមានលក្ខណៈពេញលេញឡើយ ។

គួររំលឹកដែរថា វឌ្ឍនភាព អរិយធម៌ វប្បធម៌ របស់នគរភ្នំ បណ្តាលមកពីការទំនាក់ទំនងរបស់ក្សត្រ នូវរបៀបរៀបចំស្រុកទេស ដែលមានរបបរាជានិយមជាមូលដ្ឋាន និងពាណិជ្ជកម្មតាមផ្លូវសមុទ្រ និងទន្លេនានា នៅដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ដែល



www.elibraryofcambodia.org

ជាថាមពលសម្រាប់ជំរុញការអភិវឌ្ឍន៍ និងទំនាក់ទំនងរវាងឈ្មួញសមុទ្រសៀមសព្វថ្ងៃ ដែលអ្នកដំណើរនិងពាណិជ្ជករអារ៉ាប់នៅសតវត្សរ៍ទី១០-១១ បានឱ្យឈ្មោះថា ឈ្មួញសមុទ្រខ្មែរ និងឈ្មួញសមុទ្រចិននៅសម័យនោះអមដោយកំពង់ផែជាច្រើនផង ដែលជាកត្តាមួយសម្រាប់បង្រួបបង្រួមកុលសម្ព័ន្ធទាំងឡាយ ដែលរស់នៅយ៉ាងកុះករជាធ្លុងមួយតាមដែនដីសណ្ត និងតាមវាលទំនាបក្រោមការគ្រប់គ្រងនៃព្រះរាជា ។ លើសពីនេះទៀត គេក៏អាចសន្ពោលដែរថា វិស័យសេដ្ឋកិច្ចនេះជាកត្តាមួយអាចនាំមកនូវ ឯកភាពជាតិផ្អែកវប្បធម៌ និងសាសនានៅក្នុងភូមិភាគនេះ ។

រួមសេចក្តីមក ភាពរុងរឿងរបស់នគរភ្នំ គឺនយោបាយ និងសេដ្ឋកិច្ចទីផ្សារ ដោយមានការប្រើជាលើកដំបូងនូវប្រាក់កាក់ " លុយ " ក្នុងវិស័យពាណិជ្ជកម្មតាមបែបក្លិង្គ និង ចិន ។ ក្នុងព្រឹត្តិការណ៍មួយទៀត ដែលត្រូវតែយកចិត្តទុកដាក់នោះ គឺការរកឃើញនូវជាតិដែកនាសតវត្សរ៍ទី៥ នៃគ្រិស្តសករាជ និងការប្រើប្រាស់វាដែកនេះជាការបដិវត្តន៍ផ្អែកបច្ចេកទេសមួយយ៉ាងសំខាន់បំផុត សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច ដូចជាការផលិតគ្រឿង និងឧបករណ៍ មានជា កណ្តៀវ ផាល នង្គ័ល ពូថៅ កាំបិត...ជាដើម សម្រាប់វិស័យកសិកម្ម ឬក៏ជាអាវុធសម្រាប់ការពារសន្តិសុខនិងកុលសម្ព័ន្ធតូច ធំនានា ហើយគេក៏ដឹងដែរថាដែកនេះបានត្រូវពន្ធ និងពង្រីកនៅសម័យនគរភ្នំ ប្រយោជន៍នឹងធ្វើឱ្យសង្គមខ្មែរកាន់តែរុងរឿងឡើងជាលំដាប់ ។

ការរកឃើញស្ថានីយ៍ប្រវត្តិសាស្ត្រ ដែលមានចំនួនច្រើនលើសលប់ជាងមួយរយនៅកម្ពុជាក្រោម និងមិនតិចជាង២០ នៅស្រុកសៀមសព្វថ្ងៃដោយឥតគិតនៅប្រទេសកម្ពុជាក្នុងនោះផង បានបង្ហាញឱ្យយើងដឹងថា នៅតាមមាត់សមុទ្រមានប្រជាជនមករស់នៅយ៉ាងច្រើន គឺនៅទីនោះហើយដែលវប្បធម៌ អរិយធម៌ឥណ្ឌាបានហូរចូលបន្តិចម្តងៗលាតសន្ធឹងទូទាំងអតីតទឹកដីខ្មែរ ។ ម្យ៉ាងទៀតរូបភាពថតពីលើ



www.elibraryofcambodia.org

អាកាសក៏បានបញ្ជាក់ពីសកម្មភាពតាមឆ្នេរសមុទ្រដែរ ដោយបង្ហាញឱ្យយើងឃើញនូវវត្ថុមានរបស់ប្រព័ន្ធទឹក ឬបណ្តាញផ្លូវទឹកខ្វាត់ខ្វែង ដូចជាព្រែក ស្ទឹង ដែលជីកឡើងដោយបុព្វបុរសខ្មែរនៅម្តុំអូរកែវ ច័ន្ទបុរី...។ល។

វឌ្ឍនភាពផ្នែកសង្គមកិច្ច ដែលបណ្តាលមកពីពាណិជ្ជកម្មរវាងខ្មែរ និងបរទេស ក៏បានលើកស្ទួយជីវភាពរបស់អ្នកស្រុក នៅឆ្នេរសមុទ្រឱ្យកាន់តែខ្ពស់ឡើងជាលំដាប់ ដូចជាការរកឃើញនូវវត្ថុបុរាណ ដែលបានវិភាគខាងលើជាសក្ខីភាពស្រាប់ ។ យើងនឹងខិតខំប្រមែប្រមូលនូវសក្ខីកម្មទាំងឡាយ ដើម្បីជាភស្តុតាងក្នុងការស្រាវជ្រាវនេះ ។

សូមបញ្ជាក់ថា ដើមឡើយក្នុងបរិវេណទឹកដីមួយដ៏ធំធេង ដែលនឹងក្លាយជានគរភ្នំ មានកុលសម្ព័ន្ធជាច្រើនគ្រប់គ្រងដោយមេកន្ទ្រាញ ។ នៅដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ កុលសម្ព័ន្ធទាំងអស់ដែលស្ថិតក្រោមឥទ្ធិពលក្លិង្គនោះ បានផ្តុំផ្គុំគ្នាជារដ្ឋមួយមានអំណាចកណ្តាល ដែលមានព្រះរាជាជាប្រមុខ ។ ម្យ៉ាងទៀតវត្ថុមានព្រះរាជាបង្ហាញឱ្យយើងដឹងថា ខ្មែរនាសម័យនោះ បាននូវរបៀបគ្រប់គ្រងតាមឥណ្ឌា ឬរចនាសម្ព័ន្ធក្លិង្គ ។ រីឯទំនៀមទម្លាប់ក៏មានការវិវត្តន៍តាមរបៀបថ្មីដែរ ពោលគឺពីមុនគ្រិស្តសករាជ ប្រជាជនខ្មែរទូទៅរមែងមានទម្លាប់កប់ខ្មោចឥឡូវនេះ គេបែរជានាំគ្នាបូជាសពទៅវិញ ដោយតម្រូវតាមពិធីព្រហ្មញ្ញសាសនានិងពុទ្ធសាសនា ដែលមានមហាក្សត្រខ្មែរ និងនាម៉ឺនសព្វមុខមន្ត្រីបានខ្ចីពីក្លិង្គ ។ ក្នុងវិស័យអក្សរសាស្ត្រវិញ ខ្មែរយើងបានខ្ចីតួអក្សរបល្លវៈ ដែលមានប្រភពពីឥណ្ឌាខាងត្បូង សម្រាប់ធ្វើជាអក្សរផ្ទាល់ខ្លួនដែរ ។ ទាំងនេះសឱ្យឃើញថា បុព្វបុរសខ្មែរស្ថិតក្រោមអានុភាពរបស់វប្បធម៌ក្លិង្គយ៉ាងប្រាកដ ។

ដោយសង្ខេបយើងអាចសន្និដ្ឋានថា ក្នុងការបង្កើតរដ្ឋភ្នំ និងការអភិវឌ្ឍន៍



www.elibraryofcambodia.org

វប្បធម៌សាសនាខ្មែរនៅគ្រាដំបូង គ្រប់ភូមិភាគនៃប្រទេសឥណ្ឌាបច្ចុប្បន្ន ឬ មហាជម្ពូទ្វីប បានចូលរួមវិភាគទានសឹងតែទាំងអស់ តាមរយៈអ្នកជំនួញជួញប្រែដែលបានចាកចេញពីកំពង់ផែធំៗនាសម័យនោះ ។ តែទោះបីយ៉ាងណាក៏ដោយក៏ខ្មែរនៅតែរក្សាបាននូវអត្តសញ្ញាណជាតិរបស់ខ្លួនដែរ ដោយហេតុថា វប្បធម៌ក្លិង្គគ្រាន់តែពង្រីក និងពង្រីកនូវវប្បធម៌ដើមរបស់ខ្មែរតែប៉ុណ្ណោះ ។

## រឿងព្រេងដែលទាក់ទងនឹងនគរភ្នំ

ដើមកំណើតនៃប្រវត្តិសាស្ត្រខ្មែរ ត្រូវបានបញ្ជាក់ដោយរឿងព្រេងមួយដែលកត់ត្រាដោយអ្នកការទូតចិនម្នាក់ឈ្មោះ **កាំង ថៃ** ដែលបានអញ្ជើញមកនគរភ្នំផ្ទាល់ក្នុងរជ្ជកាល **វូ** នៅដើមសតវត្សរ៍ទី៣ នៃគ្រិស្តសករាជ ។ តាមពិតរឿងនេះជាទេវកថាសំខាន់មួយដូចមានខ្លឹមសារតទៅនេះ :

" **ហ៊ុន ទេង** ( ហ៊ុន ទៀន ឬ កៅណ្ឌិន្យ ) គោរពបូជាព្រះអាទិទេព ( នៃព្រហ្មញ្ញសាសនា ) ជានិច្ចកាល ដោយមានជំនឿមោះមុតក្រៃលែង ។ (ដូច្នេះ) ព្រះអាទិទេព សព្វព្រះទ័យចំពោះទឹកចិត្តសទ្ធាជ្រះថ្លាដ៏ជ្រាលជ្រៅនេះពេកស់ ។ យប់មួយ **ហ៊ុន ទៀន** ដេកយល់សប្តិឃើញអ្នកតាឱ្យធ្នូទិព្វមួយទៅគាត់ ហើយបញ្ជាទៅគាត់ឱ្យឡើងសំពៅជំនួញមួយយ៉ាងធំ ដើម្បីធ្វើដំណើរចេញទៅ ។

ក្រោយពីភ្ញាក់ដឹងខ្លួនឡើង **ហ៊ុន ទៀន** ក៏បានឃើញធ្នូនេះនៅមុខអាសនៈ ហើយក៏យកធ្នូធ្វើដំណើរចេញតាមសំពៅដ៏ធំមួយកាត់សមុទ្រវែងអន្លាយ ។ ឃើញដូច្នោះ ទេវតាក៏បានបង្កើតខ្យល់ឡើងដើម្បីជម្រុញនាវានេះ ឱ្យបើកមកកាន់ ហ្វូ ណន (នគរភ្នំ) ។

ដោយសារនាង **លីវ យី** មានបំណងប្លន់យក ( ទ្រព្យសម្បត្តិផ្ទុកក្នុងនាវា



www.elibraryofcambodia.org

នោះ) បានជា ហ៊ុន ទៀន លើកធ្នូឡើងបាញ់សរធ្វើឱ្យទូករបស់ លីវ យី ធ្លុះពីម្ខាងទៅម្ខាងទៀត ។ ឃើញការដូច្នេះនាង លីវ យី ភ័យតក់ស្លុតជាខ្លាំង ហើយក៏ សុខចិត្តចុះចាញ់ ។ ហ៊ុន ទៀន បានក្លាយខ្លួនជាស្តេចនៅនគរ ហ្វូ ណាន ( នគរភ្នំ ) ។

សូមជម្រាបថា នៅមានរឿងមួយទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងរឿងព្រេងខាងលើនេះដែរ បានដំណាលថា : " ហ៊ុន ទៀន បានមកដល់រាជធានី ហ្វូណាន ( នគរភ្នំ ) ដោយផ្លូវទឹក ។ លីវ យី បញ្ជាទ័ពដើម្បីច្បាំងទប់ទល់នឹង ហ៊ុន ទៀន ។ ហ៊ុន ទៀន បានលើកធ្នូឡើងបាញ់ ។ លីវ យី ភ័យខ្លាចហើយក៏បានសុខចិត្តចុះចាញ់ ។ ដូច្នេះបានជា ហ៊ុន ទៀន យក លីវ យី ធ្វើប្រពន្ធ និងកាន់កាប់ព្រះរាជាណាចក្រ ហ្វូណាន ( នគរភ្នំ ) នេះទៅ " ។

សូមរំលឹកឡើងវិញថា រាជទូតចិន កាំង ថៃ បានប្រមូលឯកសារមួយចំនួនធំស្តីពីនគរភ្នំ និងនគរផ្សេងៗ ដែលស្ថិតនៅជិតខាងប្រទេសខ្មែរ ុចជាប្រទេសឥណ្ឌាជាដើម ។ ស្នាដៃរបស់លោកត្រូវបាត់បង់ទៅ ក៏ប៉ុន្តែជាភ័ព្វសំណាងវិញពីព្រោះអ្នកប្រវត្តិសាស្ត្រចិនជំនាន់ក្រោយ បានដកស្រង់នូវកំណត់ហេតុផ្សេងៗចេញពីស្នាដៃរបស់លោក ដើម្បីយកទៅប្រើប្រាស់ក្នុងឯកសាររបស់ពួកគេ ។

តាមពិតការវិភាគខ្លឹមសារនៃរឿងព្រេងនេះ បានផ្តល់ចំពោះយើងនូវពតិមានសំខាន់ៗពីរគឺ :

ទី១ - ប្រភពនៃអំណាច ដែលមានលក្ខណៈពិសិដ្ឋរបស់ព្រះរាជា ដែលបញ្ជាក់ដោយឫទ្ធានុភាពរបស់ធ្នូទិព្វសម្រាប់គ្រប់គ្រងផែនដី ។

ទី២ - កំណើតនៃសន្តតិវង្សខ្មែរ តាមរយៈការរៀបចំពិធីអភិសេករវាងព្រាហ្មណ៍កៅណ្ឌិន្យ ជាមួយនាង លីវ យី ឬ នាងសោមាដែលជាអ្នកស្រុក ។

រួមសេចក្តីមករឿងព្រេងដែលបង្ហាញខាងលើនេះមានលក្ខណៈជាប្រវត្តិ-



www.elibraryofcambodia.org

សាស្ត្រ ពីព្រោះវាបង្ហាញនូវកំណើតរបស់អ្នកស្រុក និងព្រះរាជវង្សានុវង្សខ្មែរ ដែលបាន ចាប់បដិសន្ធិឡើងនៅដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ហើយម្យ៉ាងទៀត វត្ថុបំណង របស់វា គឺការលើកតម្លៃយ៉ាងខ្ពស់នូវ របបរាជានិយម ។

មួយវិញទៀត សូមរំលឹកថា សិលាចារឹក មី សឺង ដែលជាសិលាចារឹកសរសេរជំនួ ជាតិចាម ក្នុងឆ្នាំ ៦៥៨ នៃគ្រិស្តសករាជ ក៏បាននិយាយអំពីព្រះរាជវង្សានុវង្សខ្មែរនា សម័យចេនឡាថា : " ព្រាហ្មណ៍កៅណ្ឌិន្យ បានដោតច្នូដែលបានមកពីព្រាហ្មណ៍ក្នុង ប្រទេស ភវបុរៈ " ។ ការពិពណ៌នាខាងលើ មានន័យថាព្រាហ្មណ៍កៅណ្ឌិន្យ បាន គ្រប់គ្រងដែនដីនេះ ។ តាមសិលាចារឹកដដែល បានបន្ថែមទៀតថា ក្រោយពីនោះ ព្រាហ្មណ៍ កៅណ្ឌិន្យ បានធ្វើរាជាភិសេកជាមួយនាង សោមា ។ គប្បីបញ្ជាក់នៅត្រង់ នេះថា ប្រទេសភវបុរៈ គឺជាអាណាចក្រចេនឡា ម្យ៉ាងទៀតព្រឹត្តិការណ៍នេះ ត្រូវបាន ប្រព្រឹត្តិឡើងមុនឆ្នាំ៦០៧ នៃគ្រិស្តសករាជ ។

រីឯសិលាចារឹកបក្សីចាំក្រុង ដែលចារឹកទុកនៅខេត្តសៀមរាប នាឆ្នាំ៩៤៨វិញ ក៏បានឱ្យដឹងអំពីព្រះរាជាចុងក្រោយនៃព្រះរាជាណាចក្រនគរភ្នំគឺព្រះបាទ រុទ្រវម៌្ម ដែលបានបន្តរាជបល្ល័ង្កពីព្រះបាទ កៅណ្ឌិន្យ និង នាងសោមា ។ សូមរំលឹកឡើងវិញ ថា ក្រោយពីរជ្ជកាលរបស់ព្រះបាទ កៅណ្ឌិន្យ និងជ័យវម៌្ម នាឆ្នាំ ៤៧៨ - ៥១៤ នៃ គ្រិស្តសករាជ គេឃើញមានសម័យកាលពីរ ។

## ១ - ន័យរបស់ ពាក្យ ហ្វូ ណន

យើងរាល់គ្នាដឹងហើយថា អាណាចក្រដែលសំខាន់បំផុតនៃអាស៊ីអាគ្នេយ៍ ដែលកាទតាំងឡើងក្នុងសតវត្សរ៍ទី១ និងសតវត្សរ៍ទី៧ នៃគ្រិស្តសករាជគឺអាណាចក្រ ហ្វូ ណន ។តើពាក្យនេះមានប្រភពចេញមកពីណា?

សូមជម្រាបថា ពាក្យ ហ្វូ ណន មកពីពាក្យខ្មែរ ភ្នំ ហើយរីដែលភាសាខ្មែរ



www.elibraryofcambodia.org

បច្ចុប្បន្នហៅថា ភ្នំ នៃព្រះរាជារបស់នគរខ្មែរនាសម័យបុរាណ ដែលទ្រង់មានព្រះនាម ជាភាសាសំស្ក្រឹតថា បព៌តភូបាល ឬសៃលរាជ ។ បើដូច្នេះ បានន្តរនាម កុរុង ( ក្រុងរឺ) មានន័យថា ស្តេចភ្នំ ។

## ២ - ទីតាំងរបស់ នគរភ្នំ

ស្តីពីបញ្ហារបស់នគរភ្នំ មានមតិជាច្រើនដែលផ្ទុយគ្នា តែទោះបីយ៉ាងណាក៏ដោយ ក៏យើងត្រូវពឹងផ្អែកលើការអធិប្បាយ របស់អ្នកប្រវត្តិសាស្ត្រចិនបុរាណជាមូលដ្ឋាន ។ ទីតាំងនិងព្រះនាមរបស់ព្រះមហាក្សត្រខ្មែរមួយចំនួនធំនាជំនាន់នោះដែលបានគ្រប់គ្រងប្រទេស ត្រូវបានគេស្គាល់តាមកំណត់ហេតុចិន ក្នុងរាជវង្សឈិន " ឆ្នាំ ២៦៥ - ២៨៣ នៃគ្រិស្តសករាជ " និងសិលាចារឹកខ្មែរ ។

នៅសម័យកាលទីតាំងនៅតាមដងទន្លេ នគរភ្នំ បានលាតសន្ធឹងទៅដល់ប្រទេស លិន យី លើភាគកណ្តាលរបស់ប្រទេស ចាម្ប៉ា ដែលសព្វថ្ងៃបានក្លាយជាប្រទេសវៀតណាម នៅទិសខាងលិចប្រមាណជា ៣.០០០ លី ។ នេះជាសេចក្តីអធិប្បាយបានមកពីឯកសារចិនដែលមានដូចខាងក្រោមនេះ :

នគរភ្នំ ឬ ព្រះរាជាហោចក្រ ហ្វូ ណាន ស្ថិតនៅខាងលិចហើយឆ្ងាយពីប្រទេស លិន យី ឬ ចាម្ប៉ា ៣.០០០ លី ហើយមានចម្ងាយ ៧.០០០ លី ពីហ្សេណាន់ ឬតុងកឹង ។ ឯកសារចិនបានបន្ថែមទៀតថា នគរភ្នំ " ដើមឡើយមានទំហំតែ ៣.០០០ លី តែក្រោយមកនេះត្រូវពង្រីកឡើងទៅដល់ ៦.០០០ លី " ។

ម្យ៉ាងទៀត នគរភ្នំបានស្ថិតក្នុងឈូងសមុទ្រដ៏ធំ និងមានទន្លេមួយហូរចេញពីទិសពាយ័ព្យទៅចាក់ក្នុងសមុទ្រ ។

បើយើងយោងលើការពិពណ៌នារបស់ចិននោះ យើងនឹងអាចដឹងថា អតីតនគរភ្នំស្ថិតនៅឆ្ងាយពីប្រទេសចម្ប៉ាប្រមាណជា ១.៧២៨ គីឡូម៉ែត្រ ដោយហេតុថា :-



www.elibraryofcambodia.org

មួយលីមានប្រវែង ៥៧៦ម៉ែត្រ ។ តាមពិតប្រវែងខាងលើនេះ គឺសមហេតុផលណាស់ ពីព្រោះប្រទេស ខ្មែរ លាវ ថៃ ផ្នែកកណ្ដាល និង វៀតណាមខាងត្បូង ស្ថិតក្នុងបរិវេណនៃទឹកដីរបស់នគរភ្នំទាំងអស់ ។ រីឯឈូងសមុទ្រ និងទន្លេដែលបានអធិប្បាយដោយជនជាតិចិនបុរាណ គឺពិតជាឈូងសមុទ្រថៃសព្វថ្ងៃ និងទន្លេសាប ឬទន្លេមេគង្គ ដែលនាំទឹកហូរទៅ ចាក់ឈូងសមុទ្រចិនផ្នែកកម្ពុជាក្រោម ដែលស្ថិតត្រង់វាលទំនាបខាងក្រោមនៃទន្លេមេគង្គ ។

គប្បីបញ្ជាក់នៅត្រង់នេះថា ក្នុងសម័យបុរាណព្រំប្រទល់ដីនៃអតីតនគរខ្មែរពុំទាន់មានលក្ខណៈដូចសព្វថ្ងៃនៅឡើយទេ ពោលគឺពុំទាន់បោះបង្គោលសីមាច្បាស់លាស់ទេ ។ បើយើងនិយាយបន្តទៀត បរិវេណនៃនគរខ្មែរមានការវិវឌ្ឍន៍ជានិច្ចកាល តម្រូវតាមព្រឹត្តិការណ៍នយោបាយ សេដ្ឋកិច្ច និង សាសនា វប្បធម៌ ។ ទស្សនៈនេះគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ វាជាការធម្មតាទេដែលទំហំដែនដីខ្មែរ រមែងតែងទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងប្រព័ន្ធសេដ្ឋកិច្ច ឬ នយោបាយ ។ យើងនិយាយត្រង់នេះថា នៅពេលណាដែលអំណាចកណ្ដាលបានរឹងប៉ឹងមាំមួន ពេលនោះគ្មានការបំបែករដ្ឋទៅជាអប្បគមន៍ទេ តែផ្ទុយទៅវិញនៅពេលណាអំណាចកណ្ដាលមានភាពរីករវរ រំជើបរំជួលដោយបុព្វហេតុណាមួយ គឺនៅពេលនោះហើយ ដែលពិតជាមានវិបត្តិនយោបាយពុំខាន និងជាហេតុធ្វើឱ្យប្រទេសបាត់បង់នូវឯកភាព ។

ក្នុងករណីនេះហើយ ដែលយើងអាចសន្និដ្ឋានតាមឯកសារចិនថា អាណាចក្រភ្នំបានលាតសន្ធឹងពី ៣.០០០ លី ទៅដល់ ៦.០០០ លី នៅក្នុងសម័យកាលដែលប្រទេសនេះស្គាល់នូវភាពរុងរឿង ថ្កុំថ្កើងកប់កំពូល ។ ចំពោះបញ្ហានេះ យើងនឹងអធិប្បាយឱ្យបានវែងឆ្ងាយនៅក្នុងទំព័រខាងមុខនេះ ។

ប្រភពឯកសារចិនរបស់លោក វ៉ាន់ ធីន ដែលមានជីវិតនៅឡើយ ក្នុង



www.elibraryofcambodia.org

សតវត្សរ៍ទី៨ នៃគ្រិស្តសករាជ បានសរសេរថា អាណាចក្រភ្នំតាំងនៅទិសខាងកើតពីប្រទេស លិន យី ប្រមាណ ៣.០០០ លី ។ នគរភ្នំ គឺជាប្រទេសឯករាជ្យ ហើយមានមន្ត្រីខាងស្តាំ និង ឆ្វេង ។ ក្រៅពីនេះនគរភ្នំ ជាប់តពី លិន យី ទាំងជើងគោក និងជើងទឹក លើសពីនេះទៀត ប្រទេសទាំងពីរធ្លាប់ជួបគ្នាទៅវិញទៅមកផង ។

ក្នុងព្រឹត្តិការណ៍មួយទៀត ប្រភពឯកសារចិនបានឱ្យយើងដឹងថា ប្រទេសនេះមានទីក្រុងជាច្រើនដែលព័ទ្ធដោយកំពែងឥដ្ឋ ព្រះរាជវាំង និងផ្ទះសម្បែងដ៏ច្រើន ។ មនុស្សនៅក្នុងស្រុកនេះមិនចេះស្លៀកពាក់ទាល់តែសោះ ។ គេធ្វើស្រែចំការ គេចូលចិត្តឆ្លាក់តុបតែង ហើយដាប់ក្បាច់ក្បូរលើ មាស ប្រាក់ ។ វត្ថុជាច្រើនដែលពួកគេប្រើប្រាស់ធ្វើអំពីប្រាក់ ។ គេបង់ពន្ធដារ នឹង មាស ប្រាក់ គុជ និង ទឹកអប់ ។ ពួកគេមានគម្ពីរសៀវភៅ និងឃ្លាំងសម្រាប់តម្កល់ឯកសារ ។ តួអក្សររបស់ពួកគេមានលក្ខណៈ ដូចពួកហ៊ូ (ឥណ្ឌា) ។

## គោលការណ៍រុងរឿងថ្កុំថ្កើងរបស់ នគរភ្នំ

វឌ្ឍនភាពនៃនគរភ្នំ បណ្តាលមកពីសេដ្ឋកិច្ចអន្តរជាតិ នៅដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ដោយហេតុថា ទាសអ័យបុរាណឈ្មួងសមុទ្រទាំងប៉ុន្មានរបស់ខ្មែរ គឺជាកន្លែងដែលមាន សំពៅបរទេសឥណ្ឌា និងចិន អាចមកចតដើម្បីទិញដូរ ។ម្យ៉ាងទៀត កំពង់ផែបុរាណទាំងនោះ មានសារសំខាន់ជាអនេកសម្រាប់ជនបរទេស ដើម្បីឈប់សម្រាកមុននឹងធ្វើដំណើរតទៅមុខទៀត គឺចេញពីស្រុកខ្មែរទៅកាន់ស្រុកចិន ឬ ពីប្រទេសចិនឆ្ពោះទៅកាន់ប្រទេសឥណ្ឌាវិញ ។ ភូមិសាស្ត្រនៃនគរភ្នំ ដែលស្ថិតនៅចំកណ្តាលរវាងចិននិងឥណ្ឌានេះហើយ ដែលជាកត្តាធ្វើឱ្យប្រទេសនេះមានភាពថ្កុំថ្កើង រុងរឿង ។

នៅលើទឹកដីនគរភ្នំ ព្រះរាជាខ្មែរបានចាត់ចែងឱ្យមានប្រព័ន្ធទឹកនៅគ្រប់ទិស



www.elibraryofcambodia.org

ទីទាំងអស់ ដូចជាត្រពាំង ស្រះ និង ព្រែក ដើម្បីងាយស្រួលដាំដុះធ្វើស្រែចំការ និងធ្វើចរាចរណ៍តាមផ្លូវទឹក ។ រូបភាពដែលគេបានថតពីលើអាកាសដោយយន្តហោះ បង្ហាញឱ្យយើងឃើញនូវប្រព័ន្ធទឹកដ៏ខ្វាត់ខ្វែងទាំងនោះ ដែលជាមូលដ្ឋានសេដ្ឋកិច្ច ។

ភាពចម្រើនលូតលាស់នៃព្រះរាជាណាចក្រខ្មែរនេះ ត្រូវឆ្លុះបញ្ចាំងដោយវត្ថុបុរាណជាច្រើន ដូចជាគ្រឿងអលង្ការជា ប្រាក់ ត្បូង ត្រា ស្លាបត្បូងកម្ម រូបចម្លាក់ ភាជន៍ ដែលមាន ក្បូរក្បាច់រចនាយ៉ាងល្អប្រណិត ។ តាមពិត វត្ថុបុរាណទាំងអស់នេះ គឺជាភស្តុតាងមួយយ៉ាងសំខាន់ដែលបញ្ជាក់នូវ ទំនាក់ទំនងរវាងខ្មែរនិងក្លិង្គ ព្រមទាំងប្រទេសអ៊ីតាលីបុរាណផង ។ តែទោះបីយ៉ាងណាក៏ដោយ កសិកម្មក្នុងភូមិភាគនេះ ក៏ជាមូលដ្ឋាននៃវឌ្ឍភាពរបស់នគរភ្នំដែរ ។

អំណាចកណ្ដាល រីងប៉ឹង មាំមួន ក៏អាស្រ័យលើកសិកម្មនេះដែរ ដែលជាមូលដ្ឋាននៃខឿនសេដ្ឋកិច្ចខ្មែរ ជាពិសេស គឺនៅក្នុងភូមិភាគដែនដីសណ្ដនេះហើយដែលជាកន្លែងមានជីវជាតិបំផុត ដែលជាហេតុនាំឱ្យមានការរីកដុះដាលនូវប្រជាពលរដ្ឋ តាំងតែពីសម័យបុរេប្រវត្តិសាស្ត្រម្ល៉េះ ។ រួមសេចក្ដីមក ក្នុងការបង្កើតរដ្ឋខ្មែរឥឡូវនេះ កត្តាជាមូលដ្ឋានខាងលើនេះ ក៏បានរួមចំណែកយ៉ាងសំខាន់បំផុតដែរ ។ ម្យ៉ាងទៀត សហគមន៍មនុស្សដែលបានដុះដាលជាភូមិស្រុក ក៏បានរីកសុះសាយនៅក្នុងភូមិភាគនេះ នៅតាមបណ្ដោយទន្លេមេគង្គ តាំងតែពីមុនសម័យក្លិង្គចូលស្រុកម្ល៉េះ ។

ដោយហេតុនេះ មាស ប្រាក់ កែវកង បានមកពីសេដ្ឋកិច្ចទីផ្សារ ដែលជាទ្រព្យសម្បត្តិមិនដែលមានពីមុនសោះនាសតវត្សរ៍ទី៣ នៃគ្រិស្តសករាជ ព្រះរាជា ផាន ឆេ ម៉ាន បានពង្រីកអំណាចរបស់ខ្លួន តាមរយៈការស្ថាបនានាវាចម្បាំង ។ កងទ័ពសមុទ្រខ្មែរ បានបង្ក្រាបតំបន់មេណាម ព្រមទាំងភាគខាងជើងនៃជ្រោយម៉ាឡាកា ។ ដូច្នេះការដែលបានគ្រប់គ្រងតំបន់នេះ ពុំមែនឥតមានអត្ថប្រយោជន៍សម្រាប់អំណាចកណ្ដាល



www.elibraryofcambodia.org

របស់ខ្មែរនោះទេ ។ ព្រះមហាក្សត្រខ្មែរនាសម័យនោះទ្រង់ចាប់ផ្តើមយល់ថា ភូមិភាគនេះជាយុទ្ធសាស្ត្រមួយសំខាន់បំផុត សម្រាប់ត្រួតត្រាផ្លូវទឹកឆ្លងកាត់ បូរជីក្រា ដែលពួកឈ្មួញរមែងតែប្រើប្រាស់ ដើម្បីចៀសវាងបកមកក្រោយវិញតាមរយៈ ដែសមុទ្រ ម៉ាឡាកា ។ ដោយសារឥទ្ធិពលដ៏ខ្លាំងក្លានេះហើយ ទើបព្រះបាទ ផាន ឆេម៉ាន់ បានចងស្ពានមេត្រីតាមផ្លូវទូតជាមួយរាជាណាចក្រ រ៉ូ នៅ ណាង-កាំង ប្រទេសឥណ្ឌា អ៊ី រ៉ាន និងជាពិសេសរាជវង្សមុរុណ្ឌប្រទេសដែលស្ថិតនៅទិសបូព៌ានៃ សមុទ្រ មេឌីទែរ៉ាណេជាដើម ។ នៅត្រង់នេះយើងសូមលើកយកកាក់រូបម៉ាំង ជាច្រើន មកធ្វើជាវត្ថុតាង នៃទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ដូចជា កាក់រូបស្តេច សេហ្សា នៅអង្គរបុរី ជាដើម កាក់រូបស្តេច អាងតូណាំង នៅអូរកែវកម្ពុជាក្រោម និងកាក់រូបម៉ាំងមួយចំនួន ទៀតនៅខេត្ត កញ្ចនៈបុរីនៃប្រទេសសៀមសព្វថ្ងៃនេះ ។

ម្យ៉ាងទៀត ដោយសារយើងបានរកឃើញនូវវត្ថុមានរបស់កាក់ ធ្វើអំពីប្រាក់ មាស និង សំណមួយចំនួន ដែលមានលក្ខណៈស្រដៀងនឹងកាក់គេប្រើនៅក្នុងរាជធានី ស្រីក្សេត្រា នៃព្រះរាជាណាចក្រ ព្យូ ត្រូវជាប្រទេសភូមាសព្វថ្ងៃនេះ យើងក៏អាច សន្និដ្ឋានថា នគរភ្នំពិតជាមានទំនាក់ទំនងជាមួយ ប្រទេសភូមានេះពុំខាន នៅក្នុង បុរាណកាល ។ សូមជម្រាបថា ជាច្រើនសតវត្សរ៍មុនគ្រិស្តសករាជជនជាតិក្លិង្គ បានហៅ ប្រទេសខ្មែរថា សុវណ្ណភូមិ ឬ " ដែនដីមាស " ដែលគេបានរួមបញ្ចូលនូវនគរភ្នំ របស់ខ្មែរផង ហើយនៅរវាងសតវត្សរ៍ទី៥ នៃគ្រិស្តសករាជគេឃើញវត្ថុមាននៃបំណែក ធម៌ ជាភាសាបាលី នៅស្រុកហ្មៅហ្សាជិតទីក្រុងព្រហ្ម ដែលជាសក្ខីភាពនៃឥទ្ធិពលក្លិង្គ នៅក្នុងប្រទេសនេះ ។

អ្នកការទូតចិន គឺលោក កាំង ថៃ ដែលបានអញ្ជើញមកនគរភ្នំរវាងសតវត្សរ៍ ទី៣ នៃគ្រិស្តសករាជ បានពិពណ៌នាអំពីវប្បធម៌ខ្មែរ ក្នុងកំណត់ហេតុរបស់លោកថា



www.elibraryofcambodia.org

"ភាពរុងរឿងរបស់នគរភ្នំ ដែលមានរយៈកាលប្រមាណជា ៦ សតវត្សរ៍នោះត្រូវបានចុះទន់ខ្សោយទៅវិញ ហើយរចនាសម្ព័ន្ធចាស់ក៏ពុំបានពង្រីកដូចមុនទៀតដែរ" ។

មានអ្នកស្រាវជ្រាវមួយចំនួនបានសន្និដ្ឋាន ដោយទម្លាក់កំហុសលើភាពចុះទន់ខ្សោយថា មកពីប្រទេសចិន និងប្រទេសក្បិ្លងមានវិបត្តិផ្ទៃក្នុង ទើបវិស័យសេដ្ឋកិច្ច ឬពាណិជ្ជកម្មដែលទាក់ទងជាមួយនគរភ្នំត្រូវបានផ្អាក់ ។ ជាការពិតហោស់ ព្រោះចាប់ពី សតវត្សរ៍ទី៧ នៃគ្រិស្តសករាជ កំណត់ហេតុចិនបានផ្អាកការកត់ត្រាស្តីពីប្រទេសកម្ពុជា ក្នុងរយៈពេលមួយដ៏យូរ ។ ប៉ុន្តែមូលហេតុមួយទៀតដែលគេត្រូវតែជ្រាបដែរ គឺព្រះមហាក្សត្រនគរភ្នំ មិនចង់ឱ្យមានចម្បាំងរវាងខ្មែរនឹងខ្មែរតទៅទៀត ព្រោះថាភាគីខាងណាក៏ជាខ្មែរដែរ ទើបទ្រង់ព្រះតម្រិះសម្រួលព្រះទ័យលើការផ្គុះផ្គុំ និងបង្រួបបង្រួមជាតិឡើងវិញ ដោយទុកលទ្ធភាពឱ្យស្តេចចេនឡាគ្រប់គ្រងប្រទេសម្តង ។ ដូច្នេះហើយ បានជានគរចេនឡា ដែលដើមឡើយជានគរចំណុះ បានឡើងដឹកនាំប្រទេសឱ្យមានការរីកចម្រើនជឿនលឿនទៅមុខវិញម្តង ក្រោយពីដង្ហើមបានរលោចក្រភ្នំនេះទាំងមូលនៅសតវត្សរ៍ទី៧ នៃគ្រិស្តសករាជ ។

## រាជធានីបុរាណខ្មែរ នាសម័យនគរភ្នំ និងចេនឡា

ជនជាតិខ្មែរមានរាជធានីជាច្រើននៅក្នុងអតីតកាល ។ វត្តមាននៃរាជធានីទាំងអស់នេះ ជាភស្តុតាងនៃការវិវឌ្ឍន៍របស់ប្រវត្តិសាស្ត្រកម្ពុជា ហើយក៏ជានិមិត្តរូបនៃវឌ្ឍនភាពដែរ ។

ការស្ថាបនានូវរាជធានីនិមួយៗ ត្រូវផ្អែកលើកត្តាជាច្រើន ដូចជាកត្តានយោបាយ យោធា សេដ្ឋកិច្ច និង សាសនា ។វីឯរាល់ការផ្លាស់ប្តូរទីតាំងរបស់ទីក្រុង ឬរាជធានីវិញ គឺបណ្តាលមកពីការផ្លាស់ប្តូររជ្ជកាលរបស់ស្តេចខ្មែរ ដែលជានិច្ចកាលរមែងតែតម្រូវឱ្យមានការសាងសង់នូវទីក្រុងថ្មី សម្រាប់ឧទ្ទិសដល់បុព្វបុរសនិងទេវតាប្រចាំ



www.elibraryofcambodia.org

ត្រកូលរបស់ខ្លួន ។ ដូច្នេះហើយ បានជាយើងឃើញនៅសម័យនគរភ្នំ មានរាជធានីមួយចំនួនដែលបានសាងសង់ឡើង ដូចខាងក្រោមនេះ :-

**អង្គរបុរី** : ស្ថិតត្រង់វាលទំនាបខាងក្រោមនៃទន្លេមេណាម ក្នុងខេត្តសុផាន់បូរី នៃប្រទេសថៃសព្វថ្ងៃ ( តាមទស្សនរបស់លោក ហ្សង់បស្សីលីយេ និង ហ្សបហ្សីណូ ) ពីសតវត្សរ៍ទី១ ដល់ សតវត្សរ៍ទី៥ នៃគ្រិស្តសករាជ ។ ទន្ទឹមនឹងនេះ យើងក៏បានឃើញ ទីក្រុងខ្មែរដ៏ធំមួយទៀតដែលស្ថិតនៅជិតពាមទន្លេមេគង្គ នៅខាងត្បូងកម្ពុជាសព្វថ្ងៃគឺទីក្រុង វ្យាធបុរៈ ។

**-វ្យាធបុរៈ** : ស្ថិតនៅស្រុកអង្គរបុរី ខេត្តតាកែវពីសតវត្សរ៍ទី១ ដល់ សតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ដែលមានកំពង់ផែអន្តរជាតិ អូរកែវ ។

**-ស្រេស្ឋបុរៈ** : ស្ថិតនៅប្រទេសលាវ ត្រង់ម្តុំចម្ប៉ាសាក់-វត្តភូ បានសាងសង់ដោយព្រះបាទស្រេសវម្ម័ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីខេត្តស្ទឹងត្រែង ដីខ្មែរបច្ចុប្បន្ន ។ ទីក្រុងនេះត្រូវបានស្ថាបនាឡើងចាប់តាំងពីសតវត្សរ៍ទី៥ នៃ គ.ស ។

**-ស្រីទេព** : ស្ថិតនៅខេត្ត ពេជ្របុរ៉ុន ក្នុងស្រុកថៃសព្វថ្ងៃ ពីសតវត្សរ៍ទី៦ ដល់សតវត្សរ៍ទី៧ ដែលព្រះបាទភវវម្ម័បានគ្រប់គ្រងព្រះរាជធានីនេះ ក្នុងអន្តរកាលមួយដ៏ខ្លី ។ ឥទ្ធិពលរបស់ស្រីទេពបានលាតសន្ធឹងរហូតដល់ខេត្ត អរញ្ញ និង បច្ចិមបុរីព្រមទាំងច័ន្ទបុរី ។

**-នរវរនគរ** : ស្ថិតនៅស្រុកបាភ្នំ ខេត្តព្រៃវែង ក្នុងសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ។ ទីក្រុងនេះមានឈ្មោះថា ណោ ហ្វូ ណា តាមឯកសារចិន ។

**-ភវបុរៈ** : ទីក្រុងនេះស្ថាបនាដោយព្រះបាទ ភវវម្ម័ នៅសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ស្ថិតនៅក្នុងខេត្ត កំពង់ធំ ជិតព្រៃនគរ ។

**-សម្ភុបុរៈ** : បានសាងសង់ដោយព្រះបាទ មហេន្ទ្រវម្ម័ នៅសម្បូរណ៍ផ្នែកខាង



www.elibraryofcambodia.org

លើនៃដងទន្លេមេគង្គ ក្នុងសតវត្សរ៍ទី៦ ទី៧ នៃគ្រិស្តសករាជ ។

-ឥសានបុរៈ ៖ បានកសាងដោយព្រះបាទ ឥសានវរ្ម័នទី១ នៅដើមសតវត្សរ៍ទី៧ នៃ គ.ស នៅក្បែរទីក្រុងចាស់មួយដែលត្រូវបានសាងសង់ឡើងនៅចុងសតវត្សរ៍ទី៦ គ.ស. នៅស្រុកសម្បូរព្រៃគុក ជិតស្ទឹងសែន នៅក្នុងខេត្តកំពង់ធំ ទឹកដីខ្មែរបច្ចុប្បន្ន ។

-ឥន្ទ្របុរៈ ៖ ស្ថិតនៅក្នុងតំបន់ ភូមិអៀន នៅសតវត្សរ៍ទី៨ នៃគ្រិស្តសករាជ ។

-អនិន្ទិតបុរៈ ៖ ស្ថិតនៅអ្ពុំសៀមរាប ដោយព្រះបាទ ពាលាទិត្យ នៃត្រកូលបុស្ករាក្ស នៅពាក់កណ្ដាលសតវត្សរ៍ទី៨ នៃគ្រិស្តសករាជ ។

-ហរិហរាល័យ ៖ ស្ថិតនៅទីក្រុងរលួស ដោយព្រះបាទវរ្ម័នទី២ នៅសតវត្សរ៍ទី៨ នៃគ្រិស្តសករាជ មុនការសាងសង់ ប្រាសាទបល្លៃ ។

-អមរេន្ទ្របុរៈ ៖ ស្ថិតនៅ ភ្នំស្រុក ដោយព្រះបាទវរ្ម័នទី២ នៅសតវត្សរ៍ទី៨ នៃគ្រិស្តសករាជ ។

សូមជម្រាបថា គេសង្កេតឃើញនៅមានទីក្រុងជាច្រើនទៀត ដែលស្ថិតនៅតាមតំបន់នានា ដែលអមឈូងសមុទ្រសៀមសព្វថ្ងៃ ដែលបានស្ថាបនាឡើងដោយឥទ្ធិពលវប្បធម៌ក្លិង្គ នាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ដូចជា **សុភគធានី នគរស្រីធម្មរាជ នគរលង្កាសុកា នគរតាំតានី**... ។ល។ ដែលស្ថិតក្នុងបរិវេណនៃទឹកដីរបស់ចក្រភពភ្នំ ។

## កាលបរិច្ឆេទ និងប្រភពឯកសារទាក់ទិននឹងនគរភ្នំ

ដើម្បីងាយស្រួលដល់ការស្រាវជ្រាវ យើងអាចបែងចែកប្រវត្តិសាស្ត្រជាពីរសម័យកាលធំៗគឺ ៖

ទី១ - សម័យមុនរជ្ជកាលរបស់ព្រះបាទ កៅណ្ឌិន្យវរ្ម័ន និង ទី២ - សម័យ



www.elibraryofcambodia.org

កាលក្រោយពីរជ្ជកាលរបស់ស្តេចអង្គនេះ ។

## ១ ‐ សម័យកាលមុនរជ្ជកាលរបស់ព្រះបាទ កៅណ្ឌិន្យទី២

" ឆ្នាំ ៥៧១ - ៤៧៨ នៃគ្រិស្តសករាជ "

ការល្បែងបញ្ចើញប្រវត្តិនៃសម័យកាលនេះ អាស្រ័យទៅលើកំណត់ហេតុចិន ដូចជាសៀវភៅ សាន គូ ឈើ បានសរសេរឡើងរវាង ឆ្នាំ ៣០៧ នៃគ្រិស្តសករាជ . ពង្សាវតានៃរជ្ជកាល ឈិន រវាងឆ្នាំ ២៦៥ - ៤១៤ នៃគ្រិស្តសករាជ និងរជ្ជកាល សុង រវាងឆ្នាំ ៤២០ - ៤៧៨ នៃគ្រិស្តសករាជ ។

នៅសម័យទី១នេះ យើងឃើញមានក្សត្រជាច្រើនអង្គ ដូចជាព្រះបាទ កៅណ្ឌិន្យនិងនាងសោមា " ឆ្នាំ ៥០ នៃគ្រិស្តសករាជ " ព្រះបាទ ហ៊ុន ហ្វាន់ ហ្វាង ដែលបានចូលទីវង្គត់ក្នុងព្រះជន្ម ៩០ ឆ្នាំ ។

## ២ ‐ សម័យកាលក្រោយរជ្ជកាលរបស់ព្រះបាទ កៅណ្ឌិន្យទី២ :

មុនសតវត្សរ៍ទី៣ នៃគ្រិស្តសករាជ ព្រះបាទ ហ្វាន់ ហ្វាន់ ដែលជារាជបុត្រ របស់ស្តេចអង្គខាងលើ សោយរាជបានតែ៣ ឆ្នាំប៉ុណ្ណោះ ។ ព្រះបាទ ហេរញ្ញ ( អតីត ស្រី អារ: ) ឬ ហ្វាន់ ចេម៉ាន់, ព្រះបាទធរណីវម៌្ម បានសោយរាជ្យដោយបានធ្វើឃាត ព្រះរាជបុត្ររបស់ព្រះបាទ ស្រីហរញ្ញ ក៏ប៉ុន្តែស្តេចអង្គនេះ ត្រូវបានព្រះរាជបុត្រមួយ ទៀតនៃព្រះបាទ ស្រីហរញ្ញ ធ្វើឃាតវិញ និងព្រះបាទ កៅណ្ឌិន្យវម៌្ម នៅសតវត្សរ៍ទី៤ នៃគ្រិស្តសករាជ ។ ម្យ៉ាងទៀត គេនៅឃើញមានក្សត្រជាច្រើនព្រះអង្គទៀត ដូចជា ព្រះបាទស្រីឥន្ទ្រវម៌្ម បានសោយរាជ្យស្នង ហើយធ្វើរាជទូតពលើកទៅប្រទេសចិន នៅឆ្នាំ ៤៣៤ - ៤៣៥ និង ៤៣៨ ហើយនិងព្រះបាទ ជ័យវម៌្ម ក្នុងឆ្នាំ ៤៨០ - ៥១៥ នៃ គ្រិស្តសករាជ ។

ក្នុងសម័យកាលនេះ គេឃើញមានព្រះមហាក្សត្រខ្មែរយ៉ាងសំខាន់១ខ្លះដូច



www.elibraryofcambodia.org

ជាព្រះបាទ រុទ្រវម្ម៌ ឆ្នាំ ៥១៤ - ៥៥០ នៃគ្រិស្តសករាជ" និងព្រះបាទ ភវវម្ម័ទី១" ឆ្នាំ ៥៥០ - ៦០០ នៃគ្រិស្តសករាជ" ។

## សន្តតិវង្ស នគរភ្នំ

### ១ - ព្រះបាទ ស្រីមារញ : " ពីឆ្នាំ ២២០ ដល់ ២៣០ នៃគ្រិស្តសករាជ "

តាមការស្រាវជ្រាវរបស់លោក ហ្សង់ ហ្វីឡូស្សីយ៉ា ផ្ទាំងសិលាចារឹកនេះជាសិលាចារឹករបស់ស្តេចខ្មែរមួយព្រះអង្គនាសម័យ នគរភ្នំ ដែលមានព្រះនាមថា ព្រះបាទស្រីមារញ ដែលជាគោរមនាមរបស់ស្តេច មានប្រភពនៅឥណ្ឌាខាងត្បូង ពោលគឺស្រីលង្កាសព្វថ្ងៃ ។

សិលាចារឹកខ្មែរ ដែលបានចារឡើងនៅពាក់កណ្តាលសតវត្សរ៍ទី៣ នៃគ្រិស្តសករាជ ត្រូវបានគេរកឃើញនៅភូមិ វ៉ូកាញ់ ខេត្ត ញ៉ាត្រាង ឯវៀតណាមខាងត្បូងសព្វថ្ងៃ ដែលជាអតីតកម្ពុជាក្រោមរបស់ខ្មែរ

ផ្ទុយពីទស្សនៈចាស់ៗ ដែលបានសន្និដ្ឋានថា ព្រះបាទស្រីមារញ ឬព្រះបាទហ្វាន់ ឆេម៉ាន់ នៃកំណត់ហេតុចិនថាមានការកាន់ព្រះពុទ្ធសាសនា ឯចំណែកការសិក្សាថ្មីនៃអ្នកខាងសិលាចារឹកសំស្ក្រឹត បានបញ្ជាក់ថាស្តេចអង្គនេះបានកាន់ព្រហ្មញ្ញសាសនា ។

សូមជម្រាបថា កាលដើមឡើយនាសម័យនគរភ្នំ ទីកន្លែងដែលគេបានរកឃើញនូវសិលាចារឹកនេះ ស្ថិតក្នុងដែនដីចំណុះរបស់នគរភ្នំ តែក្រោយមកក៏បានក្លាយជាកម្មសិទ្ធរបស់នគរចាម ។ ចំពោះប្រវត្តិរបស់សិលាចារឹកនេះ យើងនឹងយកមកបកស្រាយនៅក្នុងជំពូកមួយ ដែលទាក់ទងនឹងអក្សរសាស្ត្រ ។ ខ្លឹមសារនៃសិលាចារឹកនេះគឺការយកព្រះទ័យទុកដាក់របស់ព្រះអង្គ ចំពោះប្រជារាស្ត្រខ្មែរតាមគន្លងព្រះពុទ្ធសាសនា ក្នុងការធ្វើបុណ្យដាក់ទានដល់អ្នកក្រីក្រទុគ៌ត និងធ្វើចិត្តឱ្យជ្រះថ្លាដើម្បីបំបាត់នូវមច្ឆរិយៈជាដើម ។ តាមពិតអត្ថបទនេះ ជាសេចក្តីស្មើដ៏ទទូចរបស់ព្រះរាជអង្គនេះ ទៅ



www.elibraryofcambodia.org

កាន់ព្រះរាជាទាំងឡាយជំនាន់អនាគត ឱ្យប្រតិបត្តិតាមទង្វើរបស់ព្រះអង្គ ដែលជាគុណធម៌ដ៏ជ្រាលជ្រៅរបស់ព្រហ្មញ្ញសាសនា ។

## ព្រះបាទ ហ្វាន ឆាន

( រវាងឆ្នាំ ២២៥ និង ២៥០ នៃ គ.ស )

សូមរំលឹកឡើងថា ក្នុងរជ្ជកាលរបស់ព្រះ បាទ ហ្វាន ឆាន គឺក្នុងចន្លោះកាល រវាងឆ្នាំ ២៣០ និង ២៤៨ នៃគ្រិស្តសករាជ ចក្រភពភ្នំបានលាតសន្ធឹងដល់ឆ្នេរសមុទ្រនៃប្រទេសបឹងហ្គាល ហើយមានទំនាក់ទំនងតាមផ្លូវទូតជាលើកដំបូងបង្អស់ និងរាជវង្សឥណ្ឌាមុរុណ្ឌ នៅឆ្នាំ ២៤៤ នៃគ្រិស្តសករាជ ។ ម្យ៉ាងទៀតក៏បានផ្ញើរាជទូតរបស់ខ្លួនទៅកាន់ស្រុកចិន នៅឆ្នាំ ២៤៣ នៃគ្រិស្តសករាជ ដោយមានតង្វាយទៅស្តេចក្រុងចិននូវក្រុមភ្លេងមួយក្រុម និងវត្ថុផ្សេងៗជាច្រើនទៀត ។

គួរកត់សម្គាល់នៅទីនេះថា ទំនាក់ទំនងរវាងស្តេចក្រុងភ្នំ និង ស្តេចក្រុងចិនមាន លក្ខណៈពាណិជ្ជកម្មច្រើនជាងការទូត ។ ព្រះបាទ ហ្វាន ឆាន ត្រូវមន្ត្រីជាន់ខ្ពស់ម្នាក់ធ្វើឃាត ។ ឃាតកនោះហើយបានជាមេទ័ពរបស់ព្រះអង្គម្ចាស់ឈ្មោះ ហ្វាន ស៊ីយុន ឡើងសោយរាជ្យបន្ត ក្រោយពីសម្លាប់មន្ត្រីក្បត់នេះរួច ។

បើតាមឯកសារចិនដដែលថា ព្រះបាទ ហ្វាន ឆាន សព្វព្រះទ័យនឹងរឿងចម្លែក ឬ អច្ឆរិយៈ ដែលកើតមានពីប្រទេស ឆ្ងាយយ៉ាង ស្ថិតនៅខាងលិចនៃប្រទេសឥណ្ឌា ។ ក្នុងពេលស្នាក់អាស្រ័យនៅនគរភ្នំ ជនជាតិឥណ្ឌាម្នាក់បានរៀបរាប់ទូលនូវរឿង អច្ឆរិយៈ ទៅព្រះបាទ ហ្វាន ឆាន ។ ម្យ៉ាងទៀត អ្នកដំណើរនេះបានឱ្យយើងដឹងថា ដើម្បីធ្វើដំណើរទៅកាន់ប្រទេសទាំងនោះ គេត្រូវប្រើពេលវេលាពី ៣ ទៅ ៤ ឆ្នាំ ទើបមកដល់ ។

សូមរំលឹកនៅទីនេះថា អ្វីដែលជនជាតិក្លិង្គបាននិទាន សុទ្ធសឹងតែស្ថិតក្នុងភាពស្រពេចស្រពិលទាំងអស់ ដោយវាស្ថិតក្រៅពីកាលបរិច្ឆេទ ដូច្នេះហើយ បានជាដំណើរ



www.elibraryofcambodia.org

ដែលរៀបរាប់ទូលថ្វាយនូវរឿងខាងលើមានរយៈពេលវែង យូរ ដែលហួសវិស័យរបស់មនុស្សអាចនឹងជឿទៅបាន ។ ខ្លឹមសាររបស់ជនជាតិក្លិង្គនេះ មិនខុសពីអ្នកធ្វើដំណើរ និងឈ្មួញអារ៉ាប់ នាសតវត្សរ៍ទី១០ នៃគ្រិស្តសករាជ ដែលបានអធិប្បាយអំពីប្រទេស និងកោះនានានៃប្រទេស ម៉ាឡាយូ និង ខ្មែរទេ ពីព្រោះអ្វីៗដែលបានពោលមួយភាគធំ ត្រូវបានគេបំភ្លៃ ឬ បំផ្លើស ។

ការណ៍ខាងលើនេះ ជាមូលហេតុដែលធ្វើឱ្យព្រះរាជាខ្មែរមានបំណងចង់ដឹងចង់ស្គាល់នូវរឿងចម្លែកទាំងនោះ ។ ដូច្នេះបានជាព្រះអង្គត្រូវបញ្ជូនញាតិរបស់ព្រះអង្គឈ្មោះ ស៊ូរ្យ ដើម្បីធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌា ។ បើតាមសេចក្តីរាយការណ៍របស់ចិន " ដែលស្ថិតជិតឆ្នេរសមុទ្រ បឹងហ្គាល ឬ ឥណ្ឌា ប្រតិភូខ្មែរបានមកដល់រាជធានីរបស់ស្តេច រាជវង្សមុរ្យេ ក្រោយពីបានមកដល់ទន្លេគង្គា ហើយបន្តដំណើរដោយរអែបតាមទន្លេឆ្ពោះទៅទិសខាងលើ ។

មិនពេះមិនទាក់ទំនងតាមផ្លូវទូត ឯកសារចិនបានបញ្ជាក់ទៀតថា ស្តេចមុរ្យេបានទទួលរាជទូតដោយរាក់ទាក់បំផុត ព្រមទាំងនាំប្រតិភូខ្មែរទៅធ្វើទស្សនកិច្ចក្នុងប្រទេសឥណ្ឌា ។ ដើម្បីតបនឹងបំណងចង់ស្គាល់មេត្រីរបស់ព្រះមហាក្សត្រនគរភ្នំ ស្តេចក្លិង្គបានបញ្ជូនឱ្យបុរសម្នាក់ឈ្មោះ ឆេនសុង នាំសេះបួនដើម្បីយកទៅថ្វាយព្រះមហាក្សត្រខ្មែរនៅឯនគរភ្នំ ។

គួរបញ្ជាក់ថា ព្រះបាទ ហ្វាន ឆាន ខាងលើនេះ ប្រហែលជាព្រះបាទ **ស្រីមារ** ញ ដែលមានវត្តមានក្នុងសិលាចារឹក វ៉ូកាញ់ នៅកម្ពុជាក្រោម ។

ទាំងនេះ យើងគ្រាន់តែសូមនិយាយថា គេបានរកឃើញវាំនៅក្នុងភូមិ វ៉ូកាញ់ នៃ ខេត្តញ៉ាត្រាង " កម្ពុជាក្រោម " ដែលដើមឡើយជាអាណាខេត្តរបស់នគរភ្នំ ពោលគឺមុនការកាន់កាប់របស់តំបន់នេះ ដោយជនជាតិចាម ។ ឯកសារចិនបានបញ្ជាក់ឱ្យយើង



www.elibraryofcambodia.org

ដឹងថា ស្តេចនគរភ្នំអង្គនេះ មានឫទ្ធានុភាពខ្លាំងក្លាណាស់ ក្នុងអម្លុង សតវត្សរ៍ទី៣ នៃគ្រិស្តសករាជ ព្រោះថាព្រះអង្គបានបង្ក្រាបនគរ តុន-សុន ដែលស្ថិតនៅឆ្ងាយពីរាជធានីរបស់ព្រះអង្គ ប្រមាណជា ៣.០០០ លី ឱ្យក្លាយទៅជានគរចំណុះរបស់នគរភ្នំ ។

## ព្រះបាទ ហ្វាន ស៊ីយុន :

ព្រះបាទ ហ្វាន ស៊ីយុន ដើមឡើយជាមេទ័ពរបស់ព្រះបាទ ហ្វាន ធាន ដែលត្រូវគេធ្វើគត ។ តាមយើងពាន់ស្មានមើលទៅ ប្រហែលជាមានប្រតិកម្មពីសំណាក់ព្រះរាជវង្សានុវង្ស ចំពោះការគ្រប់គ្រងរបស់ព្រះបាទ ហ្វាន ស៊ីយុន បានជាពង្សាវតារចិនបានរាយការណ៍ថា ក្រោយពីឡើងសោយរាជ្យសម្បត្តិ ព្រះអង្គបានធ្វើគតព្រះរាជបុត្ររបស់ព្រះបាទ ហ្វាន ធាន មួយព្រះអង្គ ។

ក្រោយពីឡើងសោយរាជ្យព្រះអង្គ បានបញ្ជាឱ្យនាម៉ឺនសព្វមុខមន្ត្រីក្នុងព្រះ-រាជវាំង កសាងនូវរមណីដ្ឋានជាច្រើនកន្លែង ដើម្បីព្រះអង្គយាងកំសាន្ត ។ ពីបីទៅបួនដងក្នុងមួយថ្ងៃ ព្រះអង្គបើកសវនាការដោះស្រាយវិបត្តិសង្គម ជូនប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ ក្នុងប្រទេសដោយគតិបណ្ឌិត ។ ដូច្នេះហើយបានជាអ្នកស្រុកទាំងបរទេសរមែងតែងយកតង្វាយដូចជាសត្វ ចាប អណ្តើក និងអំពៅជាដើមទៅថ្វាយដើម្បីតបស្នងព្រះគុណព្រះអង្គវិញ ។

រវាងឆ្នាំ ២៤៥ និង ២៥០ នៃគ្រិស្តសករាជ ព្រះមហាក្សត្រខ្មែរអង្គនេះបានទទួលគណៈបេសកទូតមួយ គឺលោក កាំង ថៃ និង ឈូ យិន "ជូ យិន" ក្នុងព្រះរាជវាំងខ្មែរ ហើយក្នុងខណៈនោះ គេឃើញមានវត្តមានរបស់រាជទូត ឥណ្ឌានៅទីនោះដែរ ដែលបាន អញ្ជើញមកគាល់ព្រះបាទ ហ្វាន ស៊ីយុន ។

តាមកំហេតុហេតុរបស់រាជវង្ស ស៊ុន បានឱ្យដឹងថា ដើម្បីរឹតចំណងសម្ព័ន្ធភាពរវាងប្រទេសចិន និង នគរភ្នំឱ្យរឹតតែមាំមួនថែមទៀត ព្រះបាទ ហ្វាន ស៊ីយុន បានផ្ញើ



www.elibraryofcambodia.org

ប្រតិភូទូតខ្មែរទៅកាន់ប្រទេសចិនជាច្រើនលើក នៅចន្លោះឆ្នាំ ២៦៨ និង ២៨៧ នៃ គ្រិស្តសករាជ ។

## ព្រះបាទ ឆាន់ ថាន់

(៣៥៧ នៃគ្រិស្តសករាជ ឬ ?)

នៅឆ្នាំ៣៥៧ នៃគ្រិស្តសករាជ ព្រះបាទ ឆាន់ ថាន់ ដែលបានប្រកាសតាំងខ្លួនធ្វើជាព្រះមហាក្សត្រ នៃនគរភ្នំ បានផ្ញើប្រតិភូទូតទៅកាន់ស្រុកចិន ដោយមានតង្វាយជាសត្វដំរីដែលគេផ្សាំងរួច ។ " ព្រះចៅក្រុងចិន នៃរជ្ជកាល ស៊ីន ពូពី ក៏បានបញ្ជូនសត្វចម្លែកទាំងនោះ ឱ្យត្រឡប់មកកាន់ស្រុកកំណើតវិញ " ព្រោះគេបានចាត់ទុកថា ជាសត្វចង្រៃ ។

## ព្រះបាទទេវានិកា មហារាជាធិរាជ

(ពាក់កណ្តាល ឬចុង សតវត្សរ៍ទី៥ នៃ គ្រិស្តសករាជ)

សិលាចារឹកខ្មែរចាស់ជាងគេបំផុត ដែលគេបានរកឃើញនៅម្តុំវត្តភូ ចម្ប៉ាសាក់សព្វថ្ងៃនេះ បានពិពណ៌នាអំពីព្រះបាទ ទេវានីកា ដែលជាមហារាជាធិរាជខ្មែរមួយព្រះអង្គ ។ តាមខ្លឹមសារនៃសិលាចារឹក ព្រះមហាក្សត្រខ្មែរអង្គនេះ បានស្តេចយាងពីឆ្ងាយមកសោយរាជ្យនៅក្នុងភូមិភាគនេះ ។ លោកសាស្ត្រាចារ្យ ក្លូត ហ្សាក បាន សិក្សាសិលាចារឹកនេះហើយសន្និដ្ឋានថា ព្រះបាទ ទេវានីកា ជាព្រះរាជាខ្មែរ ពុំមែនជាជនជាតិចាមដូចដែលអ្នកខ្លះពោលនោះឡើយ ថ្វីត្បិតតែគេពុំបានស្គាល់ច្បាស់នូវស្រុកកំណើតប្រាកដរបស់ព្រះអង្គក៏ដោយ ។

## ព្រះបាទជ័យវរ្ម័ន កៅណ្ឌិន្យ

(៤៨០ - ៥១៤ នៃ គ.ស)

ព្រះបាទ ចៅយេតាមោ ឬ ជ័យវរ្ម័ន ដែលគេហៅក្រៅថា គាវឆេនជូ ឬ



www.elibraryofcambodia.org

កៅណ្ឌិន្យ ពោលគឺព្រះបាទ ជ័យវរ្ម័ កៅណ្ឌិន្យ បានសោយរាជ្យរវាងឆ្នាំ ៤៧០ និង ៥១៤ នៃគ្រិស្តសករាជ គឺក្នុងរជ្ជកាលរបស់ព្រះអង្គនេះហើយ ដែលព្រះពុទ្ធសាសនាបានទទួលនូវភាពរុងរឿង អស្ចារ្យ ។

ព្រះអង្គដែលជាស្តេចមួយព្រះអង្គនៅនគរភ្នំ មានឫទ្ធានុភាពយ៉ាងខ្លាំងក្លាអស្ចារ្យ ជាហេតុធ្វើឱ្យព្រះចៅអធិរាជ វូទី នៃរាជវង្ស លាង បានថ្វាយឋានន្តរសក្តិជា " ឧត្តមសេនីយ៍ សន្តិភាពប៉ែកខាងត្បូង " នៅឆ្នាំ ៥០៧ នៃគ្រិស្តសករាជ ។ ក្នុងរជ្ជកាលរបស់មហាក្សត្រអង្គនេះ គេឃើញមាន ទំនាក់ទំនង រវាងប្រទេសខ្មែរនិងប្រទេសឥណ្ឌាយ៉ាងជិតស្និទ្ធ ប៉ុន្តែព្រឹត្តិការណ៍ដែលគេត្រូវចងចាំ គឺព្រះរាជាអង្គនេះបានទទួលព្រះសង្ឃពីរអង្គ ដែលបាននិមន្តពីប្រទេសឥណ្ឌា មានព្រះនាមថាសង្ឃានាគសេន នៅឆ្នាំ ៤៨៤ នៃគ្រិស្តសករាជ ( ក្នុងរាជវង្ស ស៊ុ ) និងពោធិភទ្រៈក្នុងរាជវង្ស លាង នៅឆ្នាំ ៥០៩ នៃគ្រិស្តសករាជ ។ ព្រះអង្គបានចូលទីវង្គតនៅឆ្នាំ ៥១៤ នៃគ្រិស្តសករាជ ដែលជាឆ្នាំព្រះរាជបុត្ររបស់ព្រះអង្គ គឺព្រះបាទ រុទ្រវរ្ម័ ឡើងសោយរាជ្យស្នងព្រះអង្គ ។ តាមសិលាចារឹក អ្នកតាដំបងដែក នៃខេត្តតាកែវ បញ្ជាក់ថាព្រះអគ្គមហេសីរបស់ព្រះអង្គគឺព្រះនាង កុលប្រភាវតី ។ សិលាចារឹកនេះ បានបញ្ជាក់ទៀតថា មុនព្រះនាងសោយទីវង្គត ព្រះនាងបានចាត់ឱ្យសាងសង់ទេវាល័យសម្រាប់តម្កល់ព្រះវិស្ណុមួយព្រះអង្គ ដែលធ្វើអំពីមាសសុទ្ធព្រមទាំងលំនៅស្ថាន សម្រាប់ពួកព្រាហ្មណ៍បុរោហិត និងបានជីកស្រះទុកជាប្រយោជន៍ចំពោះអ្នកស្រុកផង ។

## ព្រះរាជកុមារ គុណវរ្ម័

( ពីឆ្នាំ ៥១០ ដល់ ? )

សិលាចារឹក នៅប្រាសាទប្រាំល្វែងដែលបានចារឡើង ដោយព្រះរាជកុមារគុណវរ្ម័ន នៅដើមសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ បានរៀបរាប់អំពីប្រវត្តិរបស់ទ្រង់



www.elibraryofcambodia.org

ផ្ទាល់ ។ ព្រះរាជកុមារ ឬ ហ្សាន់ តាង ចេង បើសរសេរជាភាសាចិន ជារាជបុត្រ របស់ព្រះនាង គុលប្រភាវតី និង កៅណ្ឌិន្យជ័យវម៌្ម ដែលបានសោយទិវង្គត នៅឆ្នាំ ៥១៤ នៃគ្រិស្តសករាជ ។

ព្រះអង្គជារាជបុត្រនៃព្រះមហាក្សត្រដែលជា "ព្រះច័ន្ទនៃរាជវង្សកៅណ្ឌិន្យ" ព្រះអង្គបានត្រួតត្រាកាន់កាប់តំបន់មួយ ដែលបិតារបស់ទ្រង់បាន " កសាងនៅលើទីទឹកភក់ " ដែលនៅស្រុកទឹកខ្មៅ ខេត្តព្រៃកប្បាសុី កម្ពុជាក្រោមសព្វថ្ងៃ ។

## ព្រះបាទ រុទ្រវម៌្ម

(ពីឆ្នាំ ៥១៤ ដល់ ៥៥០ នៃ គ.ស)

ជាបឋម ឯកសារចិនបានពិពណ៌នាទៀតថា ព្រះបាទ រុទ្រវម៌្ម បានសោយរាជ្យសម្បត្តិនៅទីក្រុង វ្យាធបុរៈ ដែលស្ថិតចម្ងាយពីសមុទ្រ ៥០០ លី ។ ព្រះរាជធានីនេះ "មានទន្លេមួយហូរពីទិសខាងជើងឈៀងខាងលិច " ពាយ័ព្យ " ទៅទិសខាងកើតឆ្ពោះទៅរកសមុទ្រ ដែលជាទិសដៅរបស់ទន្លេមេគង្គ តាមដៃទន្លេ អីថូ នៅឯកម្ពុជាក្រោម ។

កំណត់ហេតុចិនខាងលើនេះ ក៏បានបន្ថែមសេចក្តីថា នៅឆ្នាំ ៥១៩ នៃ គ្រិស្តសករាជ ព្រះរាជា រុទ្រវម៌្ម នៃនគរភ្នំ បានផ្ញើតង្វាយទៅកាន់ស្តេចក្រុងចិនដោយមានព្រះបដិមាតំណាងព្រះអង្គមួយ ធ្វើពីឈើក្រអូបដែលមកពីប្រទេសក្លិង្គ សិក សូឡូ (សាលា) និង ផ្កា ហ្វូសុី និង ឈើខ្លឹមច័ន្ទជាច្រើនប្រភេទផង ។ សូមរំលឹកដែរថា ព្រះសម្មាសម្ពុទ្ធទ្រង់បានចូលបរិនិព្វាននៅក្រោមដើមសាលា ដែលជាប្រភេទឈើមួយប្រភេទ ។

ក្រោយនេះបន្តិច ពោលគឺនៅឆ្នាំ ៥៣៩ នៃគ្រិស្តសករាជ ព្រះបាទ រុទ្រវម៌្ម បានផ្ញើប្រតិភូទូតខ្មែរទៅកាន់រាជធានីនៃរាជវង្ស ណាង ណាន កិន ដោយនាំទៅជាមួយនូវសត្វរមាសមួយទៅរស់ និងរបស់របរមួយចំនួនរបស់នគរភ្នំ ។ ព្រះបាទ



www.elibraryofcambodia.org

រុទ្រវម៌្ម បានប្រាប់ទៅចិនថា ព្រះអង្គមានសារីរិកធាតុ គឺសក់មួយសសៃរបស់ព្រះពុទ្ធអង្គ ដែលមានប្រវែងទៅដល់ ៣ម៉ែត្រ៣០ ។ ព្រះចៅអធិរាជនៃសន្តិវង្ស លាង ក៏បានផ្ញើព្រះភិក្ខុ ចាំង ចារ៍វឡៅ និមន្តទៅកាន់នគរភ្នំ ដើម្បីសូមដង្ហែព្រះសារីរិកធាតុដ៏មានតម្លៃនោះ ។

វត្តមានរបស់សិលាចារឹកមួយផ្ទាំង នៅព្រាសាទតាព្រហ្ម នៃទន្លេបាទីដែលចារឡើងដោយព្រះបាទ រុទ្រវម៌្ម នាសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ព្រមទាំងវត្តមាននៃសសរពេជ្រមួយកំណាត់ ជាវត្ថុនោបថសម្បូរណ៍ព្រៃគុក នៅទីនេះសឱ្យឃើញថា តំបន់នេះធ្លាប់បានទទួលនាទីយ៉ាងសំខាន់ជាប្រវត្តិសាស្ត្រ ក្នុងអតីតកាល ។

សិលាចារឹកខាងលើនេះ ដែលបានបកប្រែដោយលោក ហ្សក សឺដេស បានធ្វើការរៀបរាប់ឱ្យដឹងថា ព្រះបាទ រុទ្រវម៌្មជាព្រះរាជបុត្ររបស់ព្រះបាទ កៅណ្ឌិន្យ ជ័យវម៌្ម ព្រះអង្គកាន់ព្រះពុទ្ធសាសនា ហើយគោរពសក្ការៈព្រះបរមសារីរិកធាតុ នៃព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូនៃយើង ។

ខ្លឹមសារសិលាចារឹកនៅបានបញ្ជាក់ពីប្រភពពតិមាន ចិន ដែលយើងបានពិពណ៌នានៅមុននេះរួចហើយ ។

ថ្វីត្បិតតែព្រះពុទ្ធសាសនា ជាសាសនារដ្ឋក្នុងរជ្ជកាលរបស់ព្រះមហាក្សត្រ រុទ្រវម៌្ម ប៉ុន្តែព្រហ្មញ្ញសាសនានៅតែរក្សានូវឥទ្ធិពលលើសង្គមយ៉ាងខ្លាំងក្លាដែរដោយហេតុថាសាសនាខ្មែរ មានលក្ខណៈជាសំយោគ ។

តាមសិលាចារឹក K54 នៃអង្គជំនីកវិញ ដែលមានកាលបរិច្ឆេទយ៉ាងច្បាស់លាស់ពីឆ្នាំ ៥៥១ ស.ក ដែលត្រូវនឹងឆ្នាំ ៦២៥ នៃគ.ស យើងអាចដឹងទៀតថាក្នុងរជ្ជកាលរបស់ព្រះមហាក្សត្រខ្មែរអង្គនេះ មានការសាងសង់នូវព្រះសិវលិង្គថ្មនិងរូបព្រះហរិហរដែលមានឈ្មោះថា រុទ្រស្រម ។ បូជនីយដ្ឋាននេះ បានសាងសង់ឡើង



www.elibraryofcambodia.org

ដោយ ព្រាហ្មណ៍ម្នាក់ឈ្មោះ *វិទ្យាវិន័យ* ដោយយកអំណោយជាទ្រព្យ និងជាអ្នកបំរើទេវស្ថាននេះ ពីសំណាក់មន្ត្រីម្នាក់ឈ្មោះ *សិរីវត្ស* មានងារជាបោញ ។

ពាក្យ *រុទ្រស្រម* មានន័យថាអាស្រមរបស់ *ព្រះរុទ្រ* ដែលជាឈ្មោះរបស់ព្រះសិវៈ ឬព្រះឥសូរដែលមានសញ្ញានិមិត្តជាព្រះសិវលិង្គ នាសម័យមុនអង្គរ ចំពោះយើងៗជឿថា វត្តមានរបស់ពាក្យនេះនៅទីនេះមានន័យថា ថ្វីត្បិតតែជាឈ្មោះ របស់ព្រះឥសូរក៏មែនពិត ក៏ប៉ុន្តែព្រាហ្មណ៍ **វិទ្យាវិន័យ** ដែលបានសាងសង់អាស្រមនេះឡើងនោះក៏បានធ្វើឡើងក្នុងវត្ថុបំណងដ៏ពិសិដ្ឋមួយ គឺដើម្បីឧទ្ទិសដល់ព្រះ ***រុទ្រវម្ម*** ដែលជាបុព្វការីរបស់ខ្លួនដែរ ។

## ព្រះបាទភវវម្ម័

(រវាងឆ្នាំ ៥៥០ នៃ គ.ស)

ព្រះរាជនគររបស់ព្រះ **ភវវរ្ម័** ស្ថិតនៅក្នុងខេត្តក្រចេះសព្វថ្ងៃ ។ តាមលោក ភូត ហ្សែក ព្រះមហាក្សត្រអង្គនេះមានព្រះរាជបុត្រពីរព្រះអង្គ គឺព្រះបាទ ចិត្រសេន ឬ **មហេន្ទ្រវម្ម័** និងព្រះបាទ ***ភវវម្ម័ទី១*** ដែលជាស្តេចសឹកដ៏ខ្លាំងពូកែហើយតាមសិលាចារឹក ព្រះអង្គធ្វើការបង្រួបបង្រួមជាតិ ក្នុងព្រះបរមរបស់ព្រះរាជបិតា ។ ក៏ប៉ុន្តែតាមខ្លឹមសារសិលាចារឹកខ្មែរសរសេរជាសំស្ក្រឹត នៃវត្តសុបាតនារាមនៅខេត្តអ៊ូប៊ុនសព្វថ្ងៃ យើងដឹងថា ព្រះបាទ ចិត្រសេន មហេន្ទ្រវរម្ម័ ជាមួយព្រះបាទ *ភវវម្ម័ទី១* ទ្រង់មិនបានជាព្រះជេដ្ឋា ឬព្រះអនុជ កើតអំពីព្រះមាតាបិតាជាមួយគ្នាទេ តែទាំងពីរព្រះអង្គទ្រង់ត្រឹមតែជាព្រះញាតិនឹងគ្នា គឺគ្រាន់ត្រឹមតែបងប្អូននឹងគ្នា តែព្រះបាទ **មហេន្ទ្រវម្ម័** មានព្រះជន្មាយុច្រើនជាងព្រះបាទ ***ភវវម្ម័*** ។

យើងសូមលើកខ្លឹមសារនៃអក្សរថ្មនេះ បង្ហាញជូនជាពតិមានដូចតទៅ ៖
"ព្រះបាទសម្តេច **អង្គណា** ទ្រង់ព្រះនាមថា **ចិត្រសេន** ព្រះអង្គជាព្រះរាជឱរស



www.elibraryofcambodia.org

(បុត្រ) របស់ព្រះបាទ ស្រីវិរម៌្ម ជាព្រះរាជនត្តា (ចៅ) របស់ព្រះបាទ ស្រីសារវៈភោម ។ ថ្វីត្បិត តែមានឋានៈជាព្រះអនុជ តែក៏ជាព្រះជេដ្ឋារបស់ព្រះបាទ ស្រីភវវរ្ម័ន ព្រះអង្គមានព្រះនាមយ៉ាងប្រាកដក្នុងផ្លូវគុណធម៌ តាំងតែព្រះអង្គក្នុងវ័យព្រះបាទសម្ដេចអង្គនេះបានទទួលព្រះនាមវិសេសតាំងតែពេលអភិសេកថា ព្រះបាទ ស្រីមហេន្ទ្រវម៌្ម ក្រោយពីឈ្នះប្រទេសនេះទាំងអស់ ហើយបានសាងព្រះសិវលិង្គទុកជាតំណាងមួយជាសញ្ញាសំគាល់ នូវជ័យជំនះរបស់ព្រះអង្គ តម្កល់ទុកលើភ្នំនេះ" ។

## រាជវង្ស អនិន្ទិត

ឯកសារចិន ហ្សៀយ ដាំងស៊ូ (ជំពូក ១៩៧) និងសិលាចារឹកខ្មែរបានឱ្យដឹងថា ព្រះមហាក្សត្រខ្មែរសោយរាជ្យនៅ ពាលាទិត្យបុរៈ គឺស្ថិតក្នុងរជ្ជកាលរបស់ព្រះបាទ **រាជេន្ទ្រវម៌្មទី២** (៩៤៤ - ៩៦៨ នៃគ្រិស្តសករាជ) ។ តាមប្រភពឯកសារខាងលើនេះ បានបង្ហាញឱ្យដឹងថា ព្រះបាទ **រាជេន្ទ្រវម៌្មទី២** ស្ថិតក្នុងសន្តតិវង្ស **អនិន្ទិត** ។

តាមព្រឹត្តិការណ៍របស់រាជវង្ស អនិន្ទិត នៅសតវត្សរ៍ទី៨ នៃគ្រិស្តសករាជ ដែលមានមជ្ឈមណ្ឌលនយោបាយវប្បធម៌នៅអនិន្ទិតបុរៈ គឺជាភស្តុតាងមួយបង្ហាញឱ្យយើងដឹងថា នាសម័យ **ចេនឡា** ប្រទេសខ្មែរជាប្រទេស ដែលប្រកបដោយការលេចធ្លោឡើងនូវអំណាចមូលដ្ឋានជាច្រើន និងជាសារជាតិ នៃរបៀបគ្រប់គ្រងស្រុកទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ម្យ៉ាងទៀត សម័យនេះក៏ដូចសម័យនគរភ្នំដែរការលេចធ្លោនូវរាជវង្សខ្មែរនានា ជាសក្ខីកម្មមួយអាចបញ្ជាក់ឱ្យយើងឃើញនូវភាពទន់ខ្សោយរបស់អំណាចកណ្ដាល ។ ភស្តុតាងនៃបញ្ហានេះ ត្រូវបានឯកសារចិនកត់ត្រាទុកដែរ ពីព្រោះក្នុងអន្តរកាលនេះហើយ ដែលប្រទេសចេនឡាត្រូវបែងចែកជាពីរ គឺ **ចេនឡា ទឹក និង ចេនឡាគោក** ។

ព្រះរាជវាំងព្រះមហាក្សត្រខ្មែរស្ថិតនៅ **ប៉ូឡូទីប៉ូ** ដែលត្រូវនឹងពាក្យ ពាលា



www.elibraryofcambodia.org

ទិត្យបុរៈ នៃសិលាចារឹកខ្មែរនាគ្រិស្តសករាជ ៨០៦ ក្នុងរជ្ជកាលនៃព្រះបាទ រាជេន្ទ្រវរ្ម័ន ទី២ ( ៩៤៤ - ៩៦៨ នៃ គ.ស ) សូមរំលឹកថា ទីក្រុងរបស់ព្រះមហាក្សត្រខ្មែរអង្គនេះ គឺ អនិន្ទិតបុរៈ ។

ឯខ្លឹមសារដ៏សំខាន់មួយទៀត របស់សិលាចារឹកខាងលើនេះ គឺព្រះបាទ រាជេន្ទ្រវរ្ម័នទី២ បានបញ្ជាក់ថា ព្រះអង្គមានព្រះរាជបំណងចង់ស្តារឡើងវិញនូវ រាជវង្ស ពាលាទិត្យ ដែលត្រូវជាបុព្វបុរសរបស់ព្រះអង្គ ដែលសោយរាជ្យនៅ ពាលាទិត្យបុរៈ ឬ អនិន្ទិតបុរៈ ។

តាមក្រោមសិលាចារឹកប្រែរូប ( K. 806 ) ដែលបានចារឡើងនៅឆ្នាំ ៩៦១ នៃគ្រិស្តសករាជ គេឃើញមានការផ្តល់ឲ្យនូវរាជវង្ស ស្រីពាលាទិត្យ ដែលមានបុព្វបុរស កៅណ្ឌិន្យ និង សោមា ។ ព្រះបាទ ស្រីពាលាទិត្យ បានសោយរាជ្យនៅ ឯអនិន្ទិតបុរៈ តាមរយៈព្រះមាតារបស់ព្រះអង្គ ។ ម្យ៉ាងទៀតយើងក៏បានដឹងតាម រយៈសិលាចារឹក ( K. 528 ) នៃប្រាសាទ មេបុណ្យខាងកើត ដែលត្រូវចារឡើងនៅឆ្នាំ ៩៥៣ នៃគ្រិស្តសករាជ ថាព្រះអង្គបានស្ថាបនានូវសិវលិង្គមួយនៅឯ សូគិទ្ធរបុរៈ និងនៅមីកផ្សេងៗទៀតក្នុងព្រះរាជនគរ ។ ក្រៅពីឯកសារសិលាចារឹកក៏បានឲ្យដឹង ទៀតថា ព្រះរាជបុត្រីរបស់ព្រះអង្គគឺ សរស្វតី បានរៀបអភិសេកជាមួយព្រាហ្មណ៍ ម្នាក់ឈ្មោះ វិស្វរូប ហើយក្នុងចំណោមព្រះរាជបុត្រដែលប្រសូត្រចេញពីគូស្វាមី ភរិយានេះគេឃើញព្រះបាទ នរបតីន្ទ្រវរ្ម័ន ( នបតីន្ទ្រវរ្ម័ន ) ដែលត្រូវជាបិតារបស់ ព្រះបាទ បុស្គរាក្ស ។ ព្រះបាទ បុស្គរាក្ស គឺជាអ្នកបង្កើតនូវរាជវង្ស សម្ភុបុរៈ ។ ក្នុងព្រឹត្តិការណ៍មួយទៀត ដែលយើងត្រូវផ្តោតការយកចិត្តទុកដាក់ដែរ ពីព្រះរាជបុត្រី និងព្រាហ្មណ៍ វិស្វរូប ខាងលើនេះក៏បានប្រសូត្រផងដែរនូវរាជបុត្រីមួយព្រះអង្គ ដែលត្រូវជាយាយរបស់ វេទវតី ដែលមានកូនស្រីម្នាក់ឈ្មោះ មហេន្ទ្រទេវី ។ ព្រះនាង



www.elibraryofcambodia.org

**មហេន្ទ្រទេវី** បានរៀបអភិសេកជាមួយព្រះបាទ **មហេន្ទ្រវម៌្ម** ដែលបានតពូជពង្ស ពីព្រះបិតារបស់ **វេទវតី** ដែលបានគង់នៅ **ភវបុរៈ** ។ ព្រះបាទ **មហេន្ទ្រវម៌្ម** និង **មហេន្ទ្រទេវី** បានប្រសូត្របុត្រមួយព្រះអង្គគឺព្រះបាទ **រាជេន្ទ្រវម៌្មទី២** ដែលបានសោយរាជ្យនៅតំបន់សៀមរាបអង្គរ ។ បញ្ហាមួយទៀតដែលបានចោទឡើងនៅទីនេះ គឺគេពិបាកនឹងដោះស្រាយឱ្យដាច់ស្រឡះពោស់ គឺទីតាំងរបស់ព្រះរាជធានី **ពាលាទិត្យបុរៈ** ឬ **អនិន្ទិតបុរៈ** ដោយហេតុថា សិលាចារឹករបស់ព្រះបាទ **ពាលាទិត្យ** ត្រូវគេជួបប្រទះពីតំបន់អង្គរ រហូតដល់ទឹកដីកម្ពុជាក្រោម (K.911) ដូចជានៅខេត្តមាត់ជ្រូកជាដើម ។ ចំពោះយើង យើងជឿថា ព្រះរាជធានីខាងលើនេះ ពិតជាស្ថិតនៅឆ្ងាយពីតំបន់អង្គរពុំខាន ។

រីឯទីក្រុង **ភវបុរៈ** របស់ព្រះបាទ **ភវវម៌្មទី១** (៥៩៨ នៃ គ.ស) វិញដែលស្ថិតនៅម្តុំអំពិលរលំ ចម្ងាយប្រមាណជា ៣០ គីឡូម៉ែត្រ នៅទិសខាងជើងឆៀងខាងកើតនៃខេត្តកំពង់ធំ យើងជឿថា នាដើមសម័យអង្គររាជវង្ស **អនិន្ទិត** ពិតជាបានផ្លាស់ទីតាំងរបស់ខ្លួន ទៅកាន់តំបន់ខាងជើងនៃជួរភ្នំដងរែក ។

រួមសេចក្តីមក សេចក្តីអធិប្បាយនៃសិលាចារឹក ដែលជាមូលដ្ឋានប្រវត្តិសាស្ត្រនាសម័យចេនឡា ជាពិសេស គឺវត្តមានរបស់បុរាណដ្ឋានជាច្រើន នៅម្តុំជួរភ្នំដងរែងទាំងសង្ខាង បង្ហាញថាផ្ទុយពីមតិខ្លះ គឺក្នុងភូមិភាគនេះហើយដែលរាជវង្ស **អនិន្ទិតបុរៈ**បានស្ថិតនៅ ។ ជាមូលហេតុដំបូងនៃការជ្រើសរើសភូមិសាស្ត្រនេះ ដែលជាប្រភពនៃវឌ្ឍនភាព គឺថាទី១ ស្ថិតនៅឆ្ងាយពីតំបន់អង្គរ និងជានិមិត្តរូបនៃអំណាចកណ្តាល ។ ទី២ គឺជាតំបន់សេដ្ឋកិច្ច ដែលប្រកបដោយភាពងាយស្រួលក្នុងការអភិវឌ្ឍន៍តំបន់ ។ ដោយឡែកទៀត អំណាចកណ្តាល ពុំមានវត្តមាននៅទីនេះទេ ហើយថែមទាំងស្ថិតយ៉ាងឆ្ងាយពីព្រះរាជធានីផង គឺប្រហែលជាករណីនេះហើយ ដែលយើងបានជួបប្រទះ



www.elibraryofcambodia.org

នូវវត្ថុមានតម្លៃមួយចំនួនដូចជា ចានាស ជាដើម នៅលើខ្ពង់រាបខេត្ត នគររាជសីមា ។

## ទីតាំងរបស់ វ្យាធបុរៈ តាមឯកសារប្រវត្តិសាស្ត្រ

ប្រភពឯកសារចិន បានឱ្យដឹងថា អាណាចក្រភ្នំមានទំហំប្រមាណជា ៥០០០ លី ដែលត្រូវនឹង ២០០០ គីឡូម៉ែត្រ ។ ចំពោះទំហំនេះ យើងគិតថាវាសមរម្យនឹងស្ថានភាពជាក់ស្ដែង នៃភូមិសាស្ត្របុរាណនៃអតីតព្រះរាជាណាចក្រខ្មែរ ។ តាមពិតបើសិនជាគេវាស់វែងចម្ងាយនេះ តាមរយៈខ្មែរកណ្ដាល ឬ ជម្រៅ យើងឃើញថា ព្រំប្រទល់ពិតជាមិនត្រឹមត្រូវ ក៏ប៉ុន្តែបើគេគិតពីឆ្នេរនៃឈូងសមុទ្រថៃសព្វថ្ងៃ ដែលពីដើមមានឈ្មោះថា ឈូងសមុទ្រខ្មែរ វាជាការសមហេតុផល ។ ម្យ៉ាងទៀតសូមរំលឹកថា ក្នុងអាណាចក្រភ្នំប្រែថា សុវណ្ណភូមិនោះ មានរដ្ឋតូចធំជាច្រើន ដែលបានដុះដាលធំធាត់ឡើងដោយសារពាណិជ្ជកម្មអន្តរជាតិ ។

ចំពោះបញ្ហាដែលស្ដីពីទីតាំងនៃទីក្រុង **វ្យាធបុរៈ** ឬ **ទីក្រុងអង្គរបុរី** ដែលចិនហៅថា **តូមូ** នោះ មានមតិផ្សេងគ្នាជាច្រើន តែចំពោះយើងៗសូមឯកភាព ជាមួយលោក **អែម៉ូនីយេ** ដោយហេតុថា ដូចយើងអ្នកប្រវត្តិវិទូនេះបានសន្និដ្ឋានថា ទីក្រុងនេះស្ថិតនៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវសព្វថ្ងៃ ។

បុព្វហេតុដែលនាំឱ្យអ្នកប្រាជ្ញនេះ សន្និដ្ឋានដូច្នោះ គឺបណ្ដាលមកពីគេបានរកឃើញនៅលើទីតាំងនេះ នូវវត្ថុបុរាណសំខាន់ៗ នាសម័យនគរភ្នំជាច្រើន ដូចជាព្រះវិស្ណុថ្មដៃ៨ នៅភ្នំដាមួយយ៉ាងធំ កំពស់ ២ម៉ែត្រ៧០ ដែលជារូបចម្លាក់ធំជាងគេក្នុងភូមិភាគអាស៊ីអាគ្នេយ៍នេះ ។ ហើយតាមរយៈការស្រាវជ្រាវរបស់ក្រុមឯកទេសអាមេរិកកាំង ដែលសហការណ៍ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជាយើង ក៏អាចបញ្ជាក់ថា មតិរបស់អ្នកប្រាជ្ញខាងលើនេះ ពិតជាត្រឹមត្រូវមែន ។ ថ្មីៗនេះ ការថតរូបភាពតាមរយៈផ្កាយរណប (ស្លូត) បានបង្ហាញឱ្យយើងឃើញនូវកំពែងនៃទី



www.elibraryofcambodia.org

ក្រុងបុរាណនេះ ធ្វើអំពីឥដ្ឋដែលមានប្រវែង ប្រមាណ ៤គីឡូម៉ែត្រ ។

រួមសេចក្ដីមក ចំពោះយើង ការដែលគេចាត់ទុកថា វ្យាធបុរៈគឺស្ថិតនៅក្នុងតំបន់ បាភ្នំ ជាការមិនសមហេតុផលទេ ដោយសំអាងលើមូលហេតុខាងលើនេះ ថ្វីត្បិតតែ បាភ្នំ ព្រមទាំងសន្តតិវង្ស បាម្វំ (រុទ្រវម្ម៌) នៃកំណត់ហេតុចិន មានភាពស្រដៀងនឹងពាក្យ ហ្វូ ណាន ឬ នគរភ្នំ យ៉ាងណាក៏ដោយ ។ គប្បីរំលឹកថា ទីក្រុងស្ថិតឆ្ងាយពីភ្នំ ម៉ូគាន់ ឬ បាភ្នំ ប្រមាណជា ៥៣ គីឡូម៉ែត្រ ។ ម្យ៉ាងទៀតយើងក៏បានកត់សម្គាល់ដែរថា អ្នកបរទេសមួយចំនួនដែលសរសេរពីប្រវត្តិសាស្ត្រខ្មែរ ភាគច្រើនពុំបានស្គាល់ភូមិសាស្ត្ររបស់ទីក្រុងអង្គរបុរី ឬ វ្យាធបុរៈ ទេ ដូច្នេះបានជាទស្សនៈរបស់គេគ្មានប្រាកដនិយមឡើយ ។ មួយវិញទៀតនាសម័យអតីតកាល គ្មានការបែងចែក ឬវែកញែកខេត្តមួយ ទៅខេត្តមួយទៀតឱ្យបានច្បាស់លាស់ដូចសព្វថ្ងៃនេះទេ ។

ឥឡូវនេះ គប្បីលើកយកសេចក្ដីអធិប្បាយពីទីតាំងនគរភ្នំ ដែលកត់ត្រាក្នុងឯកសារចិនមកពិនិត្យ ។

ទីក្រុង វ្យាធបុរៈ ស្ថិតឆ្ងាយពីសមុទ្រចំនួន ៥០០ លី ដែលមានភ្នំ ម៉ូគាន់ (បាភ្នំ) ជាភ្នំការពារព្រះរាជនគរ ។ " មានទន្លេមួយដែលបានទឹកហូរពីទិសខាងជើងឆៀងខាងលិច តម្រង់ទៅកាន់ទិសខាងកើត ដើម្បីហូរចាក់ទៅក្នុងសមុទ្រ " ។ តាមពិតទន្លេនេះ គឺជាទន្លេមេគង្គ ដែលមានដៃទន្លេជាច្រើននៅកម្ពុជាក្រោមសម្រាប់សម្រួលដំណើរសំពៅ និងទូកដែលធ្វើជំនួញជួញប្រែ រវាងខ្មែរនិងបរទេស ។

ចំពោះទីក្រុង វ្យាធបុរៈ ដែលជារាជធានីនៃ នគរភ្នំ ថ្វីត្បិតតែយើងអាចកំណត់ទីតាំងដោយមិនភ័ន្តច្រឡំក៏ដោយ ប៉ុន្តែយើងនៅតែមានទស្សនៈមួយចំនួនទៀតដែលរោនដូចតទៅនេះ ដោយសំអាងទៅលើកំណត់ហេតុចិន និងរូបចម្លាក់សំណង់ប្រាសាទវត្ថុវប្បធម៌បុរាណ ដែលគេបានរកឃើញនៅសេសសល់ក្នុងអាណាខេត្តស្ថិត



www.elibraryofcambodia.org

ជិតឈូងសមុទ្រសព្វថ្ងៃនេះ គឺយើងអាចកត់ត្រាថា វ្យាធបុរៈ ឬ អង្គរបុរីមិនមែនតែរាជធានីមួយរបស់ចក្រភពភ្នំទេ ។ ពោលគឺ នៅមានរាជធានីមួយចំនួនទៀតដូចជា អ្វីផង "សុផាន់បុរី" លង្កាសុកា ជាដើម ដែលជាអតីតទីក្រុងរបស់នគរភ្នំ ហើយដែលសព្វថ្ងៃស្ថិតក្នុងខ័ណ្ឌស៊ីមារបស់ប្រទេសថៃឡង់ដ៍ ។

សរុបមកតាមរយៈបុរាណវិទ្យា យើងអាចសន្និដ្ឋានថា ស្ថេរភាពនយោបាយនិងសេចក្ដីរុងរឿងនៃតំបន់នេះ បណ្ដាលមកពីកសិកម្ម ពាណិជ្ជកម្ម និង តំបន់អាមាតៃដែនដីសណ្ដូរ ។ ផ្លូវទឹកមានា មានតួនាទីយ៉ាងសំខាន់បំផុត ក្នុងការផ្សព្វផ្សាយ វប្បធម៌អារ្យធម៌ ឥណ្ឌាចូលទីប្រជុំជនខ្មែរមានា ។ រូបចម្លាក់បុរាណដូចជា ព្រះគណេសព្រះបរិវារៈ ព្រះវិស្ណុ ព្រះព្រហ្ម និងព្រះពុទ្ធរូបទាំងឡាយដែលគេបានរកឃើញ អាចឆ្លុះបញ្ចាំងឱ្យយើងស្គាល់ ដឹងនូវជំនឿសាសនានាសម័យនោះ ។ ថ្វីត្បិតតែខ្មែរនាសម័យនោះ និយមអបូជាសាសនាព្រហ្ម ដែលមានព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាជាអាទិតែគេក៏នៅគោរពជូនតាដែលមានចែកស្ថានទៅដែរ ។ ការរកឃើញនូវកញ្ចក់អ្នកតាជាច្រើន បង្ហាញឱ្យយើងស្គាល់នូវជំនឿអ្នកស្រុក នៅគ្រាដើមនៃសម័យប្រវត្តិសាស្ត្រខ្មែរយើង ។

ពង្សាវតារ ពង្សាវតារបើកឡើងវិញថានាសម័យបុរាណនោះ សេដ្ឋកិច្ចមូលដ្ឋាននៃទីក្រុងអង្គរបុរី ដែលមានកំពង់ផែអូរកែវ ដែលស្ថិតនៅកម្ពុជាក្រោមសព្វថ្ងៃ គឺជាវិស័យពាណិជ្ជកម្មអន្តរជាតិ រវាងខ្មែរនិងឥណ្ឌា ព្រមទាំងចក្រភព ហ្វ្រាំងតូ-រ៉ូម៉ាំង ។ ចំពោះការជួញដូរនេះដែរជាប្រភពនៃការចាក់ឫសគល់នៃ វប្បធម៌បរទេស នៅក្នុងអតីតទឹកដីកម្ពុជា និងជាប្រភពនៃវឌ្ឍនភាពនៃព្រះរាជាណាចក្រភ្នំ យើងអាចឃើញស្លាកស្នាមមួយចំនួនតាមរយៈ រឿងព្រេងនិទានខ្មែរ ដូចជាភ្នំបូរី ភ្នំដានៅខេត្តតាកែវជាដើម ។ ចំណុចមួយទៀតរបស់រឿងនិទានស្ដីពីកំណើតនៃទីក្រុងអង្គរបូរីឈ្មោះនៃទីភ្នំ បុរី ដែល



www.elibraryofcambodia.org

ជាកន្លែងស័ក្តិសិទ្ធិបំផុតក្នុងសម័យបឋម នៃប្រវត្តិសាស្ត្រកម្ពុជា ។ តាមពិតតាមរយៈរឿងព្រេងនេះ យើងដឹងថា ភ្នំបុរីនេះគឺជា " ភ្នំរបស់ទីក្រុងអង្គរបុរី " ដែលស្ថិតនៅក្រៅបរិវេណនៃទីក្រុង ហើយគឺនៅទីនេះហើយដែលខ្មែរយើងបានសាងសង់ប្រាសាទបុរាណមួយសម្រាប់សក្ការៈបូជាព្រះអទិទេព។ សូមបញ្ជាក់ថា ទំនៀមទម្លាប់សាងសង់បូជនីយដ្ឋានសម្រាប់ព្រះរាជា នៅលើកំពូលភ្នំដែលស្ថិតនៅក្រៅទីក្រុង ឬ បុរីជាប្រពៃណី ដែលធ្លាប់មាននៅឥណ្ឌា និងចិន ។ ដូច្នេះពេលដែលបុណ្យទានម្តងៗ ទាំងព្រះរាជាទាំងប្រជារាស្ត្រតែងតែ " ឡើងភ្នំ.ចុះភ្នំ " ជានិច្ចកាលដើម្បីបន់ស្រន់ សូមសិរីមង្គល ពីសំណាក់ព្រះអាទិទេព គឺព្រះវិស្ណុ ឬព្រះនារាយណ៍ដៃ៨ ឬក៏ព្រះហរិហរៈ ដែលប្រថាប់នៅក្នុង ប្រាសាទទាំងពីរនៃភ្នំបុរីនេះ ។ ម្យ៉ាងទៀតគឺតាមរយៈកំពង់ផែនេះហើយដែលព្រះភិក្ខុសង្ឃខ្មែរបាននិមន្តទៅកាន់ប្រទេសចិន ដើម្បីចម្លងនិងប្រែគម្ពីរធម៌ថ្វាយស្តេចចិន ។ ក៏ប៉ុន្តែគ្មានអ្វីដែលថា ចម្ងាយនេះមិនមែនជាចម្ងាយរវាងសមុទ្រ និងទីក្រុងអ៊ូថង ដែលជាអតីតរាជធានីខ្មែរដ៏សំខាន់មួយ របស់អាណាចក្រភ្នំ ដែលសព្វថ្ងៃស្ថិតក្នុងប្រទេសថៃបច្ចុប្បន្ន ។

## កំពង់ផែអន្តរជាតិ អូរកែវ

តាមការស្រាវជ្រាវ កាយរាវរកឫសគល់នៃវប្បធម៌ អរិយធម៌ខ្មែរ នាសម័យនគរភ្នំ ដែលបានធ្វើឡើងដោយលោក លូអ៊ី ម៉ាល័ររេ នៅរមណីដ្ឋាន អូរកែវ ស្ថិតនៅក្នុងដែនដីសណ្តរនៃទន្លេមេគង្គខាងត្បូងភ្នំ បាថេ ក្នុងខេត្ត ក្រមួនស យើងក៏បានដឹងថា បុរាណស្ថាននេះ ជាកំពង់ផែធំមួយរបស់នគរភ្នំ ។

ក្នុងការធ្វើកំណាយស្រាវជ្រាវនោះ បានផ្តល់ឱ្យយើងដឹងនូវវត្ថុផ្សេងៗជាច្រើន ដែលខ្លះមកពីប្រទេសក្លិង្គ ចក្រភពរ៉ូម៉ាំង និងខ្លះទៀតមកពីប្រទេសចិន ។ ម្យ៉ាងទៀត គេក៏បានរកឃើញនូវវត្ថុមួយចំនួន ជាថ្មរលីង និងសំរិទ្ធ ដែលជាសមិទ្ធិផល



www.elibraryofcambodia.org

នាសម័យបុរេប្រវត្តិសាស្ត្រ ។ ដោយសំអាងទៅលើវត្ថុបុរាណទាំងអស់នោះ យើងអាចសន្និដ្ឋានថា នៅសម័យមុនគ្រិស្តចូលស្រុក គឺមានប្រជាពលរដ្ឋខ្មែរបានរស់នៅលើទីតាំងនេះហើយ ។ គួរគត់សម្គាល់ថា កំពង់ផែនេះគ្រាន់តែជាកំពង់ផែមួយ ក្នុងចំណោមកំពង់ផែជាច្រើនទៀតក្នុងដែនដីចក្រភពភ្នំ ។ បើតាមការស្រាវជ្រាវថ្មីនេះ នៅស្រុកអង្គរបូរី ខេត្តតាកែវ យើងអាចសន្និដ្ឋានដោយមិនភ័ន្តច្រឡំថា ទីក្រុង ឬ ព្រះរាជធានីរបស់**នគរភ្នំ គឺវ្យាធបុរៈ ដែលមានទីតាំងនៅ អង្គរបូរី** ពោលគឺពុំមែននៅបាភ្នំទេ ។

ប្រសិនបើយើងពិនិត្យការសិក្សារបស់លោក **ហ្សង់ ប័សស៊ីលីយេ** យើងនឹងសម្គាល់ថា ក្រុងរបស់នគរភ្នំ គឺស្ថិតនៅតំបន់វាលទំនាបខាងក្រោមនៃទន្លេមេគង្គ គឺរាជធានីអូរកែវទៅវិញ ហើយបន្ទាប់មកទៀតព្រះរាជធានីនេះត្រូវបានជម្លៀសទីតាំងមកនៅជិតតាមទន្លេមេគង្គ ភាគខាងត្បូងនៃប្រទេសកម្ពុជាសព្វថ្ងៃនេះ ។ ការដែលលោកសាស្ត្រាចារ្យលើកបែបនេះ មិនខុសពីការពិតប៉ុន្មានទេដោយហេតុថា ទាំងកំពង់ផែអូរកែវ ដែលមានទស្សនៈខ្លះ បានចាត់ទុកជារាជធានីរបស់នគរភ្នំដែរនោះ ទាំងទីក្រុងវ្យាធបុរៈ នៅអង្គរបូរី ដែលមានកំពង់ផែជាច្រើនផង ទាំងនៅអូរកែវ ដែលស្ថិតក្នុងប្រទេសវៀតណាម បានន័យថា ទីតាំងជាប្រវត្តិសាស្ត្រទាំងនេះ គឺសុទ្ធសឹងតែស្ថិតនៅក្នុងបរិវេណនគរភ្នំទាំងអស់ ។ ម្យ៉ាងទៀតតាមព័ត៌មានចក្រភពភ្នំ ត្រូវជាក្បួនព្រប្រទេសដោយហេតុនេះហើយ បានជាយើងឃើញមានព្រះរាជធានីជាច្រើននាសម័យបុរាណកាល ។ គឺក្នុងករណីនេះហើយដែលឈ្មោះស្រីម្ហារវត៌ ដែលគេជឿថា ជាស្ដេចនគរមន ត្រូវបានគេជួបប្រទះនៅលើកាក់មាសបូបនៅ (Ka 196) អង្គរបូរី ។

រួមសេចក្ដីមក ក្នុងអតីតកាលចក្រភពភ្នំ ពីសតវត្សរ៍ទី១ ដល់សតវត្សរ៍ទី៦ គេឃើញមានព្រះរាជធានីជាច្រើនដូចជា វ្យាធបុរៈ ស្រេស្ឋបុរៈ ឥសានបុរៈ (សម្បូរព្រៃគុក សតវត្សរ៍ទី៦ និងទី៧) អាវធ្យបុរៈ ស្រីទេព ។ល។ ដែលជាមជ្ឈមណ្ឌល


www.elibraryofcambodia.org

នយោបាយ និង វប្បធម៌ដ៏មហារុងរឿង ។

ទាក់ទិននឹងបញ្ហាចម្បាំងរវាងខ្មែរ និងកម្ពុជាក្រោម ដែលបានធ្វើឡើងដោយព្រះបាទមហេន្ទ្រវរ្ម័ន ឬចិត្រសេន ហើយ[illegible]ចេញពីរាជធានី វ្យាធបុរៈ (ឬ អង្គរបុរី) ដោយព្រះបាទភវវរ្ម័នទី១ដូច[illegible]ទារជ្ជកាល ថាំង និង ស៊ុយ បានពិពណ៌នា សិលាចារឹកនៃប្រាសាទ ឥដ្ឋ នៅតំបន់ ហ្គោ សាយ ស្រុកជ្រុំកហ្វា តំបន់វាលភក់នៅកម្ពុជាក្រោម បានបញ្ជាក់អំពីព្រឹត្តិការណ៍នេះស្របនឹងកំណត់ហេតុចិន ដោយមានខ្លឹមសារដូចតទៅ : ព្រះបាទភវវរ្ម័នទី១ បានដាក់បញ្ញត្តិឱ្យទ័ពរបស់ព្រះអង្គ ចំនួន ១០០.០០០ នាក់ ដកថយចេញឆ្ងាយពីទីក្រុង វ្យាធបុរៈ ដើម្បីទៅកាន់តំបន់មួយដែលស្ថិតឆ្ងាយពីនោះ ហើយមុនអនុវត្តន៍រាជបញ្ជាខាងលើនេះ ប្រជាពលរដ្ឋបានលាក់កប់ទុកនូវទ្រព្យសម្បត្តិ គ្រឿងអលង្ការធ្វើអំពីមាសប្រាក់ និង វត្ថុ ស័រិទ្ធដែលខ្លួនមាន ។

សូមជម្រាបថា សិលាចារឹកខាងលើនេះ បានត្រូវគេចារឡើងនៅលើសន្លឹកមាសស្តើងមួយ (២១ x ៤ ស.ម) ហើយបានត្រូវគេរកឃើញជាមួយវត្ថុមួយចំនួនធំដែលនៅក្នុងនោះ មានវត្ថុធ្វើអំពីមាស ២៦ ក្នុងជំរៅប្រមាណ ១ម៧០ នៅចំកណ្តាលខឿនប្រាសាទឥដ្ឋមួយ ក្នុងតំបន់ ហ្គោ សាយ ដូចដែលបានពោលនៅខាងលើនេះស្រាប់ ។

ម្យ៉ាងទៀត សិលាចារឹកនោះ[illegible]នឹងបន្ថែមទៀតថា : " មុននឹងដកទ័ពថយព្រះបាទភវវរ្ម័នទី១ បានបញ្ជាឱ្យគេធ្វើពិធីបួងសួងមួយ ថ្វាយចំពោះទេវតាផ្សេងៗ និងព្រះឥន្ទ្រ ដើម្បីសេចក្តីសិរីមង្គលដោយមានតង្វាយដូចជា រូបដំរី កងដៃ កងជើង ក្រពាត់សំពត់ និងភ្នុកដំរី ហើយក្នុងឱកាសនោះ ព្រះបាទភវវរ្ម័នទី១ បានអានព្រះឱង្ការទៅកាន់ប្រជាពលរដ្ឋខ្មែរ នៅទីនោះឱ្យ[illegible]ទៅលើសាសនាថ្មីមួយ ដែលទើបតែកោរពុកកេរ្តិ៍ ។ ម្យ៉ាងទៀតនៅខាងចុងអត្ថបទនេះ គេឃើញ[illegible]សរសើរនូវ



www.elibraryofcambodia.org

បារមីរបស់ព្រះព្រហ្មទៀតផង ។

សូមរំលឹកឡើងវិញថា តំបន់វាលភក់ខាងលើនេះ សម្បូរទៅដោយស្ថានីយ៍ប្រវត្តិសាស្ត្រ នាសម័យនគរភ្នំ ដូច្នេះហើយគ្រាន់តែនៅក្នុងស្រុក ជីកហ្វា តែមួយគេឃើញមានស្ថានីយ៍ខ្មែរមុនសម័យអង្គរ ដល់ទៅជាង ៥០ ទៅហើយ បើគេយោងលើការស្រាវជ្រាវរបស់លោក យ៉ស៊ុ ខាយ នៅក្នុងឆ្នាំ ១៩៨៧ ។

សរុបសេចក្តីមក ខ្លឹមសារនៃសិលាចារឹកខាងលើនេះដែលស្របនឹងកំណត់ហេតុចិន មានអត្ថប្រយោជន៍យ៉ាងសំខាន់ណាស់ ក្នុងការស្វែងយល់អំពីព្រឹត្តិការណ៍នយោបាយខ្មែរ នាសម័យមុនអង្គរ ។

**វឌ្ឍមានរបស់ព្រះពុទ្ធសាសនា**

ដោយមានកំពង់ផែសមុទ្រជាច្រើន ដែលស្ថិតនៅតាមឆ្នេរសមុទ្រសៀមសព្វថ្ងៃនេះ វិស័យពាណិជ្ជកម្មរវាងក្រុងភ្នំ និងប្រទេសចិន ត្រូវបានប្រព្រឹត្តឡើងយ៉ាងសកម្ម ។ ក្នុងពង្សាវតាររាជវង្សស៊ុំ ខាងត្បូងមានសេចក្តីរាយការណ៍ថា កាំង តុង ដើម្បីត្រឡប់មកនគរភ្នំវិញ និងបាននាំមកជាមួយពួកគេនូវព្រះភិក្ខុសង្ឃមួយអង្គព្រះនាមនាគសេន ។ ដោយអកុសល នាវានេះត្រូវព្យុះសង្ឃរាបោកបក់ឱ្យរសាត់ជាប់នឹងឆ្នេរសមុទ្រនៃប្រទេស លិន យី ឬ ចម្ប៉ា ដែលជាហេតុធ្វើឱ្យព្រះភិក្ខុនាគសេនធ្វើដំណើរមកប្រទេសកម្ពុជា ដោយផ្លូវគោកទៅវិញ ។

ព្រះមហាក្សត្រខ្មែរនាសម័យនោះ ដែលព្រះនាមថា កៅណ្ឌិន្យជ័យវម្ម (ចៅយេប៉ាមោ) គាវផេងឃូ ទ្រង់បានជ្រាបនូវព្រឹត្តិការណ៍ដ៏សំខាន់នេះហើយព្រះអង្គក៏បានបង្គាប់ឱ្យភិក្ខុអង្គនេះនាំព្រះរាជសារ ព្រមទាំងតង្វាយផ្សេងៗទៅថ្វាយស្តេចក្រុងចិន វូទី នៃរជ្ជកាល អ៊ី នៅឆ្នាំ៤៨៤ នៃគ្រិស្តសករាជ ។ចំពោះតង្វាយខ្មែរ គេឃើញមានរូបបល្ល័ង្កដែលធ្វើអំពីមាសសុទ្ធ ដែលមានឆ្លាក់រូបស្តេចនាគប្រកបដោយក្បាច់ក្បូរ



www.elibraryofcambodia.org

យ៉ាងល្អប្រណីត និងវត្ថុមួយចំនួនទៀត ធ្វើអំពី ភ្នុកដីរ ។

សូមជម្រាបថា គេបានរកឃើញក្នុងបរិវេណនៃវត្តស្រីមហាពោធិ នូវសិលាចារឹកមួយដែលមានខ្លឹមសារដូចតទៅនេះ : " អំណោយទៅពេទ្រង អវធ្យបុរៈ " ។ តាមរយៈសិលាចារឹកនេះ យើងដឹងថា : បុរាណស្ថានខាងលើនេះដើមឡើយមានឈ្មោះថា អវធ្យបុរៈ ឬ ទីក្រុង អហិង្សា ដែលមានមន្ទីរពេទ្រនិងប្រជាពលរដ្ឋរស់នៅយ៉ាងកុះករថែមទៀតផង ។ សេចក្តីទាំងនេះសឱ្យឃើញថា ព្រះពុទ្ធសាសនាមានវត្តមាននៅក្នុងទឹកដីខ្មែរ ដោយគេឃើញមានវត្តអារាម និងមន្ទីរពេទ្រជាស្ថូលតាំងពីដើមសម័យប្រវត្តិសាស្ត្រម្លេះ ។

ក្រៅពីនេះ ប្រភពឯកសារបានឱ្យដឹងទៀតថា ក្នុងរជ្ជកាលរបស់ព្រះបាទជ័យវម៌្ម ខាងលើនេះមានព្រះភិក្ខុខ្មែរពីរអង្គ បាននិមន្តទៅស្រុកចិនតាមសេចក្តីអញ្ជើញរបស់ស្តេចចិន ដើម្បីបកប្រែគម្ពីរព្រះពុទ្ធសាសនាមហាយាន របស់ខ្មែរដែលសរសេរជាភាសាសំស្ក្រឹត ទៅជាភាសាចិន ។ ព្រះសង្ឃទាំងពីរអង្គមានព្រះនាមថា សង្ឃបាល និង មន្ទ្រសេន ។ ព្រះសង្ឃខ្មែរព្រះនាម សង្ឃបាល បានគង់នៅប្រទេសចិន មានថេរវេលា ១៦ឆ្នាំ ហើយបានធ្វើការក្នុង ការិយាល័យទាំងប្រាំ ។ សូមជម្រាបថា ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រខាងលើនេះ មិនខុសប៉ុន្មានទេទៅនឹងការដែលព្រះសង្ឃថៃ បានបង្កើតការិយាល័យខ្មែរ-ថៃ មួយស្ថិតនៅវត្ត សាកេត នៅទីក្រុងបាងកក សម្រាប់បកប្រែគម្ពីរព្រះត្រៃបិតកខ្មែរ ទៅជាភាសាថៃ ចាប់តាំងពីឆ្នាំ ១៩៧០ មក ។

សរុបសេចក្តីមក គឺព្រះមហាក្សត្រខ្មែរនេះហើយ ដែលធ្វើឱ្យព្រះពុទ្ធសាសនាបានភាពរុងរឿង រីកចម្រើនអស្ចារ្យនៅនគរភ្នំ ដូចជា ការដែលស្តេចខ្មែរចាត់[illegible]ព្រះពុទ្ធរូបអង្គនៅឆ្នាំ ៥០៣ នៃគ្រិស្តសករាជ ទៅថ្វាយស្តេចចិនជាសក្ខីភាពស្រាប់ ។

នៅពាក់កណ្តាលសតវត្សរ៍ទី៩ នៃគ្រិស្តសករាជ ព្រះបាទ ជ័យវរ្ម័ ដែលត្រូវជា


www.elibraryofcambodia.org

ព្រះរាជបិតារបស់ព្រះបាទ គុណេវ៉ុន ដែលជាអភិបាលខេត្ត នៅម៉្តស្រុកទឹកខ្មៅ នៅកម្ពុជាក្រោម ប្រារព្ធលើជំនឿព្រះពុទ្ធសាសនាយ៉ាងមុតមាំ ។ សិលាចារឹក ថាប ម៉ឺយ បានប្រៀបធៀបបារមីរបស់ព្រះបាទ គុណេវ៉ុន ប្រដូចនឹងព្រះច័ន្ទ នៃរាជវង្ស កៅណ្ឌិន្យ។

ម្យ៉ាងទៀត ឯកសារចិនក៏បានពិពណ៌នាអំពីការដុះដាល ល្វតលោស់ នៃព្រះពុទ្ធសាសនានៅនគរភ្នំ ជាពិសេសក្នុងរជ្ជកាលរបស់ព្រះបាទកៅណ្ឌិន្យជ័យវម៌្ម ។ ក្រោយពីទ្រង់បានយាងមកពីតំបន់លីហ្គោដែលស្ថិតនៅជ្រោយ ម៉ាឡាយូ ស្តេចអង្គនេះក៏បានឡើងសោយរាជ្យនៅលើបល្ល័ង្ក ។ ព្រះបាទ កៅណ្ឌិន្យជ័យវម៌្ម បានសព្វព្រះទ័យនឹងព្រះពុទ្ធសាសនា ថ្វីត្បិតតែព្រហ្មញ្ញសាសនានិកាយ សិវៈនៅមានឥទ្ធិពលខ្លាំងក្លាយ៉ាងណាក៏ដោយ ។ សូមជម្រាបថា ទំនៀមទម្លាប់នាសម័យនោះ គឺការគោរពបូជាដល់ព្រះ មហេស្វរៈ ដែលស្ថិតនៅលើភ្នំដ៏ល្បីល្បាញមួយជាទីសក្ការៈ មានឈ្មោះថា ម៉ូតាននៅស្រុកបាភ្នំ ខេត្តព្រៃវែង ។ " ព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ បានទទួលពីព្រះអទិទេពនូវសិរីមង្គល ហើយប្រជារាស្ត្រមានសុខសន្តិភាព " ដោយហេតុថា ព្រះពោធិសត្វលោកេស្វរៈ " ទ្រង់មានមេត្តាធម៌ព្រួស ប្រណីចំពោះពួកគេ " ។

ទន្ទឹមនឹងនេះ យើងបានឃើញមានព្រះពុទ្ធរូបជាច្រើននៅតាមអរម្យដ្ឋាននានា ដែលស្ថិតនៅក្នុងបង្គោលសីមារបស់នគរភ្នំ ហើយដែលមានឥរិយាបថ ឬ មុទ្រផ្សេងៗ ម្យ៉ាងទៀត ចម្លាក់តំណាងព្រះពុទ្ធអង្គនាសម័យបុរាណ បានត្រូវចែកចេញជាពីរនិកាយធំៗ គឺនិកាយហីនយាន និងមហាយានដែលនិយមប្រើភាសាសំស្ក្រឹត ។

ជាការពិតណាស់ សារៈសំខាន់នៃព្រះពុទ្ធសាសនាមិនមែនគ្រាន់តែអប់រំមនុស្សឱ្យធ្វើអំពើល្អប៉ុណ្ណោះទេ តែសាសនានេះតែងតែបន្តកិច្ចអភិវឌ្ឍន៍សង្គម និងវប្បធម៌ខ្មែរ តាមរយៈការរីកចម្រើនផ្នែកស្ថាបត្យកម្ម សិល្បៈ ទូទាំងព្រះរាជាណា-



www.elibraryofcambodia.org

ចក្រកម្ពុជា ។ ដូចសម័យអតីតកាល បច្ចុប្បន្នកាលនេះ ព្រះពុទ្ធសាសនានៅតែផ្តល់ជូនអតិថិជនក្នុងសង្គមខ្មែរនូវប្រព័ន្ធគំនិត គឺអ្វីដែលគេហៅថាទស្សនវិជ្ជាស្របច្បាប់អភិវឌ្ឍន៍ចំណេះចេះដឹង ដោយឧបត្ថម្ភផ្លូវកាយចិត្តរបស់មនុស្ស ពោលគឺសតិសម្បជញ្ញៈតាមរយៈវិស័យសីលធម៌ ។

ស្តីពីវិស័យសិល្បៈ ការស្រាវជ្រាវរបស់យើងរវាងឆ្នាំ ១៩៩៣ និង ១៩៩៨ បានផ្តល់នូវពត៌មានបន្ថែមទៀត ដែលពុំធ្លាប់មានពីមុនមក ។ នេះជាលទ្ធផលនៃការសិក្សារបស់យើង :

ពិតហើយសព្វថ្ងៃនេះ តាមរយៈអ្នកស្រាវជ្រាវ យើងដឹងហើយថានាសម័យនគរភ្នំ ជនជាតិខ្មែរយើងនិយមព្រះពុទ្ធសាសនានិកាយ ហីនយាន និង មហាយាន ព្រមទាំងព្រហ្មញ្ញសាសនាក្នុងពេលជាមួយគ្នា ហើយការជ្រើសរើសនិកាយនិមួយៗ ត្រូវបានធ្វើឡើងតាមឆន្ទៈ ឬតាមចំណូលចិត្តផ្ទាល់របស់ពុទ្ធសាសនិកក៏ប៉ុន្តែរហូតដល់ពេលនេះ យើងមិនទាន់ដឹងច្បាស់ថា តើនិកាយមួយណាបានមកដល់កម្ពុជាមុនគេ ។ បើនិយាយម្យ៉ាងទៀត សំណួរនេះបានធ្វើឱ្យយើងចាប់អារម្មណ៍ណាស់ ក៏ប៉ុន្តែគេមិនទាន់ដោះស្រាយយ៉ាងប្រាកដប្រជានៅឡើយទេ ។ មូលហេតុបណ្តាលមកពីកង្វះភស្តុតាងជាក់ស្តែង ។

ថ្មីៗនេះ យើងមានសេចក្តីរំភើបចិត្តជាខ្លាំង ដោយបានរកឃើញនូវភស្តុតាងថ្មីៗមួយចំនួន ដែលអាចបំភ្លឺនូវការហូរចូលនៃព្រះពុទ្ធសាសនា ក្នុងអតីតព្រះរាជាណាចក្រកម្ពុជា នាដើមសម័យប្រវត្តិសាស្ត្រ។ វត្តមានរបស់ព្រះ វត្តអារាម និងព្រះភិក្ខុសង្ឃក៏ត្រូវបានបញ្ជាក់ Ka7 និង Ka29 ដែរ ។

ការវិភាគលើជ្រុងបដិមាសាស្ត្រ បានបង្ហាញឱ្យយើងឃើញថា ទន្ទឹមនឹងការគោរពទាំងពីរខាងលើនេះ ប្រជាពលរដ្ឋខ្មែរបុរាណដែលរស់នៅម្តុំអង្គរបុរី និងនៅត្រង់ប្រទេសវៀតណាមហៅកម្ពុជាក្រោមសព្វថ្ងៃ បានប្រារព្ធនិយមនិកាយមួយទៀត គឺនិកាយ



www.elibraryofcambodia.org

ពេជ្រយានដែលជាយានកណ្ដាល ហើយដែលជាមែកធាងរបស់លទ្ធិមហាយាន ។

ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀត គឺតាមការស្រាវជ្រាវផ្នែកបដិមាសាស្ត្រយើងបានរកឃើញថា ចម្លាក់តំណាងព្រះពុទ្ធអង្គដែលមានឥរិយាបថ ឬ មុទ្រាផ្សេងៗ គឺជាចម្លាក់បែបហីនយាននិយម ហើយមានចំណាស់ចាស់ជាងគេបង្អស់ ។

ការអះអាងរបស់យើង គឺពឹងផ្អែកទៅលើការរកឃើញនូវព្រះបដិមាថ្មតំណាងព្រះពុទ្ធអង្គ ឬក៏ព្រះ[illegible]ព្រះពុទ្ធជាច្រើនអង្គ ដែលមានលក្ខណៈជារចនាបថសិល្បៈគន្ធារៈ និងអមរាវតី ។ [illegible]ប្រាប់ថា គន្ធារៈជាមណ្ឌលវប្បធម៌បែបពុទ្ធនិយមដែលមានអាយុចាស់ជាង រវាង ស.វ ទី២មុន គ.ស និង ទី៣ ក្រោយ គ.ស រីឯមណ្ឌលវប្បធម៌នេះ បានដុះដាលឡើងនៅ ស.វ ទី២ នៃ គ.ស តែប៉ុណ្ណោះ ។

លក្ខណៈវិសេសវិសាលនៃរចនាបថគន្ធារៈ គឺការឆ្លាក់រូបព្រះពុទ្ធអង្គ ឬឆាកជីវិតរបស់ព្រះពុទ្ធអង្គ ជារូបរាងមនុស្សសុទ្ធសាធ ដោយយកលំនាំដើមតាមពួកក្រិកនិងរ៉ូម៉ាំង នាសតវត្សរ៍ទី៣ មុនគ្រិស្តសករាជ ដែលបានពាតសន្ធឹងឥទ្ធិពលនយោបាយ និងវប្បធម៌របស់ខ្លួនដល់ភូមិភាគនេះ ។ ព្រោះអីមុនសម័យកាលនេះ សិល្បករជាតិឥណ្ឌា គ្រាន់តែយកសញ្ញានិមិត្តតែប៉ុណ្ណោះ ដើម្បីតំណាងព្រះពុទ្ធអង្គ ឬឆាកជីវិតរបស់ព្រះពុទ្ធអង្គ របស់គ្រូនៃយើង ។ ឧទាហរណ៍ដូចជាព្រះពុទ្ធបាទ ដើមពោធិ៍ សត្វប្រើស កង់ចក្រ ។ល។ នៅតាមទីក្នុងរវាងសតវត្សរ៍ទី៣ និងទី១ មុនគ្រិស្តសករាជ ។

ដោយឡែក យើងត្រូវកត់ត្រាថា មណ្ឌលវប្បធម៌គន្ធារៈ ដែលស្ថិតនៅក្នុងភូមិភាគខាងជើងនៃប្រទេសឥណ្ឌា និងមណ្ឌលវប្បធម៌អមរាវតី នៅក្នុងភូមិភាគឥណ្ឌាខាងត្បូង បានដុះដាលឥទ្ធិពលទៅលើសិល្បៈខ្មែរ នាគ្រាបឋមនៃប្រវត្តិសាស្ត្រខ្មែរ ក៏ប៉ុន្តែពុំមានន័យថា មានតែមជ្ឈមណ្ឌលវប្បធម៌បែបពុទ្ធនិយមតែពីរនោះទេដែលបានជះឥទ្ធិពលលើសិល្បៈខ្មែរ ។ តាមពិតជាងចម្លាក់ថ្ម ជាងទង និងជាងសូនរូបខ្មែរ នាសម័យ



www.elibraryofcambodia.org

នគរភ្នំ បានទទួលឥទ្ធិពលពីមណ្ឌលវប្បធម៌សរនថ និងអជន្ត ជាដើម ។

អានុភាពនៃវប្បធម៌ឥណ្ឌាបុរាណ ទៅលើវិស័យវិចិត្រសិល្បៈខ្មែរ អាចធ្វើឡើងតាមវិធីផ្សេងៗដូចតទៅនេះ ។

វិធីទី១ : គឺជនជាតិខ្មែរយើងដែលបានរស់នៅក្នុងចក្រភពភ្នំ បានសូនរូបព្រះបដិមា ដោយយកគំរូសិល្បៈតាមចម្លាក់តូចៗ ដែលពួកពាណិជ្ជករក្លិង្គ បាននាំតាមសំពៅដើម្បីគោរពបូជាប្រចាំថ្ងៃ ឬឆ្លាក់រូបតាមគម្ពីរសាសនាទាំងឡាយ ដូចជាគម្ពីរសិល្បៈសាស្ត្រជាដើម ដែលជាក្បួនខ្នាតពិធីការដ៏សំខាន់ ។ គេបានរកឃើញនូវព្រះបដិមា ព្រមទាំងព្រះកេសព្រះពុទ្ធអង្គតូចៗជាច្រើន នៅក្នុងបរិវេណនៃព្រំប្រទល់នគរភ្នំ គឺនៅកម្ពុជាក្រោម ឬនៅទីរួមខេត្តផ្សេងៗ ក្នុងចក្រភពភ្នំដូចជាអង្គរបុរី កញ្ចនៈបុរី នគរបឋម នគររាជសីមា និងនៅប្រទេសឥណ្ឌូណេស៊ី និងម៉ាឡេស៊ី ។ ចម្លាក់បុរាណទាំងអស់នោះ ជាភស្តុតាងទាក់ទិននឹងការផ្សព្វផ្សាយនៃលទ្ធិព្រះពុទ្ធសាសនា ។

រីឯវិធីទី២ : គឺខ្មែរយើងបានអញ្ជើញទៅរៀនសូត្រ នៅប្រទេសឥណ្ឌាហើយក្រោយពីបានធ្វើមាតុភូមិនិវត្តន៍មកកាន់ស្រុកកំណើតវិញ ក៏បានសាងសង់នូវព្រះបដិមាឡើងតាមលំនាំក្លិង្គ សម្រាប់បូជា ។

សូមជម្រាបថា លទ្ធិព្រះពុទ្ធសាសនាដែលមានកេរ្តិ៍ឈ្មោះល្បីប្រពៃ បន្តិចម្តងៗបានផ្សព្វផ្សាយទូទាំងព្រះរាជាណាចក្រខ្មែរ ។ ការស្រាវជ្រាវក៏បានឱ្យយើងដឹងទៀតថា ទឹកដីខ្មែរបុរាណដែលស្ថិតនៅលើតំបន់ខ្ពង់រាប នៃប្រទេសថៃបច្ចុប្បន្ន តំបន់នេះក៏ស្ថិតនៅក្រោមឥទ្ធិពលនៃព្រះពុទ្ធសាសនា លទ្ធិហីនយាន ឬថេរវាទ ដូចតំបន់វាលទំនាបដទៃៗឯទៀតដែរ ។ សេចក្តីសន្និដ្ឋាននេះ បានមកពីការវិភាគនូវបដិមាសាស្ត្រ បែបពុទ្ធនិយម ដែលបានធ្វើឡើងក្នុងអំឡុង ១៥ ឆ្នាំចុងក្រោយនេះក្រោយពីប្រមែប្រមូលនូវវត្ថុតាងជាច្រើន ។



www.elibraryofcambodia.org

គួរកត់ត្រាថា និកាយថេរវាទ ឬនិកាយហីនយានខាងលើនេះ ដែលមានវត្ត
មាននៅក្នុងខេត្តបស្ចិមបូរី និងនគររាជសីមាបច្ចុប្បន្ន បានបែកចេញពីនិកាយ
មហាយានសង្ឃិក ដែលស្ថិតនៅក្នុងភូមិភាគខាងត្បូង ត្រង់ម្តុំអមរាវតី និងនាគារជុន-
កោណ្ឌៈ ក្នុងភូមិភាគកណ្តាលនៃប្រទេសឥណ្ឌាសព្វថ្ងៃ ។ គឺនៅក្នុងទីតាំងបុរាណទាំងពីរ
នេះហើយ ដែលគេបានជួបប្រទះនូវវត្តអារាម ព្រះចេតិយ និង ព្រះបដិមាប្រកប
ដោយក្បាច់រចនាដ៏ល្អវិចិត្រ ។

សរុបសេចក្តីមក ចំពោះសំណួរដែលបានចោទសួរថា តើនៅប្រទេសកម្ពុជា
មានរចនាបថពុទ្ធនិយមមួយណាដែលចាស់ជាងគេ យើងអាចឆ្លើយបានថា គឺរចនាបថ
ភ្នំដា ដែលមានអាយុកាលចាស់ជាងរចនាបថដទៃៗទៀត ហើយជារចនាបថផ្សំរវាង
សិល្បៈឥណ្ឌា និងក្រិក-រ៉ូម៉ាំង ដែលផ្សព្វផ្សាយដោយព្រះចៅអធិរាជ អាឡិកសង់មហា
រាជ្យ ។

ជាសេចក្តីសន្និដ្ឋាន ការវិភាគលើរូបបដិមាសាស្ត្របែបពុទ្ធនិយម នៅក្នុង
អរិយធម៌វប្បធម៌ជាច្រើននៃប្រទេសឥណ្ឌា ដូចជានៅ សានឆី អមរាវតី នាគារជុន
កោណ្ឌៈ អជន្តៈ ។ល។ បានបញ្ជាក់ថា ខេត្តនានាជាច្រើននៃមហាប្រទេសឥណ្ឌា
បុរាណ បានចូលរួមវិភាគទានយ៉ាងសកម្ម ក្នុងការស្ថាបនាសាងសង់ជឿនវប្បធម៌
អារ្យធម៌ខ្មែរបុរាណ ហើយទំនាក់ទំនងរវាងប្រទេសឥណ្ឌា និងនគរភ្នំ មានលក្ខណៈជា
អចិន្ត្រៃយ៍ ចាប់តាំងពីដើមសម័យប្រវត្តិសាស្ត្ររហូតដល់សម័យអង្គរ ។ ពីសម័យកាល
មួយ ទៅសម័យកាលមួយទៀត ប្រទេសខ្មែរបានទទួលពីប្រទេសឥណ្ឌានូវលទ្ធិសាសនា
និងរចនាបថសិល្បៈប្លែកៗពីគ្នាតាមលំដាប់លំដោយ ហើយគឺក្នុងបរិស្ថានសង្គមវប្បធម៌
នេះហើយ ដែលសិល្បៈខ្មែរប្រកបដោយភាពសំបូរបែប និងមានលក្ខណៈរុងរឿង
ថ្កុំថ្កើង ជាងវប្បធម៌អារ្យធម៌នៃប្រទេសជិតខាង ក្នុងភូមិភាគអាស៊ីអាគ្នេយ៍នេះ ។



www.elibraryofcambodia.org

## អត្ថបទរូបចម្លាក់ជាលក្ខណៈពុទ្ធនិយម :

តម្លៃជាមូលដ្ឋាននៃពុទ្ធរូបនាសម័យនគរភ្នំ ដែលរចនាអំពីថ្ម សំរិទ្ធ ឈើ ដីដុត កែវ និង ភ្លុក សម្រាប់ធ្វើពិធីសក្ការៈបូជា ដែលគេបានរកឃើញក្នុងស្រុកអង្គរបុរី គឺស្ថិតនៅលើសីលធម៌និងព្រហ្មវិហារធម៌ ដែលជាគ្រឹះរបស់សាសនានេះ ។ រូបចម្លាក់ទាំងអស់នេះ បញ្ជាក់នូវទឹកព្រះទ័យរបស់ព្រះមហាក្សត្រ និងប្រជារាស្ត្រខ្មែរគ្រប់ជាន់ថ្នាក់ ដែលស្តេចបានជាប់ជំពាក់ព្រះរាជបុព្វ័យ ទៅលើអំពើល្អដូចជាការសាងសង់សមិទ្ធផលផ្សេងៗ មានការជីកស្រះ ស្ថាបនាវត្តអារាម ដើម្បីទុកជាកេរ្តិ៍មរតកសម្បត្តិជាតិ ឬទុកជាសមិទ្ធិផលក្នុង ការតស៊ូក្នុងជប និងអត្ថផលរបស់ព្រះអង្គ និងទុកជូនមនុស្សលោកទាំងពួង ។

ចំពោះសមិទ្ធផលគ្រប់ប្រភេទ ទាំងព្រះមហាក្សត្រ និងទាំងប្រជារាស្ត្រខ្មែរ រមែងតែធ្វើកិច្ចអធិដ្ឋាននូវផលានិសង្ស ដែលកើតឡើងមកពីការស្ថាបនាសមិទ្ធផលទាំងឡាយនេះ ដើម្បីសម្រេចនូវប្រយោជន៍ផ្ទាល់នៅជាតិនេះ និងជាតិក្រោយ ព្រមទាំងប្រាសចាកនូវអំពើពាលកម្មវេរា ឆ្ពោះទៅកាន់ត្រើយបរមសុខពោលគឺព្រះនិព្វាន ។

លើសពីនេះទៀត ភាពសម្បូរបែបនៃពុទ្ធរូបខ្មែរ ក៏បង្ហាញឱ្យយើងដឹងដែរថា វប្បធម៌ឥណ្ឌាដែលបានជះឥទ្ធិពលទៅលើវប្បធម៌ខ្មែរមានច្រើនប្រភព ពោលគឺពុំមែនចេញមកពីកន្លែង ឬតំបន់តែមួយទេ ។

ដូច្នេះហើយបានជាគេរកឃើញនូវព្រះពុទ្ធរូបដែលមានរចនាបថប្លែកៗពីគ្នា គឺមានជាបែបគន្ធារៈ អមរាវតី មធុរា ឬអជន្តា ជាដើម ដែលជាភស្តុតាងបង្ហាញឱ្យយើងដឹងយល់អំពីសមត្ថភាពវប្បធម៌ និងទេពកោសល្យពិតៗរបស់ជនជាតិខ្មែរប្រមាណជា ២០០០ ឆ្នាំ មកហើយ ។



www.elibraryofcambodia.org

# ទស្សនៈស្ដីអំពីលោក

ទស្សនៈស្ដីអំពីលោកនាសម័យនគរភ្នំ ជាការរួមសង្ខាស់រវាងទស្សនៈក្លិង្គនិង មន-ខ្មែរ ដែលជាសំណល់នៃប្រព័ន្ធគំនិតរបស់ជនជាតិខ្មែរបុរាណ ហើយតាមទស្សនៈ ដែលមានលក្ខណៈជាសំយោគនេះ លោកយើងនេះត្រូវចែកជាបីឋាន ឬភាគ គឺឋានសួគ៌ ឋានមនុស្ស និងឋាននរក ។ បញ្ហានេះជាគន្លឹះសម្រាប់ការយល់អំពីវប្បធម៌នា សម័យនគរភ្នំ ។

សូមជម្រាបថា ទោះបីជាជនជាតិខ្មែរប្រតិបត្តិលទ្ធិព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ក៏ជំនឿលើឥទ្ធិពលធម្មជាតិ និងការគោរពជូនតា ចាស់ស្រុកឬអារក្ស អ្នកតានៅតាមស្រុកភូមិ ដែលជាជំនឿនាសម័យបុរេប្រវត្តិសាស្ត្រ ត្រូវបានបន្តជារៀងរាល់ថ្ងៃ ។

តាមការពិនិត្យនិងវិភាគ វត្ថុបុរាណមួយចំនួនថ្មីដែលយើងបានជួបប្រទះក្នុង ស្ថានីយ៍អង្គរបូរី យើងមានតម្រុយថា ជូនតាខ្មែរយើងដែលបានតាំងលំនៅស្ថាននៅលើ ទីតាំងនេះមានជំនឿទៅលើអារក្ស អ្នកតាចាស់ស្រុក ដូចសព្វថ្ងៃទោះបីពួកគេនិយម ប្រតិបត្តិទេវតាតូចធំ នៃសាសនាទាំងពីររបស់ជនជាតិក្លិង្គយ៉ាងណាក៏ដោយ ។

នៅឋានមនុស្ស គេឃើញមានទេវតាតូចធំជាច្រើន ដូចជាព្រះនារាយណ៍ ព្រះសិវៈ ព្រះព្រហ្ម និងវត្ថុស័ក្ដិសិទ្ធិជាអារក្ស អ្នកតា រុក្ខទេវតា យក្ស រាជសីហ៍ នរសិង្ហ ដែលបានបីបាច់ថែរក្សា ព្រមទាំងផ្ដល់សេចក្ដីសុខសប្បាយដល់មនុស្សលោក ។

នៅលើអាកាសគេសង្កេតឃើញមាន ព្រះឥន្ទ្រ ស្រីទេពអប្សរ និងសត្វ អច្ឆរិយៈមួយចំនួន ដូចជាបក្សី គ្រុឌ ឬ នរសិង្ហ ជាដើម ។

ចំណែកនៅឋាននរកវិញ ដែលជាលំនៅស្ថានរបស់ ភុជង្គនាគ នេះគេឃើញ មាននរក គឺនៅទីនេះហើយដែលពួកយមបាលធ្វើទារុណកម្មមនុស្ស ដែលបានសាង



www.elibraryofcambodia.org

អំពើបាបកម្មនៅពេលដែលគេមានជីវិតនៅឡើយ ។

សូមជម្រាបថា នេះជាសេចក្តីសន្និដ្ឋានដែលពឹងផ្អែកទៅលើការវិភាគវត្ថុបុរាណមួយចំនួន ដែលទើបតែជួបប្រទះថ្មីៗនេះ ហើយជាមូលដ្ឋាននៃទស្សនវិជ្ជាខ្មែរនាសម័យបុរាណ ។

មូលហេតុដែលនាំឱ្យជនជាតិខ្មែរទទួលទេវតា ព្រហ្មញ្ញសាសនានិងពុទ្ធសាសនា ដោយយកព្រះសុខដុមរមនា គឺដោយសារវត្ថុអច្ឆរិយៈក្តីទាំងនោះបានធ្វើឱ្យទស្សនៈជឿស្តីអំពីលោករបស់គេមានភាពរឹងមាំមួនខុសពីសម័យកាលមុនៗដូចជាខ្លឹមសារអត្ថបទនៃសិលាចារឹក ដែលមានលក្ខណៈជាព្រហ្មញ្ញសាសនាជាសក្ខីភាពស្រាប់ ។ ម្យ៉ាងទៀត ដោយយោងទៅលើទស្សនៈនេះ យើងអាចឃើញនូវឆន្ទៈខ្មែរយ៉ាងច្បាស់លាស់ ចំពោះបញ្ហាស្តីអំពីលោក ពោលគឺខុសពីសម័យមុនៗ គេឃើញក្នុងសម័យមានសក្តិភូមិ នូវការលើកតម្កើងនូវមហិទ្ធិឫទ្ធិ ឬព្រហ្មវិហារធម៌ដ៏ធំធេងមហិមារបស់ទេពត្រីមូរ្តិ ដូចជាព្រះសិវៈ ព្រះវិស្ណុ ឬព្រះនាងលក្ស្មី ជាដើមដែលជាអ្នកបង្កើត ឬរក្សាលោកយើងនេះ ។

អ្វីដែលពោលខាងលើនេះ អាចបង្ហាញឱ្យយើងឃើញអំពីជំនឿខ្មែរស្តីអំពីលោកយ៉ាងប្រាកដ ។ ដូចនេះហើយ ការបួងសួងលួងលោមទេវតា ពុំមែនជាការចៃដន្យទេ ហើយការគោរពបូជានេះនៅតែមានជីវិតដល់សព្វថ្ងៃ ។

## វិស័យអក្សរសាស្ត្រ

ថ្វីត្បិតតែយើងឃើញមានវត្ថុមានរបស់តួអក្សរជាច្រើនឆ្លាក់លើបន្ទះថ្ម ចិញ្ចៀន បន្តោងក និង ក្រវិលត្រចៀក នៅតំបន់ឆ្នេរសមុទ្រនានានៃប្រទេសសព្វថ្ងៃ នៅកំពង់ផែ អូរកែវ និងអង្គរបុរី នារវាងសតវត្សរ៍ទី១ ដល់សតវត្សរ៍ទី៣ នៃ



www.elibraryofcambodia.org

គ្រិស្តសករាជក៏ដោយ  ក៏ប៉ុន្តែគេពុំអាចចាត់ទុកថា  អក្សរចារឹកទាំងអស់នោះតំណាងអក្សរសិល្ប៍  ឬ  អក្សរសាស្ត្រនៅឡើយទេ ។ គេត្រូវរង់ចាំសតវត្សរ៍ទី៣  នៃគ្រិស្តសករាជទើបឃើញការលេចធ្លោនៃអក្សរសាស្ត្រខ្មែរ  តាមរយៈសិលាចារឹកដ៏វែងមួយ ដែលចាស់ជាងគេបង្អស់ គឺសិលាចារឹក វ៉ូកាញ់ នៅកម្ពុជាក្រោម ។

តទៅនេះ  យើងនឹងលើកយកនូវផ្ទាំងសិលាចារឹកមួយចំនួន  ដើម្បីបង្ហាញពីវិស័យអក្សរសាស្ត្រ នាសម័យនគរភ្នំ ។ ផ្ទាំងសិលាចារឹកដែលយើងនឹងលើកមកពិនិត្យនៅទីនេះមានចំនួនបួនផ្ទាំង ដែលមានដូចតទៅ :-

ទី១ - សិលាចារឹកនៅ វ៉ូកាញ់ ខេត្តញ៉ាត្រាង យៀកណាមខាងត្បូង ដែលនាសម័យដើម ស្ថិតក្នុងបរិវេណនគរភ្នំ ។

ទី២ - សិលាចារឹកនៅ អ្នកតាដំបងដែក ខេត្តតាកែវ ។

ទី៣ - សិលាចារឹក ប្រាសាទប្រាំល្វែង ក្នុងដែនកូសាំងស៊ីន កម្ពុជាក្រោម ក្នុងស្រុកទឹកខ្មៅ ខេត្តព្រែកឬស្សី ។

ទី៤ - សិលាចារឹក នៅទន្លេបាទី ខេត្តតាកែវ ប្រាសាទតាព្រហ្ម ។

## សិលាចារឹកទី ១ : សិលាចារឹកនៃវ៉ូកាញ់

តាមសេចក្តីរបស់លោក ហ្សង់ ភីលីយ៉ូហ្សា សិលាចារឹកវ៉ូកាញ់ ជាសិលាចារឹកខ្មែរនាសម័យនគរភ្នំ  ត្រូវបានចារឡើងនៅសតវត្សរ៍ទី៣  នៃគ្រិស្តសករាជ  ហើយមានលក្ខណៈជាព្រហ្មញ្ញសាសនា ។ ការសន្និដ្ឋានខាងលើនេះ ធ្វើឱ្យយើងបដិសេធនូវទស្សនៈដែលធ្លាប់មានពីមុន ។

### ក ~ អត្ថបទដើមជាភាសាសំស្ក្រឹត :

...ប្រជានំ  ...  ប្រថមវិជយ  ...  ណ្ឌិបស្យាប  ។  អាជ្ញា  បិតំ

ទសសិរាជវរេណ ... រាជគណ ... រាគមតំ បិពន្ធុ ស្រីមារ ... រាជកុល ... ៨ ...



www.elibraryofcambodia.org

ន ស្រីមារ ... លោ ... ន កុលនន្ទ- នេន អាផ្វា បិតំ ស្វផន ... ស ... មឡេ វាក្យំ

ប្រវាហិតតរំ តរិណោរ្វរេណ លោកស្យាស្យ គតាគតិ រី ... ន សិង្ហា សនាឡា

សីនេន ក្រាតរិ នាឡ្យកេ ស្វសមីករណផន្មេនតប្តេមុ យត កិត្វិាទ្របតំ សុវណ្ណមបិ

វាសស្វាវរព្វាង្គមកោម្វាតារិក ... ទំ ប្រិយហិតេ សរ្វំ វិស... ...ហា តទេ រំ

មយានុផ្វាតំ ភរិស្បែរបិ រាជភិរនុបន្តរ្យំ វិទិតមស្តុ ចមេភត្យស្យ វីរស្យ ... ។

## ខ ‑ សេចក្តីប្រែសម្រួល :

... សេចក្តីករុណាចំពោះសព្វសត្វទាំងឡាយ ... ប្រថមជ័យ ... ថ្ងៃពេញបុណ្ណមី (?) ព្រះវីររាជាទ្រង់បានប្រកាស ក្នុងរាជសភាថា " ចូរប្រជាជនក្រេប ផឹកនូវទឹកអម្រឹត ពោលគឺ ព្រះរាជបន្ទូល ព្រះបាទ ... ជាវង្សនៃព្រះបាទស្រីមរញ ទ្រង់បានជាកិត្តិយស នៃរាជវង្សស្រីមារៈ ទ្រង់បានប្រកាសក្នុងកណ្តាលជំនុំជន នូវព្រះរាជបន្ទូលស្ងួរសីហនាទជាប្រយោជន៍ ដល់ប្រជាជនទាំងឡាយ ទ្រង់ជាកវីពេ ទាំងពីរដ៏ប្រសើរទ្រង់ប្រថាប់លើសិង្ហាសនៈ( ព្រះរាជបល្ល័ង្កស្វេតឆ័ត្រ ... ហើយទ្រង់... នូវគតាគតិ គឺការអន្ទោលស្លាប់កើតនៃមនុស្សលោក ទើបត្រាស់... " កាល... បងប្អូនខ្ញុំក្តី មិនមែនអ្នកឡើតទេ បានសម្រេចបំពេញខ្លួនហើយ ( បានសោយរាជ្យតទៅ ? ) ( ខ្ញុំសូមឱ្យយក ) សម្បត្តិខ្ញុំទាំងអស់ ប្រាក់មាសសង្ហារិមក្តី អសង្ហារិមក្តីទៅប្រើជាវត្ថុសម្រាប់ជាទីរីករាយ និងជាប្រយោជន៍ដល់សត្វលោកទាំងឡាយ ។ នេះជាសេចក្តីបញ្ជារបស់ខ្ញុំ ។ សូមព្រះរាជាទាំងឡាយនៅក្នុងអនាគត ប្រតិបត្តិតាមព្រះរាជបញ្ជាខ្ញុំកុំបីខាន ។ ហើយចូរប្រឹក្សាជាមួយ សេវកាមាត្យឈ្មោះវីរ ... របស់ខ្ញុំ " ។

## សិលាចារឹកទី ២ : សិលាចារឹកនៅអ្នកតាដំបងដែក

សិលាចារឹកនេះ ជាសិលាចារឹកដែលគេបានរកឃើញនៅខេត្តតាកែវ ហើយបានពិពណ៌នាអំពីព្រះនាង កុលប្រភាវតី ដែលជាព្រះអគ្គមហេសីរបស់ព្រះបាទ



www.elibraryofcambodia.org

កៅណ្ឌិន្យវម្ម៌ ពោលគឺព្រះនាងទ្រង់ប្រាថ្នាចេញចាកលោក ហើយបានស្ថាបនាទេវាល័យតម្កល់ដេមាព្រះវិស្ណុ ដែលធ្វើអំពីមាសសុទ្ធ ព្រមទាំងលំនៅនិងស្រះសម្រាប់ពួកព្រាហ្មណ៍ ។

គប្បីរំលឹកត្រង់នេះថា ព្រះនាង កុលប្រភាវតី ត្រូវជារាជនីរបស់ព្រះរាជកុមារ គុណវម៌្ម ដែលយើងបានពិពណ៌នារួចហើយ ក្នុងទំព័រមុនៗ ។ រីឯព្រះបាទកៅណ្ឌិន្យជ័យវម្ម៌ ទ្រង់សោយទីវង្គតក្នុងឆ្នាំ ៥១៤ នៃគ្រិស្តសករាជ ត្រូវនឹងព្រះពុទ្ធសករាជ ឆ្នាំ ១០៥៧ ។

## សិលាចារឹកទី៣ : សិលាចារឹក ប្រាសាទតានៀវ

ផ្ទាំងចារឹកនេះ បានពិពណ៌នាអំពីគុណសម្បត្តិរបស់ព្រះរាជកុមារ គុណវម៌្ម ដែលជាព្រះរាជបុត្ររបស់ព្រះមហាក្សត្រ ដោយមានពាក្យពេចន៍ដូចតទៅ : ព្រះអង្គជា " ព្រះច័ន្ទនៃរាជវង្ស កៅណ្ឌិន្យ " ។ ទ្រង់បានត្រាស់បញ្ជាឱ្យចារឹកទុកថា កន្លែងដែលព្រះអង្គបានកាន់កាប់ត្រួតត្រានេះ គឺជាកន្លែងដែលព្រះវរបិតារបស់ព្រះអង្គបានប្រទានថ្វាយព្រះអង្គ ហើយគឺជាកន្លែងដែលដើមឡើយជាវាលទឹកភក់ ។

## សិលាចារឹកទី ៤ : សិលាចារឹកនៅភ្នំបាទី

សិលាចារឹកនេះត្រូវបានចារឡើង នៅសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ហើយបានឱ្យយើងដឹងថា ព្រះបាទ រុទ្រវម៌្ម ទ្រង់កាន់សាសនាព្រះពុទ្ធ ហើយគោរពព្រះបរមសារីរិកធាតុ ដែលជាព្រះកេសាមួយសរសៃជាទីសក្ការៈបូជា នៃព្រះសម្មាសម្ពុទ្ធផង ។ តាមឯកសារចិន ព្រះកេសាមួយសរសៃនេះត្រូវព្រះចៅក្រុងចិន នៃរាជវង្សស៊ុីខាងត្បូងបានសុំហើយយកបាត់ទៅ ។ ចំពោះខ្លឹមសារនៃសិលាចារឹកនេះ យើងមានសេចក្តីសង្ខេបនៃសេចក្តីបកប្រែ ដោយព្រះតេជៈគុណព្រះ ប៉ាង ខាត់ ដូចខាងក្រោមនេះ :-

" ព្រះជិនស្រីទ្រង់ឈ្នះនូវសឹកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនាទ្រង់



www.elibraryofcambodia.org

ប្រកបដោយសម្បទាគ្រប់ប្រការ មានពោធិញ្ញាណឥតទើសទាល់សល់ជំពាក់អ្វីឡើយ មានព្រះទ័យប្រកបដោយករុណាចំពោះសព្វសត្វ មានព្រះយសធំទូលំទូលាយឥតមានមោះមន្ទិលឡើយ ហើយផ្សាយទូទៅគ្រប់ទិសានុទិស ។ ព្រះអង្គស្រោចស្រង់សត្វលិចលង់ក្នុងវាលវដ្តសង្សារ គឺត្រៃភព ហើយបានផ្តល់ត្រើយត្រាណហាន់ព្រះនិព្វាន ដ៏ឧត្តមឥតអ្វីប្រៀបបានឡើយ ។ ព្រះស្រីធាតុ (គឺព្រះបរមសារីរិកធាតុ) ព្រះអង្គដែលតែងតែផ្តល់ប្រយោជន៍ធំដល់សព្វសត្វទាំងឡាយ ក៏នៅតែផ្តល់ ប្រយោជន៍ដល់សព្វសត្វលុះរហូតមកដល់ឥឡូវនេះ ... ។ អំពើជាព្រះរាជ ដែលទ្រង់ (ព្រះបាទរុទ្រវម៌្ម) បានបំពេញចំពោះព្រះធម៌ ហើយមិនមែនដើម្បីតែព្រះរាជករណីកិច្ចប៉ុណ្ណោះទេ គឺទ្រង់បំពេញដើម្បីអនុគ្រោះដល់លោកទាំងមូលផង ។ ទ្រង់គោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ... ទ្រង់ បានតាំងព្រះអង្គពេញជា ឧបាសក ដែលឥតមានអំពើបាបលាមក ... " ។

មុននឹងសរុបសេចក្តី គប្បីរំលឹកថា ការប្រើអក្សរ បានត្រូវគេប្រព្រឹត្តឡើងតាំងតែសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ក្នុងខ័ណ្ឌសីមានៃរាជ្យនគរភ្នំ ដូចជានៅម្តុំដែនដីសណ្តកម្ពុជាក្រោម ឬនៅខេត្តដែលជាប់ឆ្នេរសមុទ្រមួយចំនួននៃប្រទេសថៃ ដូចជាខេត្ត សុផាន់បុរី (សុវណ្ណបុរី) រ៉ាពា នគរស្រីធម្មរាជ ។ល។ ដែលស្ថិតនៅក្រោមឥទ្ធិពលនៃវប្បធម៌ឥណ្ឌា នាគ្រាបឋមនៃប្រវត្តិសាស្ត្រ ។ បញ្ហាដែលចោទនៅទីនេះចំពោះអ្នកស្រាវជ្រាវគឺ តើអាចចាត់ទុកថា វត្តមានរបស់តួអក្សរទាំងនោះ ដែលភាគច្រើនបានត្រូវគេសរសេរនៅលើបន្តោងខ្សែក ដែលគេពាក់ជាគ្រឿងអលង្ការជាដើម ជាភស្តុតាងនៃអក្សរសាស្ត្រខ្មែរដែរឬទេ ? ចំពោះបញ្ហានេះ យើងពុំអាចសន្និដ្ឋានដោយច្បាស់លាស់បានទេ ក៏ប៉ុន្តែអ្វីៗដែលយើងអាចនិយាយបាន គឺអក្សរសាស្ត្រឥណ្ឌា បន្តិចម្តងៗបានជ្រាបចូលក្នុងគំនិតបញ្ញាជនខ្មែរតាំងពីដើម សតវត្សរ៍ទី១ ម្ល៉េះ ដូចជាគម្ពីរដីកា ឬជាគក ... ដែលជាគោលគ្រឹះសំខាន់នៃសាសនាឥណ្ឌាទាំងពីរ គឺព្រហ្មញ្ញសាសនា និង



www.elibraryofcambodia.org

ព្រះពុទ្ធសាសនា ។ កត្តានៃការចម្រើន របស់អក្សរសាស្ត្រខ្មែរ នាសតវត្សរ៍ទី៧ នៃគ្រិស្តសករាជ គឺការផ្សព្វផ្សាយនៃសាសនា ដែលគេអាចកំណត់យ៉ាងច្បាស់លាស់ប្រាកដ តាមរយៈសិលាចារឹកទាំងនោះ ។

សូមជម្រាបថា បើយើងយកអត្ថបទនៃ សិលាចារឹកទាំងប៉ុន្មានខាងលើនេះ ដែលប្រកបដោយហេតុការណ៍ វប្បធម៌ អារ្យធម៌ខ្មែរដំបូងមកវិភាគ យើងអាចសន្និដ្ឋានដោយឥតមន្ទិលសង្ស័យថា ខ្មែរយើងមានអក្សរសាស្ត្ររបស់ខ្លួន មានលក្ខណៈភស្តុតាងយ៉ាងពិតប្រាកដមែន ចាប់តាំងពី សតវត្សរ៍ទី៧ នៃគ្រិស្តសករាជ ថ្វីត្បិតតែអក្សរសាស្ត្រនាសម័យនោះ បានត្រូវគេសរសេរឡើងជាភាសាសំស្ក្រឹតក៏ដោយ ។ម្យ៉ាងទៀត យើងក៏អាចសន្និដ្ឋានដែរថា គោលបំណងរបស់អ្នកតែងអត្ថបទសិលាចារឹក នាសម័យបុរាណ គ្មានអ្វីក្រៅពីការលាតត្រដាង នូវប្រវត្តិស្តីអំពីព្រះមហាក្សត្រ ឬវីរជននាសម័យនោះ ដែលសព្វព្រះរាជហឫទ័យ ចំពោះជំនឿក្នុងសាសនាដូចជា ព្រះរាជឱវាទ ស្តីអំពីការអន្ទោលកើត ស្លាប់របស់មនុស្សលោក ក្នុងវដ្តសង្សារ ឬអំពីវណ្ណកម្មនានា ដូចជាការធ្វើព្រះរាជអំណោយ រាជសម្បត្តិ ចំពោះប្រាសាទ និងវត្តអារាមនានា ឬក៏ការកសាងនូវសាសនវត្ថុសម្រាប់គ្រឿងសក្ការៈបូជា ក្នុងព្រះរាជាណាចក្រ ។

សូមកត់សម្គាល់ថា វិធីតែងអត្ថបទសិលាចារឹកខ្មែរនាសម័យនោះ ក៏ដូចនាសម័យក្រោយៗទៀតដែរ គឺមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ ។រីឯអត្ថរសនៃអត្ថបទសិលាចារឹកទាំងនោះ ដែលជាតម្លៃមូលដ្ឋាន គឺស្ថិតនៅលើសង្គមរស នាសម័យកាលនេះ ។ ដូច្នេះហើយ បានជាការសិក្សានូវអត្ថបទសិលាចារឹកបុរាណ អាចឆ្លុះបញ្ចាំងឱ្យយើងស្គាល់ដឹងអំពី ការរស់នៅនិងជំនឿទំនៀមទម្លាប់របស់ជនជាតិខ្មែរយើង នាសម័យបុរាណកាល ដែលបានកន្លងហួសទៅហើយ ។



www.elibraryofcambodia.org

ជាទីបញ្ចប់ គ្រប់ផ្នែកអក្សរសាស្ត្រនាសម័យនោះ ពុំទាន់មានលក្ខណៈប្រជាប្រិយ ដូចសព្វថ្ងៃនៅឡើយទេ ក៏ប៉ុន្តែមានលក្ខណៈដ៏ពិសេសមួយ គឺបម្រើសាសនា ពោលគឺ ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ។

## គ . វិស័យពាណិជ្ជកម្ម :

វត្ថុប្រើប្រាស់ដែលគេបានផលិតឡើង ពុំមែនគ្រាន់តែសម្រាប់ប្រើប្រាស់ជាឧបករណ៍តែប៉ុណ្ណោះទេ ក៏ប៉ុន្តែសម្រាប់ជួញដូរដែរ ហេតុដូច្នោះហើយ បានជាវត្ថុទាំងនោះអាចធ្វើដំណើរយ៉ាងឆ្ងាយពីទីតាំងដើមរបស់ខ្លួន ។ ពាណិជ្ជកម្មអាចធ្វើក្នុងស្រុក និងក្រៅស្រុក ហើយបង្កើតបានជាប្រព័ន្ធពាណិជ្ជកម្មមួយយ៉ាងសកម្ម ។

ដោយសារមូលហេតុដូចខាងលើនេះហើយ បានជាគេបានជួបប្រទះនូវលក្ខណៈដូចគ្នា ឬឯកភាពនៃវត្ថុបុរាណមួយចំនួន ដូចជាទេវរូប ពុទ្ធរូប ចានក្បានធ្វើអំពីដីដុត ដែលយើងបានជួបប្រទះក្នុងខេត្តនានា នៃព្រះរាជាណាចក្របច្ចុប្បន្ននេះ ។

**ប្រភពឯកសារក៏បានឱ្យដឹងទៀតថា ក្នុងវិស័យពាណិជ្ជកម្ម អាណាចក្រភ្នំ មានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយអាណាចក្រ ចិន យី តាមផ្លូវគោក និងផ្លូវទឹក ។**

អ្នកការទូតចិនម្នាក់ដែលបានមកដល់នគរភ្នំ ក្នុងអម្លុងសតវត្សរ៍ទី៣ នៃគ្រិស្តសករាជ បានកត់ត្រាថា លោកបានជួបនឹងគណៈទូតឥណ្ឌា ដែលមកពីភូមិភាគកណ្តាលនៃប្រទេសនេះ ។

សូមបញ្ជាក់ថា ទំនាក់ទំនងផ្នែកពាណិជ្ជកម្ម រវាងនគរភ្នំ និងប្រទេសឥណ្ឌា នាសម័យនោះមានសភាពជិតដិតគ្នាណាស់ ។ ដូច្នេះវត្តមានរបស់ជនជាតិក្លិង្គនៅក្នុងរាជធានីខ្មែរជារឿងធម្មតា គឺគ្មានហេតុអ្វីធ្វើឱ្យយើងភ្ញាក់ផ្អើលនោះទេ រីឯចំណែកជាតិចិនវិញក៏ដូច្នោះដែរ ហើយទំនាក់ទំនងនេះបានស្ថិតនៅរហូតដល់បច្ចុប្បន្នកាលនេះ ។



www.elibraryofcambodia.org

ប្រភពពត៌មានចិនឱ្យដឹងទៀតថា ក្នុងរជ្ជកាលរបស់ព្រះបាទ ហ្វាន់ ឆេម៉ាន់ ក៏គេបាន ឃើញបុរសម្នាក់មកពីប្រទេស តានយ៉ាង ដែលមិនដឹងច្បាស់ថានៅក្នុងខេត្តណា បានមកលក់ដូរជួញប្រែក្នុងប្រទេសឥណ្ឌា និង ក្នុងនគរភ្នំ ។

ចំពោះព្រះនាមព្រះមហាក្សត្រខ្មែរ ហ្វាន់ ឆេម៉ាន់ ដែលគ្រប់គ្រងនគរភ្នំនា សម័យនោះ តាមការស្រាវជ្រាវនៃអ្នកប្រាជ្ញមួយចំនួន អាចឱ្យយើងដឹងថាឈ្មោះនេះ ត្រូវនឹងភាសាសំស្ក្រឹត " ស្រីមរញ្ញ " នៃសិលាចារឹកវ៉ូកាញ់ ។

## ខ . ទំនាក់ទំនងផ្នែកទស្សនវិស័ និងបរទេស :

ថ្វីត្បិតតែកំណត់ហេតុចិន បានបង្ហាញឱ្យដឹងពីគ្រាដំបូងរបស់អាណាចក្រភ្នំថា ខ្មែរយើងបានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រទេសចិន និងឥណ្ឌា ប៉ុន្តែយើងត្រូវដឹង ទៀតថា ក៏នៅមានប្រទេសមួយចំនួនទៀតដែរ បានចងមេត្រីភាព ជាមួយខ្មែរយើង ដូចជា ពិភពអឺរ៉ុប និងរ៉ូម៉ាំង ។

ភស្តុតាងនៃពាណិជ្ជកម្មរវាងអាណាចក្រភ្នំ ជាមួយប្រទេសទាំងនោះ ត្រូវបាន គេដឹងតាមរយៈវត្ថុបុរាណដែលគេបានរកឃើញ នៅក្នុងតំបន់ជាច្រើនដែល ស្ថិតនៅ តាមវាលទំនាប និងឆ្នេរសមុទ្រសៀម និងវៀតណាមខាងត្បូងសព្វថ្ងៃនេះដែល ស្ថិតក្នុងបរិវេណរបស់ដែនដីខ្មែរតាំងពីបុរាណកាលមកម្លេះ ។ សូមបញ្ជាក់ថាតំបន់ទាំង អស់នោះត្រូវគេផ្តាច់ចេញពីព្រះរាជាណាចក្រខ្មែរ ក្រោយពីការបង្កើតរដ្ឋរបស់សៀម និង យួន នៅលើតំបន់ទាំងនោះ ដែលជាហេតុនាំឱ្យមានផ្តាច់ជនជាតិខ្មែរពីតំបន់ សមុទ្រ ។

សូមរំលឹកឡើងវិញថា ការផ្សារភ្ជាប់រវាងជនជាតិខ្មែរទៅ នឹងតំបន់សមុទ្រ ឡើងវិញ ត្រូវបានធ្វើឡើងក្នុងរជ្ជកាលព្រះបាទ នរោត្តម និងព្រះបាទ នរោត្តម សីហនុ ដោយមានការបង្កើតខេត្តថ្មី ដូចមានខេត្តកំពត ឬ ក្រុងព្រះសីហនុជាដើម ។



www.elibraryofcambodia.org

ភស្តុតាងបង្ហាញពីពាណិជ្ជកម្មជាមួយនឹងបរទេស ត្រូវបានរកឃើញនូវតាមតំបន់ជាច្រើនដែលធ្លាប់ជាកំពង់ផែអន្តរជាតិដូចជា កញ្ចានៈបុរី អូរកែវ កំពង់ពោធិ (អង្គរបុរី) ... ។ល។ និងមានជាអាទិ៍ដូចជាវត្ថុធ្វើពី ប្រាក់ សំរិទ្ធ ស្ពាន់ និងមាស ដែលមានរូបព្រះចៅអធិរាជរ៉ូម៉ាំងជាច្រើនអង្គ អង្កាំធ្វើពីកែវស្នូមាន រូបស្តេចនៃរាជវង្សស្សានិដ ចង្កៀងរ៉ូម៉ាំងធ្វើពីសំរិទ្ធ និង ដីដុត ថ្កាំថ្ម និង កែវមានពណ៌ចម្រុះ ចិញ្ចៀនដៃក្រវិលចម្រុះ និង ត្រចៀក ។

គួររំលឹកឡើងវិញដែរថា ដើម្បីជាពតិមានទូទៅចំពោះអ្នកស្រាវជ្រាវវត្ថុបុរាណមួយភាគតូច ដែលបានរកមកពីស្ថានីយ៍ប្រវត្តិសាស្ត្រ ដែលមានប្រភពចេញមកពីប្រទេស អឺរ៉ុប ក្លិង្គ និង ចិន ដូចជា ភាជន៍ ដែលមានជំពូក គន្ធី កញ្ចក់ឆ្លុះ គ្រាប់អង្កាំ ។ ប៉ុន្តែមួយភាគនៃវត្ថុបុរាណត្រូវខ្មែរយើងផលិតក្នុងទឹកដី នគរភ្នំ ដោយគ្រាន់តែចម្លងបែបពីគេតែប៉ុណ្ណោះ ។

រួមសេចក្តីមក ការដែលធ្វើស្ថិតិ ឬ ការប្រៀបធៀបវត្ថុបុរាណដែលជាសម្ភារៈប្រចាំថ្ងៃ ឬជាគ្រឿងអលង្ការ ដោយរាប់តាមចំនួន ដូចជាចំនួនវត្ថុរបស់ក្លិង្គមានចំនួនច្រើនជាងចិន ឬក៏វត្ថុរបស់រ៉ូម៉ាំងមានតិចជាងវត្ថុបុរាណចិន ដែលជាកិច្ចមួយគ្មានសារសំខាន់ចំពោះយើង ។ មូលហេតុមកពីមានប្រការពីរ ដែលយើងចាត់ទុកជាចម្បង : ទី១ - ក្នុងការស្រាវជ្រាវពុំទាន់ធ្វើទូទាំងទឹកដីនគរភ្នំ ដោយត្រូវរាប់បញ្ចូលក្នុងសំយោគ នូវលទ្ធផលស្រាវជ្រាវនៃស្ថានីយ៍ប្រវត្តិសាស្ត្រ ដែលស្ថិតនៅតាមឆ្នេរសមុទ្រសៀមសព្វថ្ងៃ ឬ នៅតាមតំបន់នានានៃខេត្ត តាកែវ . ទី២ - លើការស្រាវជ្រាវពុំទាន់ - ត្រូវគេរៀបចំនៅឡើយ ។

តាមពិត វត្ថុបុរាណដែលមានប្រភពផ្សេងៗ គ្រាន់តែជាសក្ខីកម្មមួយសម្រាប់ឆ្លុះបញ្ចាំងអោយដឹងរាល់គ្នាថា ជនជាតិខ្មែរនាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ មាន



www.elibraryofcambodia.org

ទំនាក់ទំនងជាមួយប្រទេសជាច្រើន ក្នុងវិស័យសេដ្ឋកិច្ច និង វប្បធម៌តែប៉ុណ្ណោះ ។ យ៉ាងណាមិញ ទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម នយោបាយ និង វប្បធម៌ខាងលើនេះមានលក្ខណៈសាកល ហើយក៏ជាយានសម្រាប់អភិវឌ្ឍន៍សង្គមមនុស្សឱ្យមានភាពលូតលាស់រុងរឿង ។

## ឥទ្ធិពលរបស់សិល្បៈ គន្ធារៈ អមរាវតី និងអនុរាធបុរៈ

ការវិភាគរូបចម្លាក់តំណាងព្រះពុទ្ធអង្គជាច្រើន នៃស្រុកអង្គរបុរីបង្ហាញឱ្យដឹងថា សិល្បៈខ្មែរនាសម័យនគរភ្នំ បានទទួលនូវឥទ្ធិពលវប្បធម៌ពីអជ្ឈអញ្ចល វប្បធម៌ក្លិង្គ គន្ធារ អមរាវតី និង អនុរាធបុរៈ ។

ពិតណាស់ហើយ ដែលព្រះកេសព្រះពុទ្ធអង្គ នៃភូមិកំពង់ពោធិ៍ បង្ហាញឱ្យឃើញនូវលក្ខណៈនៃសិល្បៈគន្ធារ នាសតវត្សរ៍ទី១ និងទី២ នៃ គ្រិស្តសករាជ ក៏ពិតមែន ប៉ុន្តែយើងពុំអាចថា ចម្លាក់បុរាណនេះបានត្រូវស្ថាបនាឡើង នៅស្រុកអង្គរបុរី ដោយសិល្បករខ្មែរនាសម័យបុរាណឡើយ ។ ប្រការដែលធ្វើឱ្យយើងសន្និដ្ឋានដូច្នេះ បណ្ដាលមកពីអវត្តមានរបស់ប្រភេទ ឬ ធាតុផ្សំដូចព្រះកេសពុទ្ធអង្គនោះនៅក្នុងតំបន់ អង្គរបុរី ឬនៅក្នុងប្រទេសកម្ពុជា តែថែមពីលើនោះទៀត ព្រះកេសនោះពុំមានលក្ខណៈពេញលេញទេ ដោយហេតុថា សំណាកព្រះកេសបុរាណនេះមិនបានត្រូវគេឆ្លាក់ផ្នែកខាងក្រោយទេ ។ គឺករណីនេះហើយ ដែលធ្វើឱ្យយើងអះអាងថា រូបព្រះកេសនេះត្រូវគេឆ្លាក់នៅក្នុងការដ្ឋាននៃប្រទេស ក្លិង្គខាងជើង ហើយបានដឹកចូលមកក្រុងអង្គរបុរី តាមកំពង់ផែអូរកែវដោយអ្នកជំនួញនាសម័យនោះ គឺប្រយោជន៍នឹងសក្ការៈបូជា ។

ប្រការមួយទៀត ដែលគួរឱ្យយើងចាប់អារម្មណ៍បំផុតនៅទីនេះគឺលក្ខណៈជាប្រវត្តិសាស្ត្ររបស់រូបចម្លាក់នេះ ដែលជាវត្ថុតាងតំណាងមួយយ៉ាងសំខាន់សម្រាប់ជាងចម្លាក់ខ្មែរ នាដើមសតវត្សរ៍ទី២ និងទី៣ នៃគ្រិស្តសករាជ ក្នុងអាណាចក្រភ្នំ ។



www.elibraryofcambodia.org

ប្រភពព្រះកេស នៃព្រះសម្មាសម្ពុទ្ធអង្គខាងលើនេះ មិនធ្វើឱ្យយើងភ្ញាក់ផ្អើលប៉ុន្មានឡើយ ពីព្រោះគេបានរកឃើញក្នុងគោលសីមារបស់នគរភ្នំ នូវព្រះពុទ្ធអង្គសំរិទ្ធជាច្រើនទៀត ដែលត្រូវបានគេដឹកមកពីស្រីលង្កា ដែលជារចនាបថ អមរាវតី និង អនុរាធបុរៈ ដូចជាព្រះពុទ្ធអង្គនៅ យ៉ុង ដឿន នគរបឋម នគររាជសីមា . អ៊ូថង ជាដើម ។ សូមជម្រាបថា ជាការគួរឱ្យអស្ចារ្យទៀតនោះ គេបានរកឃើញព្រះពុទ្ធអង្គដែលមានលក្ខណៈដូចព្រះពុទ្ធទាំងប៉ុន្មានអង្គខាងលើនេះ នៅប្រទេស ឥណ្ឌូណេស៊ី និង ម៉ាឡេស៊ី ។ ទាំងនេះបញ្ជាក់ឱ្យឃើញថា ការនាំចូលមកនគរភ្នំនូវព្រះពុទ្ធអង្គ ជារឿងធម្មតាដែលទាក់ទងនឹង ការផ្សព្វផ្សាយនៃព្រះពុទ្ធសាសនា ។

ព្រឹត្តិការណ៍ដែលគួរឱ្យចាប់អារម្មណ៍បំផុតនោះ គឺវត្ថុមានរបស់រូបចម្លាក់តំណាងព្រះពុទ្ធអង្គ ដែលជារចនាបថ អមរាវតី មកពីស្រីលង្កា នាសតវត្សរ៍ទី២-៤ នៃគ្រិស្តសករាជ ដែលគេបានរកឃើញក្នុងរាជធានីអង្គរបុរី នៅត្រង់ម្តុំវត្តគំនូរ ។ ប៉ុន្តែទន្ទឹមនឹងនេះ យើងក៏បានជួបប្រទះដែរនូវព្រះកេស នារចនាបថ គុប្តៈ ដែលមកពីការដ្ឋានគន្ធារ ដែលមានប្រភពនៅឥណ្ឌាខាងជើង ។

អាស្រ័យដោយវត្តមានរបស់ចម្លាក់បុរាណ តំណាងព្រះពុទ្ធរូបបុរាណទាំងនោះក្នុងអតីតកាលនគរភ្នំ យើងអាចយល់ថា បណ្តាខេត្តនានានៃប្រទេសឥណ្ឌាបុរាណ បានចូលរួមវិភាគទានក្នុងការស្ថាបនា ខឿនវប្បធម៌-អារ្យធម៌ខ្មែរ ។

ម្យ៉ាងទៀតតាមរយៈសិលាចារឹកយើងក៏ដឹងដែរថា ប្រទេសក្លិង្គខាងត្បូងក៏បានចូលរួមដែរ ក្នុងការស្ថាបនាខឿនវប្បធម៌ខ្មែរបុរាណ ។ យើងឃើញមានសិលាចារឹកជាច្រើនដែលគេទើបតែរកឃើញក្នុង[illegible] ១០ ឆ្នាំចុងក្រោយនេះ នៅប្រទេសសៀម និងប្រទេសខ្មែរបច្ចុប្បន្ន ទោះជាគ្មានការតាំងកាលបរិច្ឆេទក៏ដោយដូចជាសិលាចារឹកជាអក្សរបល្លវៈនៅក្លងធំ ខេត្តក្របី នាសតវត្សរ៍ទី៤-៥ នៃគ្រិស្តសករាជ (Ka85) ។



www.elibraryofcambodia.org

ក៏ប៉ុន្តែសិលាចារឹកទាំងនេះ មានលក្ខណៈចាស់ជាងគេបំផុត ហើយជាក់ស្តែងណាស់ទៅទៀត ថ្មីៗនេះកាលពីឆ្នាំ ១៩៨០ កន្លងទៅ គេបានរកឃើញក្នុងខេត្តដដែលខាងលើនេះនូវអង្កាំមួយគ្រាប់ដែលមានតួអក្សរចារឹកចំនួនពីរបន្ទាត់ ដែលបានចារឡើងក្នុងអម្លុងសតវត្សរ៍ទី ១-២ នៃគ្រិស្តសករាជ ។ ការសិក្សាស្រាវជ្រាវបានឱ្យដឹងថា តួអក្សរទាំងនោះគឺជាអក្សរព្រាហ្មិ ។ ខ្លឹមសាររបស់បន្ទាត់ទី១ នៃសិលាចារឹកនេះមានដូចតទៅ : "រូបលក្ខណៈរបស់ព្រាហ្ម. ព្រះឥន្ទ្រ ព្រះពហស្បតិ៍ និងព្រះគណេស ។ ចំណែកឃ្លាទី២ គឺសេចក្តីលើងខ្ពស់ ។ ការរកឃើញនេះបង្ហាញថា ជនជាតិខ្មែរបានស្គាល់ទេវតាក្នុងសំខាន់ៗចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជម្ល៉េះ ហើយបន្ទាប់មកទៀត ពាក់កណ្តាលសតវត្សរ៍ទី៣ នៃគ្រិស្តសករាជ ទើបគេឃើញមានការផ្សះផ្សាលើកចំរើននៃព្រហ្មញ្ញសាសនា ដូចជាវត្តមាននៃសិលាចារឹក វ៉ូកាញ់ នៅកម្ពុជាក្រោមជាសក្ខីភាពស្រាប់ ។

រួមសេចក្តីមក នៅអម្លុងសតវត្សរ៍ទី៤ និងទី៥ នៃគ្រិស្តសករាជគេឃើញមានការដ្ឋានសាងសង់រូបបដិមាផ្នែកព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនានៅក្នុងអតីតដែនដីរបស់នគរភ្នំ ដូចជាតំបន់ភាគខាងកើតនៅកម្ពុជាក្រោម តំបន់ល្បូងសមុទ្រសៀមបច្ចុប្បន្ន និងជាពិសេសនៅអង្គរបុរី ជាហេតុដែលឱ្យយើងឃើញនូវវត្តមានចម្លាក់បុរាណមួយចំនួនដែលពុំទាន់ធ្វើរួច ។ ដោយយោលទៅលើរូបចម្លាក់ព្រះពុទ្ធអង្គមួយយ៉ាងធំ ដែលគេបានរកឃើញនៅម្តុំវត្តតំនួរ ក៏ប៉ុន្តែឆ្លាក់ពុំទាន់រួចជាស្ថាពរនៅឡើយ យើងសន្និដ្ឋានថា សម្ព័ន្ធភាពផ្នែកវប្បធម៌និងសេដ្ឋកិច្ច រវាងនគរភ្នំ និងស្រីលង្កាមានសភាពជិតស្និទ្ធណាស់ ។

## ប្រពៃណីខ្មែរ តាមប្រភពឯកសារចិន :

ឯកសារចិនមួយនៅសតវត្សរ៍ទី៣ នៃគ្រិស្តសករាជ បាននិយាយថាប្រជារាស្ត្រខ្មែរចូលចិត្តរចនាក្បូរក្បាច់ និងមានឃ្លាំងដាក់សៀវភៅ ដែលមានតួអក្សរដូច



www.elibraryofcambodia.org

ជនជាតិឥណ្ឌា

ម្យ៉ាងទៀត ការរៀបចំធ្វើពិធីបូជាសពរបស់ខ្មែរជំនាន់នោះ មានលក្ខណៈដូចទៅនឹងអាណាចក្រចម្ប៉ា ។

ស្ត្រីភេទលែងខ្លួន គ្រាន់តែស្លៀកសំពត់ក្រណាត់មួយផ្ទាំង ដែលគេពាក់ "ស៊ក" ពីលើក្បាល ។ ឯបុរសវិញ គេស្លៀកសំពត់តាមបញ្ជារបស់ព្រះរាជាមានន័យថា មនុស្សដែលស្លៀកសំពត់ទាំងនោះ សុទ្ធសឹងតែជានាម៉ឺនមន្ត្រីក្នុងស្ថាប័ននានា និងក្នុងរដ្ឋបាលនាសម័យនោះ ។ គេក៏អាចដឹងដែរថាមនុស្សសាមញ្ញពិតជាត្រូវស្លៀកប៉ឹង ឬរុំក្រមាដូចបងប្អូនខ្មែរលើពុំខាន ។

នេះជាសេចក្ដីសង្ខេប ស្ដីអំពីទំនៀមទម្លាប់ខ្មែរខ្លះៗ នាសម័យនគរភ្នំដែលជនជាតិចិនបានបន្សល់ទុកក្នុងកំណត់ហេតុរបស់គេ ហើយដែលយើងអាចយកមកប្រៀបធៀបនឹងវត្ថុបុរាណនៅពេលបន្តិចទៀត ដើម្បីបង្ហាញឡើងវិញនូវជីវភាពរបស់ប្រជាជនខ្មែរ នៅគ្រាបឋមកាលនៃប្រវត្តិសាស្ត្ររបស់ខ្លួន ។

## អំពីលក្ខណៈប្រពៃណីនគរភ្នំ :

**ការនិយមស្នាដៃ :**

ការពិពណ៌នាអំពីប្រពៃណីខ្មែរ នាសម័យនគរភ្នំ ដែលបានផ្ដើមឡើងតាំងតែសតវត្សរ៍ទី១ នៃគ្រិស្តសករាជ មិនមែនជាការងាយស្រួលប៉ុន្មានទេ ជាពិសេសក្នុងរយៈកាលមួយដែលយើងខ្វះឯកសារជាលាយលក្ខណ៍អក្សរ ហើយម្យ៉ាងទៀតក្នុងសម័យកាលរួមដែលជនជាតិខ្មែរ ទើបតែទទួលឥណ្ឌូបនីយកម្ម ។

ដូច្នេះក្នុងករណីនេះការអធិប្បាយអំពីប្រពៃណីខ្មែរនាសម័យនោះត្រូវពឹងផ្អែកទៅលើវត្ថុតាងទាំងឡាយ ដែលបានមកពីស្ថានីយ៍ប្រវត្តិសាស្ត្រ ។



www.elibraryofcambodia.org

ដោយមានឯកសារមិនទាន់គ្រប់គ្រាន់នៅឡើយ យើងពុំទាន់អាចរៀបរាប់ឱ្យបានពិស្ដារ អំពីជីវភាពរបស់ខេមរជន នាសម័យដើមប្រវត្តិសាស្ត្រខ្មែរ ពោលគឺ អរិយធម៌ផ្នែកសម្ភារៈ និងជំនឿសាសនា ឬសីលធម៌ឡើយ ។ បើនិយាយម្យ៉ាងទៀត យើងគ្រាន់តែសូមលើកនូវទំនៀមទម្លាប់ខ្លះៗដែលទាក់ទងនឹងសង្គមខ្មែរដូចតទៅនេះ

ថ្វីត្បិតតែយើង ពុំអាចតាំងកាលបរិច្ឆេទនៃការនិយម ខាងលើនេះយ៉ាងច្បាស់លាស់ក៏ដោយ ក៏យើងអាចបញ្ជាក់ថា ខ្មែរយើងនាសម័យបុរេប្រវត្តិសាស្ត្របានចេះស៊ីស្លាម្លូយ៉ាងប្រាកដ ។ ការសន្និដ្ឋានបែបនេះ យោងទៅលើការរកឃើញនូវប្រអប់ធ្មេញមានពណ៌ខ្មៅ ក្នុងស្ថានីយ៍បុរេប្រវត្តិសាស្ត្រ បានច្រើន ។ សូមបញ្ជាក់ថា ធ្មេញដែលមានពណ៌ខ្មៅខាងលើនេះ បណ្ដាលមកពីការស៊ីស្លាម្លូហើយម្យ៉ាងទៀត ប្រពៃណីខ្មែរនេះ ក៏ត្រូវបានពួកកុលសម្ព័ន្ធខ្មែរលើរក្សារៀងដល់សព្វថ្ងៃនេះ ។ ឧទាហរណ៍ខាងលើនេះ សឱ្យឃើញនូវនិរន្តរភាពនៃទំនៀមទម្លាប់នេះ ។

ថ្មីៗនេះយើងបានរកឃើញ នៅឯស្ថានីយ៍អង្គរបុរីនូវក្រឡមួយចំនួនដែលផ្ទុកកំបោរពណ៌ផ្កាឈូក ។ ការរកឃើញនេះ ក៏ជាភស្តុតាងមួយយ៉ាងសំខាន់សម្រាប់បង្ហាញបញ្ជាក់អំពីការនិយមស្លាម្លូ នាសម័យប្រវត្តិសាស្ត្រ ។

ការពិនិត្យយ៉ាងល្អិតល្អន់នូវជាតិកំបោរ ដែលស្ថិតក្នុងក្រឡធ្វើអំពីដីដុតខាងលើនេះ អាចផ្ដល់ឱ្យយើងនូវពត៌មានមួយចំនួនទៀត ដែលយើងពុំធ្លាប់មានពីមុនឡើយ ។ ពត៌មានទី១ គឺកំបោរដែលយើងបានរកឃើញនោះ បានត្រូវធ្វើឡើងដោយសំបកលៀស ដែលគេបានដុតឱ្យក្លាយម៉ត់ទៅជាផេះ ដើម្បីយកមកធ្វើកំបោរ ។ ទន្ទឹមនឹងនេះ យើងក៏អាចដឹងទៀតថា សំបកលៀសដែលគេបានយកទៅផលិតកំបោរទាំង-នោះ ពិតជាបានមកពីតំបន់សំបកលៀសតាមបឹងបួ ព្រែក អូរ និង ដងទន្លេមេគង្គ ដែលក្រុមមនុស្សបានបរិភោគជាចំណីអាហារ ។



www.elibraryofcambodia.org

**ការនិយមចងស្លៀងខ្នាញ់ :**

យើងបានជួបនូវចង្កៀងពីរប្រភេទ នៅក្នុងវប្បធម៌នគរភ្នំ គឺចង្កៀងធ្វើអំពីសំរិទ្ធ និងធ្វើអំពីដីដុត ។ ប្រភេទទី១នៃចង្កៀង បានត្រូវគេរកឃើញនៅក្នុងតំបន់នៃកំពង់ផែរអូរកែវ ។ រីឯចំពោះចង្កៀងធ្វើអំពីដីដុត ដែលមានចំនួនច្រើនឥតឧបមា ត្រូវគេជួបប្រទះនៅអង្គរបូរី ។

សូមជម្រាបថា រហូតដល់ពេលនេះ យើងអាចចែកក្រុមចង្កៀងដីដុត ជាបីប្រភេទ ។ ចំពោះប្រភេទចង្កៀងដីដុតទី១ និងទី២ ដែលមានទំហំធំ ឬ មធ្យមយើងអាចសន្និដ្ឋានដោយមិនខុសពីការពិតប៉ុន្មានថា ឧបករណ៍សម្រាប់បំភ្លឺរាត្រីទាំងនេះត្រូវបានគេប្រើប្រាស់តាមបូជនីយដ្ឋាន និងទីកន្លែងនានា ។ ចំណែកប្រភេទចង្កៀងទី៣វិញ ដែលមានខ្នាតតូច ប្រហែលបានត្រូវគេប្រើអុជនៅពេលនេសាទត្រី ។ ការអះអាងខាងលើមានមូលដ្ឋានចេញពីប្រពៃណីប្រើចង្កៀងតូចបែបនេះបានត្រូវអ្នកនេសាទត្រីមួយចំនួននិយមរហូតដល់បច្ចុប្បន្នកាលនេះ ជាពិសេសនៅពេលដែលគេចាប់ត្រីនៅពេលយប់ ។ ការប្រៀបធៀបទំនៀមខាងលើនេះ ជាហេតុផលដែលបណ្ដាលឱ្យយើងហ៊ាន សន្និដ្ឋានដូច្នេះ ។

ចំពោះប្រភេទចង្កៀងទាំងឡាយ ដែលយើងទើបបានអធិប្បាយខាងលើ សូមមេត្តាមើលរូបភាពដែលយើងបានភ្ជាប់ក្នុងឯកសារនេះ ។ ទស្សនៈខាងលើនេះ មានលក្ខណៈសមរម្យត្រឹមត្រូវក្នុងសម័យមួយ ដែលប្រជារាស្ត្រខ្មែរមានជំនឿលើបុព្វបុរសនិងភាពអមតៈរបស់ព្រលឹង ឬការចាប់ជាតិឡើងវិញ ដោយកប់កំសូសំណោញ់ និងចង្កៀងតូចៗ ក្នុងភាជន៍ ជាសំណែនចំពោះអ្នកស្លាប់ ។ ក្រៅពីចង្កៀង ខ្មែរបុរាណក៏បានរំលែកផ្ទុះដូចសព្វថ្ងៃនេះដែរ ។



www.elibraryofcambodia.org

**ការនិយមទូក :**

រហូតមកដល់ពេលនេះ យើងពុំទាន់បានរកឃើញ នូវបន្ទះក្តារនៃទូក ឬទូកទាំងមូលនៅក្នុងស្ថានីយ៍អង្គរបុរីនៅឡើយ ថ្វីត្បិតតែទូកធ្វើអំពីឈើជាច្រើន បានត្រូវគេរកឃើញនៅកម្ពុជាក្រោមក៏ដោយ ។

ព្រឹត្តិការណ៍ដ៏សំខាន់ទៀត ដែលយើងគប្បីលើកនៅទីនេះ គឺការនិយមនាវាចម្បាំង ដែលស្ថាបនាដោយជនជាតិខ្មែរ នៅសម័យនោះ ហើយដែលអ្នកប្រវត្តិវិទូចិន បានកត់ត្រាក្នុងពង្សាវតាររបស់គេ ។ សូមជម្រាបនៅទីនេះដែរថានៅអំឡុងសតវត្សរ៍ទី៣ មុនគ្រិស្តសករាជ សង្គមខ្មែរដែលកាន់មានវឌ្ឍនភាពដ៏មហារុងរឿងជឿនលឿនទៅហើយនោះ ក៏ចេះធ្វើទូកប៉ោយដែរ ។

តាមរយៈអ្វីដែលយើងទើបតែរៀបរាប់ខាងលើនេះ យើងដឹងថា ប្រជាពលរដ្ឋខ្មែរចេះស្ថាបនាទូក សម្រាប់យកមកដឹកជញ្ជូនឥវ៉ាន់ ឬក៏សម្រាប់ធ្វើដំណើរតាមផ្លូវទឹក ពីកន្លែងមួយទៅកន្លែងមួយទៀត ជាពិសេសក្នុងរដូវវស្សា ដែលពោរពេញទៅដោយទឹក ។ ជាការត្រឹមត្រូវណាស់ ដែលយើងអាចនិយាយថា សង្គមខ្មែរប្រកបដោយវប្បធម៌ដែលមានទឹកជាមូលដ្ឋាន និងការនិយមទូកជាអចិន្ត្រៃយ៍ថែមទៀត ។ តាមចម្លាក់បុរាណយើងដឹងថាមានការ និយមទូកធ្វើអំពីឈើមិនដាច់ តាំងតែសម័យ បុរេ-ប្រវត្តិសាស្ត្ររហូតដល់សព្វថ្ងៃ មិនត្រឹមតែនៅតាមសមុទ្រប៉ុណ្ណោះទេ ថែមទាំងនៅតាមវាលទំនាប បឹងបួ ស្ទឹង ព្រែក ដែលជាសាខារបស់ទន្លេតូច ធំ សម្រាប់លក់ដូរ ។ សព្វថ្ងៃនេះ ការនិយមនិងផលិតទូកនៅតែមាន តាមស្រុក ភូមិ ។

រួមសេចក្តីមក [illegible] យានជំនិះមួយមានលក្ខណៈសំខាន់ចម្បង ក្នុងវប្បធម៌ អារ្យធម៌ខ្មែរ [illegible] មិនលិច លុះត្រាតែគេយកជ័រឈើមកបិទ[illegible]ក្តារទូកដែលគេផ្គុំក្តារឱ្យជិតគ្នា ។ ហើយតាមរយៈការរកឃើញថ្មីៗនេះនូវកូន



www.elibraryofcambodia.org

ភាជន៍មួយដែលមានកំពូលបិទជិតដោយជ័រ ដែលធ្លាប់ប្រើសម្រាប់បិទទូក យើងក៏អាចសន្និដ្ឋានយ៉ាងត្រឹមត្រូវបានដែរថា ខ្មែរយើងចេះធ្វើទូកដោយប្រើជ័រចុង នាសម័យនគរភ្នំដែរ ។

**ការនេសាទត្រី :**

ត្រីជាម្ហូបអាហារមួយចម្បងសម្រាប់ខ្មែរ ហើយក៏ជាប្រភពមួយនៃវឌ្ឍនភាព របស់វប្បធម៌ អារ្យធម៌ខ្មែរ ។ ភាពសម្បូរណ៍នៃត្រីនៅប្រទេសខ្មែរ បានត្រូវបញ្ជាក់ដោយសុភាសិតខ្មែរមួយ "ដីមានទឹក មានត្រី" ។ នៅទីនេះ យើងគ្រាន់តែសូមលើកនូវឧបករណ៍ដ៏តូចមួយ គឺកំសួសំណាញ់ដែលធ្វើពីដីដុត ដើម្បីបង្ហាញឱ្យដឹងថា ខ្មែរយើងនាសម័យនោះចេះចិញ្ចឹមត្រី សម្រាប់ចិញ្ចឹមជីវិតតែប៉ុណ្ណោះ ។

ម្យ៉ាងទៀត វត្ថុមានរបស់ជន្ទួញធ្វើអំពីសំរិទ្ធ និងឆ្អឹងសត្វ ក៏អាចចាត់ទុកថាជាឧបករណ៍សម្រាប់ចាប់ត្រី ក្នុងអតីតកាលដែរ ។ យើងពុំទាន់បានរកឃើញផ្ទសន្ទូចនៅក្នុងស្ថានីយ៍អង្គរបូរីនៅឡើយទេ ក៏ប៉ុន្តែវត្ថុមានរបស់វានៅក្នុងវប្បធម៌នាសម័យបុរេ-ប្រវត្តិសាស្ត្រ ដូចជាសំរោងសែនជាដើម ក៏អាចបញ្ជាក់ឱ្យយើងដឹងដែរថា ទំនៀមទម្លាប់ខាងលើនេះ នៅតែប្រព្រឹត្តិរហូតទៅដល់បឋមសម័យប្រវត្តិសាស្ត្រ ។

សូមជម្រាបថា ក្រៅពីជន្ទួញ និងកំសួសំណាញ់ ថ្មីៗនេះយើងបានរកឃើញបន្តោងខ្សែកមួយធ្វើអំពីកែវស្លួ មានឆ្លាក់រូបមនុស្សស្ទូចត្រី ។ នេះជាសក្ខីភាពថ្មីយ៉ាងសំខាន់បំផុត ស្ដីអំពីការរស់នៅរបស់ខេមរជន នាសម័យបុរាណកាល ។ ទំនៀមស្ទូចត្រីរឺការនេសាទត្រីបែបនេះ ដោយប្រើសំណាញ់ដោយមានកំសួសំណេ ដែលពីមុនជាដីដុត ការត្រូវបន្សល់ទុករហូតដល់សព្វថ្ងៃនេះ ។

**ការធ្វើស្រែចំការ :**



www.elibraryofcambodia.org

តាមរយៈការពិនិត្យ សិក្សាវត្ថុបុរាណមួយចំនួន ដែលជាសំណល់នៃមូលដ្ឋានវប្បធម៌នាដើមគ្រិស្តសករាជមក យើងបានដឹងថា គ្រឹះនៃសេដ្ឋកិច្ច និង សង្គមខ្មែរ គឺកសិកម្ម ហើយវិស័យនេះហើយ ដែលជាប្រភពនៃវឌ្ឍនភាពនៃសម័យអង្គរ រវាងសតវត្សរ៍ទី៩ដល់សតវត្សរ៍ទី១៤ ។

ជាការពិតណាស់សង្គមខ្មែរយើង នាសម័យនគរភ្នំ ជាសង្គមធ្វើស្រែចំការដូចសព្វថ្ងៃ ប៉ុន្តែជាអកុសល ការបំផ្លិចបំផ្លាញនូវស្ថានីយ៍ប្រវត្តិសាស្ត្រ និងការពុំទាន់ផ្តោតអារម្មណ៍ទៅលើសារសំខាន់នៃបញ្ហាធម្មជាតិនេះ ធ្វើឱ្យយើងជួបប្រទះនូវផលវិបាកក្នុងការសំយោគអំពីវប្បធម៌ខ្មែរ នាគ្រាបឋមនៃប្រវត្តិសាស្ត្រ ។

តាមការស្រាវជ្រាវថ្មីនេះរបស់យើងនៅអង្គរបុរី និងតាមឯកសារមួយចំនួនដែលយើងបានសិក្សា នៅប្រទេសសៀម និងវៀតណាមខាងត្បូង យើងអាចបញ្ជាក់ថាប្រជារាស្ត្រខ្មែរនាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ពិតជាធ្វើស្រែចំការដូចខេមរជនសព្វថ្ងៃ [illegible] តាមរយៈការវិភាគនៃរូបចម្លាក់មួយ តំណាងមនុស្សប្រុសស្រីរបស់យើងឃើញថា [illegible] នៃជនគរភ្នំ មិនខុសពីជីវិតនៅជនបទនៃព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ [illegible] ។ ដោយសារឯកសារខាងលើនេះ យើងដឹងថាអ្នកស្រុក ភាគច្រើនគឺធ្វើ [illegible] ស្រូវ ពោត ល្ង ល្ពៅ ល្ហុក ម្ទេស ត្រកួន ។ល។ ហើយក្នុងការដាំដំណាំ ពួកគេត្រូវឆ្ការព្រៃដុត ដើម្បីបង្កើននូវជីរជាតិដូចជនជាតិដែលរស់នៅតាមព្រៃភ្នំ ឬខ្ពង់រាប ។

ភស្តុតាងសំខាន់មួយ ដែលធ្វើឱ្យយើងរឹតតែជឿជាក់ថា ខ្មែរនាសម័យនោះក្រៅពីពាណិជ្ជកម្ម ធ្វើស្រែចំការ គឺការពិពណ៌នាក្នុងសិលាចារឹកមួយចំនួន អំពីអំណោយជាដីធ្លីចំពោះបូជនីយដ្ឋាននានា ពីសំណាក់ព្រះរាជាម្ចាស់ផែនដី ។

មួយវិញទៀត ប្រសិនបើយើងឡើងទៅលើកំពូលភ្នំដា ហើយចោលក្រសែភ្នែកយ



www.elibraryofcambodia.org

ភ្លុកចុះទៅផ្នែកខាងក្រោម យើងពិតជានឹងឃើញនូវវាលស្រែបុរាណ ដ៏ធំធេងពោត សន្ធឹងដាច់កន្ទុយភ្នែក ? ។ ទាំងនេះជាសក្ខីកម្មមួយបញ្ជាក់ប្រាប់យើងឱ្យដឹងថា គឺនៅទីនោះហើយ ដែលបុព្វបុរសយើងធ្វើស្រែចំការ ។

**ឧស្សាហកម្មលោហធាតុ :**

ជាងដែក ជាងទង់ខ្មែរនាសម័យនគរភ្នំ ដែលជាអ្នកតពូជពង្សពីបុព្វបុរសរបស់ខ្លួន នាសម័យបុរេប្រវត្តិសាស្ត្រ ចេះស្លលោហធាតុ ដើម្បីផលិតនូវវត្ថុប្រើប្រាស់ ឬតុបតែងយ៉ាងល្អប្រណីត ។ វត្តមានរបស់ឧស្សាហកម្មលោហធាតុ បានធ្វើឱ្យទម្រង់សង្គមខ្មែរ នាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ បានផ្លាស់ប្តូរ ដោយហេតុថាគេសង្កេតឃើញមានការបែងចែកប្រជាពលរដ្ឋជាក្រុមៗ ដែលមានជំនាញខុសប្លែកៗពីគ្នា ដូចជាក្រុមជាងដែក ជាងទង និង ជាងឈើ ។ល។ ក្នុងសង្គមខ្មែរ ។ ទន្ទឹមនឹងនេះគេក៏បានឃើញបណ្តាញពាណិជ្ជកម្មជាច្រើនខ្ទាត់ខ្ទែង ទូទាំងព្រះរាជាណាចក្រ ជាហេតុដែលបណ្តាលឱ្យយើងអាចសន្និដ្ឋានថា សម័យនេះជាសម័យរុងរឿង ថ្កុំថ្កើង ក្នុងវិស័យឧស្សាហកម្មលោហធាតុ ។

នៅសម័យនគរភ្នំ ការសិក្សាស់ហេល់វប្បធម៌ បានបញ្ជាក់ឱ្យយើងដឹងថា ខ្មែរយើងចេះស្លលោហធាតុ ដូចជាមាស ដែក សំរឹទ្ធ សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ និង វត្ថុសម្រាប់សក្ការៈបូជា ដូចជាព្រះបដិមាជាដើម ។ ក្រៅពីនេះគេក៏ឃើញមានវត្តមានរបស់ ឧស្សាហកម្មស្លកែវដែរ ។

**វត្ថុធ្វើអំពីមាស :**

មាសជាលោហធាតុមួយដែលជនជាតិខ្មែរ ចាត់ទុកថាជាវត្ថុពិសិដ្ឋ ត្រូវគេប្រើប្រាស់ដើម្បីស្លរូបទេវតា ឬគ្រឿងអលង្ការផ្សេងៗ ។ យ៉ាងណាមិញមាសក៏ជានិមិត្ត



www.elibraryofcambodia.org

រូប នៃភាពបរិសុទ្ធ និងអមតៈដែរ ដូច្នេះហើយបានជាលោហធាតុនេះមានតម្លៃជាងអ្វីៗ ទាំងអស់ តាំងពីសម័យបុរាណរហូតដល់សម័យសព្វថ្ងៃ ។

ការឃើញនូវឧបករណ៍ជាងទង ដូចជាពុម្ព និង ក្រឡ សម្រាប់ស្ងួមាសនៅស្រុកអង្គរបូរី បញ្ជាក់ថា ប្រភពនៃជាងទងខ្មែរ ពិតជាបានកើតចេញពីតំបន់នេះ ។

លទ្ធផលនៃការស្រាវជ្រាវរបស់យើង បានឱ្យដឹងថា មាសដែលជនជាតិខ្មែរបុរាណបានប្រើនោះ មានភាពសម្បូរបែបជាអតិបរមា និងលក្ខណៈខុសប្លែកៗពីគ្នាដែលមានដូចតទៅនេះ :-

**ទេវរូប :**

ទេវរូបឬពុទ្ធរូប ធ្វើអំពីមាសមានចំនួនតិច ហើយទំហំតូច ។ យើងពុំបានឃើញផ្ទាល់ទេ ក៏ប៉ុន្តែតាមសេចក្តីអធិប្បាយរបស់អ្នកស្រុកយើងដឹងថា ព្រះបដិមាទាំងនោះ តំណាងព្រះវិស្ណុនិងព្រះពុទ្ធអង្គប្រក់នាគ ។

**សិរពេជ្រ :**

សិរពេជ្រមាស និងត្រាប្រមាសជាច្រើន ត្រូវបានគេរកឃើញ ។

**មាសសន្លឹក :**

មាសសន្លឹកស្តើងៗជាច្រើន ត្រូវបានគេរកឃើញនៅក្រោមខឿនប្ញជនីយដ្ឋាន ។ នៅលើសន្លឹកមាសទាំងនោះ គេអាចឃើញនូវសញ្ញានិមិត្តដូចជា ព្រះពុទ្ធអង្គ ព្រះនារាយណ៍ សត្វអណ្តើក ស្លឹកពោធិ រូបហនុមានកាន់ដំបង គោនន្ទិន ខ្យងស័ង្ខ កងចក្រ ។

**គ្រឿងអលង្ការ :**

ក្នុងចំណោមអលង្ការជាច្រើន គេឃើញមានក្រវិលក្រមុំ ក្រវិលត្រចៀក,



www.elibraryofcambodia.org

ត្រសាលត្រចៀក. បន្តោងក អង្កាំគ្រប់ខ្នាត ចិញ្ចៀនដៃនិងជើង ។

ចិញ្ចៀនមាសទាំងនោះមានដាំត្បូង ធ្វើអំពីកែវស្ល ឬធ្វើអំពីថ្មដែលមានគោធនិន ព្រះនាង លក្ស្មី ។ ជួនកាល គេក៏បានឃើញដែរ នូវរូបទន្សាយ ខ្យងស័ង្ខ ឬ ផ្កា ។

**កាក់មាស :**

ក្រៅពីវត្ថុវប្បធម៌ទាំងនោះ គេនៅឃើញមានកាក់មាសមួយចំនួនទៀតមានជាភស្តុតាងនៃការជួញប្រែជាមួយប្រទេសជិតខាង ជាពិសេស ប្រទេសចិន និងនគរទ្វារវតីនៃជនជាតិមន ដែលទើបតែត្រូវបានបង្កើតឡើងនៅចុងសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ។

កាក់មាសខ្លះមានរូបមានក់ពង់វងារនៅម្ខាង ហើយរីឯម្ខាងទៀតព្រះអាទិត្យ រះ និង លិច ឬ ក៏រូបសត្វ... ។

សរុបជម្រាបថា សម្ភារៈធ្វើអំពីមាសដែលយើងបានរៀបរាប់ខាងលើនេះមិនខុសពីសម្ភារៈ ដែលគេបានរកឃើញនៅអូកំពង់ផែ អូរកែវ និង នៅអ៊ូថង ព្រមទាំងនៅខេត្តកញ្ចានបុរីប្រទេសថៃបច្ចុប្បន្ននេះ ។ ទន្ទឹមនឹងនេះគប្បីជ្រាបថាមួយភាគធំនៃគ្រឿងអលង្ការមាសបុរាណត្រូវគេរំលាយសម្រាប់យកមាស ។ នេះជាការខាតបង់ដ៏ធំ ។

## ការប្រើប្រាស់ ស្ពាន់ និង សំណ :

ក្រៅពីថ្មគេឃើញមានការប្រើប្រាស់លោហធាតុទាំងពីរប្រភេទនេះ អាចជាប្រពៃណីដែលមានមកតាំងពីសម័យមុនគ្រិស្តចូលស្រុកម្ល៉េះ ។

នាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ មានការពិពណ៌នានៅនគរភ្នំ អំពីការនិយមស្ពាន់ និងសំណ ដោយអ្នកស្រុកនគរភ្នំ ។ តើស្ពាន់ និងសំណបានមកពីតំបន់ណា? តើវាទាំងពីរនេះជាវត្ថុធាតុ ដែលដឹកនាំចូលពីក្រៅ ឬក៏នៅក្នុងស្រុក ? ។



www.elibraryofcambodia.org

សូមបញ្ជាក់ថា សំរិទ្ធដែលបុព្វបុរសខ្មែរ ប្រើក្នុងតំបន់នានានៃចក្រភពភ្នំស្ថិតនៅក្នុងបរិវេណនៃអតីតដែនដីខ្មែរដោយហេតុថានាសម័យនោះ ពុំទាន់មានគោលសីមានៅឡើយ ។ បញ្ហាព្រំប្រទល់ដែន ជាបញ្ហាមួយថ្មីថ្មោងក្នុងប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ ។

នៅកម្ពុជាក្រោម ពិសេសនៅអ៊ូរកែវ និង កោះត្រល់ ដែលសព្វថ្ងៃបានក្លាយទៅជាកម្មសិទ្ធ របស់វៀតណាមខាងត្បូង គេឃើញមានអណ្តូងរ៉ែស្ពាន់ជាច្រើន ។ ឯនៅប្រទេសលាវវិញ គេក៏ជួបលោហធាតុនៅក្នុងភូមិភាគខាងត្បូងនៃប្រទេសដូចជា នៅចាសាក់ និង សាវ៉ាវ៉ាន់ ។

ចំពោះការជីកយករ៉ែស្ពាន់វិញ គេឃើញនៅមានជនជាតិភាគតិច មន-ខ្មែរ មួយចំនួន ដូចជា រដែរ ស៊ីដាំង និង ព្រៅ ដែលរស់នៅតាមខ្ពង់រាប និង តំបន់ព្រៃភ្នំនានា នៅឯកម្ពុជាក្រោម និងនៅវៀតណាមភាគកណ្តាល នៅតែប្រព្រឹត្តរបរជីវកម្មនេះនៅឡើយ ។

សូមរំលឹកថា នៅស្ថានីយ៍បុរេប្រវត្តិមួយចំនួន គេបានឃើញនូវឧបករណ៍ប្រើប្រាស់អំពីស្ពាន់ ឬសំរិទ្ធ ដែលមានអាយុប្រមាណជា ១៥០០ឆ្នាំ ទៅ ២០០០ឆ្នាំ មុនគ្រិស្តសករាជ ហើយការប្រើប្រាស់លោហធាតុនេះ ដោយសហគមន៍មនុស្ស បុរាណបានត្រូវបន្តពីឆ្នាំ៥០០ មុនគ្រិស្តសករាជ រហូតដល់សម័យប្រវត្តិសាស្ត្រមិនដាច់ ។

ចំណែករ៉ែដែកវិញ ដែលគេបាននិយាយច្រើនជាងគេបំផុតនាសម័យដើមប្រវត្តិសាស្ត្រខ្មែរ ហើយដែលយើងកាន់ទុកថា "វប្បធម៌ដែក សម័យនគរភ្នំ" នោះ តាមការស្រាវជ្រាវរបស់លោក ល្វីអ៊ី ម៉ាឡឺរ៉េ នៅក្នុងដែនដីសព្វកម្ពុជាក្រោម បានឱ្យដឹងថា អណ្តូងរ៉ែជាច្រើន ត្រូវបានគេរកឃើញនៅភូមិភាគកណ្តាលនៃប្រទេសលាវសព្វថ្ងៃ ។ លោកបានបញ្ជាក់ទៀតថា ជាពិសេសរណ្តៅរ៉ែសំខាន់ស្ថិតនៅផ្នែកខាងជើង ថាខែក នៃប្រទេសលាវ និងនៅតុង គីង ស្រុកយួនសព្វថ្ងៃ ។



www.elibraryofcambodia.org

សូមជម្រាបថាសព្វថ្ងៃនេះ ជនជាតិ មន-ខ្មែរ បាហ្ណា នៅ កុង ទុំ វៀតណាមខាងត្បូង បានប្រើធាតុរ៉ែសំណនេះ សម្រាប់ផលិតគ្រឿងអលង្ការប្រុសស្រីដើម្បីតុបតែងខ្លួន ភាគច្រើនអណ្ដូងរ៉ែ និងស្ពាន់ ស្ថិតនៅតំបន់ជ្រលងភ្នំ និងខ្ពង់រាប ។ ម្យ៉ាងទៀតនៅជ្រោយម៉ាឡាកា គេក៏បានជួបនូវអណ្ដូងរ៉ែជាច្រើនដែរ ។ វត្ថុមានរបស់អណ្ដូង រ៉ែស្ពាន់ សំណ ព្រមទាំងគ្រឿងអលង្ការជាច្រើនដូចជាចិញ្ចៀន បន្ទោងខ្សែកបដិមា តំណាងទេវតា ឬក៏កាក់ដែលគេប្រើនៅអូរកែវ អង្គរបូរី និងអ៊ូថង អាចបញ្ជាក់ថា ធាតុរ៉ែខាងលើនេះពុំបាននាំចូលពីប្រទេសក្រៅទេ ។

យ៉ាងណាមិញ ការនិយមប្រើ ស្ពាន់ និង សំណ នៅតែគេនិយមប្រើរហូតដល់សព្វថ្ងៃ ពិសេសក្នុងការសូនបដិមា ពុម្ពនិងព្រះពុទ្ធអង្គ ។

## ទម្បូនមីជីដុត :

វឌ្ឍនភាពនៃវប្បធម៌ខ្មែរនាសម័យនគរភ្នំ មិនអាចកើតចេញពីភាពមិនប៉ិនប្រសប់ ឬ ទេពកោសល្យដ៏ឧត្តុង្គឧត្តម ពីជនជាតិខ្មែរបានឡើយ ។ កំហុសដ៏ធ្ងន់របស់អ្នកប្រវត្តិវិទូមួយចំនួន ដែលបានយកនយោបាយជាមូលដ្ឋាន ពោលគឺ ខ្វះភាពជាក់លាក់ច្បាស់លាស់ ហើយមិនព្រមលះបង់នូវទស្សនៈចាស់គំរិលដើម្បីបិទបាំងនូវភាពអវិជ្ជារបស់ខ្លួនទាំងនោះ បានមានមតិថា គេពុំអាចសន្និដ្ឋានថានគរភ្នំជារបស់ជនជាតិខ្មែរ ឬមនទេ ។ ចំពោះបញ្ហានេះ យើងបានជម្រាបហើយថា យើងអាចយកជាការបាន ដរាបណាមានភស្តុតាងជាក់ស្ដែងដែលមានលក្ខណៈជាវិទ្យាសាស្ត្រ ។ ទោះជាយ៉ាងណាក៏ដោយ ស្ថានការណ៍ស្រាវជ្រាវផ្នែកបុរាណវិទ្យា នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន បានចង្អុលបង្ហាញយើងឱ្យឃើញយ៉ាងច្បាស់នូវ លក្ខណៈវប្បធម៌ នាសម័យនគរភ្នំយ៉ាងប្រាកដ ។



www.elibraryofcambodia.org

យោងទៅលើវត្ថុវប្បធម៌ធ្វើអំពីដីដុត ដែលមានចំនួនដ៏ច្រើនលើសលប់ដូចជា ភាជន៍ ( រាប់សែន ) រូបចម្លាក់តំណាងទេវរូប ពុទ្ធរូប និងបុព្វបុរសស្ថាបត្យកម្មនានា ដូចជា ប្រាសាទ ស្តូបកំពែងទីក្រុង គ្រឿង ឥដ្ឋ ។ល។ យើងអាចចាត់ទុកថា វប្បធម៌នគរភ្នំ គឺជាវប្បធម៌ដីដុតដ៏ធំសម្បើមមួយ ជាងពេលណាៗទាំងអស់ ។

រីឯនៅខេត្តកំពង់ធំឯណោះវិញ ការសាងសង់រាជធានីមួយអំពីឥដ្ឋ នៅចុងសតវត្សរ៍ទី៦ ដើមសតវត្សរ៍ទី៧ នៃគ្រិស្តសករាជ ដែលបានធ្វើឡើងនៅឯស្រុកសម្បូរព្រៃគុក ក៏ជាសក្ខីកម្មបង្ហាញនូវប្រពៃណីប្រើឥដ្ឋដែរ ដើម្បីសាងសង់នូវប្រាង្គប្រាសាទទាំងឡាយដូចជាក្រុមប្រាសាទ របួស ឬ តួលៃទ ជាច្រើនដែលបានប្រសូត្រឡើងនៅក្រោយសម័យនគរភ្នំ ។

មូលដ្ឋានស្ថាបត្យកម្មនគរភ្នំ អង្គរបូរី ឬ វ្យាធបុរៈ ក្នុងចំណោមមូលដ្ឋាននគរភ្នំនានាដែលស្ថិតនៅ អូរកែវ ឬនៅតាមតំបន់ផ្សេងៗ ក្នុងឆ្នេរសមុទ្រសៀមសព្វថ្ងៃ គឺដីដុត ឬឥដ្ឋ ។ ការប្រើប្រាស់ដីដុត ឬឥដ្ឋ ក្នុងការស្ថាបនាបូជនីដ្ឋាន ឬធ្វើឧបករណ៍ប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃ ( កំសួល ត្រល់ ចង្កៀង ឆ្នាំង ) សឲ្យឃើញថាដីដុតជាវត្ថុធាតុងាយរក ហើយថោកជាងថ្ម ឬ ក៏ផ្តល់នូវភាពងាយស្រួលក្នុងការសាងសង់នានា ។

អ្វីៗដែលទើបអធិប្បាយនេះ ពុំមែនមានន័យថា ខ្មែរនាសម័យនោះមិនចេះឬមិននិយមថ្ម ដើម្បីកសាងប្រាសាទ ឬព្រះបដិមានោះទេ ដោយហេតុថាគ្រប់ប្រាសាទតូច ធំ ថ្ម និង ដីដុតត្រូវគេប្រើក្នុងពេលជាមួយគ្នា ឬ ផ្ទួនគ្នា ។ចំពោះការនិយមជាទូទៅនូវដីដុតនេះ យើងសូមរំលឹកថា ទេពកោសល្យ របស់សិល្បករខ្មែរ បានមានកេរ្តិ៍តកប់កំពូល ហើយគុណសម្បត្តិដ៏វិសេសវិសាលនេះ មិនមែនកើតឡើងដោយគ្មានមូលហេតុនោះទេ ។ តាមពិត សិល្បករនាសម័យនគរភ្នំ បានទទួលនូវការចេះដឹងគ្រប់វិស័យ



www.elibraryofcambodia.org

ពីបុព្វបុរសរបស់ខ្លួននាសម័យបុរេប្រវត្តិសាស្ត្រដែលមានកម្រិតវប្បធម៌ អរិយធម៌ ដ៏ខ្ពង់ខ្ពស់រុងរឿងទៅហើយ ។ រួមសេចក្ដីមកវឌ្ឍនភាពនៃសម័យនគរភ្នំ គឺកើតចេញពីការរួមសង្គ្រាស់ រវាងជឿនវប្បធម៌ខ្មែរ និងឥណ្ឌ ។ បើនិយាយម្យ៉ាងទៀត ឥណ្ឌបានផ្ដល់ទៅខ្មែរនូវទ្រឹស្ដីមនោគមសាសនាថ្មី បច្ចេកទេសថ្មីសម្រាប់អភិវឌ្ឍន៍នូវជឿនសង្គមវប្បធម៌មូលដ្ឋាន ដែលខ្មែរមានពីមុន ប្រយោជន៍នឹងធ្វើឱ្យខ្មែរក្លាយទៅជា អរិយៈប្រទេសដ៏ជឿនលឿន ល្បីល្បាញក្នុងអតីតកាល ។

យើងអាចចែកស្លាបត្យកម្មជីដុតជា បីប្រភេទគឺ ចំនួនដែលយើងយកចិត្តទុកដាក់ជាងគេ ការនិយមនៅទីនេះ ជាទូទៅនូវឥដ្ឋក្នុងសម័យមុនអង្គរ ដែលជាលក្ខណៈដ៏ពិសេសមួយ នៃអរិយធម៌ខ្មែរបុរាណ ។ ទី១ - ប្រាង្គប្រាសាទ ឬ បូជនីយដ្ឋានដែលមានលក្ខណៈជាពុទ្ធនិយម ដែលក្នុងនោះត្រូវបញ្ចូលនូវក្បាច់ក្បូរសម្រាប់លំអទេវស្ថាន ។ ទី២ - ចម្លាក់តំណាងទេវរូប និងពុទ្ធរូប ព្រមទាំងរូបចម្លាក់បុព្វបុរស និងអារក្សអ្នកតា ។ ទី៣ - វត្ថុប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ។ ក្នុងជំពូកទី២ គប្បីត្រូវរាប់បញ្ចូលនូវវត្ថុដែលជាសញ្ញានិមិត្តរបស់ទេវតា ឬភាពពិសិដ្ឋដូចជា លិង្គ យោនី ផ្កា កងចក្រ និងសត្វអច្ឆរិយៈមួយចំនួន ដែលជាអវតាររបស់ទេវតា នៃលទ្ធិព្រហ្មញ្ញសាសនា ដូចជាហង្ស អណ្តើក កណ្តុរ ហនុមាន ព្រះគោឈោស ។ល។

ភាពប៉ិនប្រសប់ការ របស់ជនជាតិខ្មែរនាសម័យនោះ គឺពុំមែនគ្រាន់តែស្ថិតនៅភាពល្អស្រស់បំព្រង ឬក្បូរក្បាច់ល្អិតល្អន់ នៃរូបចម្លាក់បុរាណប៉ុណ្ណោះទេ គឺប៉ុន្តែស្ថិតនៅលើវិធីលាយពណ៌ឥដ្ឋ ដែលប្រដូចទៅនឹងចម្លាក់ថ្ម ឬវត្ថុពិតថែមទៀតផង ។ ដូច្នេះហើយ នៅពេលដែលគេសម្លឹងទៅរូបចម្លាក់បុរាណខ្លះ ដែលមានអាយុជិត ២០០០ឆ្នាំមកហើយ គេមានអារម្មណ៍ថា គេស្ថិតនៅចំពោះមុខវត្ថុពិតៗ ។

ដូចគ្នាដែរ វត្ថុបុរាណមួយចំនួនក៏ត្រូវគេផាត់ពណ៌ដែរ ដូចជា ក្រឡ ឆ្នាំង



www.elibraryofcambodia.org

កន្និកោដិ និងព្រះបដិមា ។ កុំភ្លេចពណ៌ខ្មៅ ស និង ក្រហម ដែលគេនិយមសម្រាប់លាបបដិមា ឬឧបករណ៍សម្រាប់ប្រើប្រាស់ ក្នុងពិធីសាសនាដែលមានលក្ខណៈពិសិដ្ឋ ។

## ការប្រើមន្តអាគម-គាថា

សម័យនគរភ្នំ ប្រជាពលរដ្ឋខ្មែរដែលស្ថិតនៅក្រោម អានុភាពនៃវប្បធម៌សំស្ក្រឹតពិតជាមានជំនឿទៅលើសិល្ប៍មន្តអាគម ដូចសម័យក្រោយៗដែរ ដូច្នេះបានជាទៅឧបកិច្ចលើសំណៅ ឬវត្ថុមួយចំនួនទៅតាមបូជនីយដ្ឋានមួយនានា ដែលស្ថិតក្នុងព្រះរាជនគរ វ្យាធបុរៈ ឬអង្គរបុរី ដែលមានចំនួនរាប់សិបកន្លែង ។ ដូច្នេះហើយឃើញថាអាជ្ញាធរខ្មែរ ប្រជាពលរដ្ឋខ្មែរ នាសម័យនោះជឿថា មន្តអាគម អាថាន់គាថាទាំងឡាយ ដែលគេឧបកិច្ចនោះ មានតម្លៃពិសិដ្ឋណាស់ មកពីគេឱ្យតម្លៃទៅលើរូបមន្តជាភាសាសំស្ក្រឹត ឬជាសញ្ញានិមិត្ត គឺមិនខុសពីសព្វថ្ងៃ ប៉ុន្មានឡើយ ។

ម្យ៉ាងទៀត ការដែលប្រើបន្ទោងខ្សែក ចិញ្ចៀន និងក្រវិលត្រចៀក ដោយមានរូបមន្តពិសិដ្ឋជាភាសាសំស្ក្រឹត ចារពីលើ ក៏ជាវត្ថុតាងយ៉ាងសំខាន់មួយទៀតដែលបង្ហាញនូវការនិយម ចូលចិត្តរបស់ខ្មែរនូវមន្តអាគម គាថា ដើម្បីប្រាថ្នានូវសេចក្ដីសុខសប្បាយ ចំរុងចំរើនរបស់ខ្លួន ។ ចំពោះមនុស្សបុរាណ ការនិយមមន្តអាគម គាថា ដោយមានលក្ខណៈជាយល័ក្ខអក្សរ ចារលើគ្រឿងអលង្ការ សន្លឹកមាស ប្រាក់ស្ពាន់ៗ ដើម្បីយកទៅកប់ជុំវិញប្រាសាទ ឬព្រះវិហារជាដើម ពិតជាមានមហិទ្ធិឫទ្ធិ ស្រេចដូចបំណងរបស់ខ្លួនមែន ។ ម្យ៉ាងទៀតអ្នកដែលមិនជឿ ឬនិយមនូវរូបមន្តទាំងនោះ ពិតជានឹងជួបនូវផលវិបាកផ្សេងៗពុំខាន ។ សូមជម្រាបថា ជំនឿនេះបន្តិចម្ដងៗកាន់តែរីកលូតលាស់ ហើយលាតសន្ធឹងពេញទូទាំងប្រទេសកម្ពុជា រហូតមកដល់សព្វថ្ងៃ ។

សូមជម្រាបថា ការនិយមមន្តអាគមបែបនេះ បានធ្វើឱ្យមនុស្សជំនាន់បុរាណ



www.elibraryofcambodia.org

មានជំនឿទុកចិត្តលើខ្លួនឯង និងទៅលើកិច្ចការនានាដែលខ្លួនត្រូវប្រព្រឹត្តពោលគឺបំបាត់នូវការភិតភ័យ ។ គប្បីបញ្ជាក់នូវត្រង់នេះថា គេបានរកឃើញសន្ទឹកមាសជាច្រើនដែលជារូបសត្វគោនន្ទិន ព្រះវិស្ណុ ផ្កាឈូក សត្វអណ្តើក កងចក្រ ខ្យងស័ង្ខ ។ល។ ជាសញ្ញានិមិត្តនៅក្រោមស្រទាប់ឥដ្ឋ នៃបាតប្រាសាទ ។ ឥឡូវនេះ អ្វីៗដែលបានពោលខាងលើនេះ បានក្លាយទៅជាទម្លាប់ហើយ ជាក់ស្តែងពេលសាងសង់វត្តអារាមម្តងៗ ខ្មែរយើងនៅតែបញ្ចុះអាថាន់ដូចសម័យបុរាណកាល ។

## វត្ថុអច្ឆរិយៈ

### ក . ទេវរូប និងពុទ្ធរូប :

វត្ថុស័ក្តិសិទ្ធិដូចជា រូបព្រះពុទ្ធអង្គ ឬទេវរូបតូចៗធ្វើអំពីកែវស្ល ឬដីដុត និងព្រះបដិមាពុម្ព ដែលជនជាតិខ្មែរទាំងមូល បានទទួលស្គាល់ថា ជាវត្ថុស័ក្តិសិទ្ធិហើយជាទីសក្ការៈបូជា ត្រូវបានខ្មែរនាសម័យនគរភ្នំផលិតរចនាឡើង សម្រាប់គ្រឿងសិរីមង្គលប្រចាំខ្លួន ឬប្រចាំព្រះរាជនគរខ្មែរ ។

គេមានជំនឿជាទូទៅថា អ្នកមានអំណាចគ្រប់គ្រងសង្គម ជាអ្នកស្ថិតក្រោមការថែរក្សារបស់ព្រះអាទិទេព ជាពិសេសព្រះអវលោកេស្វរៈ ។ ដូច្នេះដើម្បីកំចាត់ភាពអាស្រូវទាំងឡាយ គេច្រើនតែផ្តោតទម្ងន់ទៅលើមន្តអាគម និងការគោរពបូជាព្រះបដិមា ។

ការរកឃើញនូវវត្ថុបុរាណទាំងអស់នេះ ធ្វើឱ្យយើងកាន់តែស្វែងយល់អំពីជំនឿរបស់ខេមរជន នាដើមសតវត្សរ៍ទី១ ដល់សតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ។ ម្យ៉ាងទៀតព្រឹត្តិការណ៍នេះ វាអស្ចារ្យណាស់សម្រាប់ការស្រាវជ្រាវ អំពីប្រភព អារ្យធម៌ វប្បធម៌ខ្មែរ នាសម័យមួយដែលអតីតអាណាចក្រភ្នំ ស្ថិតនៅក្រោមឥទ្ធិពលវប្បធម៌ឥណ្ឌា ។ បណ្ឌិតស្រាវជ្រាវបានយល់ថា ជំនឿទាំងនេះជាមូលដ្ឋានសម្រាប់សម័យ



www.elibraryofcambodia.org

ចេនឡា និងអង្គរ ដោយហេតុថា ការឆ្លាក់ សូ និងស្ទូនរូប ដែលជានិមិត្តរូបនៃព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ដែលនៅតែបានជនជាតិខ្មែរអនុវត្តន៍ រហូតដល់សព្វថ្ងៃនេះ ។

ខ . សត្វអច្ឆរិយៈ :

រូបសត្វដ៏ពិសិដ្ឋជាច្រើន ដែលជាយានជំនិះ ឬជាអវតាររបស់ទេវតានៃព្រហ្មញ្ញសាសនា ដូចជាគោនន្ទិន ដីរី អណ្តើក សត្វក្ងោក ។ល។ ត្រូវបានយើងរកឃើញក្នុងបរិវេណ នៃទីក្រុងអង្គរបុរី និងក្នុងតំបន់ផ្សេងៗទៀត ដែលស្ថិតមិនឆ្ងាយពីទីតាំងបុរាណនេះ ។

អត្ថន័យនៃវត្តមានរបស់សត្វពិសិដ្ឋទាំងនោះ ដែលគេបានធ្វើឡើងសម្រាប់តំណាងអច្ឆរិយភាព ឬឫទ្ធានុភាពឥទ្ធិពលនៃធម្មជាតិ ត្រូវភ្ជាប់នឹងវិស័យសាសនា ដែលបានហូរចូលមកនគរភ្នំ នាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ។

វត្តមានរបស់សត្វក្រពើ ត្រកួត ពស់ កង្កែប ។ល។ មិនមែនគ្រាន់តែធ្វើឱ្យការវាយតម្លៃស្ថានភាពជំនឿសាសនា មានភាពត្រឹមត្រូវតែប៉ុណ្ណោះទេ ប៉ុន្តែបញ្ជាក់ឱ្យយើងយល់យ៉ាងច្បាស់ ប្រព័ន្ធគំនិតខ្មែរនាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ មានលក្ខណៈសំយោគថែមទៀតផង ។

ចំណេកបំអារម្មណ៍ជាចុងក្រោយ ដែលធ្វើឱ្យយើងមានការភ្ញាក់ផ្អើលជាខ្លាំង គឺរូបចម្លាក់ដីដុតមួយចំនួន ដែលមានលក្ខណៈជាទេវតាខ្មែរពាក់កណ្ដោក និងជាក្បឿងពាក់កណ្ដោក ។ តំរុយាបថចម្លែកនេះ បញ្ជាក់នូវសម្ព័ន្ធភាពជំនឿសាសនាដែលមាន ក្នុងរដ្ឋដំបូងរបស់ខ្មែរ ប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ។

គ . សញ្ញានិមិត្តរបស់ទេវតានិងព្រះសម្មាសម្ពុទ្ធ : លិង្គ និង យោនី

ត្រូវបញ្ចូលក្នុង វិស័យបដិមាសាស្ត្រខ្មែរបុរាណ ចំពោះវត្ថុសក្ការៈបូជា ជារូប



www.elibraryofcambodia.org

ចម្លាក់តូចៗ មានព្រះសិវលិង្គ យោនី ស្ពានទ្វេរានី និងស្លឹកពោធិដែលតំណាងនូវការត្រាស់ដឹងរបស់ ព្រះបរមគ្រូនៃយើង ។ ក្នុងពេលជាមួយគ្នានេះ យើងបានរកឃើញសញ្ញានិមិត្តមួយចំនួនដែលយើងពុំអាចយល់អត្ថន័យយ៉ាងច្បាស់លាស់ ដូចជារូបកាកបាទជាដើម ។ គឺព្រះគាថា និងសញ្ញានិមិត្តទាំងនោះហើយដែលជាបុព្វហេតុនៃការផុះដាលនៃសាសនាគ្រិស្តនៅអតីតកម្ពុជា ។

ឃ. អារក្ស អ្នកតា :

ក្នុងការស្រាវជ្រាវរបស់យើងៗ បានជួបប្រទះនូវក្បាលអ្នកតាចាស់ស្រុកជាច្រើន ដែលធ្វើអំពីបាយអរថ្មនិងដីដុត ជាហេតុដែលបណ្តាលឱ្យយើងយល់ឃើញថាជំនឿលើបុព្វបុរសជនជាតិខ្មែរ ដែលបានបដិសន្ធិឡើង នាសម័យមុនគ្រិស្តចូលស្រុកនៅតែបន្តក្នុងសម័យឥណ្ឌូបនីយកម្ម ។ លើសពីនេះ វត្ថុមានរបស់ក្បាលអ្នកតាជាច្រើនខាងលើនេះ ធ្វើឱ្យឃើញនូវលក្ខណៈសំយោគនៃផ្នែកជំនឿខ្មែរ រវាងជំនឿខ្មែរ និងសាសនាគ្រិស្ត ដែលជាមូលដ្ឋាននៃសីលធម៌ខ្មែរ ។

តាមការពិត ជនជាតិខ្មែរគ្មានប្រាថ្នាអ្វី ក្រៅពីការចង់បាននូវសេចក្តីសុខសប្បាយ ឬសុភមង្គល ក្នុងគ្រួសារ សង្គម ដែលជាវត្ថុបំណងរបស់ខ្មែរបុរាណនោះទេ ហើយនៅក្នុងសម័យបច្ចុប្បន្ននេះ យើងក៏នៅឃើញជំនឿលើអារក្ស អ្នកតា ចាស់ស្រុកនៅតែរស់រវើកនៅឡើយ ។

## ការស្លៀកពាក់

ប្រភពឯកសារចិន បានពិពណ៌នាអំពីសំលៀកបំពាក់របស់ជនជាតិខ្មែរយើងនៅព្រែនគរភ្នំដូចតទៅ : មនុស្សមានសម្បុរខ្មៅ សក់រួញអង្កាញ់ ភាគច្រើនទាំងពីរភេទនៅអាក្រាតខ្លួន ស្លៀកសារុងធ្វើអំពីអំបោះ និងដើរជើងទទេ។ រីឯនាម៉ឺន មន្ត្រីវិញគេស្លៀកសារុងរបាប់ និងពាក់ស្បែកជើងផង ។



www.elibraryofcambodia.org

ការស្រាវជ្រាវរបស់យើងក៏អាចបញ្ជាក់ថា មនុស្សសាមញ្ញទាំងពីរភេទស្លៀកប៉ឹង ដូចកុលសម្ព័ន្ធខ្មែរលើដែរ ។ ត្រង់នេះ យើងសូមឱ្យគេដូរគំនិតមួយដែលយល់ច្រឡំថា ខ្មែរយើងនាសម័យនគរភ្នំ មិនចេះស្លៀកពាក់តីដើរស្រាត ។

ចំពោះបញ្ហាស្លៀកពាក់ ឯកសារចិនបានឱ្យយើងដឹងថា : " ស្ត្រីភេទពែងខ្លួនគ្រាន់តែស្លៀកសំពត់ក្រណាត់មួយផ្ទាំង ដែលគេពាក់ ( ស៊ក ) ពីលើក្បាល ។ ឯបុរសវិញគេស្លៀកសំពត់តាមបញ្ជារបស់ព្រះរាជា ។ ចំណែកគ្រួសារពួកអភិជនគេស្លៀកសំពត់ចរបាប់ ។ ចំពោះអ្នកក្រីក្រ គេប្រើក្រណាត់ធម្មតា " ។

បើតាមការវិភាគរបស់យើង ការស្លៀកសំពត់ ( ចរបាប់ ឬ ក្បិន ) តាមបញ្ជារបស់ព្រះរាជា មានន័យថា មនុស្សដែលស្លៀកពាក់ទាំងនោះ សុទ្ធតែជានាហ្មឺនមន្ត្រីក្នុងស្ថាប័ននានា និងក្នុងរដ្ឋបាលនាសម័យនោះ ។ គេក៏អាចដឹងដែរ មនុស្សសាមញ្ញពិតជាត្រូវស្លៀកប៉ឹង ឬរុំ ក្រមាដូចបងប្អូនខ្មែរលើជាពុំខាន ។ គប្បីសង្កត់ធ្ងន់ថា ក្បិនដែលយើងបានឃើញតាមរូបចម្លាក់ខ្លះ ខ្មែរយើងពុំទាន់បោះបង់ចោលនៅឡើយ ពីព្រោះខ្មែរបច្ចុប្បន្នកំពុងនិយមវាយ៉ាងជាប់ពោរជាពិសេសនៅតាមអរាណខេត្តនានា ។ ម្យ៉ាងទៀតប្រសិនបើយើងធ្វើការប្រៀបធៀប យើងអាចនិយាយថា សំពត់ ឬក្បិនខ្មែរពិតជាមានប្រភពចេញពីប្រទេសឥណ្ឌាខាងត្បូងពុំខាន ។

គួរកត់សម្គាល់ថា សេចក្តីអធិប្បាយរបស់អ្នកសង្កេតការណ៍ចិនខាងលើត្រឹមត្រូវសមស្របនឹងរូបចម្លាក់ ធ្វើអំពីដីដុតមួយចំនួន ដែលយើងបានជួបប្រទះ តែយើងសូមជួយបន្ថែមនៅទីនេះថា សំពត់របស់ស្ត្រីនាសម័យនោះ មានលក្ខណៈផ្សេងៗពីគ្នា ហើយមានច្រើនប្រភេទ ពោលគឺ ខ្លះខ្លី ខ្លះវែង មានផ្នត់ ឬឥតផ្នត់ តាមចំណូលចិត្តរបស់បុគ្គលម្នាក់ៗ ។

បញ្ហាគួរចាប់អារម្មណ៍បំផុត គឺសំលៀកបំពាក់ដែលយើងបានពិពណ៌នាទៅ



www.elibraryofcambodia.org

ខាងលើនេះ មិនត្រឹមតែត្រូវបានមនុស្សធម្មតា ឬអភិជនទាំងអស់និយមតែប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវបានគេស្លៀកបំពាក់ទេវរូបផងដែរ ។ ការដែលទេវតាចេះស្លៀកពាក់ដូចមនុស្សលោក ធ្វើឱ្យយើងឃើញនូវភាពពិសិដ្ឋ របស់ទេវរូបនាសម័យបុរាណដែលមនុស្សខ្មែរបុរាណបានចាត់ទុកថាមានជីវិតរស់នៅដូចមនុស្សលោកធម្មតា ។

ដោយឡែកយើងបានឃើញនៅវត្តកំពង់ពោធិ រូបទេវទេពប្រណមពីប្រភេទដែលធ្វើអំពីដីដុត : ប្រភេទពែងខ្លួន ពោលគឺគ្រាន់តែស្លៀកពាក់ខ្លីមានផ្គត់តាមរបៀបកុលសម្ព័ន្ធខ្មែរលើសពីផ្ទៃ និងប្រភេទមួយទៀត ប្រកបដោយគ្រឿង អលង្ការដែលធ្វើអំពីមាសប្រាក់ ។

ចំពោះចម្លាក់ប្រភេទក្រោយនេះ យើងឃើញមានពាក់កងកន់ទាំងពីរនៅឯកំភួនដៃទាំងសងខាង សង្វារពីទ្វេខ្វែង និងថាប់សួង នៅលើដើមទ្រូង ។ រីឯនៅលើក្បាលរបស់ទេពប្រណមវិញ ដែលស្ថិតក្នុងឥរិយាបថលុតជង្គង់ គេឃើញមានពាក់ក្បាំងមុខជាច្រើនជាន់ធ្វើអំពីសន្លឹកមាស ។ សូមជម្រាបថា ថ្វីត្បិតតែយើងគ្មានភ័ព្វសំណាងជួបប្រទះ នូវក្បាំងមុខរបៀបនេះជាវត្ថុបុរាណក៏ដោយ ប៉ុន្តែពត៌មានដែលយើងបានមកពីអ្នកស្រុក បានបញ្ជាក់ឱ្យយើងដឹងថា ក្បាំងជាច្រើនដែលគេជីកបានដោយខុសច្បាប់ សុទ្ធសឹងតែធ្វើអំពីមាស ។

យ៉ាងណាមិញ គេក៏បានជួបផងដែរនូវរូបព្រះពុទ្ធអង្គ ទ្រង់អង្គុយក្នុងឥរិយាបថវជ្រយាន ដោយមានមកុដរាជ្យនៅលើព្រះកេស និងកុណ្ឌលនៅត្រចៀក ។ តាមរូបចម្លាក់ត្រូវចែកជាបីសណ្ឋាន គឺក្បាំងមុខ ឬឈ្លេះត្រ មកុដរាជ្យ រនាំងបន្ទោះ ឬមួយ ។

## ការនិយម អង្កាំ និង ផ្គាំ ជាគ្រឿងអលង្ការ

វត្ថុមានរបស់អង្កាំ និងផ្គាំ ធ្វើអំពីថ្មកែវ ភ្លុក ឆ្អឹង ប្រាក់ មាស ឬសំណ ដែលអាចរំឭកមួយផតកំណើត ក្នុងស្ថានីយ៍ប្រវត្តិសាស្ត្រ ហើយដែលមានពណ៌ចម្រុះគ្រប់ពណ៌



www.elibraryofcambodia.org

គ្រប់ខ្នាត មិនគ្រាន់តែបញ្ជាក់ឱ្យយើងឃើញនូវភាពរុងរឿង ឬវិបុលភាពរបស់សង្គម តែប៉ុណ្ណោះទេ ក៏ប៉ុន្តែនូវទំនាក់ទំនងផ្នែកពាណិជ្ជកម្ម រវាងជនជាតិខ្មែរ និងប្រទេសជិតឆ្ងាយមួយចំនួន ដែលស្ថិតនៅជុំវិញព្រះរាជាណាចក្រនគរភ្នំ ថែមទៀតផង ។

តាមការស្រាវជ្រាវរបស់យើងៗ អាចចែកអង្កាំ និងផ្តាំជាបីប្រភេទ ដូចតទៅនេះ : ទី ១ - អង្កាំ និងផ្តាំ ដែលមានប្រភពចេញពីប្រទេសឥណ្ឌា ទី ២ - អង្កាំ និងផ្តាំ ដែលមានប្រភពចេញពីចក្រភពរ៉ូម៉ាំង និងទី ៣ - អង្កាំ និងផ្តាំអាយដែលបានផលិតដោយជនជាតិខ្មែរនៅលើទឹកដីនគរភ្នំ ។

ផ្អែកទៅលើការស្រាវជ្រាវដដែលនេះ យើងអាចកត់សម្គាល់បានទៀតថា ហេតុផលនៃសេចក្តីសន្និដ្ឋានបែបនេះ បណ្តាលមកពីការវិភាគនូវលក្ខណៈរបស់ដុំត្បូងអង្កាំនិងផ្តាំនីមួយៗ ដែលបានរកឃើញក្នុងស្ថានីយ៍ប្រវត្តិសាស្ត្រធំបី គឺសុផាន់បូរី អូរកែវ និងអង្គរបូរី ដែលសុទ្ធសឹងជាបូរីបុរាណទាំងអស់ ដែលស្ថិតក្នុងសម័យកាលវប្បធម៌នគរភ្នំ ។

ដោយផ្អែកទៅលើសំណល់នៃបំណែកអង្កាំផ្ទុំ និង គំនរកញ្ចក់ពណ៌យ៉ាងច្រើនលើសលប់ ដែលគេបានចររហ៊ើ ឬ ស្ទូ យើងអាចណែនាំអ្នកស្រាវជ្រាវឱ្យដឹងថាមានកន្លែងផលិតអង្កាំ និង ផ្តាំ យ៉ាងច្រើនព្រាកដនៅរាជធានីអង្គរបូរី ហើយការផលិតនេះត្រូវបានធ្វើឡើងដោយជាងទងដ៏ចំណានៗ ដែលបានចម្លងរូបអន្តផ្ទុំរបស់ក្លិង្គ ឬពួករ៉ូម៉ាំង ថ្វីត្បិតតែបុព្វបុរសខ្លួនចេះធ្វើអង្កាំ តាំងតែសម័យមុនក្លិង្គចូលស្រុកក៏ដោយ ។

រួមសេចក្តីមក អង្កាំ និង ផ្តាំគ្រប់បែបយ៉ាង ដែលគេបានរកឃើញនៅក្នុងរាជធានីបុរាណខ្មែរនានា ពុំមែនសុទ្ធសឹងតែជាគ្រឿងអលង្ការ ដែលគេបាននាំចូលពីបរទេសនោះទេ ក៏ប៉ុន្តែបានត្រូវរចនាឡើងដោយអ្នកស្រុក ដែលគ្រាន់តែបានចម្លងគំរូមកពីក្រៅតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត សូមជម្រាបថា ការប្រើប្រាស់នូវអង្កាំ និងផ្តាំ ដោយ



www.elibraryofcambodia.org

ដោតពាក់ជាខ្សែក កុលសម្ព័ន្ធខ្មែរលើ និងប្រជាពលរដ្ឋខ្មែរដែលរស់នៅចុងកាត់មាត់ញក នៅតែនិយមប្រពៃណីនេះជាទម្លាប់ រហូតដល់សព្វថ្ងៃ ។

## ការបូជាសព

តាមឯកសារចិន ការបូជាសពរបស់ជនជាតិខ្មែរ នាសម័យនគរភ្នំមានលក្ខណៈដូចគ្នាទៅនឹងអាណាចក្រ លិនយី ឬ ចាម្ប៉ា ។

ក្នុងខណៈដែលគេកាន់មរណទុក្ខ គេត្រូវកោរសក់និងកោរពុកមាត់ ។ រីឯពិធីរំលាយសពវិញ គេឃើញមានបួនយ៉ាង គឺការបោះចោលសពក្នុងទឹកទន្លេ តាមទំនៀមទម្លាប់ក្លិង្គ ការដុតសពដោយភ្លើង ការកប់សពក្នុងដី និងការយកខ្មោចទៅដាក់ចោលក្នុងព្រៃជ្រៅ ដើម្បីឱ្យសត្វសាហាវស៊ី ។

យើងមិនបដិសេធពតិមានខាងលើនេះ ដែលកត់ត្រាដោយជនជាតិចិនទេតែយើងសូមបំភ្លឺថា អ្វីដែលបានលើកមកនេះពុំទាន់គ្រប់ជ្រុងជ្រោយទេ ពីព្រោះនៅមានទម្លាប់មួយទៀត ដែលនៅសល់រហូតដល់សព្វថ្ងៃ គឺការយកសពទៅទុកក្នុងរូងភ្នំដែលគេជឿថា ជាកន្លែងអាថ៌កំបាំង ឬស័ក្តិសិទ្ធិ ។

ជុំវិញបញ្ហាបូជាសព ប្រភពឯកសារចិនបានបន្ថែមទៀតថា ក្រោយពីបូជាសពដោយភ្លើង ខ្មែរបុរាណតែងតែប្រមូលធាតុដែលនៅសល់ ដើម្បីយកទៅដាក់ក្នុងកោដិ ឬក្រឡមួយ ហើយបន្ទាប់មកទៀត គេបិទមាត់កោដិនោះយ៉ាងជិតហើយយកទៅបោះក្នុងទន្លេ ។ ចំពោះការបិទមាត់កោដិនេះ យើងសូមបញ្ជាក់ថាគេបិទ កោដិដោយបេជ័រទឹក ។

ឯកសារចិនបានបញ្ជាក់ទៀតថា បើជាស្ដេច កោដិដែលដាក់ព្រះអដ្ឋិនោះត្រូវធ្វើអំពីមាស ដែលជាលោហធាតុមួយតំណាងភាពបរិសុទ្ធ និងអមតៈព្រោះវាមិនងាយ



www.elibraryofcambodia.org

សឹក ហើយបើជាមនុស្សធម្មតា ឬសពមុខមន្ត្រីវិញ គេរមែងតែប្រើកោដិប្រាក់ ឬដីដុត ។

ទោះបីយ៉ាងនេះក្តី ក៏យើងនៅតែឃើញការបន្ត នូវប្រពៃណីកប់សពក្នុងដី ដែលជាទំនៀមទម្លាប់នាសម័យបុរេប្រវត្តិសាស្ត្រខ្មែរ ។ ជួនកាលគេកប់សពអង្គុយ ដោយហេតុគេជឿថាឥរិយាបថនេះអាចធ្វើឱ្យមនុស្សអាចចាប់ជាតិឡើងវិញយ៉ាងងាយស្រួល ដូចពេលដែលមនុស្សនៅក្នុងគភ៌ម្តាយ ។ យ៉ាងហោចិញ្ចការពិនិត្យសិក្សានូវភាជន៍តូចធំមួយចំនួនធំ ក៏អាចផ្តល់ឱ្យយើងនូវពត៌មានយ៉ាងសំខាន់មួយថ្មីទៀត គឺមានក្រឡមួយចំនួន ត្រូវផ្ទុកនូវឆ្អឹងសព ។ ឧទាហរណ៍នេះ អាចបង្ហាញឱ្យយើងដឹងថា ការបូជាសពខ្លះត្រូវធ្វើឡើងពីរដង ហើយត្រូវធ្វើឡើងដោយប្រើរយៈពេលវេលាវែង ពោលគឺក្នុងរយៈកាលទីមួយគេកប់ខ្មោច ឬសពក្នុងក្តារមឈូស ឬក្នុងដីតែម្តង ដោយមិនបាច់តម្កល់សពក្នុងក្តារមឈូស ហើយបន្ទាប់មកគេរើសឆ្អឹងសពដើម្បីយកទៅកប់ ក្នុងកោដិ ឬក្រឡដី ។

គប្បីរំលឹកថា ពិធីកប់សពពីរដងផ្ទួនគ្នាខាងលើនេះ ត្រូវបានប្រារព្ធឡើងតាំងតែមុនសម័យប្រវត្តិសាស្ត្រម្ល៉េះ ។

## លទ្ធិមេនិយម

សង្គមខ្មែរនាសម័យនគរភ្នំ ដែលតពីសម័យបុរេប្រវត្តិសាស្ត្រ ជាសង្គមដែលគេនិយមមេជាធំ ដូចនេះហើយ បានជាកំណត់ហេតុចិន បានឱ្យដឹងថា នគរភ្នំដើមឡើយដឹកនាំដោយនាង លីវ យី ។ រីឯក្នុងព្រះរាជវង្សានុវង្សខ្មែរវិញ គឺនាងនាគទេ ដែលជាម្ចាស់ទឹកម្ចាស់ដីនៃគោកធ្លក ។ ភស្តុតាងមួយទៀត ដែលគេអាចចាត់ទុកថា ជាសំណល់នៃជំនឿវប្បធម៌ នាសម័យឥណ្ឌូបនីយកម្ម គឺទំនៀមទម្លាប់ស្ត្រីដណ្តឹងប្រុសធ្វើប្តី ដែលគេនៅជួបក្នុងកុលសម្ព័ន្ធខ្មែរលើមួយចំនួន ។



www.elibraryofcambodia.org

អ្វីដែលទើបពោលនៅខាងលើនេះ ក៏ត្រូវបានបញ្ជាក់ដោយឯកសារចិនដែរ ដែលឱ្យដឹងថា នៅនគរភ្នំ គឺស្រីៗទេដែលជាអ្នកទៅដណ្ដឹងប្រុសៗ ។ រីឯសេរីភាពក្នុងការទាក់ទងនឹងបុរស តាមទំនើងចិត្តដែលបានកត់ត្រាដោយ ជនជាតិចិននៅនគរភ្នំ ក៏ជាសារធាតុនៃលិទ្ធិមេនិយមនេះដែរ ។

សូមជម្រាបថា បន្តិចម្ដងៗទំនៀមនេះ ត្រូវលប់បំបាត់ដោយវប្បធម៌អារ្យធម៌ឥណ្ឌា ក៏ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ឥទ្ធិពលរបស់ស្ត្រីភេទ ជាពិសេសតួនាទីរបស់ម្ដាយក្នុងសង្គមខ្មែរនាជំនាន់ក្រោយៗ នៅតែត្រូវរក្សាទុកដដែល ដូចជាពាក្យសុភាសិតមួយបានពោលថា សុខចិត្តស្លាប់បា កុំឱ្យស្លាប់មេ ។

សូមបញ្ជាក់ថា ប្រពៃណីខ្មែរនិយមមេជាធំ នាសម័យនគរភ្នំ តាមការពិតសមស្របនឹងច្បាប់ធម្មជាតិ ព្រោះថាគឺម្ដាយនេះហើយ ដែលផ្ដល់នូវជីវិតជូនចំពោះមនុស្សលោក ។ ស្ត្រីភេទគឺជាប្រភពនៃជីវិត ។

## ទំនៀម សីលធម៌

សង្គមខ្មែរនាសម័យនគរភ្នំ ជាសង្គមមានប្រពៃណីជាមូលដ្ឋាន ដូច្នេះហើយបានជាទំនៀមទម្លាប់ទាំងឡាយ ត្រូវបានគេប្រកាន់យកយ៉ាងខ្ជាប់ខ្ជួន ព្រោះគេបានចាត់ទុកថា ជាច្បាប់ ឬវិន័យរបស់សង្គមមនុស្ស ។

ឯកសារចិន បាននិយាយថា អ្នកស្រុកអាណាចក្រភ្នំជាមនុស្សចូលចិត្តនិយមនូវសច្ចធម៌ និង យុត្តិធម៌ ហើយដើម្បីរកការពិតណាមួយ ដូចជាការបាត់បង់នូវវត្ថុណាមួយជាដើម គេពូតបាយជាពំនូតតូចៗ ហើយយកទៅថ្វាយចំពោះព្រះភ័ក្ត្រទេវតាហើយអង្វរករជួយជនទុច្ចរិត ដែលបានលួចរបស់ ។ ស្មេកឡើងម្ចាស់ដែលបាត់របស់ក៏បានយកពំនូតបាយទាំងនោះ ទៅចែកចាយឱ្យមនុស្សក្នុងផ្ទះដែលគេសង្ស័យ ដើម្បីយក



www.elibraryofcambodia.org

ទៅបរិភោគ ។ ធ្វើដូច្នេះគេជឿថា មាត់របស់ជនទុច្ចរិតពិតជាមានឈាមហូរចេញពុំខាន ហើយជាហេតុធ្វើឱ្យពុំអាចទំពារពំនូតបាយបានឡើយ ។ រីឯជនសុចរិតវិញ គេអាចលេបពំនូតបាយយ៉ាងងាយស្រួល ដោយគ្មានឧបសគ្គអ្វីទាំងអស់ ។

ឯកសារចិនក៏បានបញ្ជាក់បន្ថែមទៀតថា គេត្រូវបង្អត់បាយបីថ្ងៃ ចំពោះជនណាដែលត្រូវទទួលនូវការចោទប្រកាន់ ហើយបន្ទាប់មកគេតម្រូវឱ្យជននោះលូកដៃក្នុងខ្ទះដែលមានទឹកកំពុងពុះ ។ បើសិនជាអ្នកដែលត្រូវគេចោទប្រកាន់នោះជាអ្នកស្លូតត្រង់បរិសុទ្ធពិតមែន ដៃរបស់គេពិតជានឹងមិនរលាកជាដាច់ខាត ។ ចំពោះជនដែលបានលួចវត្ថុវិញ ដៃរបស់គេនឹងត្រូវរលាកពុំខានឡើយ ។ ម្យ៉ាងទៀតគេអាចបង្ខំឱ្យជនដែលជាប់ចោទ លូកយកពូថៅ ឬច្រវាក់ដែលគេដុតក្រហមឆ្អៅ ឱ្យដើរក្រាំពីរជំហាន ។ អ្នកដែលគ្មានកំហុសពិតជាពុំសូវរលាក ។

សូមជម្រាបថា ប្រពៃណីខាងលើនេះ ពុំខុសពីទំនៀមទម្លាប់ខ្លះៗដែលប្រតិបត្តិដោយក្រុមកុលសម្ព័ន្ធខ្មែរលើប៉ុន្មានដែរ ដូចជាវិធីលូកយកសំណក្នុងខ្ទះដែលមានទឹកពុះជាដើម ។ សូមរំលឹកឡើងវិញ ដូចជនជាតិភ្នងខ្មែរនាសម័យនគរភ្នំ បានចាត់ទុកថា ដៃស្តាំជានិមិត្តរូបនៃការពិត អំពើល្អ រីឯដៃឆ្វេងតំណាងនូវអ្វីៗជារបស់អាក្រក់ អយុត្តិធម៌ ។

ចំពោះវិធានការទាំងប៉ុន្មានខាងលើនេះ ដែលទាក់ទងនឹងវិស័យសីលធម៌ គប្បីយើងសង្កត់ទម្ងន់ទៅលើកត្តាចិត្តសាស្ត្រជាងកត្តាផ្សេងៗទៀត ដោយហេតុថា វាជាយុទ្ធវិធីមួយប្រកបដោយប្រសិទ្ធភាព ហើយអ្នកមានកំហុសពិតជារុញរា ភ័យខ្លាចនឹងទារុណកម្មខាងលើនេះពុំខាន ។

## អំពីបណ្ណសារ

សូមរំលឹកឡើងវិញថា វឌ្ឍនភាពរបស់សង្គមខ្មែរយើងនាសម័យនគរភ្នំ



www.elibraryofcambodia.org

បណ្ដាលមកពីពាណិជ្ជកម្ម និងទេពកោសល្យនៃជនជាតិនេះ ដែលបានកែឆ្នៃអារ្យធម៌រតកវប្បធម៌របស់ខ្លួន ។ ហេតុនេះហើយ បានជាអ្នកប្រវត្តិសាស្ត្រចិននាសម័យនោះនិយាយថា មានឃ្លាំងដាក់សៀវភៅឯកសារប្រចាំជាតិ រីឯអក្សររបស់ខ្មែរវិញមានលក្ខណៈ ដូចជាអក្សរដែលគេសរសេរនៅប្រទេស លិន យី ឬ ចាម្ប៉ា ពោលគឺអក្សរដែលមានប្រភពចេញពីប្រទេសឥណ្ឌា ។

តាមពិតការពិពណ៌នា អំពីឃ្លាំងឯកសារដោយជនជាតិចិនខាងលើនេះ ជាព្រឹត្តិការណ៍មួយដ៏សំខាន់ណាស់ ហើយបើយើងពិនិត្យទៅលើបញ្ហានេះឱ្យបានស៊ីជម្រៅ យើងអាចសម្គាល់ថា ការដែលប្រទេសខ្មែរអាចមានលទ្ធភាព មានឃ្លាំងសៀវភៅ ឯកសារប្រចាំជាតិរបស់ខ្លួនបាន លុះត្រាតែមានស្ថេរភាពនយោបាយនិងភាពរុងរឿងផ្នែកវប្បធម៌ ឬសេដ្ឋកិច្ច ហើយប្រទេសនេះឈានទៅរកវឌ្ឍនភាពកំពូល ។ មិនមែនគ្រាន់តែសង្គមខ្មែរមានការរីកចម្រើន ក្នុងវិស័យអក្សរសិល្ប៍អក្សរសាស្ត្រតែប៉ុណ្ណោះទេ ក៏ប៉ុន្តែក្នុងវិស័យសិក្សាអប់រំថែមទៀតផង ពោលគឺការផ្ទេរនូវការចងចាំ ចំណេះដឹងទាំងប៉ុន្មានរបស់សង្គមជាតិ តាមរយៈការកត់ត្រាដោយតួអក្សរ ។ នេះបញ្ជាក់ឱ្យឃើញថា នៅសម័យនោះមានការចាប់ផ្ដើមនូវការស្ថាបនានូវស្មារតីជាតិ ឬសតិសម្បជញ្ញៈជាតិមួយយ៉ាងប្រាកដ ហើយចលនាបែបនេះ គឺជាសកម្មភាពមូលដ្ឋានរបស់សង្គមជាតិ ដែលយើងអាចចាត់ទុកថា កម្លាំងស្នេហាជាតិមួយដ៏ជាក់ស្ដែង ។ បើគ្មានពង្សាវតារទេ ក៏មិនខុសពីកុលសម្ព័ន្ធខ្មែរ ដែលរស់នៅខ្ពង់រាបប៉ុន្មានទេ ហើយពិតជាគ្មានប្រទេសកម្ពុជាសព្វថ្ងៃឡើយ ។

ម្យ៉ាងទៀត យោងតាមសកម្មភាពនេះ ទំនៀមទម្លាប់ជាអធិរាជ្ញ របស់អ្នកកាន់អំណាចខ្មែរ ដែលបានប្រកាន់យ៉ាងខ្ជាប់ខ្ជួន តាំងពីសម័យមុនអង្គរ រហូតដល់បច្ចុប្បន្នកាល គឺផ្ដល់វត្ថុទានរបស់បណ្ណាល័យ នៅតាមប្រាសាទសំខាន់ៗមួយចំនួន ( ភ្នំរុង បាគង



www.elibraryofcambodia.org

ព្រះគោ អង្គរវត្ត បាយ័ន ... ) និងស្នៀនប្រចាំព្រះបរមរាជវាំងដើម្បីកត់ត្រានូវព្រះរាជពង្សាវតារ នៃព្រះមហាក្សត្រដែលបានសោយរាជ្យក្នុងព្រះរាជាណាចក្រកម្ពុជា ជាសក្ខីភាពស្រាប់ (K.1036) យើងអាចបញ្ជាក់ថា អ្វីៗដែលពិពណ៌នាថ្លែងការណ៍ដោយជនជាតិចិន មាន ភាពត្រឹមត្រូវពិតប្រាកដ ។

## គម្ពីរសាសនា

ថ្វីត្បិតតែយើងមានកង្វះឯកសារ ស្តីពីបញ្ហានេះក៏ដោយ ក៏ប៉ុន្តែតាមរបាយការណ៍ ពីក្រុមប្រវត្តិវិទូចិនសម័យរាជ្យកាល លាង បានឱ្យដឹងថា មានស្តេចខ្មែរនាជំនាន់នោះ បានបញ្ជូនជនជាតិឥណ្ឌាម្នាក់ឈ្មោះ បរមាថ ឬ គុណរតន ដែលបានមកស្នាក់អាស្រ័យនៅរាជាណាចក្រភ្នំ ដើម្បីនាំយកគម្ពីរជាច្រើនខាងព្រះពុទ្ធសាសនាទៅកាន់ប្រទេសចិន។ បញ្ហានេះ ឯកសារចិនបានលើកមកនិយាយដោយបញ្ជាក់ថា នៅចន្លោះគ្រិស្តសករាជ ៥៣៥ និង ៥៤៥ មានរាជទូតចិនបាន[illegible]មកនគរភ្នំ តាមព្រះរាជតម្រិះរបស់ស្តេចចិន ដើម្បីសុំឱ្យព្រះមហាក្សត្រខ្មែរផ្តល់ចំពោះប្រទេសចិន នូវគម្ពីរផ្នែកព្រះពុទ្ធសាសនា ។

គួរកត់សម្គាល់ថា គម្ពីរដីកាទាំងប៉ុន្មាន សុទ្ធសឹងតែទាក់ទងព្រះពុទ្ធសាសនានិកាយមហាយាន ហើយនិកាយនេះខុសពីនៅកម្ពុជា ត្រូវបានជនជាតិចិន ព្រះរព្ធប្រតិបត្តិ រហូតដល់សព្វថ្ងៃនេះ ។

តាមការវិភាគរបស់យើង គម្ពីរព្រះពុទ្ធសាសនាទាំងនោះដែលនាំទៅចិន មានលក្ខណៈ ជាក្រាំងធ្វើអំពីក្រដាសដូចសព្វថ្ងៃ ពោលគឺ ពុំមែនជាសាស្ត្រាស្លឹករឹតទេ ។ តាមការពិតការចារគម្ពីរដីកាលើក្រាំង ឬស្លឹករឹត ជាប្រពៃណីដែលហូរចេញពី ប្រទេសក្លិង្គ ជាពិសេសពីស្រីលង្កា ម្លោះហើយគេបានជួបរហូតដល់សព្វថ្ងៃនូវទំនៀមនេះ នៅកម្ពុជាក្រោម នៅស្រុកសៀម ខ្មែរ លាវ និងនៅប្រទេសភូមាដែលជាតំបន់ធ្លាប់



www.elibraryofcambodia.org

ស្ថិតក្រោមឥទ្ធិពលវប្បធម៌ក្លិង្គទាំងអស់ ។

ម្យ៉ាងទៀតសូមជម្រាបថា ការផ្សព្វផ្សាយនៃលិទ្ធិព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនាទាំងឡាយ ដែលជាយានសម្រាប់ជម្រុញអភិវឌ្ឍន៍មនោគមវិជ្ជា របស់លិទ្ធិសាសនា ។ យ៉ាងណាមិញជនជាតិក្លិង្គ ក៏បានប្រើប្រាស់ផងដែរនូវព្រះបដិមាដើម្បីងាយស្រួលក្នុងការផ្សព្វផ្សាយមនោគមវិជ្ជាថ្មីនេះ ។ ក្នុងករណីនេះហើយបានជាយើងឃើញនូវការនាំចូលក្នុងអតីតដែនដី នគរភ្នំ និងនៅប្រទេសឥណ្ឌូនេស៊ីនូវរូបចម្លាក់តំណាងព្រះពុទ្ធអង្គ ដែលជាសិល្បៈក្លិង្គ អមរាវតី ឬ គន្ធារ សុទ្ធសាធ ។

សូមរំលឹកឡើងវិញដែរថា ក្នុងកំណត់ហេតុចិន ដើម្បីបកប្រែគម្ពីរជាភាសាសំស្ក្រឹត ទៅជាភាសាចិនដែរ ។ ព្រះអង្គទាំងពីរអង្គនោះ គឺ សង្ឃបាល និង មន្ទ្រសេន ។ យ៉ាងណាមិញតាមសិលាចារឹកវ៉ាបេកន្ទេល យើងឃើញថាមានការតម្កល់នូវព្រះគម្ពីររាមកេរ្តិ៍ និង បុរាណៈ នៅបូជនីយដ្ឋាន ដើម្បីឱ្យគេសូត្រប្រចាំថ្ងៃផង ។

## ផ្ទះសម័យ

ដោយបានការបញ្ជាក់ពីកំណាយស្ថានីយ៍ប្រវត្តិសាស្ត្រនានា គេអាចដឹងថាផ្ទះនាសម័យនគរភ្នំ ត្រូវបានសាងសង់អំពីឈើ ហើយស្ថិតខ្ពស់ពីដី ប្រយោជន៍នឹងការពារសត្វសាហាវ ឬទឹកជំនន់ ។ ម្យ៉ាងទៀត តាមរយៈកំណត់ហេតុចិនយើងក៏អាចដឹងដែរថាផ្ទះនាសម័យនោះដែលស្ថិតនៅជិតមាត់សមុទ្រ ប្រក់ស្លឹកចាក ប៉ុន្តែជាក់ស្តែងផ្ទះអ្នកមានប្រក់ក្បឿងធ្វើអំពីដីដុត ។ កន្លងមកនេះ យើងបានរកឃើញរូបភាពនៃផ្ទះព្រមទាំងក្បឿងដីដុតមួយចំនួន នៅឯស្ថានីយ៍អង្គរបូរី ដែលជាភស្តុតាង នៃផ្ទះសម្បែងរាស្ត្រនៅសម័យកាលខាងលើនេះ ។

ប្រការមួយទៀតដែលគេត្រូវកត់ត្រា គឺផ្ទះនាសម័យនគរភ្នំ ត្រូវគេតុបតែង



www.elibraryofcambodia.org

ដោយក្បាច់ក្បូរយ៉ាងល្អប្រណីត ។

មួយវិញទៀត ផ្ទះនិមួយៗមានរបងឈើឡោមព័ទ្ធ ហើយឈើទាំងនោះត្រូវបានគេកាប់យកចេញពីព្រៃ ។ ដូច្នេះហើយបានជាគេអាចសន្និដ្ឋានថា ដីធ្លីខ្មែរនាសម័យនោះ សុទ្ធសឹងតែមានកម្មសិទ្ធិ លើកលែងតែដីព្រៃ ហើយសិទ្ធិទៅលើដីធ្លីនេះ ត្រូវបានផ្ទេរទៅគ្រួសារញាតិសន្តាន ជាបន្តបន្ទាប់គ្នាដោយមិនដាច់ ។

## ការគោរពបូជាភ្នំ

សម័យនគរភ្នំ ភ្នំទាំងឡាយត្រូវគេចាត់ទុកជាកន្លែងស័ក្តិសិទ្ធិ ដោយហេតុថាជាកន្លែងដែលទេវតាប្រថាប់ ។ តាមឯកសារចិន "ជាញឹកញាប់អាទិទេពយាងចុះប្រថាប់លើកំពូលភ្នំម៉ូតាន់ ( ភូខៅ. ទម្បៅតភាក់ ) ពីព្រោះភ្នំនេះគឺជាទីកន្លែងដែលព្រះបានជ្រើសរើសសម្រាប់សម្តែងនូវអិទ្ធិឫទ្ធិរបស់ព្រះអង្គ ។ គឺនៅទីនេះហើយដែលព្រះអាទិទេពប្រសិទ្ធិពរជ័យ សិរីមង្គល ថ្វាយចំពោះព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ ហើយប្រជារាស្ត្រ ក៏បាន ទទួលសេចក្តីសុខសប្បាយផងដែរ" ។

សូមជម្រាបថា ការដែលព្រះចៅអធិរាជខ្មែរគ្រប់ព្រះអង្គ នាសម័យនគរភ្នំស្តេចយាងឡើងភ្នំ សម្រាប់ធ្វើពិធីបួងសួងព្រះសិរៈ ដើម្បីសេចក្តីរុងរឿង ថ្កុំថ្កើង របស់ព្រះរាជនគរ និងប្រជារាស្ត្រ ជាព្រះរាជកិច្ចមួយដ៏ឧត្តុង្គឧត្តម ហើយប្រកបដោយសីលធម៌ ដ៏ធំធេងអស្ចារ្យ ។ ព្រះរាជកិច្ចនេះ ក៏ត្រូវបានព្រះមហាក្សត្រខ្មែរនាសម័យអង្គរ ដូចជាព្រះសុរ្យវម៌្មទី១ និងទី២ ជាដើម បានប្រារព្ធប្រណិបត្តិតាមយ៉ាងជាប់លាប់ដើម្បីកសាងស្ថាបនាប្រទេសជាតិ ។

សូមរំលឹកឡើងវិញដែរថា ប្រភពសិលាចារឹកបានឱ្យដឹងថា ព្រះបាទសុរ្យវម៌្មទី១ ព្រះអង្គបានស្តេចយាងធ្វើបុណ្យបួងសួង នៅលើប្រាសាទព្រះវិហារដែលស្ថិតលើភ្នំ



www.elibraryofcambodia.org

ព្រះវិហារ ។ រីឯព្រះបាទសុរ្យវរ្ម័នទី២ វិញ ព្រះអង្គក៏ដើរតាមគន្លងអតីតម្ចាស់មហាក្សត្រខ្មែរ ដទៃៗទៀតដែរ គឺស្ដេចបានធ្វើដំណើរយ៉ាងវែងឆ្ងាយដើម្បីប្រារព្ធពិធីបូជាយញ្ញនៅលើកំពូលភ្នំ វត្តភូ ដែលជាបូជនីយដ្ឋានដ៏ពិសិដ្ឋតាំងតែ ពីសម័យចេនឡាម្ល៉េះ ។ តើព្រះរាជសកម្មភាពនេះ ពុំមែនមិនប្រកបដោយវិរភាព សីលធម៌ និងព្រហ្មវិហារធម៌ដ៏មហាធំធេងទេឬ ?

តាមពិត ជំនឿសាសនា មានអានុភាពយ៉ាងខ្លាំងក្លាបំផុត និងប្រព័ន្ធនយោបាយ ហើយនិងវិស័យស្ថាបត្យកម្មដូចជា ការជីកស្រះភ្នំនៅចង្កេះភ្នំដាដើម្បីធ្វើជាទីសក្ការៈបូជាទេវតា និងការសាងប្រាសាទថ្ម គឺអាស្រមមហោបុរីដែលស្ថិតនៅទិសខាងត្បូង ក្រៅកំផែងព្រះរាជធានីអង្គរបុរី ជាសក្ខីភាពស្រាប់ ។

## វិស័យនយោបាយ សាសនា

រដ្ឋបាលនៃអាណាចក្រភ្នំ ត្រូវបានរៀបចំឡើងតាមរបៀបគ្រប់គ្រងដែលមាននៅប្រទេសកម្ពុជា ដោយហេតុថាខ្មែរយើង បានទទួលឥទ្ធិពលវប្បធម៌នៃប្រទេសនេះ តាំងពីបឋមនៃប្រវត្តិសាស្ត្ររបស់ខ្មែរ ។

ក្នុងករណីនេះហើយ យើងឃើញអ្នកដឹកនាំកំពូលនៃប្រទេសជាតិ ជាព្រះមហាក្សត្រប្រថាប់នៅក្នុង ព្រះបរមរាជវាំងធ្វើអំពីឈើមួយ ដោយមានរបងឥដ្ឋព័ទ្ធជុំវិញ ។ ព្រះរាជវាំងរបស់ព្រះរាជា ស្ថិតមិនឆ្ងាយប៉ុន្មានពីភ្នំពិសិដ្ឋមួយ ។ គឺនៅលើកំពូលភ្នំដាក្បែរអង្គរបុរីនេះហើយដែលព្រះមហាក្សត្រខ្មែរយាងឡើងធ្វើការគោរពបូជាចំពោះព្រះមហេស្វរ ដែលជាឈ្មោះរបស់ព្រះសិវៈ ។ម្យ៉ាងទៀតនៅទីនេះក៏មានតម្កល់ ទូវព្រះសិវលិង្គ មួយឈ្មោះព្រះគិរិស ដែលជានិមិត្តរូបរបស់ព្រះសិវៈបុរស ។ ដូច្នេះហើយបានជាព្រះអង្គមាន ងារនូវនាមថា ក្រុងភ្នំ ( ក្រុង ភ្នំ )



www.elibraryofcambodia.org

ឬស្ដេចភ្នំដែល ជាឈ្មោះ សម្គាល់ភ្នំដែលជាព្រះរាជសក្ការបូជា ។

សូមបញ្ជាក់ថា ការដែលព្រះសិវៈសណ្ឋិតនៅលើកំពូលភ្នំនោះ ពុំមែនរឿងមួយចៃដន្យទេ ក៏ប៉ុន្តែសមស្របតាមទស្សនវិជ្ជារបស់ជនជាតិខ្មែរ ដែលធ្លាប់មានអក តាំងតែពីសម័យបុរេប្រវត្តិសាស្ត្រ ។ ការសិក្សាអំពីជំនឿវប្បធម៌ខ្មែរ នាសម័យមុនឥណ្ឌូបនីយកម្មបានឱ្យយើងដឹងថា ដំបូក ទួល ភ្នំ ត្រូវ បានជនជាតិខ្មែរធ្វើសក្ការៈបូជា ចាត់ទុក ថាជាកន្លែងពិសិដ្ឋ ហើយបានត្រូវគេលើកឡើង តាងឱ្យស្មើទៅនឹងឋានទេវតា ក៏ប៉ុន្តែពុំមែនជាទេវរាជដូចដែលគេបានយល់ច្រឡំនោះទេ ។ ហេតុផលព្រោះតែកាលនោះ ប្រជាពលរដ្ឋខ្មែរគេជឿថា អាទិទេពមេឃ ឬក៏វត្ថុស័ក្ដិសិទ្ធិ ដូចជាអារក្ស អ្នកតា ស្ថិតនៅប្រចាំនៅគ្រប់ទីកន្លែង ដែលខ្ពស់ពីដី ដូចនេះ សញ្ញាណជំនឿកាលនោះនេះ បានកើតចេញពីជំនឿវប្បធម៌ សម័យកាល ឥណ្ឌូ-ខ្មែរ ក៏ប៉ុន្តែវិវឌ្ឍន៍តាមកាលកំណត់ ពោលគឺ ពិធីសាសនា ព្រះរាជាអាចហៅព្រះអាទិទេពនេះ ដូចជាព្រះឥសូរបានដឹង ឬអាច ប្រាថ្នា ឬ សណ្ឋិតក្នុងព្រះកាយរបស់ព្រះអង្គ ។ នេះជាវត្ថុតាងបង្ហាញឱ្យឃើញលក្ខណៈពិសិដ្ឋ របស់រាជាធិបតេយ្យ ។ គឺក្នុងករណីនេះហើយ បានជាគេឃើញមានសម្ព័ន្ធភាព រវាងព្រះរាជានិង អាទិទេពយ៉ាងប្រាកដ ។

រួមសេចក្ដីមក ចំពោះជនជាតិខ្មែរ ទួល ឬ ភ្នំ ជាទីនៅដ្ឋានរបស់អារក្សវត្ថុ មិនចំពោះតែទេវតាក្នុង តែប៉ុណ្ណោះទេ ក៏ប៉ុន្តែចំពោះទេវតាខ្មែរផងទៀតផង ។ នៅប្រទេសខ្មែរ ដែលមានភ្នំជានិមិត្តរូប គេឃើញទេវតាប្រភពក្នុង មករួមរស់ជាមួយគ្នាដោយសុខដុមរមនា ។ គឺនៅក្នុងពេលជាមួយគ្នានេះ និងដោយមានមូលហេតុដូចគ្នានេះ ដែលគេឃើញខ្មែរនាសម័យនគរភ្នំ បានសាងមានប្រាង្គប្រាសាទ ពោលគឺបូជនីយដ្ឋានដែលមានលក្ខណៈព្រហ្មញ្ញសាសនានៅលើភ្នំ ឬកំពូលភ្នំ រហូតដល់ទីណាដែលគ្មានភ្នំ ឬទួល គេក៏លើកដីឱ្យខ្ពស់ធ្វើជាជើង សម្រាប់កសាងប្រាសាទភ្នំពីលើ ។



www.elibraryofcambodia.org

មួយវិញទៀត ជាទូទៅចំពោះខ្មែរបុរាណ ព្រះរាជាដែលជាអ្នកគ្រប់គ្រងផែនដីទាំងមូល ជាអ្នកតំណាងអាទិទេព ដោយហេតុថា អំណាចរបស់ព្រះអង្គ គឺជាអំណាចផ្តាច់ដែលមានលក្ខណៈពិសិដ្ឋ ។ ក្នុងកំណត់ហេតុចិន យើងដឹងថា អំណាចរបស់ព្រះមហាក្សត្រ ឬជារាជសម្បត្តិរបស់ព្រះអង្គ ត្រូវបន្តពីព្រះបិតា ទៅរាជបុត្រ ហើយដោយសារហេតុផលនេះហើយ គេបានជួបប្រទះនូវវិបត្តិរាជវង្ស ក្នុងទំព័រប្រវត្តិសាស្ត្រនៃប្រ-ទេសកម្ពុជា ។ តែទោះបីយ៉ាងណា ក៏ប្រជារាស្ត្រអាចលើកតាំងជ្រើសរើសវីរជនណាមួយដែលខ្លួនពេញចិត្ត ដើម្បីឱ្យឡើកសោយរាជ្យ ដូចករណីខ្លះដែលបានពិពណ៌នាដោយកំណត់ហេតុចិន ។

ក្នុងព្រឹត្តិការណ៍មួយផ្សេងទៀត តាមរយៈកំណត់ហេតុចិន យើងក៏ដឹងទៀតថា ព្រះរាជាខ្មែរនាសម័យនគរភ្នំមានឋានៈជា មហារាជាធិរាជ ឬសាវិភោម ដែលជាស្តេចចក្រពត្រិ ។ ឋានៈរបស់ព្រះមហាក្សត្រខ្មែរ ក្នុងអំឡុងសតវត្សរ៍ទី១ ដល់សតវត្សរ៍ទី៦ មិនត្រូវធ្វើឡើងឱ្យយើងភ្ញាក់ផ្អើលទេ ដោយហេតុថាចក្រភពខ្មែរនាសម័យនោះ ជាការផ្សំផ្គុំនៃរដ្ឋតូចធំជាច្រើន ដែលចំណុះទៅនឹងអំណាចកណ្តាលដែលគ្រប់គ្រងដោយព្រះ ចៅអធិរាជ ។ ដោយអាស្រ័យហេតុនេះហើយ បានជាយើងឮគេនិយាយអំពីលក្ខណៈជាសាមន្តរាជ របស់អធិរាជាណាចក្រភ្នំជាញឹកញាប់ ក្នុងព្រះរាជពង្សាវតារចិន ។

អ្វីដែលអធិប្បាយខាងលើនេះ បញ្ជាក់ឱ្យយើងឃើញនូវរបបនយោបាយនិងរចនាសម្ព័ន្ធផ្នែករដ្ឋបាល របស់ប្រទេសខ្មែរនាគ្រាបឋមនៃប្រវត្តិសាស្ត្រ ។ គួរកត់សម្គាល់ថា របៀបដឹកនាំគ្រប់គ្រងសង្គមខ្មែរ នាសម័យនោះមានលក្ខណៈស្រួយ ដោយហេតុថា កាលណាអំណាចកណ្តាលខ្សោយ ដោយប្រការណាមួយពួកសាមន្តរាជតែងតែទាមទារឯករាជ្យភាពរៀង១ខ្លួនជានិច្ច ហើយការទាមទារនេះនាំមកនូវ



www.elibraryofcambodia.org

សង្គ្រាមបះបោរ រាំរែងជានិច្ចកាល ។ម្យ៉ាងទៀតអាណាចក្រចេនឡា ក៏ស្គាល់នូវករណីនេះដែរ ព្រោះថា នេះជាសារជាតិរបស់ប្រទេសកម្ពុជា ដែលជាក្សត្រប្រទេស ។

ក្នុងវិស័យរដ្ឋបាល គេឃើញមានមន្ត្រីឆ្វេង និងមន្ត្រីនៅប្របព្រះមហាក្សត្រ ។ ក្នុងសវនាការ គេឃើញមន្ត្រីឆ្វេងអង្គុយនៅខាងឆ្វេង និងមន្ត្រីស្តាំអង្គុយនៅខាងស្តាំ ។ ម្យ៉ាងទៀត ព្រះរាជាអមទៅដោយមន្ត្រីធំតូចជាច្រើនទៀតផង ។ រីឯនៅតាមអាណាខេត្តនានាវិញ គេឃើញអាជ្ញាអភិបាលខេត្ត ដែលជាអ្នកត្រួតត្រាគ្រប់គ្រង ។ មន្ត្រីទាំងនោះសុទ្ធសឹងតែជាប់សាច់ញាតិជាមួយព្រះរាជា ហើយប្រកបដោយឥទ្ធិពលយ៉ាងខ្លាំងក្លាបំផុត ។

ក៏យោគយល់ហេតុមិនបានឱ្យដឹងទៀតថា ជារៀងរាល់ព្រឹក ព្រះមហាក្សត្រខ្មែរប្រទានសវនាការ ដល់ប្រជារាស្ត្រ និងជនបរទេស ។ ពួកគេបានបេកគម្រាបមកថ្វាយស្តេចខ្មែរជានិច្ចកាល ដើម្បីសម្តែងនូវការវកិច្ច និងកតញ្ញូតាធម៌ ។ នៅពេលដែលព្រះអង្គប្រទានសវនាការម្តងៗ គេឃើញព្រះអង្គប្រថាប់ ដោយទម្លាក់ព្រះបាទឆ្វេងដល់ដីហើយបញ្ឈរព្រះបាទស្តាំ ។ នៅចំពោះមុខព្រះភក្ត្ររបស់ព្រះរាជាគេឃើញមានកម្រាលមួយផ្ទាំង ហើយនៅលើកម្រាលនោះមានភាជន៍ធ្វើអំពីមាសសុទ្ធនិងជីផុតប្រកបដោយគ្រឿងក្រអូបផ្សេងៗជាប្រពៃណីក្នុងដែលព្រះរាជាខ្មែរប្រតិបត្តិតាម ។

ម្យ៉ាងទៀតប្រភពឯកសារចិន ក៏បានបន្ថែមនូវពត៌មានមួយចំនួនទៀតដូចជាយានជំនិះរបស់ស្តេចជាដើម...។ កាលណាយាងចេញទៅក្រៅព្រះបរមរាជវាំងឬយាងចូលមកវិញ ព្រះអង្គប្រថាប់លើដំរី ។ រីឯពួកមន្ត្រីនិងស្រីស្នំក៏ដូច្នេះដែរ ។ បើតាមប្រភពឯកសារចិនដដែល ព្រះរាជាខ្មែរនាសម័យនគរភ្នំ សព្វព្រះហឫទ័យនឹងការបរបាញ់ដំរី ហើយក្នុងការបរបាញ់នេះ ព្រះអង្គអាចប្រើពេលច្រើនថ្ងៃ ឬ ច្រើនខែ ។ តាមពិតការបរបាញ់នេះបញ្ជាក់នូវលក្ខណៈពិសិដ្ឋរបស់របបរាជាធិបតេយ្យខ្មែរ ។ សូមរំលឹក



www.elibraryofcambodia.org

ឡើងវិញថា ពាក្យ វ្យាធបុរៈ ដែលជាឈ្មោះរបស់ព្រះរាជធានីខ្មែរមួយដំបូងបង្អស់ មានន័យថាទីក្រុងរបស់អ្នកទាក់ដំរី ។ នៅទីបញ្ចប់សូមជម្រាបថា ការបរបាញ់ដំរីស្ទាត់ជំនាញនេះ បានធ្វើឱ្យព្រះកិត្តិនាម និងកេរ្តិ៍ឈ្មោះរបស់ព្រះរាជាខ្មែរ ល្បីរន្ទឺទូទាំងប្រទេស ហើយធ្វើឱ្យប្រជានុរាស្ត្រកោតសរសើរក្រៃលែង ។

## ចំពោះ ទីក្រុងរបស់នគរភ្នំ

តាមទស្សនៈរបស់លោកសាស្ត្រាចារ្យ ហ្សក សឺដេស ( ១៩៦៨ ) ទីក្រុងអង្គរបូរី អាចថាជាទីក្រុងរបស់ព្រះបាទ រុទ្រវម៌្ម ដែលជាស្តេចចុងក្រោយបង្អស់របស់នគរភ្នំ នាសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ដែលមានកំពង់ផែអន្តរជាតិសមុទ្រមួយគឺអូរកែវ លាតសន្ធឹងទៅទិសអគ្នេយ៍ ក្នុងទឹកដីខ្មែរកម្ពុជាក្រោម ដែលបានក្លាយទៅជាស្រុកវៀតណាមខាងត្បូង ។ តែតាមពិត នេះជាទីក្រុងមួយក្នុងចំណោមទីក្រុងជាច្រើន នៃចក្រភពនគរភ្នំ ។ ដោយសារកំហេតុហេតុមិនបានឱ្យដឹងថាយ៉ាងដូចម្តេចហោស់ ក៏មានទីក្រុងចំនួន ១២ ទៀត ហើយមានប្រឡាយទឹកមិនតិចជាង ២០០ គីឡូម៉ែត្រ ដែលស្ថិតក្នុងបរិវេណនៃព្រះអធិរាជាណាចក្រភ្នំ ។

ម្យ៉ាងទៀតទីក្រុងអង្គរបូរីនេះ ត្រូវស្ថាបនាឡើងនៅដើមសម័យប្រវត្តិសាស្ត្រ ពោលគឺសតវត្សរ៍ទី១ និងទី២ នៃគ្រិស្តសករាជ បើយើងសំអាងទៅលើបដិមាសាស្ត្រ និងកាក់រូបម៉ាំង ដែលគេបានរកឃើញថ្មីៗនេះ ។

ពប្បីរំលឹកនៅទីនេះដែរ តាមការស្រាវជ្រាវរបស់អ្នកបុរាណវិទូថៃ យើងក៏រកឃើញសន្និដ្ឋានថា ឥទ្ធិពលវប្បធម៌របស់នគរភ្នំ បានលាតសន្ធឹងរហូតដល់ទីក្រុងស្រេស្ឋបុរៈ នៅចម្ប៉ាសាក់ ( លាវ ) និង នៅឥសានបូរី ព្រមទាំងស្រីទេព ដែលស្ថិតនៅក្នុងពេជ្របុរីន និងនៅខេត្ត អ៊ូបនសុត្តថ្ងៃនេះ ។ បុរាណស្ថាននិងបដិមាសាស្ត្រ


www.elibraryofcambodia.org

ជាច្រើនដែលគេបានរកឃើញក្នុងទីក្រុងខាងលើនេះ  ក៏អាចធ្វើឱ្យយើងជឿជាក់ថា បុរីនេះត្រូវ បានចាប់បដិសន្ធិឡើង រវាងសតវត្សរ៍ទី ៥-៦ នៃគ្រិស្តសករាជ ហើយម្យ៉ាងទៀត ទីតាំងបុរាណនេះក៏ជាផ្នែកមួយនៃព្រះអធិរាជាណាចក្រភ្នំដែរ ។

## ការអប់រំសិក្សា

បើនិយាយអំពីស្ថានភាពនៃការស្រាវជ្រាវសព្វថ្ងៃ  យើងពុំអាចនិយាយអំពីវិស័យអប់រំសិក្សានាសម័យនគរភ្នំ ដោយលំអិតបានទេ ។ ការស្រាវជ្រាវកំពុងត្រូវបានបន្ត ។ ដូច្នេះហើយ អ្វីដែលយើងអធិប្បាយនៅខាងក្រោមនេះ ត្រូវពឹងផ្អែកទៅលើបុរាណវត្ថុមួយចំនួនតូច ដែលយើងបានជួបប្រទះតែប៉ុណ្ណោះ ។

តើអ្វីទៅដែលគេហៅថា ការអប់រំ សិក្សា ហើយតើការអប់រំសិក្សានាសម័យនោះ បានធ្វើឡើងដោយអ្នកណា ? នេះជាបញ្ហាចម្បងដែលយើងត្រូវតែដោះស្រាយ ។

ថ្មីៗនេះ អ្នកស្រុកបានជីករកឃើញនូវ បំណែកនៃផ្ទាំងរូបចម្លាក់មួយធំធ្វើអំពីថ្ម ហើយផ្ទាំងរូបនេះ ត្រូវបានយកមកតាំងក្នុងសារមន្ទីរ ស្រុកអង្គរបុរី ព្រមទាំង សិលាចារឹក និងវត្ថុបុរាណមួយចំនួនទៀត ។

ការពិនិត្យយ៉ាងហ្មត់ចត់ នូវរូបដែលឆ្លាក់នៅលើផ្ទាំងថ្មបុរាណនេះ បញ្ជាក់ឱ្យដឹងថា រូបមនុស្សដែលត្រូវគេឆ្លាក់ឡើងទាំងប៉ុន្មាននោះ គឺជារូបរបស់ពួកព្រាហ្មណ៍បុរោហិត ដែលជាបណ្ឌិតផ្នែកពិធីការកើតសាសនា និងខាងអប់រំក្នុងព្រហ្មញ្ញសាសនា ។

សូមជម្រាបថា  ពួកព្រាហ្មណ៍  បុរោហិត  ក្នុងសង្គមខ្មែរ  ជាពិសេសនៅក្នុងសម័យចេនឡា និងអង្គរវត្ត  បានបំពេញនូវនាទីយ៉ាងសំខាន់បំផុតក្នុងព្រះបរមរាជវាំង បើយើងសំអាងលើប្រភពសិលាចារឹក  ហើយតួនាទីចម្បងរបស់ពួកគេក៏ត្រូវបានរក្សាទុកដល់សព្វថ្ងៃ  ក្នុងព្រះរាជាណាចក្រខ្មែរបច្ចុប្បន្ន ដូចជាពិធីច្រត់ព្រះនង្គ័ល  កោរសក់


www.elibraryofcambodia.org

ជុំក ព្រះរាជអភិសេក ។ល។

សូមរំលឹកឡើងវិញថា បើគ្មានក្បួនខ្នាត គ្មានការបង្ហាត់បង្រៀន ឬការអប់រំ ម្ល៉េះប្រពៃណីជាតិមួយចំនួន ដែលមានតាំងពីសម័យបុរាណ ពុំអាចបន្តវេនរហូតដល់សព្វថ្ងៃទេ ។ បើនិយាយម្យ៉ាងទៀត ការផ្ទេរនូវចំណេះដឹង ឬចំណេះវិជ្ជាពីសម័យមួយទៅសម័យមួយទៀត ត្រូវធ្វើឡើងតាមរយៈការអប់រំ ។ នេះជាសេចក្តីសន្និដ្ឋានទីមួយរបស់យើង មិនតែចំពោះព្រហ្មញ្ញសាសនា ឬព្រះពុទ្ធសាសនាទេក៏ប៉ុន្តែចំពោះវិស័យផ្សេងៗឯទៀតដែរ ដូចជាផ្នែកស្ថាបត្យកម្មជាដើម ។

យើងមានវត្ថុតាងដ៏សំខាន់ទៀត គឺវត្តមានរបស់អាស្រម ព្រោះថាការអប់រំបង្ហាត់បង្រៀន ក្បួនតម្រា គម្ពីរ យុទ្ធគជា និងទេវកថានានា គ្រប់ប្រភេទបានត្រូវអនុវត្តន៍នៅទីនោះ ដោយពួកព្រាហ្មណ៍ដែលភាគច្រើន ជាបណ្ឌិត អ្នកប្រាជ្ញខាងសាសនា អក្សរសាស្ត្រ និងវិទ្យាសាស្ត្រផ្សេងៗ ដូចជា ក្បួនតែងកាព្យឃ្លោង, តារាសាស្ត្រ ហោរាសាស្ត្រ ។ល។ ជាការពិតហោស់ តាមការស្រាវជ្រាវរបស់លោក អាដេមារ ឡឺក្លែរ នាសតវត្សរ៍មុន យើងបានដឹងថា ច្បាប់ក្រិត្យក្រមខ្មែរគ្រប់គ្រងរដ្ឋមួយចំនួនធំ ដូចជា វិស័យតុលាការជាដើម បានកើតចេញពីច្បាប់ព្រហ្មញ្ញសាសនាទាំងអស់ ដែលបានហូរចូលស្រុកខ្មែរ នាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ។

គឺដោយសារការអប់រំ បង្ហាត់បង្រៀន នៃពួកព្រាហ្មណ៍ទាំងអស់នេះហើយ ដែលជាគ្រូប្រកបដោយការចេះដឹងជ្រៅជ្រះ ទើបភាសា និងអក្សរខ្មែរត្រូវបានថែរក្សាកោរជីវិតរស់រវើក មិនរលត់សាបសូន្យ ពីសម័យមួយទៅសម័យមួយទៀត ។

សរុបមក ការសិក្សាអប់រំមានតួនាទីយ៉ាងសំខាន់បំផុត ក្នុងសង្គមខ្មែរបុរាណ ហើយប្រហែលជាដោយមូលហេតុនេះហើយ បានជាជនជាតិឥណ្ឌា បាននិយាយអំពីវត្ត [illegible] ឬ ឃ្លាំង សម្រាប់ផ្ទុកឯកសារសរសេរនានា ដែលគេហៅថា ផ្គត់ ក្នុង



www.elibraryofcambodia.org

ក្រុងភ្នំសម្រាប់មូលហេតុចម្បង ដូចដែលបានពោលរួចមកហើយ ។

ដូចនេះការដែលអ្នកស្រាវជ្រាវ សង្កត់ទម្ងន់ទៅលើតួនាទីអប់រំនៃអាស្រម នានា ដូចជា អាស្រមមហាឫសី នៅស្រុកអង្គរបុរី ខេត្តតាកែវជាដើម ជាការសមហេតុផលយ៉ាងប្រាកដ ។

## ការបង់ពន្ធដារ

បញ្ហាពន្ធដារនៅអាណាចក្រភ្នំ ដែលជនជាតិចិន បានលើកយកមកនិយាយ ឆ្លុះបញ្ចាំងឱ្យយើងដឹងអំពី ការគ្រប់គ្រងរៀបចំសង្គមខ្មែរបុរាណ ។ កាលសម័យបុរាណ ប្រជាពលរដ្ឋបង់ពន្ធជាមាស ប្រាក់ ត្បូង គុជ គ្រឿងក្រអូប និងវត្ថុមានតម្លៃផ្សេងៗ ។

ជាការពិតណាស់ ការបង់ពន្ធជាវត្ថុមានតម្លៃខាងលើនេះ អាចផ្ដល់នូវលទ្ធភាព ចំពោះរាជការ[illegible]អំពីសកម្មភាពសង្គមនានាដូចជាការឧបត្ថម្ភបូជនីយដ្ឋាន [illegible] ម្យ៉ាងទៀតការយកពន្ធដាទៅលើទំនិញនានាជាកិច្ច[illegible]នៅក្នុងសង្គម ដោយហេតុថា បើគ្មានពន្ធដារទេ ពិតជា[illegible]

[illegible]

ការធ្វើភាជន៍ បានស្គាល់នូវកម្រិតវឌ្ឍនភាពខ្ពស់កប់កំពូល ដូចជាវត្ថុមានរបស់ក្រឡ ឆ្នាំង ចាន ចង្កៀងរាប់ពាន់ សែន ដែលស្ថិតក្នុងបរិវេណនៃទីក្រុងអង្គរបុរីជាសក្ខីភាពស្រាប់ ។ ក្នុងការធ្វើភាជន៍ ជនជាតិខ្មែរបានប្រើឧបករណ៍ដូចសម័យបុរេប្រវត្តិសាស្ត្រ ក៏ប៉ុន្តែទទឹមនឹងនេះ គេឃើញមានវត្ថុមានរបស់ក្រឡ ចាន ឆ្នាំង ក្អម មួយចំនួន ដែលមានលក្ខណៈជាក្បូរ្ត ហើយដែលយើងពុំបានពើបប្រទះពីមុនឡើយក្នុងសហគមន៍ខ្មែរ ។



www.elibraryofcambodia.org

នៅទីនេះ យើងគ្រាន់តែសូមបង្ហាញបញ្ជាក់ នូវតួនាទីរបស់ភាជន៍មួយចំនួន ដែលគេធ្វើសម្រាប់ពិធីបូជាសព ពោលគឺពុំមែនសម្រាប់ប្រើប្រាស់ដាក់ម្ហូបអាហារឡើយ ។ ក៏ប៉ុន្តែទោះយ៉ាងណាក៏ដោយ ក៏យើងនៅតែពុំដឹងច្បាស់នៅឡើយទេថា តើភាជន៍ខ្លះដែលមានទម្រង់ក្លិង្គ ត្រូវបានគេនាំចូលពីស្រុកក្លិង្គ ឬផលិតនៅទីឯកន្លែងផ្ទាល់តែម្តង ។ បើនិយាយឱ្យចំទៅ អ្វីដែលយើងចង់និយាយនៅទីនេះ គឺពិធីកប់សពក្នុងក្រឡ ដែលយើងបានជួបប្រទះជាញឹកញាប់ក្នុងស្ថានីយ៍អង្គរបូរី ។

មុនដំបូងបង្អស់ យើងត្រូវដឹងថា វប្បធម៌នាសម័យនគរភ្នំ ជាវប្បធម៌សំយោគ ព្រោះថាជាសម័យកាលមួយ ដែលយើងអាចចាត់ទុកថា ជាសម័យបដិវត្តន៍ផ្នែកមនោគមវិជ្ជា និងសាសនា ។ គឺក្នុងករណីនេះហើយ ដែលសំណង់វប្បធម៌ដើមរបស់ខ្មែរត្រូវផ្លាស់ប្តូរខ្នាត ឬទម្រង់ ហើយការផ្លាស់ប្តូរផ្នែកវប្បធម៌នេះ បានធ្វើឡើងយ៉ាងសន្សឹមៗសមស្របតាមចំណូលចិត្ត និងសេចក្តីត្រូវការរបស់ខ្មែរ ពោលគឺពុំមែនដោយការបង្ខំណាមួយទេ ។

រួមសេចក្តីមក ថ្វីត្បិតតែវប្បធម៌សម័យនគរភ្នំ ជាការបន្តនៃខឿនវប្បធម៌នាសម័យបុរេប្រវត្តិសាស្ត្រក៏ដោយ ក៏ប៉ុន្តែសម័យនេះ គឺជាសម័យបដិវត្តក្នុងវិស័យជំនឿសាសនាយ៉ាងប្រាកដ ដោយហេតុថា ជនជាតិខ្មែរដែលទើបតែនិយមប្រតិបត្តិ នូវមនោគមវិជ្ជាសាសនាក្លិង្គ ចាប់ផ្តើមនិយមប្រតិបត្តិពិធីបូជាសពដោយភ្លើង ហើយបន្តិចម្តងៗទម្លាប់នេះ បានត្រូវគេអនុវត្តន៍ជាទូទៅទូទាំងប្រទេសដែលបានត្រូវជ្រួតជ្រាបដោយឥទ្ធិពលវប្បធម៌ក្លិង្គ ។

ជាការពិតណាស់ ដែលខ្មែរយើងបាននិយមពិធីបូជាសពបែបនេះ តាំងតែសម័យបុរេប្រវត្តិសាស្ត្រម្ល៉េះ ហើយម្យ៉ាងទៀត ការបូជាសពដោយភ្លើង គឺជាភស្តុតាងបញ្ជាក់ឲ្យឃើញថា ខ្មែរនាសម័យនោះចេះគោរព សក្ការៈបុព្វបុរសរបស់ខ្លួនរួចមក



www.elibraryofcambodia.org

ហើយ ។ ឧទាហរណ៍ជាក់ស្តែងមួយ គឺគេបានរកឃើញនៅស្រុកសង្កះខេត្តសុរិន្ទ្រ នូវក្រឡដីដុតជាច្រើនផ្ទុកដោយផេះ និងកំទេចឆ្អឹងជាសំណល់របស់ដែលគេបានបូជាសពដោយភ្លើង ។

អ្វីដែលបានពោលខាងលើនេះ អាចជួយយើងឱ្យយល់ដល់តួនាទីរបស់ក្រឡឆ្នាំងមួយចំនួនធំ ដែលឥតមានរន្ធ ឬមានរន្ធតូចមួយចោះនៅខាងក្រោយតួថ ឬចំហៀង ។ រួមសេចក្តីមក គឺដោយសារខ្មែរយើងបានចូលសាសនាក្លិង្គនាសម័យនោះ ហើយការចូលសាសនាក្លិង្គ គឺជាការវិវត្តទំនៀមទម្លាប់របស់សង្គម បានជាគេជួបប្រទះនៅស្ថានីយ៍អង្គរបុរី និងនៅតំបន់នានាជុំវិញរាជធានីបុរាណនេះ នូវក្រឡ ឆ្នាំង ដែលមានចំនួនលើសលប់រាប់មិនអស់ ។ កត្តានេះក៏បញ្ជាក់ឱ្យឃើញនូវការដុះដាល ឬភាពរុងរឿងនៃសាសនាក្លិង្គ ក្នុងសង្គមខ្មែរបុរាណ ។

គប្បីរំលឹកឡើងវិញថា ការធ្វើភាជន៍នៅតែរស់រវើក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចជានៅខេត្តកំពង់ឆ្នាំង និង តាកែវ ជាដើម ទាំងនេះបញ្ជាក់នូវនិរន្តរភាពនៃប្រពៃណីធ្វើធាន ឆ្នាំង របស់ខ្មែរ ដែលជាសមិទ្ធិផលមួយមានអាយុរាប់ពាន់ឆ្នាំមកហើយ ។

## ពពួកសត្វស្រុក និងព្រៃ

តាមរូបដែលគេឆ្លាក់លើបន្ទោងខ្សែក ធ្វើអំពីកែវស្ល និងចម្លាក់ដីដុតនៃស្ថានីយ៍អង្គរបុរី យើងអាចសង្កេតឃើញនូវសត្វមួយចំនួន ដែលរស់នៅតាមព្រៃឬក្នុងស្រុកភូមិ ដូចជាប្រើស រមាស ខ្លា គោ ក្របី ឆ្កែ ឆ្មា ស្វា សណ្តុរ សេះ ដំរីនិងទន្សាយជាដើម ។

រីឯសត្វស្លាបវិញ យើងបានឃើញសត្វគ្រុច ក្ងោក មាន់ និង មេអំបៅ ។



www.elibraryofcambodia.org

ចំណែកសត្វដែលរស់នៅក្នុងទឹកសាបមាន ត្រី កង្កែប ហ៊ីង អណ្ដើក កន្ធាយ ពស់ ។ វត្ថុមានរបស់សំបកខ្យងសមុទ្រ ឆ្អឹងត្រីបបែល និងរូបចម្លាក់មឹកជាភស្តុតាង នៃទំនាក់ទំនងផ្នែកពាណិជ្ជកម្មរវាងអង្គរបុរី និងតំបន់ឆ្នេរសមុទ្រសៀមសព្វថ្ងៃ ។

សារៈសំខាន់របស់វត្ថុបុរាណទាំងឡាយខាងលើនេះ អាចធ្វើឱ្យយើងស្គាល់នូវបរិស្ថាន ដែលខ្មែរនាសម័យភ្នំរស់នៅប្រចាំថ្ងៃយ៉ាងប្រាកដ ។ យ៉ាងណាមិញវត្ថុបុរាណទាំងនោះ ក៏អាចឱ្យយើងដឹងនូវប្រភេទសត្វ ដែលជនជាតិខ្មែរយើងទទួលទានជាម្ហូបអាហារ ។

## វិស័យនយោបាយក្រៅប្រទេស

តាមរយៈវត្ថុបុរាណ ដូចជា កាក់ ផ្ដាំ ចង្កៀង បដិមាករ និងកំណត់ហេតុចិន យើងអាចសន្និដ្ឋានថា នគរភ្នំបានមានស្ពានមេត្រីជាមួយប្រទេសឥណ្ឌា ចិន និងជាពិសេសចក្រភពរ៉ូម៉ាំង ។ ទំនាក់ទំនងទាំងនេះ ត្រូវបានធ្វើឡើងយ៉ាងសកម្មតាមរយៈផ្លូវទូត និងពាណិជ្ជកម្មផង តែក្រោយមកមានការរអាក់រអួល ចាប់តាំងពីចុងសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ដែលជាហេតុធ្វើឱ្យសេដ្ឋកិច្ចរបស់នគរភ្នំ ធ្លាក់ក្នុងភាពវិនាសអន្តរាយ ។ ការសន្និដ្ឋាននេះ ពឹងផ្អែកទៅលើភាពចុះទន់ខ្សោយនៃអំណាចកណ្ដាលរបស់នគរភ្នំ ដែលប្រឈមមុខនឹងការងើបបះបោររបស់ ចេនឡា ហើយបន្តិចម្ដង១បានគាបសង្កត់ និងនៅទីបញ្ចប់បានបំបែកចក្រភពភ្នំតែម្ដង ។

## វិស័យសេដ្ឋកិច្ច

ថ្វីត្បិតតែពាណិជ្ជកម្មក្រៅប្រទេស និងក្នុងប្រទេស ជាប្រភពនៃវឌ្ឍនភាពរបស់នគរភ្នំក៏ដោយ ក៏ប៉ុន្តែយើងមិនត្រូវបំភ្លេចនូវកសិកម្ម ដែលជាវិស័យសំខាន់បំផុតដែរនៃវិស័យសេដ្ឋកិច្ច ។



www.elibraryofcambodia.org

វឌ្ឍនភាពនិងវិបុលភាពនៃនគរភ្នំ អាចមានឡើងក៏ដោយសារនយោបាយទឹកនាសម័យនោះដែរ ដែលគេអាចឃើញនៅក្នុងស្រុកអង្គរបូរី ក្នុងមុំដែនដីសណ្តនៅកម្ពុជាក្រោម និងនៅតាមឆ្នេរសមុទ្រសៀមសព្វថ្ងៃនេះ ។ សូមជម្រាបថារូបភាពដែលគេថតនៅលើអាកាស បង្ហាញឱ្យដឹងថា មានប្រព័ន្ធទឹកខ្វាត់ខ្វែងនាសម័យបុរាណ ដែលមានរហូតដល់សព្វថ្ងៃនេះ ។

ក្នុងដែនដីសណ្ត គេឃើញមានវត្តមានរបស់ព្រែកជាច្រើន ដែលជនជាតិខ្មែរនាសម័យ នគរភ្នំ និងចេនឡា បានជីកបង្ហូរទឹកនៃទន្លេមេគង្គ ឱ្យបន្សាបទឹកប្រៃដែលបានជ្រួតជ្រាបក្នុងតំបន់ ប្រយោជន៍នឹងធ្វើស្រែចំការ ។ ម្យ៉ាងទៀតបណ្តាញព្រែកទាំងនោះ ក៏បានផ្តល់នូវភាពងាយស្រួលក្នុងការធ្វើដំណើរ តាមទូកនិងសំពៅ តូច ធំ ទាំងឡាយ ក្នុងភូមិភាគនេះ ។

ចំពោះសកម្មភាពសេដ្ឋកិច្ចដ៏មហាថ្កុំថ្កើង ប្រភពឯកសារចិនបានឱ្យដឹងថា នាសម័យនោះគេច្រូតស្រូវបានបីដងក្នុងមួយឆ្នាំ ។ រីឯប្រភពសិលាចារឹកវិញ មានការរាយការណ៍អំពីដើមឈើខ្លះៗដូចជា ទទឹម អំពៅ ស្វា គ្រូច ដូង ត្នោត ខ្នុរ ។ល។

សេចក្តីសន្និដ្ឋានខាងលើនេះ បង្ហាញឱ្យយើងដឹងនូវភាពរុងរឿង អស្ចារ្យនៃអាណាចក្រភ្នំ ដែលជាមូលដ្ឋាននៃសង្គមខ្មែរ នាសម័យបុរាណ ។

## ការកាត់ទោស

នាគ្រាបឋមនៃប្រវត្តិសាស្ត្ររបស់នគរភ្នំ គេអាចសម្គាល់ថា គេពុំទាន់មានវិធានការតឹងរ៉ឹងចំពោះអ្នកទោសនៅឡើយទេ ហើយទំនៀមទម្លាប់នាសម័យនោះទាំងអស់ មានលក្ខណៈស្រដៀងនឹងពួកកុលសម្ព័ន្ធខ្មែរលើ ជាពិសេសក្នុងវិស័យពិន័យ ។

ឯកសារចិនបានឱ្យដឹងថា នាសម័យនោះគេមិនមានគុកសម្រាប់ដាក់ជនជាប់



www.elibraryofcambodia.org

ពិរុទ្ធទេ ។ ចំពោះអ្នកមានទោសស្រាល គេគ្រាន់តែដាក់វិន័យបន្តិចបន្តួចតែប៉ុណ្ណោះ ក៏ប៉ុន្តែសម្រាប់ជនដែលមានទោសធ្ងន់វិញ គេយកជនទាំងនោះឱ្យក្រពើ ឬសត្វព្រៃស៊ីតែម្តង ។ ម្យ៉ាងទៀតបើបីថ្ងៃក្រោយសត្វសាហាវមិនស៊ីទេ គេនឹងដោះលែងអ្នកទោសទាំងអស់នោះ ។ ការដាក់ទោសុបោកម្មបែបនេះ បង្ហាញឱ្យយើងឃើញយល់អំពីប្រព័ន្ធតុលាការនាសម័យបុរាណ ដែលជាមូលដ្ឋាននៃសីលធម៌ខ្មែរនាសម័យនោះ ។

## គ្រឿងភ្លេងស្គរ

សិលាចារឹកជាច្រើន បានបង្ហាញឱ្យឃើញថា ព្រះរាជាអ្នកការពារសាសនា និងរក្សាគ្រប់គ្រងប្រាសាទ តូច ធំ ទាំងឡាយ ។ ក្នុងវិស័យសាសនាព្រះមហាក្សត្របំពេញជានិច្ចកាលនូវពិធីសក្ការៈបូជាផ្សេងៗចំពោះទេវតា ព្រមទាំងធ្វើឱ្យប្រទេសជាតិមានសេរីភាពនយោបាយ ។

ដូច្នេះហើយ ក្នុងអត្ថបទសិលាចារឹក K.៦០០ គេឃើញមានការអធិប្បាយអំពីគ្រឿងភ្លេងដែលគេប្រើនាសម័យនោះ ។

ដោយមានឯកសារមិនទាន់គ្រប់គ្រាន់នៅឡើយ យើងពុំអាចរៀបរាប់ឱ្យបានពិស្តារ នូវគ្រឿងឧបករណ៍ភ្លេងទាំងអស់ទេ ។ ថ្មីៗនេះនៅពេលដែលគេជីកយកវត្ថុបុរាណដោយខុសច្បាប់ ក្នុងក្រុមប្រាង្គប្រាសាទឥដ្ឋ នៅភូមិកំពង់ពោធិ គេបានរកឃើញនូវជួងនិងកណ្តឹងសំរឹទ្ធជាច្រើន ។ ក្រៅពីនេះគេបានរកឃើញមានស្គរ មានឆ្លាក់រូបអ្នកដេញចាប៉ីដងវែង ជាពិសេស នៅក្នុងភូមិភាគដែនដីសណ្តនៃកម្ពុជាក្រោម ។

សូមជម្រាបថា ចំពោះប្រភពនៃពាក្យចាប៉ី ពាក្យនេះ គឺជាពាក្យដែលកើតចេញពីភាសាសំស្ក្រឹតសុទ្ធសាធ ។

ម្យ៉ាងទៀត គេសង្កេតឃើញមានការថ្វាយតង្វាយជាវង់ភ្លេង ចំពោះព្រះចៅ



www.elibraryofcambodia.org

ក្រុងចិនដោយមានអ្នកភ្លេងជាមួយផង ពីសំណាក់ស្ដេចនគរភ្នំ ។

## ទំនាក់ទំនង ផ្នែកវប្បធម៌រវាងតំបន់នានា

បុព្វហេតុដែលនាំឱ្យមានការទាក់ទង រវាងខ្ពង់រាប និងវាលទំនាប ឬពីតំបន់មួយទៅតំបន់មួយទៀត គឺបណ្ដាលមកពីពាណិជ្ជកម្ម នូវវត្ថុធាតុដើមមួយចំនួន ដែលជាសេចក្ដីត្រូវការរបស់សង្គមមនុស្ស ។ ដូច្នេះ គេមិនត្រឹមតែត្រូវការវត្ថុមកពីក្លិង្គទេ គេត្រូវការនូវវត្ថុធាតុដើមដែលមានក្នុងស្រុកផងដែរ ថ្វីត្បិតតែវត្ថុធាតុទាំងនោះស្ថិតនៅឆ្ងាយដាច់ស្រយាលយ៉ាងណាក៏ដោយ ។ ប្រការនេះជាឫសគល់នៃការរីកចំរើនដុះដាលនៃវប្បធម៌ ឥណ្ឌូ-ខ្មែរ ដែលថ្មីៗនេះយើងបានឃើញស្លាកស្នាមយ៉ាងច្រើនលើសលុបនៅខេត្តសៀមរាប (ប្រាសាទព្រៃក្មេង) និងនៅខេត្តបន្ទាយមានជ័យ (ស្ថានីយ៍ភូមិស្នាយ) ។

គេសង្កេតឃើញថា ក្នុងសម័យនោះ ការផ្សព្វផ្សាយនៃព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា បានចូលមកដល់តំបន់ដីជ្រៅ ដូចជានៅម្ដុំវត្តភូ និងស្រីទេពជាហេតុបណ្ដាលឱ្យមានការកសាងរាជធានី ក្នុងភូមិភាគនេះ ហើយក្នុងសង្គមខ្មែរមានការបែងចែកជាវណ្ណៈ ថ្វីត្បិតតែគ្មានភាពតឹងរ៉ឹងដូចទៅប្រទេសក្លិង្គក៏ដោយ ។ ឯរចនាសម្ព័ន្ធថ្មីដូចជាផ្នែករដ្ឋបាល ដែលដឹកនាំដោយក្រុមជំនាញការផ្សេងៗ ក៏កើតឡើងដែរ គឺមនុស្សទាំងនោះស្ថិតនៅក្រោមការដឹកនាំរបស់មេខ្លួន ។

ក្នុងអំឡុងសតវត្សរ៍ទី៦ នៃ គ្រិស្តសករាជ នគរភ្នំដែលមានអំណាចយ៉ាងខ្លាំងក្លាបំផុត បានជះឥទ្ធិពលវប្បធម៌របស់ខ្លួន ក្រោយពីបានត្រួតត្រាតំបន់មួយភាគធំ នៃភូមិភាគកណ្ដាលនៃឥណ្ឌូចិនយើងនេះ ដែលក្នុងនោះ គេឃើញក្រៅពីតំបន់នានាក្នុងឈូងសមុទ្រសៀមសព្វថ្ងៃ និងស្ថិតមិនឆ្ងាយពីនោះ ដូចជាខេត្ត ល្ពោ សុផាន់បុរី (សុវណ្ណបុរី) ច័ន្ទបុរី ជលបុរី អ៊ូថង ពេជ ប៊ុន នគររាជសីមា សុរិន្ទ្រ អ៊ូបុន និង តំបន់វត្តភូ



www.elibraryofcambodia.org

ជាដើម ។ កំប៉ុន្តែចាប់តាំងពីសតវត្សរ៍ទី៧ ឥទ្ធិពលរបស់នគរភ្នំត្រូវចុះទន់ខ្សោយ ហើយត្រូវបានស្ថិតក្រោមឥទ្ធិពលរបស់ចេនឡា យ៉ាងប្រាកដ ។រីឯនៅស្រុកខ្មែរវិញ គេឃើញមានខេត្ត ព្រៃវែង ស្វាយរៀង តាកែវ, កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម និង កំពង់ធំ ដែលស្ថិតនៅក្រោមអានុភាពរបស់នគរភ្នំ ។ យើងដឹងពីការផ្សព្វផ្សាយវប្បធម៌ នគរភ្នំ តាមរយៈស្ថាបត្យកម្មបុរាណ ដោយហេតុថា ក្នុងសម័យកាលនោះមានការផ្សំគ្នារវាង សិល្បៈខ្មែរ និងសិល្បៈក្លិង្គ ហើយបានបង្កើតនូវរចនាបថភ្នំដា ( ៥៤០-៦០០ នៃ គ.ស ) ដែលជារចនាបថមួយស្ថិតក្នុង សម័យកាលនគរភ្នំ ។ នៅដើមសតវត្សរ៍ទី៧ ពោលគឺនៅសម័យចេនឡា ទើបយើងឃើញមានវត្តមានរបស់ប្រាង្គប្រាសាទឥដ្ឋ ក្នុងរចនាបថសម្បូរព៌ព្រៃគុក ព្រៃក្មេង និងកំពង់ព្រះ ជាក់លាក់ គឺនៅរវាងឆ្នាំ ៦១៥ ដល់ ៨០០ នៃគ្រិស្តសករាជ ។

ដោយមានការជ្រោមជ្រែង បង្រួបបង្រួមអាណាខេត្តនានា ដោយព្រះមហាក្សត្រខ្មែរនាសម័យបុរាណដូចជា ខ្លឹមសារនៃអត្ថបទសិលាចារឹកជាច្រើន ជាសក្ខីកម្មស្រាប់ វប្បធម៌នាសម័យនគរភ្នំ និង ចេនឡា មានការលូតលាស់ជាខ្លាំង ហើយចំពោះឥទ្ធិពលនៃវប្បធម៌ក្លិង្គនេះ គេក៏អាចធ្វើតាមវត្ថុបុរាណ ដូចជា ទេវរូប ពុទ្ធរូប គ្រឿងតុបតែងប្រាសាទ គ្រឿងអលង្ការ និងបូជនីយដ្ឋានមួយចំនួន ។

ឯកសារស្តីអំពីវត្តមានរបស់អ្នករាំ នាសម័យនគរភ្នំ មានពីរប្រភេទគឺរូបចម្លាក់ និង សិលាចារឹក ។ សូមជម្រាបថា សម្រាប់ខ្មែរនាសម័យបុរាណរបាំជាពិធី មួយដែលមានតួនាទីយ៉ាងសំខាន់បំផុត ក្នុងសង្គមខ្មែរបុរាណ ដោយហេតុថារបាំជាតង្វាយបូជាពិសិដ្ឋ ដែលព្រះរាជាខ្មែរថ្វាយចំពោះ ព្រះអាទិទេពនៃព្រហ្មញ្ញសាសនា ដើម្បីសេចក្តីសុខចំរើនរបស់ប្រទេសជាតិ ឬស្រុកភូមិ ។ ម្យ៉ាងទៀតតង្វាយជារបាំចំពោះទេវតាតាមរយៈបូជនីយដ្ឋាន ដូចជាប្រាង្គប្រាសាទនានា ត្រូវបានគេកត់សម្គាល់ឃើញ



www.elibraryofcambodia.org

យ៉ាងច្រើន ក្នុងផ្ទាំងសិលាចារឹក ដូចជាសិលាចារឹក K.៦០០. K.៥១ ជាដើម ដែលត្រូវចារឡើងនាសតវត្សរ៍ទី៦ និងទី៧ នៃគ្រិស្តសករាជ ។ តាមពិតវត្តមានរបស់ក្រុមអ្នករាំ អ្នកច្រៀង និងអ្នកលេងភ្លេងជាប្រពៃណីដែលខ្មែរយើងរក្សារហូតដល់សព្វថ្ងៃក្នុងសង្គម ។

រីឯប្រភពឯកសារដែលទាក់ទងនឹងតន្ត្រី នាសម័យនគរភ្នំវិញ គេឃើញមានរូបចម្លាក់អ្នករាំ និងអ្នកដេញចាប៉ីលើបន្ទះដីដុតនិងលើសន្ទឹកមាសស្តើងៗមួយចំនួន ក៏ប៉ុន្តែនាគ្រាបរមនៃប្រវត្តិសាស្ត្រខ្មែរនោះ ទាំងលក្ខណៈរបាំ ទាំងលក្ខណៈឧបករណ៍មានទម្រង់ជាក់ស្តែង ។ ទាំងនេះបញ្ជាក់នូវឥទ្ធិពលដ៏ខ្លាំងក្លា របស់វប្បធម៌ខ្មែរនាសម័យបុរាណ ។

## ភាសា

ភាសារបស់ប្រជាជនជាតិខ្មែរគ្រប់អជ្ឈដ្ឋាន នាសម័យប្រវត្តិសាស្ត្រប្រើប្រាស់គឺភាសាដែលស្ថិតនៅក្នុងអំបូរភាសាមន-ខ្មែរ ហើយភាសានេះគោត ក៏បានត្រូវបង្កើតឡើងនាសម័យបុរេប្រវត្តិសាស្ត្រ ពោលគឺមុនការប្រាស្រ័យទាក់ទងជាមួយជនជាតិឥណ្ឌា ។

ថ្វីត្បិតតែពលរដ្ឋខ្មែរនាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ បានខ្ចីតួអក្សរក្លិង្គដើម្បីយកមកកត់ត្រា នូវព្រឹត្តិការណ៍ផ្សេងៗប្រចាំជាតិរបស់ខ្លួនក៏ដោយ ក៏ប៉ុន្តែរហូតដល់សព្វថ្ងៃនេះ យើងពុំទាន់ឃើញមានភស្តុតាងណាមួយ យ៉ាងច្បាស់លាស់នៅឡើយ ដែលបានចារឡើងនៅក្នុងយុគ្គសម័យនោះក្រៅពីអក្សរ២-៣ តួ ឬបន្ទាត់តែប៉ុណ្ណោះ(Ka85) ។ តាមពិតគេត្រូវរង់ចាំដល់សតវត្សរ៍ទី៣ នៃគ្រិស្តសករាជ ទើបឃើញនូវ វត្តមាននៃសិលាចារឹក ដែលប្រកបដោយអត្ថបទវែងហើយដែល



www.elibraryofcambodia.org

ជាប្រភពនៃអក្សរសាស្ត្រខ្មែរ ។

សូមរំលឹកឡើងវិញថា ការដែលផ្ទាំងសិលាចារឹក ដូចជាសិលាចារឹកវត្តកញ្ចុំ ជាដើម ត្រូវបានចារឡើងជាភាសាសំស្ក្រឹត ពុំមែនមានន័យថាជនជាតិក្លិង្គជាអ្នកចារឯកសារទាំងនោះទេ គឺប៉ុន្តែគឺជនជាតិខ្មែរទេដែលជាអ្នកចារទៅវិញ ។ មួយវិញទៀតការចារជាភាសាសំស្ក្រឹតនោះ ក៏អាចសបញ្ជាក់ឱ្យយើងឃើញនូវចំណេះដឹង យ៉ាងជ្រៅជ្រះរបស់ខ្មែរនាជំនាន់នោះ ជាពិសេស គឺមជ្ឈដ្ឋានអ្នកដឹកនាំស្រុកទេស ដែលមានវិជ្ជាយ៉ាងខ្ពង់ខ្ពស់អស្ចារ្យ ។

ទន្ទឹមនឹងសិលាចារឹកដែលប្រើតួអក្សរ និងភាសាសំស្ក្រឹត គេក៏បានជួបនូវផ្ទាំងសិលាចារឹកជាច្រើន ដែលបានសរសេរឡើងជាភាសាខ្មែរសុទ្ធសាធ ដោយប្រើតួអក្សរក្លិង្គ ប៉ុន្តែផលវិបាករបស់ផ្ទាំងអក្សរថ្មទាំងនោះ បណ្ដាលមកពីការគ្មានការកំណត់កាលបរិច្ឆេទ លើកលែងតែផ្ទាំងសិលាចារឹក នៅវាលកន្ទេលដែលត្រូវបានចារឡើងនៅឆ្នាំ៦១៣នៃគ្រិស្តសករាជ សិលាចារឹកទួលវត្តគំនូរ K.៦០០ ត្រូវបានចារឡើងនៅឆ្នាំ៦១១ នៃគ្រិស្តសករាជ ។ ការវិភាគលក្ខណៈនៃតួអក្សរគ្រាន់តែអាចបញ្ជាក់ថា អក្សរថ្មទាំងនោះត្រូវបានចារឡើង រវាងសតវត្សរ៍ទី៣ និងទី៦ នៃគ្រិស្តសករាជ តែប៉ុណ្ណោះ ។

## ការប្រើត្រសាល់ត្រចៀក

ក្រៅពីគ្រឿងអលង្ការធ្វើអំពីមាស ប្រាក់ និង សំរិទ្ធ ដូចជាកងដៃ កងជើង ដែលគេការរកឃើញនៅក្នុងស្រុកអង្គរបុរី នៅមានគ្រឿងតុបតែងខ្លួនប្រុសស្រីមួយប្រភេទទៀត ធ្វើអំពីសំរិទ្ធ គឺត្រសាល់ត្រចៀក ។ វត្ថុបុរាណទាំងអស់នេះជាស្លាកស្នាមសំអាងប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់ ដែលមានលក្ខណៈទាក់ទងនឹងប្រវត្តិបុរាណវិទ្យា និងប្រវត្តិសាស្ត្រមួយចំនួន ដូចជាអូរកែវ ស្រីធម្មរាជ យ៉ាឡា អូរកែវ ។ល។



www.elibraryofcambodia.org

ដែលសុទ្ធសឹងតែជាបុរាណដ្ឋានចំណាស់ នាសម័យនគរភ្នំ ។

ម្យ៉ាងទៀត ភស្តុតាងផ្នែកបុរាណវិទ្យា ដូចជារូបចម្លាក់និងពុម្ពថ្មដាតូចៗជាច្រើន ដែលគេបានរកឃើញ ក៏អាចចាត់ទុកជាសំអាងមួយដ៏ជាក់ច្បាស់ស្ដីអំពីការ ធ្វើប្រាក់ត្រសាល់ត្រចៀកដែរ ។

រួមសេចក្ដីមក មនុស្សខ្មែរដែលរស់នៅអង្គរបុរី ក៏ជាប់ទាក់ទងផ្នែកវប្បធម៌ និង សេដ្ឋកិច្ច ជាមួយក្រុងតូចធំដ៏ទៃទៀត នៃអាណាចក្រភ្នំដែរ ព្រោះថាកំណាយស្រាវជ្រាវលើផ្នែកបុរាណវិទ្យា ក្នុងស្ថានីយ៍ប្រវត្តិសាស្ត្រជាច្រើន ក៏បានផ្ដល់នូវត្រសាល់ត្រចៀក ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងវត្ថុសិល្បៈ នៅក្រុងអង្គរបុរីដែរ ។

ចំណែកការនិយមត្រសាល់នេះ សូមជម្រាបបញ្ជាក់ថា បើយើងអះអាងទៅលើការសិក្សាលក្ខណៈរូបចម្លាក់មួយចំនួន ជាថ្ម និង ដីដុត យើងអាចសន្និដ្ឋានថាការនិយមនូវគ្រឿងអលង្ការនេះមិនជាច្រើនប៉ុន្មានដែរ ពីព្រោះប្រហែលជាមានតែអ្នកមានទេដែលពាក់ត្រសាល់ត្រចៀក ។

ទាក់ទងនឹងប្រវត្តិរបស់ត្រសាល់ យើងសូមបញ្ជាក់ថា ត្រចៀកនៃទេវតាជាច្រើន ដូចជាព្រះសុរិយានៅក្រុងស្រីទេព និងយក្សនៅកំពង់យុក ( កម្ពុជាក្រោម ) ជាដើម សុទ្ធសឹងតែត្រូវបានបំពាក់ដោយគ្រឿងពាក់អាការខាងលើនេះ មិនខុសពីទ្វារបាល ជាស្វា ឬគ្រុឌ នៃប្រាសាទបន្ទាយស្រី នាសតវត្សរ៍ទី១០ ឡើយ ។

## ព្រះបដិមាពុម្ព ឬព្រះពុម្ព

ការរកឃើញនូវពុម្ពជាច្រើន ដែលធ្វើអំពីថ្ម និង ដីដុត បញ្ជាក់ឱ្យដឹងថាវិធីធ្វើព្រះដោយប្រើពុម្ព ត្រូវបាននិយមដោយជនជាតិខ្មែរយើង តាំងតែពីសម័យនគរភ្នំម្ល៉េះ។ មួយវិញទៀត ការធ្វើពុម្ពបែបនេះនៅតែរស់រវើក តាំងពីសម័យនោះ រហូត



www.elibraryofcambodia.org

មកដល់សព្វថ្ងៃ ដោយបានឆ្លងកាត់សម័យអង្គរ ដែលជាសម័យមួយដ៏មហារុងរឿងថ្កុំថ្កើងក្នុងប្រវត្តិសាស្ត្រខ្មែរ ។

បើនិយាយម្យ៉ាងទៀត ចាប់ពីសម័យនគរភ្នំ រហូតមកដល់ថ្ងៃនេះជិត ២០០០ ឆ្នាំមកហើយ ដែលវិចិត្រករខ្មែរយើង បានបន្តបច្ចេកទេសធ្វើពុម្ពនេះពីសម័យមួយទៅសម័យមួយទៀត ដោយមិនដាច់ ។ បញ្ហាដែលចោទឡើងនៅទីនេះគឺថា តើជនជាតិក្លិង្គជាអ្នកបង្រៀនខ្មែរ ឱ្យចេះធ្វើពុម្ពខាងលើនេះឬក៏ជាទម្លាប់របស់ខ្មែរដែលមានឡើងតាំងតែសម័យប្រវត្តិសាស្ត្រ ។ តាមការស្រាវជ្រាវរបស់យើង ការធ្វើពុម្ពបែបនេះកើតមានប្រាកដ នៅក្នុងសម័យបុរេប្រវត្តិសាស្ត្រក្នុងការធ្វើឧបករណ៍ប្រើប្រាស់ ឬគ្រឿងអលង្ការនានាប្រចាំថ្ងៃ ដូចជាផ្លែដឹង កាំបិត ចិញ្ចៀន កងដៃ កងជើង ម្ជុល ។ល។ ដោយហេតុថាពុម្ពដីដុតមួយចំនួនធំ បានត្រូវគេរកឃើញ ។ ការរកឃើញនូវព្រះបដិមានៅក្នុងភូមិភាគឥណ្ឌូចិននេះ មានតែព្រះបដិមាពុម្ពមនទេដែលចាស់ជាងគេ ។

## ពេទ្យ

ការរកឃើញនូវប្រដាប់កិនថ្នាំ ធ្វើអំពីថ្មរំលីងជាច្រើននៅក្នុងបរិវេណនៃព្រៃប្រាសាទបុរាណនានា នៅស្រុកអង្គរបូរី សបញ្ជាក់ឱ្យយើងដឹងថា បូជនីយដ្ឋាននាសម័យនគរភ្នំ ក៏ដូចសម័យអង្គរដែរ នារជ្ជកាលនៃព្រះបាទជ័យវរ្ម័ទី៧ (ស.វ.ទី១២-១៣ គ.ស) សុទ្ធសឹងជាកន្លែងព្យាបាលជំងឺផ្សេងៗរបស់ប្រជាពលរដ្ឋដោយមានការមើលខុសត្រូវរបស់គ្រូពេទ្យដែលជាព្រាហ្មណ៍ ។

សូមជម្រាបថា ឧបករណ៍កិនថ្នាំទាំងនោះមានពីរផ្នែក គឺត្បាល់ និងអង្រែ ប៉ុន្តែរាងខុសៗពីគ្នា ។ ម្យ៉ាងទៀតភាគច្រើននៃប្រដាប់កិនថ្នាំទាំងនោះធ្វើឡើងដោយថ្មជា ពណ៌ខៀវរលោង និងថ្មភក់ ។

ដោយសារតែឧបករណ៍កិនថ្នាំខាងលើនេះ យើងអាចដឹងថា រុក្ខជាតិជាច្រើន



www.elibraryofcambodia.org

ប្រភេទ ត្រូវបានខ្មែរយើងនាសម័យនគរភ្នំ យកមកប្រើជាថ្នាំសម្រាប់ទប់ទល់នឹងរោគា ។ នេះជាប្រភពឯកសារស្ដីអំពីការថែរក្សាជម្ងឺ តាមរបៀបបុរាណ ដូច្នេះចំពោះវិស័យវេជ្ជសាស្ត្រយើងជឿជាក់ថា ថ្ងៃក្រោយយើងពិតជានឹងមានពត៌មានបន្ថែមទៀតជាមិនខាន ។

## ព្រះរាជធានីស្រីទេពនៅខេត្ត ពេជ្របុរី

ឯកសារចិនបានឱ្យយើងដឹងថា ចក្រភពភ្នំ មានទីក្រុងតូច ធំ ជាង ១០០ ។ ដូច្នេះហើយ ទីក្រុងស្រីទេពអាចជាទីក្រុងមួយ ក្នុងចំណោមទីក្រុងទាំងនោះ ។ស្ថិតនៅចន្លោះនៃភូមិភាគកណ្ដាល និងឥសាន ត្រង់ខ្សែស្របទី១៦ អង្សា ខាងជើង ខ្សែបណ្ដោយទី១០១ អង្សា ខាងកើត ទីក្រុងស្រីទេពស្ថិតក្នុងខេត្តពេជ្របុរី (ពេជ្របូរណ៍ ) ដែលជាខេត្តមួយមានទីតាំងស្ថិតនៅភូមិភាគខាងជើង ។ និងភូមិភាគឥសាន ។ ខេត្តនេះមានផ្ទៃក្រឡាប្រហែល២៨៦ គីឡូម៉ែត្រ ហើយមានកំពស់ពីផ្ទៃសមុទ្រ ប្រមាណជា ១១៤ម៉ែត្រ ។

ខេត្តពេជ្របុរី មានព្រំប្រទល់ជាប់ជាមួយខេត្តជិតខាងមួយចំនួន ដូចជា ខាងជើងជាប់នឹងខេត្ត ឡឿយ ខាងត្បូងជាប់ខេត្ត ពពបូរី ខាងកើតជាប់ខេត្ត ជ័យភូមិ និងនគររាជសីមា និងខាងលិច ខេត្តពិចិត្រ ភិស្ណុលោក និងណគរខនស្វគ៌ ។ សូមជម្រាបថា ក្នុងបរិវេណនៃខេត្តទាំងប៉ុន្មានខាងលើនេះ មានបូជនីយដ្ឋានជាច្រើនដែលបានសាងសង់ឡើង ដោយបុព្វបុរសខ្មែរនាសម័យបុរាណ ។

កេរ្តិ៍ឈ្មោះនិងកិត្តិនាមផ្ទាល់របស់ខេត្ត ពេជ្របុរី គឺទីក្រុងស្រីទេព ដែលបានចាប់បដិសន្ធិឡើងនាសម័យនគរភ្នំ ហើយដែលជាទីក្រុងខ្មែរបុរាណមួយដ៏ធំជាងគេបំផុត ក្នុងព្រះរាជាណាចក្រថៃបច្ចុប្បន្ន ។ ជាបឋម គេសង្កេតឃើញថា ទីក្រុងនេះមានលក្ខណៈជារូបគ្រោងនៃទីក្រុងភ្លោះមួយគូរ ដែលចែកចេញជាពីរផ្នែក គឺផ្នែកដែលស្ថិត



www.elibraryofcambodia.org

នៅក្នុងក្រុង និងផ្នែកដែលស្ថិតនៅក្រៅក្រុងបុរាណនេះ ដែលជាមរតកវប្បធម៌បុរាណ ។

ការស្រាវជ្រាវរបស់អ្នកបុរាណវិទូថៃ បានឱ្យដឹងថា ផ្នែកក្នុងក្រុងមានសណ្ឋានរូបរាងស្ទើរមូល ស្ទើរជ្រុង ឡោមព័ទ្ធជុំវិញដោយគូទឹកដោយមានទំនប់ខ័ណ្ឌជាំង ហើយមានច្រកទឹកចេញចូល ឬទ្វារទឹកចំនួន ៨ ។ ម្យ៉ាងទៀត ក្នុងបរិវេណនៃទីក្រុងនេះ គេសង្កេតឃើញមានស្រះទឹក ត្រពាំង រាយប៉ាយពាសពេញទីនោះប្រយោជន៍នឹងទ្រទ្រង់ជីវិត នាសម័យបុរាណកាល ។

ចំណែកផ្នែកក្រៅក្រុងវិញ ដែលមានទ្រង់ទ្រាយជារាងចតុកោណកែង គេឃើញនៅជុំខាងលើនូវគូទឹក ទំនប់ខ័ណ្ឌជាំងនៅរួមគ្នាជាមួយនឹងផ្នែកក្នុងក្រុង ។ គូទឹកបុរាណនេះ មានទ្វារឬច្រកទឹកចេញចូល ៧កន្លែង ។

ការសិក្សាស្រាវជ្រាវ បានឱ្យដឹងទៀតថានៅក្នុងតំបន់ផ្ទៃនៃទីក្រុងស្រីទេពមានបូជនីយដ្ឋានជាច្រើនដូចជា ប្រាង្គប្រាសាទស្រីទេព ប្រាសាទបងប្អូនពីរនាក់ និងបុរាណស្ថានជាច្រើនទៀត ដែលបានត្រូវគេបំផ្លិចបំផ្លាញស្ទើរតែទាំងអស់ទៅហើយ ។ ដូចនេះរមណីដ្ឋានខ្មែរផ្សេងៗទៀត យើងឃើញនៅផ្លូវចេញចូលទិសខាងកើតមានខ្ទម អ្នកតាស្រីទេព ដែលពលរដ្ឋគោរពសក្ការៈបូជា ។

សូមជម្រា[illegible]ដីនៃទីក្រុងទាំងមូលមានទំហំប្រមាណជា ២៩៨៩ ម៉ែត្រ ត្រូវជា ៤.៧ គីឡូម៉ែ[illegible] ពោលគឺផ្នែកខាងក្នុងមាន ១៣០០ រ៉ៃ និងផ្នែកខាងក្រៅក្រុងមាន ១៥៨៩ រ៉ៃ ។

ក្រៅពីនោះ នៅខាងក្នុងក្រុងស្រីទេពឆ្ពោះទៅទិសខាងជើង មានក្រុងបុរាណដ្ឋានមួយ នៅត្រង់ម្តុំភូមិស្រះស្បូវ ស្ថិតចម្ងាយប្រមាណជា ១.៥ គីឡូម៉ែត្រពីទីក្រុងបុរាណដ៏ល្បីល្បាញនេះ គឺភ្នំឃ្លាំងក្រៅ ។



www.elibraryofcambodia.org

បុរាណវត្ថុដែលគេបានជួបប្រទះក្នុងក្រុងស្រីទេព មានទាំងព្រះបដិមាស្ថាបនាឡើងតាមទម្រង់ពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ដែលជាហេតុនាំឱ្យយើងមានការលំបាកច្រើន ក្នុងការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរ ក្នុងសម័យកាលនោះ ។ បើយើងពិនិត្យលក្ខណៈនៃបដិមាកម្មទាំងនោះ ដែលគេបានរកឃើញរហូតដល់សព្វថ្ងៃ យើងឃើញថា ក្នុងទីក្រុងនេះជនជាតិខ្មែរនិយមសាសនាធំៗពីរគឺព្រះពុទ្ធសាសនា និង ព្រហ្មញ្ញសាសនា ដោយឥតបញ្ចោលនូវជំនឿអារក្សអ្នកតាក្នុងនោះផង ដែលជាជំនឿជាប្រពៃណីរបស់ស្រុកភូមិ ។

ក្នុងវិស័យសិល្បៈ ដោយសារជនជាតិខ្មែរនាសម័យនោះ បានកាន់សាសនាក្លិង្គទាំងពីរ បានជាយើងឃើញនូវទេវរូបថ្ម នៃលិទ្ធិព្រហ្មញ្ញសាសនាជាច្រើនដូចជារូបព្រះនារាយណ៍ពាក់មួកឈរកាច់ចង្កេះ ឬព្រះវិស្ណុ សិវលិង្គ ព្រះក្រឹស្ន ព្រះសុរិយា ។ រីឯបដិមាកម្មខាងផ្នែកសាសនាព្រះពុទ្ធវិញ គេឃើញមានរូបព្រះពុទ្ធអង្គ សិលាចម្លាក់ថ្ម និងបង្ហាញឱ្យឃើញ ព្រមទាំងព្រះបដិមាពុទ្ធ ធ្វើអំពីដីដុតជាច្រើន ។

ដើម្បីឱ្យដឹងច្បាស់ ពីកាលបរិច្ឆេទនៃបដិមាកម្ម ពោលគឺចំណាស់ៈរបស់វត្ថុសិល្បៈបុរាណទាំងអស់នោះ គួរតែឲ្យយើងលើករូបចម្លាក់បុរាណ និងសិលាចារឹកដែលគេបានរកឃើញក្នុងបរិវេណសីមានៃទីក្រុងនេះ មកពិនិត្យសិក្សាឱ្យបានហ្មត់ចត់សិន ។ តាមការស្រាវជ្រាវវិភាគ យើងអាចដឹងថា ថ្វីត្បិតតែរូបចម្លាក់បុរាណនៃទីក្រុងស្រីទេពមានអាយុខុសប្លែកពីគ្នាក៏ដោយ ក៏ប៉ុន្តែចម្លាក់ដែលចាស់ជាងគេស្ថិតក្នុងរចនាបថភ្នំដាឬទួលភ្នំ ដូចជាព្រះក្រឹស្ណ និងនារាយណ៍ជាដើម ។ រីឯអក្សរនៃ សិលាចារឹកដែលចាស់ជាងគេ ដែលសរសេរលើបំណែកថ្មមួយមានរូបរាងបួនជ្រុង គឺអក្សរបល្លវៈ នៃប្រទេសឥណ្ឌាខាងត្បូង ។

ត្រង់នេះអ្នកស្រាវជ្រាវ បានសន្និដ្ឋានថា ទីក្រុងស្រីទេពនេះកើតឡើងក្នុង



www.elibraryofcambodia.org

សម័យនគរភ្នំ ។ ម្យ៉ាងទៀតសូមជម្រាបថា បន្ទាប់មកទៀតអ្នកបុរាណវិទូថៃក៏បានរកឃើញនូវសិលាចារឹកពីរផ្ទាំងទៀត ដែលមានចារឈ្មោះព្រះមហាក្សត្រខ្មែរមួយព្រះអង្គ គឺព្រះបាទភវវម៌្មទី១ ដែលគ្រប់គ្រងអាណាចក្រចេនឡាវាងឆ្នាំ៥៩៧ នៃគ្រិស្តសករាជ ពោលគឺមុនព្រះបាទឥសានវម៌្មទី១ ដែលបានទទួលកេរ្តិ៍មរតកពីស្តេចអង្គនេះ ។

ដូច្នេះបើតាមការវិភាគរបស់យើង បដិមាកម្មនិងសិលាចារឹកទាំងនេះទេមិនគ្រាន់តែផ្តល់ចំពោះយើង នូវអាយុកាលរបស់ទីក្រុងនេះតែប៉ុណ្ណោះនោះទេក៏ប៉ុន្តែនូវប្រវត្តិកំណើតរបស់ព្រះរាជធានីខ្មែរ ដ៏ធំសម្បើមនេះថែមទៀតផងដែរ ហើយទីក្រុងនេះស្ថិតនៅក្រោមឥទ្ធិពលអំណាច របស់អាណាចក្រនគរភ្នំ ។

អ្នកប្រវត្តិវិទូ បានបញ្ជាក់ថា វត្តមាននៃសិលាចារឹកនៃព្រះបាទ ភវវម៌្មទី១ ដែលជាភស្តុតាងប្រវត្តិសាស្ត្រយ៉ាងសំខាន់ឱ្យយើងដឹងថាអាណាចក្រចេនឡាបានពង្រីកអំណាចរបស់ខ្លួន ចូលមកដល់ខាងក្រោមដងទន្លេមេគង្គឯណោះ ហើយការគ្រប់គ្រងទីក្រុងនេះដោយជនជាតិខ្មែរ បានប្រព្រឹត្តទៅតាំងតែពីសម័យនគរភ្នំ រហូតដល់សតវត្សរ៍ទី ១១-១២ នៃគ្រិស្តសករាជ បើតាមខ្លឹមសារនៃផ្ទាំងសិលាចារឹកទី២ ដែលបានត្រូវចារឡើងជាអក្សរខ្មែរនាសម័យអង្គរ ។ ក្រៅពីនេះ នៅមានវត្ថុសិល្បៈមួយចំនួនទៀត ដូចជាព្រះពុទ្ធអង្គ ទេវតា ទ្វារបាលធំៗជាដើម ដែលស្ថិតនៅក្នុងរចនាបថបាយ័ន នៃព្រះបាទជ័យវម៌្មទី៧ ( គ.ស ១១៨០-១២១៦ ) ។

ម្យ៉ាងទៀត ព្រឹត្តិការណ៍មួយសំខាន់ដែលយើងត្រូវផ្តោតអារម្មណ៍ គឺវត្តមានរបស់លិទ្ធិថេរវាទនៅក្នុងតំបន់នេះនាគ្រាបឋមនៃប្រវត្តិសាស្ត្រខ្មែរនាសម័យមុនអង្គរ។

វត្ថុតាងចាស់ជាងគេ ដែលគេបានជួបប្រទះនៅទីក្រុងស្រីទេព មានលក្ខណៈជាពុទ្ធសាសនានិកាយថេរវាទ ឬ ហីនយាន ថែមទៀតផង គឺជាគាថាបាលី " យេ ធម្មា "



www.elibraryofcambodia.org

ដែលគេបានដាក់លើបល្ល័ង្កព្រះ ។ ក្រៅពីនេះនៅមានវត្ថុបុរាណមួយចំនួនទៀត ដែលបញ្ជាក់នូវវត្តមានរបស់ព្រះពុទ្ធសាសនា ផងវត្ថុទាំងនោះដូចជា ធម្មចក្រ ឬបំណែកធម្មចក្រ បង្គោលសីមាថ្មភក់ និងថ្មបាយក្រៀមព្រះបដិមាពុទ្ធ ។ល។

ចំពោះសាសនដ្ឋានដែលគេប្រទះឃើញ នៅក្នុងទីក្រុងស្រីទេពនោះហើយ ដែលមានសារៈសំខាន់ជាងគេបំផុត គឺបុរាណស្ថានទាក់ទងព្រះពុទ្ធសាសនា ។ បុរាណស្ថាននេះ ដែលមានលក្ខណៈជាសិល្បៈក្មែរ បានត្រូវសាងសង់លើប្រថែនផ្ទាំងថ្មបាយក្រៀម ដោយមានរាងបួនជ្រុង កំពស់ប្រមាណ៦ម៉ែត្រ ហើយតួអង្គអាគារធ្វើអំពីឥដ្ឋដុត មានរាងបួនជ្រុង ជំរៅជារាងកំពុកពោះកែង មានទ្វារខាងមុខបែរទៅរកទិសខាងកើត ហើយមានទ្វារបញ្ឆោតបីទៀត ។ នៅលើខឿនសាសនដ្ឋាននេះគេឃើញមានរូបចម្លាក់ធ្វើអំពីបាយអជាច្រើន ដូចជា សត្វ ដំរី មនុស្ស ជាដើមសម្រាប់លំអបុរាណស្ថាននេះផង ( មើលរូបភាព ) ។ សូមបញ្ជាក់ថា ដោយចម្លាក់តុបតែងនេះមានលក្ខណៈស្រដៀងនឹងសិល្បៈមន បានជាគេយល់ច្រឡំថា សាសនដ្ឋានខាងលើនេះជាសិល្បៈមន ឬតព្វាក ។ ប៉ុន្តែទស្សនៈនេះពុំមានមូលដ្ឋានទេ ។ ចំពោះការដុះដាលលេចធ្លោនៃនគរមន ឈ្មោះទ្វារវតី តាមប្រសាសន៍របស់លោក ខុបរ៉ុង នគរនេះបានត្រូវបង្កើតឡើងនៅសតវត្សរ៍ទី៦ ពោលគឺក្រោយពីការបែកបាក់របស់អាណាចក្រភ្នំ ។

## ប្រព័ន្ធធារាសាស្ត្រ

បុរាណដ្ឋានខ្មែរជាច្រើន បានបន្សល់ទុកនូវតួទឹកព័ទ្ធជុំវិញទីក្រុងដូចជាវត្តភូ. ស្រីទេព អង្គរបុរី និងសុរិន្ទ្រ ជាដើម ។ តើតួទឹកទាំងនេះមានសារៈសំខាន់អ្វីខ្លះក្នុងអតីតកាល ។ សូមជម្រាបថា ការជីកតួទឹក និងលើកទំបន់ជាកំពែងទីក្រុងព័ទ្ធជុំវិញទីក្រុងបុរាណជាប្រពៃណីមួយ ដែលគេពីរប្រទះនៅដើមសម័យប្រវត្តិសាស្ត្រ ដូចដែលបានពិពណ៌នាដោយកំណត់ហេតុចិន ។



www.elibraryofcambodia.org

នៅព្រះរាជាណាចក្រខ្មែរ ក្នុងសម័យនគរភ្នំ និងនាដើមសតវត្សរ៍ទី១ នៃគ្រិស្តសករាជ និងសម័យចេនឡា គូទឹកនិងទំនប់ដីដែលហ៊ុមព័ទ្ធទីក្រុងនានាមានតួនាទីពីរសំខាន់ គឺក្រៅពីតម្រូវការទឹកក្នុងការប្រើប្រាស់របស់ព្រះរាជនគរ ទឹកជារបាំងមួយសម្រាប់ឱ្យមនុស្សបុរាណការពារទប់ទល់នឹងសត្រូវ ដែលមកពីខាងក្រៅដែរ ។ សូមកុំភ្លេចថា ក្នុងប្រទេសខ្មែរនាសម័យនោះ មានរដ្ឋតូចៗជាច្រើនដែលប្រឆាំងនឹងអំណាចកណ្តាលជានិច្ចកាល ហើយរចនាសម្ព័ន្ធនយោបាយនេះជាសារជាតិរបស់អារ្យធម៌ខ្មែរ ។

ប្រភពពត៌មានថា លក្ខណៈគូទឹកដែលជនជាតិខ្មែរបានជីកឡើងនោះមានសណ្ឋានស្ទើរមូល ដែលជាហេតុសម្គាល់ឱ្យដឹងថា ជាទីក្រុងបុរាណនាសម័យដើមប្រវត្តិសាស្ត្រ ហើយទម្រង់មូលនៃទីក្រុង ត្រូវបានគេសម្គាល់យ៉ាងជាក់ច្បាស់ដោយរូបថតលើអាកាស ។ ម្យ៉ាងទៀត កំណើតនៃទីក្រុងបុរាណខ្មែរជាច្រើននៅ កម្ពុជា ឬនៅភូមិភាគឥសាន និងភូមិភាគកណ្តាលនៃប្រទេសថៃ បណ្តាលមកពីកំណើនចំនួនប្រជាជន នាសម័យលោហធាតុ ជាពិសេសសម័យដើមប្រវត្តិសាស្ត្រដែលសហគមន៍មនុស្សចាំបាច់ត្រូវការ ក្នុងការបង្កបង្កើនផល បំពេញទៅតាមសេចក្តីត្រូវការរបស់ពួកគេ ក្នុងជីវិតប្រចាំថ្ងៃ ។ កំណើនចំនួនប្រជាជន តម្រូវឱ្យមានការពង្រីកផ្ទៃដីដាំដុះ នៅតំបន់វាលរាបនៃទីក្រុងនានា ប្រយោជន៍នឹងបង្កើនផ្ទៃផលិតនិងផលកសិកម្ម ។ គឺក្នុងករណីនេះហើយ ដែលការជីកគូទឹកនិងលើកទំនប់ដីដើម្បីបង្កើននូវប្រព័ន្ធធារាសាស្ត្របូរបថ្មី ក្នុងទីក្រុងបុរាណជាការចាំបាច់បំផុត ដើម្បីនាំមកនូវនិរន្តរភាព និងវឌ្ឍនភាពរបស់សង្គមខ្មែរនាសម័យនោះ ។

## សេចក្តីសន្និដ្ឋាន

អាណាចក្រសំខាន់បំផុតនៃអាស៊ីអាគ្នេយ៍ តាំងតែអម្ពុងសតវត្សរ៍ទី១



www.elibraryofcambodia.org

ដល់ឆ្នាំ៦២៧ នៃគ្រិស្តសករាជ គឺអាណាចក្រភ្នំ ក្រុងភ្នំ ដែលចិនហៅថា ហ្វូណន ។ នគរខ្មែរ ដំបូងនេះត្រូវបានបង្កើតឡើងដោយការផ្សព្វផ្សាយវប្បធម៌ អារ្យធម៌ឥណ្ឌា ហើយពាក្យ ក្រុងភ្នំ គឺជាពាក្យខ្មែរបុរាណ (កុរុង វ្នំ) សំដៅភ្នំនៃព្រះរាជាណាចក្រខាងលើនេះ ដែលទ្រង់មានព្រះនាមតាមភាសាសំស្ក្រឹតថា បពិតភូបាល ឬសៃលរាជ ។ តាមពិតនាសម័យបុរាណ ជនជាតិចិនបានប្រើ ឋាននូវនាមដើម្បីហៅប្រទេសដែលមានស្តេចសោយរាជ្យផងដែរ ។

នគរភ្នំជាកុរុព្រប្រទេស ដែលបានចាប់បដិសន្ធិឡើងដោយការបង្រួបបង្រួមផ្សំផ្គុំនៃរដ្ឋតូចធំជាច្រើនដូច្នេះហើយ បានជាគេបានរកឃើញនូវរាជធានីបុរាណជាច្រើននៃអតីតព្រះរាជាណាចក្រភ្នំនេះ ដែលស្ថិតក្បែរមាត់ដងទន្លេមេគង្គផ្នែកខាងក្រោមក្នុងស្រុកអង្គរបុរី ខេត្តតាកែវ និងទន្លេចៅពុក្សា ក្នុងបរិវេណស្រុកអូថង នៃខេត្តសុផាន់បុរី ប្រទេសសៀមបច្ចុប្បន្ននេះ ។

តាមពិត នាសម័យដ៏មហារុងរឿង ដែនដីនៃព្រះរាជាណាចក្រភ្នំ ដែលមានអង្គរបុរី និង អូថងជារាជធានី បានលាតសន្ធឹងពីភូមិភាគខាងត្បូងនៃកម្ពុជាក្រោម តាកែវ ព្រៃវែង ស្វាយរៀង កណ្តាល សៀមរាប បន្ទាយមានជ័យ ។ល។ ហើយពី តំបន់វាលទំនាបទាំងនេះ ដល់ដងទន្លេមេគង្គផ្នែកកណ្តាលរហូតដល់ផ្នែកធំនៃទន្លេចៅពុក្សា និងឧជ្ជោយម៉ាម្សាកា ក្នុងបច្ចុប្បន្ន ។ សេចក្តីសន្និដ្ឋាននេះ សំអាងលើភស្តុតាងនៃវត្ថុបុរាណជាច្រើន ដូចជារូបចម្លាក់ គ្រឿងអលង្ការ និងរបស់ប្រើប្រាស់ប្រចាំថ្ងៃ ដូចជាចាន ឆ្នាំងជាដើម ដែលគេបានរកឃើញនៅស្ថានីយ៍ប្រវត្តិសាស្ត្រ អូរកែវ អូថង និងថ្មីៗនេះនៅភូមិស្វាយ ស្រុកព្រះនេត្រព្រះ និង អង្គរបុរី ឬវ្យាធបុរៈ ដែលស្ថិតពុំឆ្ងាយប៉ុន្មានពីក្រុងបាភ្នំ នៃខេត្តព្រៃវែង ។ ឯកភាពផ្នែកស្ថាបត្យកម្ម និងបដិមាសាស្ត្រ វប្បធម៌-អារ្យធម៌ រវាងស្ថានីយ៍ប្រវត្តិសាស្ត្របុរាណទាំងនោះក៏ជាសក្ខីកម្មមួយយ៉ាង-



www.elibraryofcambodia.org

សំខាន់បំផុត ដើម្បីបញ្ជាក់នូវខឺណ្ឌសីមារបស់អាណាចក្រភ្នំដែរ ដែលត្រូវគេផ្ទៀងផ្ទាត់ នឹងកំណត់ហេតុចិនទាសម័យរាជវង្សលាង នៃពាក់កណ្ដាល ពុទ្ធសតវត្សរ៍ ទី១១ ។

ការសន្និដ្ឋានខាងលើនេះ បានមកពីការវិភាគ សិក្សាវត្ថុតាងមួយចំនួនដែលជាមូលដ្ឋាននៃប្រវត្តិសាស្ត្រ ។ គប្បីរំលឹកនៅត្រង់នេះថា វឌ្ឍនភាពរបស់អាណាចក្រភ្នំ បណ្ដាលមកពីពាណិជ្ជកម្មរវាងខ្មែរនិងបរទេស ។

វត្ថុមានរបស់កាក់ និងចង្កៀងរ៉ូម៉ាំងជាច្រើននៅក្នុងស្ថានីយ៍ប្រវត្តិសាស្ត្រ នាសតវត្សរ៍ទី១ នៃគ្រិស្តសករាជ បានត្រូវអ្នកវិភាគពិពណ៌នាថាជាសក្ខីកម្មផ្នែកពាណិជ្ជកម្ម ជាមួយអាណាចក្រភ្នំ ហើយបានហៅព្រឹត្តិការណ៍នេះថា ជាព្រឹត្តិការណ៍សេដ្ឋកិច្ចមួយយ៉ាងសំខាន់ ។ ម្យ៉ាងទៀតទំនាក់ទំនងរវាងខ្មែរនិងចក្រភពរ៉ូម៉ាំងតាមរយៈ "គ្រឿងទេស" ត្រូវបានកត់ត្រាតាមរយៈរឿងព្រេងមួយចំនួននៅស្រុកបាភ្នំខេត្តព្រៃវែងសព្វថ្ងៃនេះ ។

ស្ថានីយកំពង់ផែសមុទ្រអន្តរជាតិមួយយ៉ាងធំសម្បើម ដែលខ្មែរនិយមហៅថា កំពង់ផែអូរកែវ នាសម័យនោះបានត្រូវគេរកឃើញនៅកម្ពុជាក្រោម ។ កំពង់ផែព្រមទាំងវត្ថុបុរាណជាច្រើនទាំងនោះ ជាភស្តុតាងផ្នែកពាណិជ្ជកម្មយ៉ាងសកម្មរវាងរដ្ឋខ្មែរដំបូងបង្អស់ និងប្រទេសឆ្ងាយមួយចំនួន ដែលមានជាអាទិ៍ ចក្រភពអ៊ីរ៉ង់ ចក្រភពរ៉ូម៉ាំង ចិន និង ក្លិង្គ ។

ថ្វីត្បិតតែភាពថ្កុំថ្កើង រុងរឿងនៃនគរភ្នំ បណ្ដាលមកពីវិស័យពាណិជ្ជកម្មនេះដែរ ដែលប្រទេសខ្មែរបានធ្វើជាមួយប្រទេសជិតខាង ក៏ប៉ុន្តែដើម្បីធ្វើឱ្យជំនួញអន្តរជាតិនេះអាចអនុវត្តន៍ទៅបាន លុះត្រាតែប្រទេសនេះ មានមធ្យោបាយដឹកជញ្ជូន ពោលគឺអារេច្ចេកទេសខ្ពស់ក្នុងការសាងសង់សំពៅតូចធំនានា ដើម្បីឆ្លងកាត់តំបន់មួយទៅតំបន់មួយទៀត ឬប្រទេសមួយទៅប្រទេសមួយទៀត តាមផ្លូវសមុទ្រ ។ យើងចង់



www.elibraryofcambodia.org

និយាយនៅត្រង់នេះថា ខ្មែរយើងចេះប្រើ ឬធ្វើសំពៅដើម្បីធ្វើជំនួញជួញប្រែ ។

សូមរំលឹកថា ឯកសារចិនបាននិយាយថា នៅនគរភ្នំគេឃើញមានសំពៅធំៗ បើកបរទៅមកកាត់សមុទ្រ ។ រីឯកន្ទុំនៃសំពៅទាំងនោះ មានរាងជាក្បាលនិងកន្ទុយត្រី ហើយមានប្រវែងប្រមាណជា ៣០ ម៉ែត្រ ។

ម្យ៉ាងទៀតអ្នកសង្កេតការណ៍ចិនសម័យបុរាណបានមើលឃើញថា វត្ថុដែលគេលក់ដូរនោះមាន មាស ប្រាក់ សំពត់ព្រែ ចរបាប់ គ្រឿងកែវ ភ្លុកដំរី សំណកណហ៊ាំង ទង់ដែង គ្រឿងក្រអូប ក្រមួន និងគុជខ្យងដែលបានពីបាតសមុទ្រ ។ ពួកចិនក៏បានបញ្ជាក់ទៀតថា អ្នកស្រុកពូកែណាស់ក្នុងការមុជក្នុងបាតសមុទ្រ ដើម្បីរាវរកគុជទាំងនោះដែលអាចសភាពរឹងជាងដែកទៅទៀត ដោយហេតុថា "យកដែកដំមិនខ្ទេចពេជ្រទេ តែរឿងខ្ទេចដែកទៅវិញ ។ មិនតែប៉ុណ្ណោះជនជាតិខ្មែរ ជាជាងទង ដ៏ចំណាន ដូចជាការធ្វើកងដៃ ចិញ្ចៀន ចានក្បានអំពីមាសប្រាក់ ។ មួយវិញទៀត ខ្មែរនាសម័យនោះក៏មានសភាពស្ទាត់ជំនាញក្នុងការសូនរូប ត្បាញសូត្រ ស្លកែវ ដើម្បីធ្វើគ្រឿងអលង្ការ ។

ការរកឃើញនូវវត្ថុបុរាណដ៏សំខាន់សន្ធឹកសន្ធាប់ នៅក្នុងដែនដីសណ្ដរ ( កម្ពុជាក្រោម ) នៅខេត្តពោធិ៍កែវបច្ចុប្បន្ន ជាពិសេសនៅក្នុងទីក្រុងវ្យាធបុរៈ និងក្នុងឈូងសមុទ្រសៀមសព្វថ្ងៃ ជាសក្ខីកម្មមួយបញ្ជាក់នូវវឌ្ឍនភាពកប់កំពូល នៃវប្បធម៌-អារ្យធម៌ របស់ខ្មែរនាសម័យនគរភ្នំ ។

ចំពោះវត្ថុតាងស្ដីអំពីពាណិជ្ជកម្មរវាងខ្មែរ និងចិនវិញ ក្រៅពីកំណត់ហេតុចិន គេឃើញនៅមានវត្ថុមានវត្ថុបុរាណជាច្រើនទៀត ដូចជាកញ្ចក់ឆ្លុះមុខមាត់ កាក់ និងគ្រឿងខ្មែរមួយចំនួន ដែលបានទទួលឥទ្ធិពលវប្បធម៌ចិន ។

ជាទីអវសាន យើងសូមធ្វើសំណូមពរដូចតទៅនេះ ៖ គប្បីយើងថែរក្សាវត្ថុ



www.elibraryofcambodia.org

ពាងទាំងអស់នោះឱ្យគង់វង្ស ដោយហេតុថា វាជាស្លាកស្នាមនៃសំណង់វប្បធម៌ខ្មែរបុរាណ ។ ដូច្នេះហើយ ការកកាយស្ថានីយ៍ប្រវត្តិសាស្ត្រដោយមិនគោរពតាមបទវិទ្យាសាស្ត្រ គ្រាន់តែយកវត្ថុបុរាណទៅលក់ដូរ ជាការខាតបង់ផ្នែកប្រវត្តិសាស្ត្រមួយយ៉ាងធំធេងបំផុត ។ ទង្វើនេះអាចប្រៀបបាននឹងការបំផ្លិចបំផ្លាញនូវអត្តសញ្ញាណជាតិ ឬព្រលឹងជាតិរបស់យើង ។

សរុបសេចក្តីមក គេស្គាល់ ឬវាយតម្លៃវប្បធម៌ជាតិយើង តាមរយៈវត្ថុបុរាណដែលជាសមិទ្ធផលសង្គមទាំងអស់នោះ ហើយបើសិនជាយើងបាត់បង់នូវវត្ថុពាងទាំងអស់នោះ តើយើងនឹងមានអ្វីទៀតសម្រាប់បង្ហាញនូវភាពចំណាស់ ឬទេពកោសល្យរបស់ ជនជាតិខ្មែរយើង ។

## កំណត់ហេតុ

១- តាមការស្រាវជ្រាវរបស់លោកបុរាណវិទូ ពីយែរ ឌុបម៉ុង ជនជាតិមនដែលស្ថិតក្នុងអម្បូរមន-ខ្មែរ បានបង្កើតនគរមនមួយឈ្មោះថា នគរទ្វារវតី ឬឌូឡប៉ូទីក្រោយពីការបែកបាក់ នៃចក្រភពនគរភ្នំ នៅចុងសតវត្សរ៍ទី៦ ។ រួមសេចក្តីមក មុនអន្តរកាលនេះ នៅក្នុងចក្រភពនគរភ្នំ គេពុំទាន់ឃើញមាននូវវត្តមានរបស់ជនជាតិមន ដែលរួមឈាមជ័រជាមួយខ្មែរនៅឡើយទេ ។ យ៉ាងណាមិញ មុនសតវត្សរ៍ទី១ នៃគ្រិស្តសករាជ យើងក៏ពុំទាន់ឃើញមាននូវវត្តមានរបស់នគរខ្មែរ ឬកម្ពុជរដ្ឋដែរ ។ ទាំងនេះបង្ហាញឱ្យយើងឃើញយ៉ាងច្បាស់ថាការបង្កើតរដ្ឋ ឬ ការសាបសូន្យនៃរដ្ឋណាមួយ ដូចជារដ្ឋមន និងរដ្ឋចម្ប៉ា គឺជាបញ្ហាដែលពាក់ព័ន្ធនឹងវិស័យនយោបាយ និងវប្បធម៌ ដែលត្រូវបានប្រព្រឹត្តឡើងក្នុងអតីតកាលដ៏យូរលង់ ។ បើនិយាយម្យ៉ាងទៀត មុនការបែកបាក់រដ្ឋនគរភ្នំ នៅចុងសតវត្សរ៍ទី៦ នគរភ្នំ គឺជាកម្ពុជរដ្ឋដែលត្រូវបង្កើតឡើង



www.elibraryofcambodia.org

ក្រោមឥទ្ធិពលនៃវប្បធម៌ក្លិង្គ ហើយរដ្ឋនេះជាការរួមផ្សំ នូវកុលសម្ព័ន្ធតូច ធំ នានាជាច្រើន ។ គឺក្នុងករណីដ៏ពិសេសនេះហើយ ដែលគេអាចសន្និដ្ឋានថា ក្នុងកុលសម្ព័ន្ធមន-ខ្មែរជាច្រើននៅឧបទ្វីបឥណ្ឌូចិននេះ មានតែជនជាតិខ្មែរនិងមនទេ ដែលបានកសាងរដ្ឋរបស់ខ្លួនខុសពីកុលសម្ព័ន្ធមន-ខ្មែរផ្សេងៗទៀត ដែលរស់នៅតាមព្រៃភ្នំរហូតដល់សព្វថ្ងៃ ។

ការស្រាវជ្រាវរបស់អ្នកឯកទេសខាងប្រវត្តិសាស្ត្របុរាណខ្មែរ ខាងលើនេះ បានឱ្យដឹងថា នគរមនមុនគេនោះស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទីក្រុងបាងកកសព្វថ្ងៃ ហើយមានឈ្មោះថា នគរបឋម ដែលមានព្រះចេតិយមួយដ៏ធំសម្បើម ស្ថិតនៅក្នុងព្រះរាជធានីនោះ ។ម្យ៉ាងទៀតគ្មានអ្វីមកសំអាងថា នគរមន បានចាប់បដិសន្ធិឡើងនៅសតវត្សរ៍ទី១ នៃគ្រិស្តសករាជឡើយ ។

គប្បីកត់សម្គាល់ថា សហគមន៍ដែលមានរាជធានីស្ថូល គឺនគរបឋមនោះ បានលាតសន្ធឹងឥទ្ធិពលរបស់ខ្លួន ទៅលើទីតាំងមួយចំនួនធំទៀត ដូចជានៅខេត្ត រាជបុរី សុផាន់បុរី អ៊ូថង និង សិង្ហបុរី ជាដើម ហើយម្យ៉ាងទៀតមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយខ្មែរ ដែលនៅជាប់ខឿនរបស់ពួកគេ និងត្រូវជាបងប្អូនជាមួយគ្នាផង ។

ការស្រាវជ្រាវថ្មីៗរបស់យើង បានបង្ហាញថា នាចុងសតវត្សរ៍ទី៦ ដើមសតវត្សរ៍ទី៧ ជនជាតិខ្មែរនៅ វ្យាធបុរៈ ឬ អង្គរបុរី មានទំនាក់ទំនងផ្នែកវប្បធម៌ និងពាណិជ្ជកម្មជាមួយសហគមន៍នៃជនជាតិមន ដែលតាំងក្នុងទឹកដីថៃសព្វថ្ងៃ ដូចជាភាពស្រដៀងគ្នា នៃព្រះបដិមាតំណាងព្រះពុទ្ធអង្គ និងកាក់មាសដែលមានចារតួអក្សរដូចជា ព្រះបាទ " ស្រីទ្វារវតី " ជាដើម ។ ភស្តុតាងមួយទៀត គឺវត្តមានរបស់ព្រះពុទ្ធសាសនាថេរវាទ ដែលកើតចេញមកពីប្រទេសក្លិង្គ ( ស្រីលង្កា ) តែមួយដែលដើម



www.elibraryofcambodia.org

ឡើយគេយល់ថា លទ្ធិព្រះពុទ្ធសាសនានេះខ្មែរនាសម័យបុរាណ បានចម្លងពីបងប្អូនមន ។ នៅត្រង់នេះយើងចង់និយាយថា ទាំងខ្មែរទាំងមន បានប្រើប្រាស់នូវភាសាបាលីជាយានទាំងអស់គ្នា ថ្វីត្បិតតែខ្មែរចូលចិត្តនិយមភាសាសំស្ក្រឹតជាងភាសាបាលីក៏ដោយ ។

ប្រភពឯកសារចាស់ បានឱ្យដឹងថា ជនជាតិមនដែលកាន់ព្រះពុទ្ធសាសនាបានប្រើភាសាបាលី នៅចុងសតវត្សរ៍ទី៦ ដើមសតវត្សរ៍ទី៧ នៃគ្រិស្តសករាជ រីឯជនជាតិខ្មែរវិញ និយមប្រើភាសាសំស្ក្រឹតតែប៉ុណ្ណោះ ។ ថ្មីៗនេះ ការរកឃើញនូវបូជនីយដ្ឋានព្រះពុទ្ធសាសនា ព្រមទាំងចម្លាក់រូបកងចក្រ និងសិលាចារឹកជាភាសាបាលី នៅខេត្តបច្ចិមបុរី (ប្រាជិនបុរី) ដែលជាខេត្តមួយដែលមានជនជាតិខ្មែររស់នៅយ៉ាងកុះករនៅឡើយ បានបង្ហាញថា ពុទ្ធសាសនិកខ្មែរយើងនាសម័យបុរាណ ក៏បាននិយមភាសាបាលីដែលមានកំណើតចេញពីលង្កាទ្វីបទៅហើយដូចបងប្អូនមនអញ្ចឹងដែរ ។ តាមពិតការរកឃើញថ្មីខាងលើនេះ គ្រាន់តែផ្ដល់នូវពត៌មានបន្ថែម លើប្រភពឯកសារមួយទៀតស្ដីអំពីវត្តមានរបស់ភាសាបាលីនៅក្នុងអម្ពុងចុងសតវត្សរ៍ទី៦ ដើមសតវត្សរ៍ទី៧ នៃគ្រិស្តសករាជ គឺសិលាចារឹកភាសាបាលី ដែលគេបានចារឡើងនៅក្រោយខ្នង រូបព្រះពុទ្ធអង្គទ្រង់ឈរនៃទួលព្រះធាតុនៅខេត្តកំពង់ស្ពឺតែប៉ុណ្ណោះ ។ ការដែលអ្នកស្រាវជ្រាវថៃ បានសន្និដ្ឋានថាសមិទ្ធិផលជាវត្ថុវប្បធម៌បុរាណ ដូចជាប្រាង្គប្រាសាទ ព្រះរាជធានីចាស់ៗជាច្រើន ឬទីប្រជុំជនសំខាន់ៗ ដែលគេជួបប្រទះក្នុងទឹកដីថៃ នាសម័យបច្ចុប្បន្ននេះជា កម្មសិទ្ធិរបស់ជនជាតិមនទាំងអស់ គឺជាការបំភាន់ការពិត ។ សូមជម្រាបថា ការយល់ឃើញបែបដូច្នេះ ពុំមានលក្ខណៈត្រឹមត្រូវទេ ពីព្រោះមួយភាគធំនៃវត្ថុបុរាណ ត្រូវបានស្ថាបនាឡើងរវាង សតវត្សរ៍ទី១ ដល់សតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ពោលគឺមុនការបង្កើតរដ្ឋទ្វារវតី ។ ម្យ៉ាងទៀត ជនជាតិមនពុំបាន



www.elibraryofcambodia.org

ប្រាវជ្រឿទៅលើលិទ្ធិព្រហ្មញ្ញសាសនាទេ ។

ទន្ទឹមនឹងនេះ សូមកត់សម្គាល់ថា មានអ្នកប្រាជ្ញថៃ និងអឺរ៉ុបមួយចំនួននៅតែចាត់ទុកថា សិល្បៈនាគ្រាបឋមនៃប្រវត្តិសាស្ត្រនៅប្រទេសថៃ គឺជាសិល្បៈខ្មែរនាសម័យនគរភ្នំសុខោទ័យ ។

គ្មានអ្វីជាអាថ៌កំបាំងទេ ពីព្រោះសំណល់វប្បធម៌ចាស់ដែលមានវត្ថុបុរាណទាំងអស់នោះ ដែលគេបានរកឃើញក្នុងទឹកដីថៃ លាវ និងយួនសព្វថ្ងៃ មានដើមកំណើតជាខ្មែរ ។ ទាំងខឿនវប្បធម៌មន ទាំងខឿនវប្បធម៌ខ្មែរ ខឿនវប្បធម៌ទាំងពីរនេះ បានកើតចេញពីពុម្ពវប្បធម៌ដើមតែមួយ តាំងតែសម័យបុរេប្រវត្តិសាស្ត្រម្លេះ ។ ដូចនេះការពោលរបស់អ្នកស្រាវជ្រាវថៃ និងយួន បានធ្វើឡើងគ្រាន់តែមានវត្ថុបំណងតែមួយគត់ គឺការបំបាត់នូវលក្ខណៈប្រវត្តិសាស្ត្រនេះ ។ បានសេចក្ដីថា ទាំងវត្ថុបុរាណនាសម័យនគរភ្នំនៅស្រុកថៃ ទាំងវត្ថុបុរាណនាសម័យនគរភ្នំនៅស្រុកយួន ឬលាវ សុទ្ធសឹងតែជាវត្ថុបុរាណរបស់ខ្មែរទាំងអស់ ហើយការដែលគេចាត់ទុកថាជារបស់មន ដែលបានរលត់បាត់នគរទៅហើយនោះ ជាការខុសឆ្គងមួយដែលយើងពុំអាចទទួលស្គាល់ជាដាច់ខាត ។

សូមជម្រាបថា វត្ថុបុរាណទាំងនេះមានលក្ខណៈដូចគ្នា ក៏ប៉ុន្តែនៅស្រុកសៀមគេចាត់ទុកថាជារបស់មន ។ រីឯនៅស្រុកលាវវិញ គេចាត់ទុកថាជារបស់បុរាណទៅវិញ ។

មិនតែប៉ុណ្ណោះ វត្ថុបុរាណទាំងពីរប្រភេទនេះ ថ្វីត្បិតតែសព្វថ្ងៃស្ថិតក្នុងតំបន់ពីរខុសប្លែកពីគ្នា ក៏ប៉ុន្តែមានប្រភពនិងដើមកំណើតតែមួយ ពីព្រោះស្ថិតនៅលើអតីតអាណាចក្រខ្មែរតែមួយ ដោយគ្រាន់តែក្រោយមក មួយភាគធំនៃចក្រភពភ្នំ បានក្លាយទៅជាទឹកដីថៃតែប៉ុណ្ណោះ មួយភាគទៀត ក៏បានក្លាយទៅជាទឹកដីលាវ ឬ យួនតែប៉ុណ្ណោះ ។ ចំពោះយើងជាខ្មែរ យើងនៅតែបន្តចាត់ទុកថា របស់បុរាណទាំងអស់



www.elibraryofcambodia.org

នោះ ជារបស់ដូនតារបស់ខ្លួន ទោះបីទីតាំងអស់នោះបានឈប់ក្លាយជាកម្មសិទ្ធរបស់ខ្លួនក៏ដោយ ។ដូចនេះ ជាសច្ចភាពផ្នែកប្រវត្តិសាស្ត្រ ។

ដូច្នេះគ្រប់ការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រខ្មែរបុរាណ បើមិនបានយកការវិភាគខាងលើនេះធ្វើជាមូលដ្ឋានទេ មានន័យថាការស្រាវជ្រាវទាំងនោះ ក៏គ្មានយុត្តិធម៌ និងប្រកបដោយលក្ខណៈវិទ្យាសាស្ត្រដែរ ព្រោះថាវត្តមានរបស់ជនជាតិថៃ លាវ និង យួន នៅក្នុងភូមិភាគនេះ ជាព្រឹត្តិការណ៍ថ្មីថ្មោងទេ ។

ចំពោះវប្បធម៌-អារ្យធម៌ នៃទីក្រុងអង្គរបុរីនេះ នឹងមានរៀបចំសៀវភៅមួយដោយឡែក ។

២- ចំពោះយើងអង្គរបុរី គឺជាវិញ្ញាបុរៈ ពោលគឺ ពុំមែនបាភ្នំដែលលោក ហ្សក ស៊ុដែស បានពោលនោះទេ ។ តទៅនេះ យើងសូមជូនទូវខ្លឹមសារនៃចារឹកមួយដែលបានចារនៅលើសន្លឹកមាស ហើយដែលទាក់ទងនឹងការបោះបង់ចោលទូវព្រះរាជធានីនេះ នាសម័យនគរភ្នំ ដោយព្រះបាទភវវរ្ម័នទី១ ក្រោមការវាយលុករបស់ព្រះបាទ ចិត្រសេនមហេន្ទ្រវរ្ម័ន ដែលជាស្តេចនៃអាណាចក្រចេនឡា ។

សន្លឹកមាស ( ទំហំ៣១ X ៤ស.ម ) ¨ ដែលកប់ក្នុងជម្រៅដីជាង ១.៧០ម៉ែត្រ នៅចំកណ្តាលប្រាសាទ ( ឥដ្ឋ ) ត្រូវបានគេរកឃើញនៅទួល ហ្គោ-សាយ. ក្នុងសង្កាត់ ឌីកហ្កា. ដែលស្ថិតក្នុងតំបន់ ¨វាលកក់¨ ព្រមទាំងវត្ថុផ្សេងៗ១ឯទៀត ដែលក្នុងនោះមានវត្ថុធ្វើអំពីមាសចំនួន២៦ ។ សិលាចារឹក ( ដែលត្រូវបានចារលើសន្លឹកមាសនោះ ) ដោយស្មៀនរបស់ព្រះបាទ ភវវរ្ម័ ជាព្រះរាជបញ្ញត្តិរបស់ព្រះអង្គ ស្តីពីការដកទ័ពថយចំនួន ១០០.០០០ នាក់ ហើយម្យ៉ាងទៀតមុនការអនុវត្តន៍ ទូវព្រះរាជបញ្ជានេះ ប្រជាពលរដ្ឋបានកប់ទ្រព្យសម្បត្តិ. លោហធាតុមានតម្លៃ ( មាស ប្រាក់ កែវកង ) គ្រឿងអលង្ការ ព្រមទាំងរបស់មានតម្លៃទាប ដូចជាសរីទ្ធជាដើម ។ សញ្ញានិមិត្តជាសត្វ



www.elibraryofcambodia.org

ដីត្រូវបានគេយកទៅថ្វាយចំពោះពពួកទេវតា និង ព្រះឥន្ទ្រ ។ បន្ទាប់មក គឺការដកថយនៃកងទ័ពទៅកាន់តំបន់មួយដែលស្ថិតយ៉ាងឆ្ងាយពីនេះ ។ ក្នុងឱកាសនោះ ព្រះមហាក្សត្រ បានកោះហៅប្រជារាស្ត្រ របស់ព្រះអង្គឱ្យចុះចូលនឹងជំនឿសាសនាមួយថ្មីទើបតែរៀបចំឡើង ។ អត្ថបទសិលាចារឹកបានបន្តទៀតដោយលើកតម្កើងនូវបារមីព្រះព្រហ្ម ដែលបានដឹកនាំប្រជារាស្ត្រ ដែលចាញ់សង្គ្រាមឱ្យមានជំនឿលើសាសនាដែលទើបរៀបចំថ្មីនោះ។ ពត៌មាននេះមានសារសំខាន់ សម្រាប់ប្រវត្តិសាស្ត្រកម្ពុជា ដោយហេតុថា សិលាចារឹកបានពិពណ៌នាអំពីការវាយលុកទីក្រុង វ្យាធបុរៈ រាជធានីរបស់នគរភ្នំ ដោយការកាន់កាប់ នៃនគរភ្នំរបស់ ព្រះបាទចិត្រសេន មហិន្ទ្រវម្ម័ ដែលជាព្រះរាជានៃ ចេនឡា ដែលកំណត់ហេតុចិន នៃសន្តិវង្ស ស៊ុយ និង ថាំង បានគូសបញ្ជាក់យ៉ាងច្បាស់លាស់ ។

( ឯកសារ :- ហ្គិរ៉ារ-ហ្គេស្លាំង, កម្ពុជានាគ្រាបុរាណ, ទំព័រទី១០ នៅក្នុង អង្គរ និង សិល្បៈខ្មែរ ១០សតវត្សរ៍, ប៉ារីស, ឆ្នាំ១៩៩៧ )

៣- ទាំងជនជាតិថៃ ទាំងជនជាតិលាវ ជនជាតិទាំងពីរនេះស្ថិតក្នុងអម្បូរតែមួយ ដែលគេឱ្យឈ្មោះថា អម្បូរថៃ-វៀត ។ វត្តមានរបស់ជនជាតិថៃ ឬ សៀមនៅលើទឹកដីថៃសព្វថ្ងៃនេះ ( ព្រះរាជាណាចក្រថៃឡង់ ) គឺជាព្រឹត្តិការណ៍មួយថ្មីថ្មោងក្នុងទំព័រប្រវត្តិសាស្ត្រនៃឥណ្ឌូចិន ពីព្រោះមុនសតវត្សរ៍ទី១៣ នៃគ្រិស្តសករាជ ជនជាតិថៃ និងលាវ ពុំទាន់បានធ្វើដំណើរពីយូណាន់ ចុះមកកាន់ភូមិភាគឥណ្ឌូចិននេះនៅឡើយទេ ។ ដូចនេះហើយ បានជាគេជួបប្រទះនៅលើទឹកដីនៃប្រទេសថៃ និងលាវសព្វថ្ងៃនេះ នូវបុរាណស្ថានខ្មែរ នាសម័យមុនអង្គរ, អង្គរ និងក្រោយអង្គរជាច្រើន ដែលពុំអាចបញ្ចូលក្នុងខឿនវប្បធម៌ ថៃ-លាវ បានឡើយ ដោយហេតុថា ភូមិភាគដែលកាន់កាប់និងគ្រប់គ្រងសព្វថ្ងៃនេះ ដោយប្រទេសទាំងពីរនេះជាអតីតកម្មសិទ្ធិរបស់ជនជាតិខ្មែរយើង



www.elibraryofcambodia.org

នាសម័យបុរាណ ។ម្យ៉ាងទៀតគប្បីរំលឹកឡើងដែរថា ការកាន់កាប់ទឹកដីកម្ពុជាក្រោម ឬប្រទេសវៀតណាមខាងត្បូង ក៏ជាបញ្ហាថ្មីថ្មោងមួយទៀតដែរ ដែលបានប្រព្រឹត្តិឡើង ជាបន្តបន្ទាប់គ្នានៅដើមសតវត្សរ៍ទី១៧ នៃគ្រិស្តសករាជ ។ ដូច្នេះហើយ បានជាគេ ឃើញនៅក្នុងភូមិភាគនេះ នូវវត្តមានរបស់ជនជាតិខ្មែរជាច្រើនលាននាក់ ដែលជាម្ចាស់ ទឹកម្ចាស់ដីកំពុងរស់នៅ ព្រមទាំងវត្ថុបុរាណជាច្រើនដែលបានស្ថាបនាឡើង ដោយដូន តារបស់ខ្លួនតាំងតែពីបុរាណកាលម្ល៉េះ ។

រួមសេចក្តីមក ត្រូវតែស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរយើង ត្រូវតែយក ចំណុចជាប្រវត្តិសាស្ត្រទាំងប៉ុន្មានខាងលើនេះ ជាមូលដ្ឋាន បើពុំដូច្នោះទេ គេពុំអាច ស្គាល់នូវប្រភពនៃវប្បធម៌ និងអារ្យធម៌ខ្មែរដល់ជម្រៅបានឡើយ ។ អតីតប្រទេស កម្ពុជា ពុំមែនជាប្រទេសសព្វថ្ងៃនេះទេ ហើយផុយទៅវិញ ។ ក្នុងសម័យអតីតកាល ប្រទេសខ្មែរយើង ជាមហាប្រទេសដែលមានទឹកដីយ៉ាងធំធេងល្វាតូ ហើយទឹកដីនៃ ចក្រភពខ្មែរនេះ បន្តិចម្តងៗត្រូវបំព្រួញដោយការវាតទីនៃជនជាតិយួន ពារ និងសៀម ដែលជាអ្នកលេបទឹកដីខ្មែរ " avaleurs des terres khmères " បើតាមព្រះរាជឱង្ការ របស់ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រខ្មែរ នៃព្រះរាជា ណាចក្រកម្ពុជា ។

៤- វត្តមាននៃសិល្បៈខ្មែរ នាសម័យនគរភ្នំ និងចេនឡា នៅម្តុំវត្តភូដែលជា រាជធានីខ្មែរមួយដ៏ធំសម្បើម និងមានចំនួនយ៉ាងច្រើនឥតគណនាចាប់ពីសតវត្សរ៍ ទី៧ រហូតដល់សតវត្សរ៍ទី១៣ នៃគ្រិស្តសករាជ ពោលគឺមុនការវាយលុកដណ្តើមយក ទឹកដីនេះ ដោយព្រះបាទ ហ្វា ង៉ុំ ដែលជាស្តេចលាវមុនគេបង្អស់ ដែលស្តេចបានយាងមក ពីក្រុងអង្គរ ។ គេបើញមានជាអាទិ៍ នូវវត្ថុបុរាណជាច្រើន ដូចជាប្រាង្គប្រាសាទឥដ្ឋជា ច្រើនដែលគេហៅ ផ្តែរចំនួនពីរដែលជារចនាបថសម្បូរណ៍ព្រៃគុក ព្រះកេសនៃព្រះវិស្ណុ



www.elibraryofcambodia.org

ប្រាក់ ស្រះ ( កុរុក្សេត្រ ដោយព្រះបាទ ទេវានីកា នាសតវត្សរ៍ទី៥ នៃគ្រិស្តសករាជ ) ត្រពាំង អណ្តូង បល្ល័ង្ក តំកល់ព្រះគោនន្ទិនដែលមានចារសិលាចារឹកពីរផ្ទាំង ( ចុងសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ) របស់ព្រះបាទចិត្រសេន មហេន្ទ្រវរ្ម័ ( នៅឆ្នាំ ១៩៩០ - ១៩៩១ ) ត្បាល់ និង អង្រែកិនថ្នាំបុរាណ បំណែកទេវរូប ។ល។ ( សូមមើល : Santoni, M. 1993, Approche archéologique.......Ibid.)

៥- ចំពោះសិលាចារឹកខ្មែរនាសម័យនគរភ្នំ នៅកម្ពុជាក្រោម គេឃើញមានដូចតទៅ : K.៥ ( សរសេរជាភាសាសំស្ក្រឹត ២៧បន្ទាត់លើទ្វារស្តាំប្រាសាទ, សតវត្សរ៍ទី ៥ នៃគ្រិស្តសករាជ ផែរក្សាទៅសារមន្ទីរព្រៃនគរ ), K.៦ ( ភាសាខ្មែរ, សតវត្សរ៍ទី៦ នៃគ្រិស្តសករាជ, ១០បន្ទាត់, គ្មានកាលបរិច្ឆេទ ), K.៧ ( ភាសាខ្មែរ, សតវត្សរ៍ទី៨ នៃគ្រិស្តសករាជ, ត្រូវបាត់បង់ហើយ, ប្រែក ស៊ុំដេស, BEFEO XXXVI, ទំព័រ ៣-៥, បន្ទះរូបលេខទី ១-២ ), K.៨ ( ខ្មែរសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ, ១០បន្ទាត់, សារមន្ទីរជាតិភ្នំពេញ K.៤២១ ( សតវត្សរ៍ទី៨ នៃគ្រិស្តសករាជ, ១៨បន្ទាត់,BEFEO, XIII, បន្ទះរូបលេខ XXXI ), K.៥១៧ ( ភាសាខ្មែរ, សតវត្សរ៍ទី ៦-៧ នៃគ្រិស្តសករាជ, បាត់បង់ហើយ ) និង K.៧៩៨ មកពីផ្សារដែក, ប្រាសាទថាបមឿយ ) ។ ក្រៅរាប់បញ្ចូលក្នុងបញ្ជីឯកសារខាងលើនេះ នូវសិលាចារឹកអំពីផ្ទៀត គឺសិលាចារឹកខេត្តឡុងសៀង ដែលរូបភាពបោះពុម្ពក្នុងសៀវភៅនេះ និងចារឹកចារលើសន្លឹកមាសដែលបារ៉ា ហ្សេឡូង់ បានពលើងខាងលើ ។

៦- សិលាចារឹកចាស់ជាងគេបំផុតនៅប្រទេសថៃបច្ចុប្បន្ន ហើយមានកាលបរិច្ឆេទ គឺសិលាចារឹកនៃប្រាសាទភូមិពោន ស្រុកសង្ខៈ ខេត្តសុរិន្ទ្រ ដែលត្រូវចារឡើងនៅឆ្នាំ ៤៣៤ សក ត្រូវនឹងឆ្នាំ ៥១៣ នៃគ្រិស្តសករាជ ។ នេះសឱ្យឃើញថា ភូមិភាគឥសាននៃប្រទេសថៃបច្ចុប្បន្ន បានទទួលឥទ្ធិពលវប្បធម៌ឥណ្ឌានាសម័យនគរភ្នំម្លេះ



www.elibraryofcambodia.org

ថ្វីត្បិតតែនាសម័យនោះព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានឈ្មោះចេនឡានៅឡើយ ។ មួយវិញទៀត ស្ថានីយ៍បុរេប្រវត្តិសាស្ត្រដែលមានចំនួនរាប់មិនអស់ បានត្រូវគេរកឃើញក្នុងភូមិភាគនេះ ។ ក្នុងករណីនេះ វត្តមាននៃវប្បធម៌សៀមក្នុងតំបន់នេះ ទើបតែផ្តើមឡើងក្នុងសម័យក្រោយអយុធ្យា តែប៉ុណ្ណោះ ។

៧- តាមទស្សនៈលោកសាស្ត្រាចារ្យ ហ្សង់ ភីលីយោហ្សា ព្រះបាទមារញដែលដើមឡើយគេសរសេរថា មារៈ ដោយអានខុស ស្ថិតក្នុងត្រកូលកៅណ្ឌិន្យដែលបានយាងចេញមកពីប្រទេសឥណ្ឌាខាងត្បូង ដើម្បីមកកាន់នគរភ្នំ ។ វង្សត្រកូលកៅណ្ឌិន្យនេះវាពាក់ព័ន្ធទៅនឹងស្តេច តមិល ដែលបានបន្សល់សិល្បៈដែលមានលក្ខណៈចាស់ជាងគេបំផុតក្នុងចក្រភពភ្នំ ។

៨- ចំពោះរូបចម្លាក់មួយចំនួន ដូចដែលមានលេខរៀងនៅខាងក្រោមនេះ យើងពុំទាន់អាចសន្និដ្ឋានថា ជារបស់បុរាណសុទ្ធសាធបាននៅឡើយ ថ្វីត្បិតតែរូបទាំងនោះបានមកពីស្រុកអង្គរបូរីក៏ដោយ ។ ចំពោះយើងមានមន្ទិលសង្ស័យថា រូបទាំងនេះជារូបចម្លងចេញពីចម្លាក់បុរាណពិត១ ដែលអ្នកស្រុកបានយកទៅលក់ឱ្យបរទេស ។ រូបទាំងអស់នោះ គឺរូបទី២ នៃផែនរូប ៣៩, រូបទី៤ នៃផែនរូប ៤៨, រូបទី១ នៃផែនរូប ៥០, រូបទី២ នៃផែនរូប ៥៣, រូបទី៣ នៃផែនរូប ៥៦, រូបទី២ នៃផែនរូប ៨០, រូបទី១ និងទី ៣ នៃផែនរូប ៨១, រូបទី២ នៃផែនរូប ៨២, រូបទី២-៣ នៃផែនរូប ៨៣, រូបទី២ នៃផែនរូប ៨៤, រូបទី២ ក.ខ.គ និង ៣ ក.ខ នៃផែនរូបទី ៨៩, រូបទី ៣.៥ នៃផែនរូបទី ៩៨, រូបទី៤ ក.ខ ផែនរូបទី ១០០, រូបទី៣ នៃផែនរូប ១០៤ និង រូបទី៦ នៃផែនរូប ១០៥ ។ ក្រៅពីនេះ ចម្លាក់ទាំងថ្ម, ទាំងដីដុត ឬជាតិដើមផ្សេង១ សុទ្ធតែជាវត្ថុបុរាណពិតៗរបស់ខ្មែរ ដែលភាគច្រើនស្ថិតក្នុងសារមន្ទីរជាច្រើននៅឯបរទេស ។

៩ ចំពោះចំណងជើងរូបភាពខ្លះដែលមានសំណួរ (?), យើងពុំដឹងប្រភពឬ



www.elibraryofcambodia.org

ចំណាស់យ៉ាងប្រាកដ ។ មួយវិញទៀត វាអាចជារូបចម្លងផងដែរ ។ យើងភ្ជាប់មក គ្រាន់តែជាពត៌មានតែប៉ុណ្ណោះ ។

១០- ចំពោះពាក្យ "លុយ" យើងជឿថាពាក្យនេះកើតចេញពីពាក្យ Louis ដែលឲ្យមានន័យដូចពាក្យខ្មែរគឺកាក់ ។ សូនរំលឹកផងដែរថា ដោយសារមិនបានទទួលឥទ្ធិពលពីបារាំងជនជាតិខ្មែរសុរិន្ទ្រពុំស្គាល់ពាក្យ "លុយ" ។ គេនិយមពាក្យកាក់ ឬប្រាក់ទៅវិញ តាមបែបខ្មែរបុរាណ ។

## ប្រភពឯកសាររូបភាព

**លេខរៀងផែនរូប**

-ផែនរូបទី ១.៥.៦.៧.៨

ដកស្រង់ចេញពីសៀវភៅសិល្បៈ ពាមិល មុនពុទ្ធសករាជ ទី១៩ ឆ្នាំ ១៩៧៩ បាងកក ។

-ផែនរូបទី ៩

រូប១ និង ៤ ដកស្រង់ចេញពី : SRISUCHAT, Amar, 1990. Significiant archaeological objects in Thailand associated with Maritime Trade. The Silpakorn Journal, vol. 33, No 6. January - February.

រូប ២ ដកស្រង់ចេញពី : SMITH R-B and WATSON, W. 1979. Protohistory and the early historical kingdom. Early South-East-Asia ផែនរូបទី XL OXFORD.

រូប៣ ដកស្រង់ចេញពី PRACHABARN Mira kim and VIRAPASERT Mayuree 1988. New researches and theses. Artifacts from khwan lukpat in Krabi, Muang Boran Journal, vol. 10, No 1, Jan-March. សូមមើលរូបទំព័រ ១៣៦ និង WALES D and MACBILL. J.R, 1988. History and Archaeology of PATTANI, Muang Boran Journal, vol. 14, No 3 កក្កដា-កញ្ញា. រូបទំព័រ ៤៣ ។



www.elibraryofcambodia.org

-ផែនរូបទី ១០

រូប១ : ដកស្រង់ចេញពី : ទីក្រុងមឿងសិង្ហ និង ប្រាសាទ មឿងសិង្ហ ១៩៨៦. ក្រុមសិល្បករ ថៃ បាងកក សូមមើលរូបនៅទំព័រ ១២ ។

រូប២ : អាចមើល : ភិរិយៈក្រៃសីគុរ ១៩៩០ ។ ប្រវត្តិសិល្បៈ និងបុរាណវិទ្យា ប្រទេសថៃ. បាងកក ទំព័រ ១៨៥ និងនៅក្របសៀវភៅផ្ទាល់ ។

រូប៧ : ភិរិយៈ ក្រៃសីគុរ ១៩៨០. ប្រវត្តិសិល្បៈ..........ទំព័រ ១៨៩

រូប៨ : ដកស្រង់ពី : SRISUCHAT, Amara 1990. Significiant....... ទំព័រ13.

រូប៩ : ដកស្រង់ចេញពី : MALLERET, L 1959. L'archéologie du Delta du Mékong, Vol 1 PEFFO, សូមមើលផែនរូប ។

-ផែនរូបទី ១២

ដកស្រង់ចេញពី : ទីក្រុងបុរាណ និងផែនការថែរក្សា ពុទ្ធសករាជ ២៥៤២-២៥៤៩ ទស្សនាវដ្ដី មឿងបុរាណឆ្នាំ២៣ លេខ៣ កក្កដា-កញ្ញា ឆ្នាំ 1997 ទំព័រ 168 ។

-ផែនរូបទី ១៤

រូបដកស្រង់ចេញពី : សុភ័ក្រជិស ជីសកុល. ១៩៨៥ មឿងស្រីទេពនៃខេត្តពេជ្របូរ៍ណេ ទស្សនាវដ្ដី អ.ស.ថ (ទេសចរណ៍ប្រទេសថៃ ) ឆ្នាំទី២៦ លេខ៧ ។

ផែនរូបទី ១៥

ដកស្រង់ចេញពី : CUCARZO, Maur and ZOLESE, Patricia 1994, An attempt to inventory khmer monumental remains through geomagnetic modelling : The ancient city of Wat Phu Southeast



www.elibraryofcambodia.org

Asian Archaeology 1994. vol. II, Center for Southeast Asian Studies. University of Hull - ( Proceedings of the 5th International Conference of the European Association of Southeast-Asian Archaeology, Paris, 24th-28th October 1994) ។

-ផែនរូបទី ២០

រូប៤ : ដកស្រង់ចេញពីបុរាណវិទ្យា ជាភាគរូបរួមនៃបុរាណវិទ្យានៃភូមិភាគខាងត្បូង រូបទំព័រ១០៤ ក្រុមសិល្បករថៃ. ១៩៨៧ ( ពុទ្ធសករាជ ២៥៣១ ) ។

-ផែនរូបទី ២១

រូប២ក និង២ខ ដកស្រង់ចេញពី : HALLADE, Madeleine, 1968, Inde រូបភាពលេខ១៥៧ ទំព័រ២០០ រូប២ ។

-ផែនរូបទី ២២

រូប៤ : ដកស្រង់ចេញពី : THUAPAI ឬជាសិល្បៈទ្វារវតី ទស្សនាវដ្ដី សិល្បៈវប្បធម៌ឆ្នាំទី៨ លេខ៨ មិថុនា ឆ្នាំ១៩៨៦ ទំព័រ៥១ ។

-ផែនរូបទី ៣០

ដកស្រង់ចេញពី : HALLADE, Madeleine, 1968. Inde រូបភាពលេខ៤ ទំព័រ១៩ ។

-ផែនរូបទី ៣៣

រូប ៣-៤ : ដកស្រង់ចេញពី បុរាណវិទ្យាប្រវត្តិសាស្ត្រ. ១៩៨៥ ក្រុមសិល្បករថៃ រូបទំព័រ៨៦ សិលាចារឹកព្រះបាទ ចិត្រសេន អហោន្នវ័ន្ទទី២ K ៥០៥ ។

-ផែនរូបទី ៣៤

រូប១ : ដកស្រង់ចេញពីមគ្គុទ្ទេសក៍សារមន្ទីរ ស្រីធម្មរាជ ក្រុមសិល្បករថៃ



www.elibraryofcambodia.org

ឆ្នាំ១៩៨៥. រូបទំព័រ៧៧

រូប២ : ចម្លងពី Carte postale របស់សារមន្ទីរជាតិ នៅបាងកក ឆ្នាំ ១៩៨៩ ។

-ផែនរូបទី ៣៥

រូប១ : ដកស្រង់ចេញពី : មគ្គុទេសសារមន្ទីរ ស្រីធម្មរាជ, ក្រុមសិល្បករថៃ ឆ្នាំ១៩៨៥ រូបភាពនៅក្របសៀវភៅ ។

រូប៣ និង៤ ដកចេញពី : O'CONNOR, Stanley J. 1971. Hindu Gods of Peninsular Siam.

រូបភាពលេខ ៣០-៣១

រូប២ ដកស្រង់ចេញពី : ស្រ៊ស័ក្រវលលិភោតអ, ១៩៧៦ ចេញពីកំពង់ផែឈ្មុះតឹងដល់សង្ខ្លា, ទស្សនាវដ្តីមឿងបុរាណ, ឆ្នាប់លេខ២, លេខ២, មករា-មិនា, រូបថតទំព័រ៧០ ។

-ផែនរូបទី ៣៦

រូប១ ដកស្រង់ចេញពី : DUPONT, P 1956. Le Ganésa de Rochefort-Sur-Mer, Arts រូប៤ ដកស្រង់ចេញពី : O'CONNOR, Stanley J. 1971. Hindu.... រូបភាពលេខ៤ ។

ផែនរូបទី ៣៧

រូប ១, ២ និង ៣ ដកស្រង់ចេញពី : O'CONNOR, Stanley J. 1971 Hindu.... រូបភាពលេខ ២, ១៣ និង ១៥ ។

ផែនរូបទី ៣៨

រូប ១, ២ និង ៣ ដកស្រង់ចេញពី : O'CONNOR, Stanley J.



www.elibraryofcambodia.org

1971. Hindu.... រូបភាពលេខ ២៦ A ២១A និង ២៣A

រូបភាព៤ ដកស្រង់ចេញពី : HALLADE, M. 1968. Inde រូបភាពលេខ ១៥០, ទំព័រ២០០ ។

-<u>ផែនរូបទី ៣៩</u>

រូប៤ ដកស្រង់ចេញពី : HALLADE, M. 1968. Inde រូបភាពលេខ១៥១, ទំព័រ២០០ ។

-<u>ផែនរូបទី ៤០</u>

រូប២ ដកស្រង់ចេញពី : BOISSELIER, J 1965. Récentes recherches archéologiques en Thaïlande, Arts Asiatiques, XII និង ១៩៧៥. Travaux de la mission archéologique française en Thaïlande, xxv. សូមមើលផែនរូប ។

រូប៣ ដកស្រង់ចេញពី O'CONNER, Stanley J. 1971. Hindu Gods of Peninsula Siam, Artibus Asiae, Ascona-

រូបភាព ២០A ។

-<u>ផែនរូបទី ៤១</u>

រូប៣ ដលស្រង់ចេញពីទស្សនាវដ្តី Connaissance des Arts ។

រូប៤ ដកស្រង់ចេញពី FREDERIC, L. The Art of Southeast-Asia, Temples, and Sculpture, រូបភាពលេខ ២៦២ ។

-<u>ផែនរូបទី ៤២</u>

រូប១ក និង ១ខ ដកស្រង់ចេញពី : សុភ័ទ្រដិស ដិកុល ១៩៨៥ រឿងស្រីទេព ....ទេសចរណ៍ប្រទេសថៃ ។

-<u>ផែនរូបទី ៤៣</u>



www.elibraryofcambodia.org

រូប៥ ដកស្រង់ចេញពី : COOMARASWAMY, A.K, 1927, History of Indian Art and Indonesian Art Pl. New Delhi ។

-ផែនរូបទី ៤៩

រូប១ ដកស្រង់ចេញពី : ឯកសារថៃ

រូប២ ដកស្រង់ចេញពី : ឯកសារថៃ

រូប៣ ដកស្រង់ចេញពី : ឯកសារថៃ

រូប៤ ដកស្រង់ចេញពី : SARAYA, Thida, 1988, ស្រីទ្វារវតី បោះពុម្ពលើកទី៣ បាងកក រូបភាពទំព័រ១៧១ ។

-ផែនរូបទី ៥០

រូប២ ដកស្រង់ចេញពី : MALLERET, 1963. L'archéologie du Delta du Mékong, vol. XLIII, ផែនរូបទី VI.

រូប ៣ ដកស្រង់ចេញពី : ភិរិយៈក្រៃសិក្ស, ១៩៩០, ប្រវត្តិសិល្បៈ....ទំព័រ ២២៥.

រូប៤ ដកស្រង់ចេញពី : ទស្សនាវដ្ដី មឿងបុរាណ ច្បាប់ពិសេសស្ដីពីខេត្តអ៊ូថង់ រាជធានី, ប្រទេសថៃ ។

-ផែនរូបទី ៥២

រូប៤ ដកស្រង់ចេញពី : ភិរិយៈក្រៃសិក្ស ១៩៩០, ប្រវត្តិសាស្ត្រសិល្បៈ និងវត្ថុបុរាណវិទ្យានៃប្រទេសថៃ, បាងកក ។

-ផែនរូបទី ៥៤

ព្រះសិរៈជិនគោនទិ, ថ្ម, បង្គោលសីមាតុបតែងក្លោងទ្វារចូលទីក្រុងអង្គរបុរី ឬវ្យាធបុរៈ ( សារមន្ទីរហ្គីមេ, ប៉ារីស)២-៣ ព្រាហ្មណ៍បុរោហិត, ព្រះបរិហរៈ,



www.elibraryofcambodia.org

ជីជុត អង្គរបូរី ។

-ផែនរូបទី ៥៥

រូប ១,២ និង : MALLERET, 1961. L'archéologie du Delta du Mékong, vol. 3. PEFEO Paris. សូមមើលផែនរូប ។

រូប៥ ដកស្រង់ចេញពី : ភិរិយៈ ក្រែសីកុ្យ ១៩៩០ ប្រវត្តិសាស្ត្រសិល្បៈ..... ។

-ផែនរូបទី ៥៧

រូប៤ MALLERET, L. 1963. L'archéologie du Delta du Mékong vol. 4 Le Cibassac

ផែនរូបទី XII-PEFEO, vol XLIII. Paris ។

-ផែនរូបទី ៥៨

រូប ១, ២, ៣ និង ៤ ដកស្រង់ចេញពី : ភិរិយៈ ក្រែសីកុ្យ ១៩៦០ ប្រវត្តិសាស្ត្រសិល្បៈ..........ទំព័រ ២២៤-២៣៥ ។

-ផែនរូបទី ៥៩

រូប៤ ដកស្រង់ចេញពី : មទស អោភាកុល, ១៩៩៧, បញ្ហាទីក្រុងសុផាន់ភូមិ, ទស្សនាវដ្តី មឿងបុរាណ, ឆ្នាំលេខ ៣, កក្កដា-កញ្ញា រូបទំព័រ១៥៧ មកពីទីក្រុងអ៊ូថង ( អ៊ូទង )

រូប៥ ដកស្រង់ចេញពី : BOISSELIER, J. 1966. Manuel d'Archéologie d'Extrême- Orient, le Cambodge. I. សូមមើលរូបភាពនៅទំព័រទាក់ទិននឹងវិស័យប្រវត្តិសាស្ត្រ ។

-ផែនរូបទី ៦១

រូប៣ ដកស្រង់ចេញពី : NOONSUK, Breecha, 1984. Si Chon : an ancient Hindu site Muang Boran Journal, vol. 10 N° 1-Jan-



www.elibraryofcambodia.org

March. ទំព័រ៤៨ ផែនរូបទី៦ ។

-ផែនរូបទី ៦៦

រូប ១, ៣ និង ៤ ដកស្រង់ចេញពី : ភិរិយៈ ក្រៃសីក្សា ១៩៦០ ប្រវត្តិសាស្ត្រ សិល្បៈ........ទំព័រ ១៨១, ១៩០ និង ១៩៧ ។

-ផែនរូបទី ៦៩

រូប៧ និង ៨ ដកស្រង់ចេញពី : The Oc Eo - Funan culture, The Long

An province Department of Archaeology TAN AN 1990 - និង Van Hoa Oc Eo va cac van hoa co Dong bang cuu long - Long Xuyen 1984 ។

-ផែនរូបទី ៧០

រូប២ ដកស្រង់ចេញពី : អោភាកុល, អាណោចក្រភ្នំ និង អង្គរ, ទស្សនាវដ្ដី មឿងបុរាណ, ឆ្នាំទី២២, ច្បាប់២២, លេខ៣ កក្កដា-កញ្ញា ឆ្នាំ១៩៩៦, ទំព័រ ១២៩ ។

រូប២ ដកស្រង់ចេញពី : អោភាកុល, អាណោចក្រភ្នំ និង អង្គរ, ទស្សនាវដ្ដី មឿងបុរាណ, ឆ្នាំទី២២, ច្បាប់២២, លេខ៣ កក្កដា-កញ្ញា ឆ្នាំ១៩៩៦, ទំព័រ ១២៩ ។

-ផែនរូបទី ៧១

រូប១ ដកស្រង់ចេញពី : HALLADE, M. 1968. Inde. Un millénaire d'art bouddhique. Rencontre de l'Orient et l'Occident, Fribrurg, Illustration N° 40.

រូប៥ ដកស្រង់ចេញពី : ភិរិយៈ ក្រៃសីក្ស, ១៩៩០, ប្រវត្តិសាស្ត្រសិល្បៈ.....



www.elibraryofcambodia.org

ទំព័រ២២២ ។

-ផែនរូបទី ៧៣

រូប២ ដកស្រង់ចេញពី : MALLERET, L. 1961. L'archéologie du Delta du Mékong, vol. XLIII, Tome 2, មើលរូបទី LXXXIV រូបទី២ ។

-ផែនរូបទី ៧៤

រូប១ និង ៣ ដកស្រង់ចេញពី : ភិរិយៈ ក្រៃសីក្ស. ១៩៩៦. ប្រវត្តិសាស្ត្រសិល្បៈ......... ។ទំព័រ២០៩ ។

-ផែនរូបទី ៧៧

រូប៤ ដកស្រង់ចេញពី : PHILIPPE-GROSLIER, B. 1966, L'Indochine រូបលេខ៩ ។

-ផែនរូបទី ៧៨

រូប១ ដកស្រង់ចេញពី : FRÉDERIC, L. The Art of Southeast - Asia, Temples and Sculpture រូបលេខ២៥០ ។

រូប៣ ដកស្រង់ចេញពី : ភិរិយៈ ក្រៃសីក្ស. ១៩៩៦. ប្រវត្តិសាស្ត្រសិល្បៈ.... ទំព័រ២៤៣, រូប៤ ។

-ផែនរូបទី ៨០

រូប១ ដកស្រង់ចេញពី : PHILIPPE-GROSLIER, B 1966, L'Indochine. មើលរូបភាពលេខ១៩ ។

រូប៣ ចម្លងចេញពី : ប័ណ្ណប្រៃសណីយ៍ នៅសារមន្ទីរ នៅអាំស្ទែកដាំ, ប្រទេសហូឡង់ ។

-ផែនរូបទី ៨២



www.elibraryofcambodia.org

រូប៣ ដកស្រង់ចេញពី : SMITH R.P and WASTON W, 1979. Early South-East Asia,....Oxford University Press ។

-ផែនរូបទី ៨៤

-ផែនរូបទី ៨៥

រូប១ ដកស្រង់ចេញពី : MALLERET L, 1963. L'archéologie... ផែនរូបទី XXXII.

រូបទី២ ដកស្រង់ចេញពី : SMITH R - B and WATSON W. 1979. Early South-East-Asia,....
ផែនរូបទី XII b.

រូប៣ ដកស្រង់ចេញពី : ភិរិយៈ ក្រៃសឹក្ស, ១៩៨៩ ប្រវត្តិសិល្បៈ.....បាងកក, ទំព័រ២១២ ។

-ផែនរូបទី ៨៦

រូប២ ដកស្រង់ចេញពី : SMITH R-B and WATSON, W 1979. Early South-Asia...Oxford.
រូប៥ ដកស្រង់ចេញពី : ភិរិយៈ ក្រៃសឹក្ស ១៩៨៩ សិល្បៈតាមិល មុនពុទ្ធសករាជ១៩, បាងកក, ទំព័រ១៤១ ។

-ផែនរូបទី ៨៧

រូប២ SMITH, R -B and WATSON, W. 1979. Early South-East Asia. Protohistory...
ផែនរូបទី XII d. Oxford.

រូប៤ ដកស្រង់ចេញពី : PHILIPPE - GROSLIER, B. 1966, L'indochine. N°15.



www.elibraryofcambodia.org

រូប៥ ដកស្រង់ចេញពី : MALLERET, L. 1963. L'archéologie...

ផែនរូបទី XXIII.

-ផែនរូបទី ៨៨

រូប៣ ដកស្រង់ចេញពី : MALLERET, L. 1963. L'archéologie.

ផែនរូបទី XXX.

-ផែនរូបទី ៩១

រូប២ ដកស្រង់ចេញពី : SMITH R-B. and WATSON, W. 1979. Early South-East Asia.. Oxford

-ផែនរូបទី ៩២

រូប៤ កម្មសិទ្ធិផ្ទាល់ខ្លួនរបស់លោកអតីតទីប្រឹក្សាទូតរុស្ស៊ី នៅរាជធានីភ្នំពេញ ។

-ផែនរូបទី ៩៥

រូប១

រូប២ ដកស្រង់ចេញពី : PAK NAM, No Na, Dvaravati art styles in Pattani, Muang Boran Journal.

រូប៤

-ផែនរូបទី ៩៨

រូប១ ដកស្រង់ចេញពី : គីរិយេះក្រែស៊ីក្ស. ១៩៦០ ប្រវត្តិសិល្បៈ... ទំព័រ២៣៨ ។ រីឯទេវរូបព្រះគណេសវិញមានក្នុងសៀវភៅនេះដែរ នៅទំព័រ២៣៧ ។

រូប២ ដកស្រង់ចេញពី : WRIGHT, Michael, 1985. Images of Ganesa in Siam, ilestration P. 78, Muang Boran Journal, July-Sept. vol 11, 3.



www.elibraryofcambodia.org

-ផែនរូបទី ៩៩

រូប១ ដកស្រង់ចេញពី : BOISSELIER, J. 1965. Récentes découvertes... និង 1972. Travaux de la mission archéologique.. សូមមើលរូបភាពក្នុងឯកសារទាំងនោះ ។

-ផែនរូបទី ១០០

រូប២ រកឃើញនៅអង្គរបូរី តែអ្នកស្រុកបានយកទៅលក់ឱ្យឈ្មួញថៃហើយ ។

-ផែនរូបទី ១០៨

រូប១ និង រូប៣ ដកស្រង់ចេញពី : NOONSUCK Preecha, 1984. Si Chon : an ancient hindu site Muang Boran Journal, vol. 10, N° 1, January-March រូបទំព័រ៣៧ និង ៤០ ។

រូប២ ដកស្រង់ចេញពី : ស្រីស័ក្រវល្លិភោតម. ចេញពីកំពង់ថៃ ឈ្មោះតឹងដល់សង្ខ្លា ទស្សនាវដ្ដី មឿងបុរាណ ច្បាប់២ លេខ២ មករា - មិនា ១៩៧៦ រូបភាពទំព័រ៦៧ ។

រូប ៤, ៦ និង ៧ ដកស្រង់ចេញពី : PAK NAM, No Na Dvaravati Art styles in Pattani, Muang Bran Journal.

រូប៥ ដកស្រង់ចេញពី : SARAYA, Thida, 1988, Sri Dvaravati, Third Edition, Bangkok, រូបនៅទំព័រ១២៦ ។

-ផែនរូបទី ១០៩

រូប១១ វត្ថុបុរាណថៃរក្សាទុក រកឃើញក្នុងក្រឡមួយ នៅតំបន់សៀមរាប ដកលំទុកនៅសារមន្ទីរហ្គីមេ, ទីក្រុងប៉ារីស ដោយមានលេខសារពើភ័ណ្ឌ MG 24478 ។



www.elibraryofcambodia.org

-ផែនរូបទី ១១០

រូប២ ដកស្រង់ចេញពី : MALLERET, L. 1960. L'archéologie du Delta du Mékong. Tome 2 PEFFO, vol. XLIII, សូមមើលផែនរូប ។

-ផែនរូបទី ១១១

រូប ៦ - ១០ : ដកស្រង់ចេញពី : MALLERET, L. 1961. L'archéologie du Delta du Mékong. សូមមើលផែនរូប ។

រូប ៦ -១០ : ដកស្រង់ចេញពី : BOISSELIER, J 1965. Récentes recherches... Travaux de la mission....

-ផែនរូបទី ១១២

រូប ៤-៩ ដកស្រង់ចេញពី : MALLERET, L. 1961. L'archéologie du Delta du Mékong ... សូមមើលផែនរូប ។

រូប ១២ - ១២ ដកស្រង់ចេញពី : BOISSELIER, J. 1961. Récentes recherches archéologiques en Thailande, Arts Asiatiques, XII. និង ១៩៧២. Travaux de la mission archéologique française en Thaïlande, Arts Asiatiques, XXV. សូមមើលរូប និង ផែនរូប ។

-ផែនរូបទី ១១៣

រូប២ ដកស្រង់ចេញពី : MALLERET, L. 1960. L'archéologie du Delta... ផែនរូបទី XCIV.

-ផែនរូបទី ១១៤

រូប១ ដល់២៨ ដកស្រង់ចេញពី : MALLERET, L. 1960. L'archéologie du Delta.... សូមមើលផែនរូប ។

រូប២៩ និង ៣០ ដកស្រង់ចេញពី : BOISSELIER, J. 1965. Récentes



www.elibraryofcambodia.org

| | | | | | | |
|---|---|---|---|---|---|---|
| | កៅណ្ឌិន្យ-ជ័យវរ្ម័ន | | មហាកពាយ ហើយការ ពង្រីកយាន | នៅខេត្ត ចាំប្លា. នគរស្រីធម្មរាជ ល៉េតទី ។ល។ នៃឈូងសមុទ្រ សៀមសព្វថ្ងៃ | ជំនឿផ្សំ រវាង ព្រហ្ម និយម សាសនា មន-ខ្មែរ | ប្រទេសនគរភ្នំ ឡើង ដល់កំពូល ចងស្ពានមេត្រី ភាពតាមរយៈទូត ជាមួយចិន |
| ៦១៥-៦២៨ | ព្រះបាទឥសាន វរ្ម័នទី១ | ឥសានបុរី (សម្បូណ៌ព្រៃគុក) | | | | ព្រហ្មញ្ញសាសន៍ និងព្រះពុទ្ធសាសនា |
| ស.វទី៦-ស.វទី៨<br>៥៥០-៦០០ | សម័យចេនឡា ភវវរ្ម័នទី១ | ភវបុរៈ | រាជធានីថ្មី ថាលាបរិវ៉ត | | ព្រហ្មញ្ញ សាសនា ផ្សំនិង ពុទ្ធសាសនា | ការចាប់ផ្ដើមវាយ ប្រទេសនគរភ្នំ វាយបានតំបន់ទំនាបកណ្ដាលនៃ មន្ទ្រមេគង្គ<br>-ចងស្ពានមេត្រីជា មួយនិងចម្ប៉ា |
| ៦០០-៦១៥ | មហេន្ទ្រវរ្ម័ន របស់ភវវរ្ម័នទី១ | | (រាជធានី ចេនឡា, សម្បូណ៌ព្រៃគុក ព្រៃក្មេង កំពង់ព្រះ) | | | វាយយកបានតំបន់ ខេត្តក្រចេះ និង មង្គលបុរី |
| | | ឥសានបុរៈឬ សម្បូណ៌ ព្រៃគុក កំពង់ធំ | | វត្តមានសិល្ប: នៅវៀតណាម ខាងត្បូង សៀម លាវ និង កម្ពុជា បច្ចុប្បន្ន | | វាយយក បានខេត្ត កណ្ដាល ព្រៃវែង តាកែវ និង ច័ន្ទបុរី ចងស្ពានមេត្រីជា មួយចិន និង ចម្ប៉ា |
| ៦០៨-៦៥៥ | ភវវរ្ម័នទី២ | | | | | |


www.elibraryofcambodia.org

| | | | | | | |
|---|---|---|---|---|---|---|
| ៦៥៥-៦៨១ | ជ័យវរ្ម័នទី ១ | ឥសានៈ ឧតរ ( ចាំ ) | | | គណៈបរិបាលៈធំ និង ព្រាហ្មណ៍ សាសនា | វប្បធម៌ អារ្យធម៌ ចេនឡាឡើងដល់ កំពូល |
| ៧១០-៧១៥ | ការដណ្តើមរាជ្យសម្បត្តិគ្នា<br>ចេនឡាដីគោក<br>ចេនឡាទឹកលិច | ព្រៃវែង<br>ភវៈបុរៈ<br>សម្ភុបុរៈ | | | | ការរាតត្បាតរបស់ជ្វា និងអាណាចក្រ ព្យាការរបស់ជ្វា មកលើចេនឡាទឹកលិច |

១ ពាក្យ ប្លុក់ ដែលគេសរសេរជាអក្សរចំណ ត្រូវជាពាក្យដែល បែរភាសាសំស្ក្រឹត ។ អ៊ុំបុរាណ សំដៅទីក្រុងសក្ការៈ ឬ ស្តេច ។



www.elibraryofcambodia.org




www.elibraryofcambodia.org

## ផែនទីរូបទី១




www.elibraryofcambodia.org

## ផែនរូបទី២




ដែនដីខេត្តនានា នៃអតីត ប្រទេសឥណ្ឌា

ចាប់តាំងពីសតវត្សទី១ នៃ គ.ស រាណាខេត្តជាច្រើន នៃអតីតប្រទេសឥណ្ឌា បានចូលរួមចំណែកក្នុងការស្ថាបនា នូវរដ្ឋខ្មែរដំបូងបង្អស់ ដែលមានឈ្មោះថា នគរភ្នំ ។ ខឿនវប្បធម៌ . អារ្យធម៌ ដ៏មហារុងរឿង ភ្លឺថ្លើងនេះ បានបន្សល់ទុកនូវ រាជធានីបុរាណ និងវត្ថុបុរាណជាច្រើនក្នុងឧបទ្វីបឥណ្ឌូចិនយើងនេះដែលដើមឡើយជាទឹកដីលំនៅឋានរបស់ជនជាតិខ្មែរ។ ដោយសារការទាក់ទងផ្នែកវប្បធម៌ និងពាណិជ្ជកម្មរវាងខ្មែរ និងក្លិង្គ មានរយៈវេលាវែង បានជាសិល្បៈខ្មែរបានស្គាល់នូវគ្រប់រចនាបថ នៃប្រទេសឥណ្ឌាទាំងអស់ ។ មួយវិញទៀត ការដែលមានជនជាតិខ្មែរភាគតិចរស់នៅប្រទេសឡាវ, យួន និង សៀមនាបច្ចុប្បន្នកាលនេះក៏ពុំមែនជារឿងចៃដន្យដែរ ។ ជនជាតិខ្មែរទាំងអស់នោះគឺជាអ្នកដែលបាន តពូជពង្ស ពីសម័យនគរភ្នំមកយ៉ាងប្រាកដ ។

www.elibraryofcambodia.org

## ផែនរូបទី៣




ផែនទីនគរភ្នំ ឬហ្វូណន ឆ្នាំ ៦៥០ គ.ស ស្រាវជ្រាវដោយអ្នកប្រាជ្ញឥណ្ឌា



ផែនទីស្ដីអំពីទីតាំងបុរាណសំខាន់ៗ នៃ រដ្ឋនគរភ្នំ
ស.វ ទី ១ ដល់ ទី ៦ នៃ គ.ស

២

www.elibraryofcambodia.org

ផែនរូបទី៤




ផែនទីនៃរាជធានីខ្មែរខ្លះៗ នាសម័យនគរភ្នំ
ពី ស.វ ទី ១-៦ នៃ គ.ស

www.elibraryofcambodia.org








<u>រូបភាពទី ១-៦ :</u>

រូបទី១. តំបន់ស្រាវជ្រាវនៅខេត្តចម្ប៉ាសាក់ វត្តភូដោយមានស្ថានីយ៍ផ្សេងៗ (រូបនិងប្លង់ដោយ សាំងតូនី និង ហ្សង់ពីយែរបេស្យាហ្ស៍ ) ១.ផ្លូវ សាយ. ២.ណុងផ្កាវ. ៣.ណុងសម្បត្តិ. ៤.ផ្លូវ ខ្វក. ៥.ពានកូយ. ៦.ពានសាផាន. ៧.ណុងសម្បត្តិ. ៨.ការដ្ឋានថ្ម. ៩.ណុងសម្បត្តិណាំល. ១០.ណុងសម្បត្តិណាយ. ១១.ណុងសម្បត្តិបួពូរ៉ាង. ១២.ណុងសម្បត្តិនាយ. ១៣.ហួយក្លៀង. ១៤. សាងមៀង. ១៥.ណុងសាមៀង. រូបទី២-៦ ផ្តែរមុនអង្គរ. មុន៦០០ គ.ស : ២-ប្រាសាទថាទម្ហូនសាយ. ៣-ប្រាសាទណុងសម្បត្តិ រចនាបថថលាបរិវ៉ត. ៤-ប្លង់ប្រាសាទណាសំសៀន. មុនអង្គរ ស.វ ទី៦ នៃ គ.ស. ៥-៦ : សិលាចារឹកព្រះបាទមហេន្ទ្រវម៌្ម Ka177និង Ka178មុនឆ្នាំ៦៥០ គ.ស (រូបភាពរបស់សាំងតូនីថតក្នុងបរិវេណទីក្រុងស្រេស្ឋបុរៈ ឬលិង្គបុរៈ)



www.elibraryofcambodia.org

# ផែនទីរូបទី៥



ផែនទីស្ដីអំពី បុរាណស្ថាន នៃ ប្រទេសថៃបច្ចុប្បន្ន
នាសម័យនគរភ្នំ (ឯកសារថៃ)



www.elibraryofcambodia.org

ផែនរូបទី៦



រំដែនទីស្ដីអំពី ទីក្រុងខ្មែរបុរាណនាសម័យនគរភ្នំ
នៅក្នុងប្រទេសថៃ បច្ចុប្បន្ន ភូមិភាគខាងត្បូង
( ឯកសារថៃ )



www.elibraryofcambodia.org

## ផែនរូបទី៧




**ផែនទីស្ដីពីខ្យល់រដូវ ប្រទេសថៃភាគខាងត្បូងបច្ចុប្បន្ន**
**សម័យនគរគ្រឹ** (ឯកសារថៃ)



www.elibraryofcambodia.org

# ផែនរូបទី៨







ផែនទីស្តីអំពី ទីក្រុងនានានៃអាណាចក្រ នគរភ្នំ
ក្នុងតំបន់ភាគខាងត្បូងនៃប្រទេសថៃ បច្ចុប្បន្ន
( ឯកសារថៃ )



www.elibraryofcambodia.org

## ផែនរូបទី៩



១



២



៣



៤

<u>រូបភាពទី ១-៤ :</u>

សំពៅបុរាណ ស.វ ទី ៥-៦ គ.ស, ១-ស្នាមពុម្ព, នគរបឋម, ២-កាក់មានរូបសំពៅ ខេត្តសង្ខ្លា, ៣-៤ : ខេត្តនគរស្រីធម្មរាជ (ថៃបច្ចុប្បន្ន)



www.elibraryofcambodia.org




**រូបភាពទី ១_១០:**

ចង្កៀង និង កាក់រ៉ូម៉ាំង ចក្រភពនគរភ្នំ ១_២.ចង្កៀង ដីដុត និង សំរិទ្ធ ពោរមទ្វេចៅប្រយ៉ា និង កញ្ចនៈបូរី គ.ស ៤០០_៦០០, ៣_៥.កាក់ អង្គរបុរី គ.ស ទី១_៣, ៨_៩.គ.ស ៣០០ បន្ទាយកុ និង ព្រៃនគរដង, ១០_កាក់រូវកែវ គ.ស ទី២_៣



www.elibraryofcambodia.org



( ប្រទេសថៃបច្ចុប្បន្ន )



www.elibraryofcambodia.org

ផែនរូបទី១២



ផែនទី នៃទីក្រុងរាជបុរី នាសម័យនគរភ្នំ

( បច្ចុប្បន្ន នៅប្រទេសថៃ )



www.elibraryofcambodia.org

## ផែនរូបទី១៣



១



២

### រូបភាពទី ១_៣ :

១_គ្រឹះនៃវត្តឈ្លង, ទិសខាងត្បូងជៀងខាងកើត, ទីក្រុងអ៊ូថង ខេត្តសុពណ៌បុរី ( បច្ចុប្បន្នប្រទេសថៃ ) ស.វ ទី៥_៧ គ.ស, ២_ចេតិយបូវត្ត ( ស្ថានីយ៍ទី១ ) ទីក្រុងអ៊ូថង, ៣_គូទឹកព័ទ្ធជុំវិញ ទីក្រុងអ៊ូថង



៣



www.elibraryofcambodia.org

# ផែនរូបទី១៤



១



## រូបភាពទី ១_៣ :

១_ផែនទីស្រីទេព, ខេត្តពេជ្របុរ,

២_ប្រាសាទឥដ្ឋស្រីទេព ស[illegible]_៧ នៃ

គ.ស ឡើងជាថ្មបាយក្រៀម

៣_គូទឹកព័ទ្ធជុំវិញ

២



៣



www.elibraryofcambodia.org

ផែនរូបទី១៥






www.elibraryofcambodia.org

ផែនរូបទី១៦






www.elibraryofcambodia.org

# ផែនរូបទី១៧



១



<u>រូបភាពទី ១_៣ :</u>

១_ស្ទឹងអង្គរបូរី, ការជីកកកាយតាមវិធីសាស្ត្រ ដោយក្រុមស្រាវជ្រាវខ្មែរ និង អាមេរិក នៅឆ្នាំ[illegible], ២_គ្រោងឆ្អឹងមនុស្ស និង កុលភាជន៍ ដាក់ម្ហូបអាហារ, គ.ស ១០០_៣០០

២



៣

www.elibraryofcambodia.org




ផែនទីនៃទីក្រុង អង្គរបុរី ដោយសាកលវិទ្យាល័យហាវៃ



www.elibraryofcambodia.org



១



២



៣

## ប្រព័ន្ធធារាសាស្ត្រអង្គរបុរី

**រូបភាពទី ១_៣ :**

ព្រែក, គូទឹក និង កំពែងព័ទ្ធជុំវិញទីក្រុង វ្យាធបុរៈ ស្រុកអង្គរបុរី ខេត្តតាកែវ



www.elibraryofcambodia.org

# ផែនរូបទី២០



១



២



៣

<u>**រូបភាពទី ១-៤ :**</u>

១- រូងភ្នំនៅចង្កេះភ្នំដា, គ.ស រវាង ៥០០-៦០០ អង្គរបុរី,



៤

២- ប្រាសាទរូងភ្នំ, ទិដ្ឋភាពទីទៅ, ចង្កេះភ្នំដា

៣- រូបពង្រីក,

៤-ប្រាសាទរូងភ្នំ,តំបន់ជំផន់, អំពើស្ទឹងព្រះ ខេត្តសង្កា



www.elibraryofcambodia.org

# ផែនរូបទី២១



១



២ក



២ខ

រូបក្បាច់កុដុ :

១. ភ្នំដា, ស.វ ទី ៥-៦ គ.ស.

២. (ក,ខ), ក្បាច់កុដុ, ថ្ម, ខេត្តម៉ាធុរ៉ា (ឥណ្ឌា), ស.វ ទី ២០០-៣០០



www.elibraryofcambodia.org

## ផែនរូបទី២២



១



២



៣

**រូបភាពទី ១-៤ :**

១-៣ : ប្រាសាទអាស្រមមហាឫសី, សិល្បៈភ្នំដា, ថ្ម គ.ស រវាង ៥០០-៦០០

៤- ទេវល័យ លំអដោយគុម្ពុគ្រប់ទិស, គ.ស ៥០០-៦០០ រជ្ជកាល រាជវង្ស បល្លវៈ នៅឥណ្ឌា ។



៤



www.elibraryofcambodia.org

## ផែនរូបទី២៣



១



២



៣

**រូបភាពទី ១_៣ :**

១_ ប្រាសាទហាន់ជ័យ ថ្ម. កំពង់ចាម គ.ស ៦០០

២_ ផ្តែប្រាសាទហាន់ជ័យ

៣_ កំពូលជាផ្កាឈូក រចនាបថភ្នំដា



www.elibraryofcambodia.org

## ផែនរូបទី២៤



១



២



៣



៤

<u>**រូបភាពទី ១-៤ :**</u>

ប្រាសាទហាន់ជ័យ និង ក្បាច់ក្បូរប្រាសាទ ខេត្តកំពង់ចាម

ចុង ស.វ ទី៦ ដើមទី៧ គ.ស



www.elibraryofcambodia.org

# ផែនរូបទី២៥



១



២



៣

<u>រូបភាពទី ១_៣ :</u>

ប្រាសាទរកាស្រមមរោះ ឫសី. ថ្ម នឹង ឥដ្ឋ. ក្រុមប្រាសាទ ខាងជើង. សម្បូរណ៍ ព្រៃគុក គ.ស ៦០០



www.elibraryofcambodia.org

## ផែនរូបទី២៦



១



២



៣



៤

**រូបភាពទី ១-៤ :**

អប្រង់ព្រាសាទតូចសម្រាប់រំលឹកព្រឹត្តិការណ៍

សង្រ្គាបព្រាសាទ ជីផុត. អង្គរបូរី. ស.វ ទី៥-៦ គ.ស



www.elibraryofcambodia.org

ផែនរូបទី២៧



១



២



៣



៤

រូបភាពទី ១-៤ :

១-៣ : ផ្តែរ, រចនាបថ ថលាបរិវ៉ត,

២- ផ្តែរប្រាសាទវត្ត ចុងគូ, វត្តបន់, ច័ន្ទបុរី គ.ស ៦០០

៤- បំណែកផ្តែរ, វត្តចុងគូ (ច័ន្ទបុរី)



www.elibraryofcambodia.org

## ផែនរូបទី២៨



១

Ka 193



២

Ka 194

រូបភា...

១_២ : សិលាចារឹកក្នុង រជ្ជកាល របស់ព្រះបាទ ភវវម៌្ម (ស្រីទេព)

៣_ ព្រះពុទ្ធអង្គ , ៤_ ព្រះវិស្ណុ ចុង ស.វ ទី៦



៣



៤



www.elibraryofcambodia.org



១



២



៣

<u>រូបភាពទី ១_៣ :</u>

ផ្តែរទ្វារប្រាសាទ, រចនាបថ ថលាបរិវ័ត ស.វ ទី៦ គ.ស

១_ ប្រាសាទព្រះធាតុ, ក្រចេះ (សារមន្ទីរ ភ្នំពេញ)

២_ ខេត្តស្ទឹងត្រែង (សារមន្ទីរជាតិភ្នំពេញ)

៣. ផ្តែរ ថ្ម, កែវសាពី រក្សានៅវត្ត សុភត្រនរាម, ខេត្តអ៊ូប៊ុន (បច្ចុប្បន្ន)



www.elibraryofcambodia.org



១



២

**រូបភាពទី ១_២ :**

ជនជាតិខ្មែរស្លៀកពាក់តាមក្បិង្គ. គំនូរដកស្រង់ចេញពីកំណត់ហេតុចិន ស្តីពីនគរលង្កាសូកា គ.ស រវាង ៥០០_៦០០

២. ចម្លាក់ជនជាតិឥណ្ឌា, សិល្បៈ ហ្គ្រិចកូ-រ៉ូម៉ាំង, ស.វ ទី៤ ( សារមន្ទីរ ប្រ៊ិទិសមុយហ្សេអ៊ុម )



www.elibraryofcambodia.org

## ផែនរូបទី៣១



Ka6 ១



Ka 194 ៤




៥



២

Ka 195



៣

Ka26

<u>**រូបភាពទី ១_៥ :**</u>

១_ការរកឃើញសិលាចារឹកភាសាសំស្ក្រឹត នៅរជ្ជកាលព្រះបាទជ័យវម្ម័ទី១ នៅអង្គរបុរី (Ka6) ដោយមីសែលត្រាណេ, ២_សិលាចារឹកស្រុកវៀកាញ់, រជ្ជកាលព្រះសីមារញ (?) ស.វ ទី៣ គ.ស, កម្ពុជាក្រោម, ៣_អង្គរបុរី ស.វ ទី៥_៦ (សារមន្ទីរជាតិ), ៤_សិលាចារឹកវត្តហ្លួងគូវ, វត្តភូ, រជ្ជកាលព្រះបាទគុណវម្ម័(?) ស.វ ទី៥ គ.ស នៅប្រទេសលាវ, ៥_ខ្មែរបុរាណ ៦០០_៧០០ សិលាចារឹកភាសាខ្មែរ ក ៧១០ ។



www.elibraryofcambodia.org

# ផែនរូបទី៣២



១



៤

Ka 32



Ka29 ៥



Ka86 ៦



Ka57

២



Ka84

៣

<u>រូបភាពទី ១_៥ :</u>

សិលាចារឹកអង្គរបូរី និង ព្រៃវែង, ១_ចារឹកសារមន្ទីរអង្គរបូរី, ២_ចារឹក, សារមន្ទីរអង្គរបូរី (K a 57), ៣_ជើងភ្នំសុពរកាលី Ka84 ស្រុកឆ្លូងក្រចេះ, គ.ស ៦០០_៧០០, ៤_អង្គរបូរី, អភិរក្សដ្ឋានសៀមរាប គ.ស ៦_៧, ៥_អង្គរបូរី, ភាសាខ្មែរ ស.វ ទី៦ ( សារមន្ទីរជាតិ )



www.elibraryofcambodia.org



Ka76

១



Ka 191

៣



២



K. 505

៤

Ka 192

<u>រូបភាពទី ១_៣ :</u>

សិលាចារឹក គ.ស ៦០០_៧០០, ១_ ខេត្តឡុងសៀង, រជ្ជកាលព្រះបាទជ័យវម៌្ម ទី១ (?) កម្ពុជាក្រោម (Ka 76), ២_ ខេត្តអ៊ូប៊ុនរាជធានី, រជ្ជកាលព្រះបាទ មហេន្ទ្រវម៌្ម, ៣_ ព្រះបាទមហេន្ទ្រវម៌្ម ខេត្តបុរីរម្យ, ៤_ ខាវរ៉ាំង K.505, ឆ្នាំ៦៣៩ នៃ គ.ស (សៀមបច្ចុប្បន្ន)



www.elibraryofcambodia.org

ផែនរូបទី៣៤



**រូបភាពទី ១-៣ :**

ព្រះវិស្ណុ, ថ្ម, នគរស្រីធម្មរាជ, កំពស់ ៧៨ស.ម (សារមន្ទីរនគរស្រីធម្មរាជ ), ២- វត្តសាលាចឹង, ឆៃ យ៉ា, សុរ៉ាតធានី, គ.ស រវាង ៣០០-៤០០, កំពស់ ៦៧ ស.ម(សារមន្ទីរបាងកក), ៣- អង្គរបូរី,(សារមន្ទីរជាតិភ្នំពេញ) ។



www.elibraryofcambodia.org

ផែនរូបទី៣៥



១



២



៣



៤



៥

<u>រូបភាពទី ១-៥ :</u>

១-២ : ព្រះវិស្ណុ, ថ្ម, ឥទ្ធិពលបល្លវៈ, បែបសិល្បៈតាមិល កំពស់ ២,៤២ម គ.ស រវាង ៣០០-៤០០, កប៉ង, ផាងង៉ា (រូបក្រោយ និង មុនជួសជុល ), ៣-៤ : ចម្លាក់ព្រះវិស្ណុ និង នាងឧមា ថ្ម ( ដូចគ្នា ), ៥- ជីជុត, អង្គរបូរី, សម័យកាលដូចគ្នា កំពស់ ៤១ ស.ម



www.elibraryofcambodia.org

## ផែនរូបទី៣៦



១



២ក



២ខ



៣



៤

រូបភាពទី ១_៤ .

១_ព្រះគណេស.ថ្ម. កម្ពុជាក្រោម គ.ស រវាង ៤០០_៥០០ (សារមន្ទីរ រ៉ូស្សី ផត ). ២_ទេវរូបកាន់ត្រីសូរជើងជាន់ក្របី. ជីផុត. អង្គរបុរី. គ.ស រវាង ៣០០_៤០០. ៣_ព្រះវិស្ណុ. ថ្ម. អូរកែវ. កម្ពុជាក្រោម គ.ស ៤០០_៥០០ (សារមន្ទីរព្រៃនគរ ). ៥_ព្រះវិស្ណុ. គ.ស ៤០០_៥០០ អង្គរបុរី (សារមន្ទីរជាតិភ្នំពេញ )



www.elibraryofcambodia.org

## ផែនរូបទី៣៧



១



២



៣



៤

<u>រូបភាពទី ១_៤ :</u>

១_ចម្លាក់ប្រាសាទឥណ្ឌា, ឥន្ទ្រាប្រទេស, គ.សទី៣, ២_ព្រះវិស្ណុ, ថ្ម ពេជ្របូរី, សារមន្ទីរបាងកក, ៣_ព្រះវិស្ណុ ថ្ម, កំពស់ ៦៥ ស.ម, ធគរស្រីធម្មរាជ គ.ស វាង ៣៥០_៤៥០, ៤_កាន់កងចក្រ, ធីផុត, អង្គរបូរី ស.វ ទី ៤_៥, កំពស់ ៣០ ស.ម



www.elibraryofcambodia.org



១



២



៣



៤

<u>រូបភាពទី ១_៤ :</u>

១_ព្រះវិស្ណុ, ថ្ម, សុំាតថានី, គ.ស ៥៥០_៦០០,

២_ព្រះវិស្ណុ, ស្ទឹងព្រះ, សង្ក្គា,

៣_វត្តស្រី វិជ័យ, សុំាតថានី, គ.ស ៥៥០_៦០០,

៤_ចម្លាក់ ទាក់ទិនព្រះពុទ្ធសាសនា, គ.ស ២០០_ ៣០០ ម៉ាធុរ៉ា, ឥណ្ឌា



www.elibraryofcambodia.org

## ផែនរូបទី៣៩


១


៣


២


៤

**រូបភាពទី ១_៤ :**

១_ព្រះកល្កិនអវតា អវតារបស់ព្រះវិស្ណុ, ថ្ម គ.ស រវាង៥០០_៦០០ (សារមន្ទីរ ហ្គីមេតារីស ), ២_កល្កិន កាន់លោកនៅដៃស្ដាំ, ជីដុត,អង្គរបូរី, គ.ស រវាង ៥០០_៦០០, បុរាណ? ៣_ចម្លាក់នៅសារមន្ទីរភ្នំពេញ, ៤_ចម្លាក់ថ្ម ព្រះពុទ្ធ-សាសនា, គ.ស ២០០_៣០០, ម៉ាធុរ៉ា, ឥណ្ឌា។



www.elibraryofcambodia.org

## ផែនរូបទី៤០


១


២


៣


៤

**រូបភាពទី ១_២ :**

១_ព្រះវិស្ណុ, ថ្ម, ស្មៀកធោលី, សុរ៉ាតធានី,

២_ថ្ម, អ៊ូថង(អូរទង) សុផាន់បូរី, គ.ស រវាង ៥៥០_៦០០

៣_ព្រះវិស្ណុ ខេត្តពេជ្របូរី, ប្រទេសថៃបច្ចុប្បន្ន

៤_ថ្ម, មកពីផ្ទូន ស្រីមហាពោធិ៍, ខេត្តបច្ចឹមបូរី ស.វ ទី៦(សារមន្ទីរហ្គីមេ)



www.elibraryofcambodia.org



១



២



៣



៤

<u>រូបភាពទី ១_៤ :</u>

១_ព្រះវិស្ណុ. ថ្ម. ទួលដៃបួន. កំពស់ ១.៨៣ម.
សារមន្ទីរជាតិ

២_ជីផុត. អង្គរបូរី ស.វ ទី៧ គ.ស កំពស់
០,៨៣ម ( បុរាណ? )

៣_ព្រះវិស្ណុ. កំពង់ចាមក្ជូវ ស.វ ទី៦ ( ស្រុក
បារាំង )

៤_រូបភាពព្រះសុរិយា. ធគរស្រីធម្មរាជ
គ.ស ៥០០_៦០០ ( សារមន្ទីរថៃ )



www.elibraryofcambodia.org

## ផែនរូបទី៤២



១ក



១ខ



២

**រូបភាពទី ១-២ :**

១-ចម្លាក់ព្រះនារាយណ៍, ថ្ម, គ្មានដៃជើង, ទីក្រុងស្រីទេព គ.ស រវាង ៥០០-៦០០ ខេត្តពេជ្របុិន (សៀម)

២-ចម្លាក់ព្រះនារាយណ៍, ថ្ម, បាក់ដៃ ទីក្រុងស្រីទេព, ខេត្តពេជ្របុិន (សារមន្ទីរជាតិបាងកក)



www.elibraryofcambodia.org

## ផែនរូបទី៤៣




<u>រូបភាពទី ១_៥ :</u>

១_ព្រះក្រិស្ណៈ,វត្តកោះ,កំពស់ ១,៦០ម, គ.ស ៥៥០_៦០០ (សារមន្ទីរជាតិ). ២_ព្រះក្រិស្ណៈ, ថ្ម, ស្រីទេពពេជ្របូរណ៍ (ផេតបូន), គ.ស ៥៥០_៦០០, កំពស់ ១,០៤ម (សារមន្ទីរបាងកក), ៣_ព្រះពលរាម, ភ្នំដា, ថ្ម, កំពស់ ១,[illegible], គ.ស ៥៥០_៦០០ (សារមន្ទីរជាតិ ), ៤_សំពត់, រូបពង្រីក, ៥_ព្រះក្រិស្ណៈ, រថនាបថភ្នំដា, សារមន្ទីរស្តុកខូល



www.elibraryofcambodia.org

## ផែនរូបទី៤៤



១



២



៣



៤

<u>រូបភាពទី ១_៤ :</u>

ទេវរូបថ្ម, អង្គរបុរី, គ.ស ៥០០_៦០០, ១_ព្រះកេសព្រះវិស្ណុ, ២_ព្រះនាងឧមា, ៣_៤ ព្រះក្រិស្ណ និង ព្រះកេស, សារមន្ទីរ ជាតិភ្នំពេញ



www.elibraryofcambodia.org

ផែនរូបទី៤៥



១



២



៣

<u>រូបភាពទី ១_៣ :</u>

ព្រះវិស្ណុថ្ម គ.ស ៥៥០_៦០០, ១_ព្រះវិស្ណុ កំពស់១.៤៨ម ស.វ ទី៦ គ.ស តំបន់វាំងស្រះ ខេត្តសុរ៉ាតធានី, ២_ព្រះវិស្ណុ, តំបន់គោកប៉ីប, ខេត្តបច្ចីមប៉ុរី ស.វ ទី៦ គុ.ស កំពស់ ១៦៧ ស.ម, ៣_នគរស្រីធម្មរាជ គ.ស



www.elibraryofcambodia.org

ផែនរូបទី៩៦



១ ២ ៣

**រូបភាពទី ១_៣ :**

១_ព្រះវិស្ណុ, ថ្ម, តាគូច, ផាងង៉ា, គ.ស ៥៥០_៦០០,

២_គោកប៉ុ, ស្រីមហាពោធិ៍(សារមន្ទីរខេត្តបច្ចិមបុរី) គ.ស ៥៥០_៦០០

កំពស់ ២៨,២ស.ម,

៣_អង្គរបុរី, សារមន្ទីរជាតិភ្នំពេញ



www.elibraryofcambodia.org

## ផែនរូបទី៤៧



១



២



Ka 83 A ៣

<u>រូបភាពទី ១_៣ :</u>

១_ព្រះហរិហរៈ,ថ្ម, រចនាបថភ្នំដា, អាស្រមមហារូសី, អង្គរបុរី តាកែវ ស.វ ទី៦, កំពស់ ១,៧៥ម, (សារមន្ទីរហ្គីមេ,ប៉ារីស). ២_ព្រះវិស្ណុ,ថ្ម, រចនាបថភ្នំដា អង្គរបុរី, តាកែវ ស.វទី៦ កំពស់ ២,៧០ម សារមន្ទីរជាតិភ្នំពេញ,៣_ថ្ម,អង្គរបុរី មានសិលាចារឹកជាគាថា, ៤_សិលាចារឹក, រជ្ជកាលព្រះបាទភវវម៌្ម **Ka129**,ខេត្តតាកែវ



Ka 129 ៤



www.elibraryofcambodia.org

# ផែនរូបទី៤៨



១



២



៣



៤



៥



៦

**រូបភាពទី ១_៦ :**

ព្រះវិស្ណុថ្ម. អង្គរបុរី. គ.ស ៦០០_៧០០.

១_អង្គរបុរី. សារមន្ទីរជាតិ. ២_ព្រះកេសវិស្ណុ លក្ខណៈខ្មែរ. កំពស់ ២៥,៥០ស.ម ៣_សារមន្ទីរជាតិ. ៤_ព្រះវិស្ណុរូបភាពព្រះគណេស គ.ស ៥_៦ (?) អង្គរបុរី. ៥_៦. ព្រះកេសព្រះវិស្ណុ. អង្គរបុរី



www.elibraryofcambodia.org



**រូបភាពទី ១_៦ :**

ចម្លាក់ និង ក្បាច់, ១_ទីក្រុងល្វ ឬ លពបូរី, ២_ព្រះកេសវិស្ណុ គ.ស ៥០០_៦០០, ៣_៤ : ក្បាលយក្ស និង សសរស្តូប, ៥_៦ : ក្បាច់ប្រាសាទ, វត្តកំពង់ហ្លួង, អង្គរបូរី គ.ស ៥០០_៦០០



www.elibraryofcambodia.org

## ផែនរូបទី៥០




<u>**បភាពធី ១_៦ :**</u>

ចម្លាក់ទេវតាផ្សេងៗ ១_ព្រះវិស្ណុ, ជីផុត, អង្គរបូរី គ.ស ៥០០_៦០០.(?) ២_ព្រះសុរិយា, ថាយហៀមថាន់ តៃនិញ កម្ពុជាក្រោម គ.ស ៥០០_៦០០, ៣_ទេវរូប, កំពស់ ៧៥ ស.ម.ចម្បាសក្តិ, លាវ គ.ស ៥៥០_៦០០,រូបភាពរបស់ហ្សិតូ ៤_ព្រះនាងគង្គា, ឧត្តរធានី គ.ស ៦០០_៧០០, ៥_យក្ស, អង្គរបូរី, ជីផុត, គ.ស ៤០០_៥០០.(?) ៦_ព្រះសីវៈជាតាបស, ថ្ម គ.ស ៦០០, សារមន្ទីរជាតិ។



www.elibraryofcambodia.org

## ផែនរូបទី៥១



១



២



៣



៤



៥

**រូបភាពទី ១_៤ :**

១_គោនណ្ឌិន, ថ្មភក់, របនាបថ ថលាបរិវ័ត, ក្របេះ ស.វ ទី៦ គ.ស, ២_សំរឹទ្ធ, ឃុំភ្នំដិន, ស្រុកគីរីវង់ តាកែវ ស.វ ទី៦_៧ គ.ស, ៣_ថ្មភក់, ទីក្រុងស្រីទេព ខេត្តភេជ្របុន ស.វ ទី៦_៧ គ.ស, ៤_ថ្ម, អង្គរបូរី, ខេត្តតាកែវ គ.ស ៦០០, ៥_ត្បូងគោ.កែវស្លូ, អង្គរបូរី ស.វ ទី៤_៥ គ.ស កំពស់១.៩ ស.ម



www.elibraryofcambodia.org

# ផែនរូបទី៥២



១



២



៣



៤

**រូបភាពទី ១_៤ :**

១ និង ៣ ព្រះស្គន្ទជិះលើក្ងោកថ្ម, អង្គរបុរី (សារមន្ទីរជាតិ) ២_ថ្ម, អង្គរបុរី, គ.ស ៦០០, ( សារមន្ទីរហ្គីមេប៉ារីស ), ៤_បំណែកព្រះស្គន្ទជិះក្ងោក, អយុធ្យា, កំពស់១១២ ស.ម គ.ស ៥០០_៥៥០



www.elibraryofcambodia.org

## ផែនរូបទី៥៣





១

២



៣



៤

<u>រូបភាពទី ១_៤ :</u>

ព្រះព្រហ្ម ថ្ម. អង្គរបុរី. ១_ថ្មសារមន្ទីរជាតិ. ២_ជីផុត កំពស់៥៧.៧ស.ម. ៣_ជីផុត កំពស់៣៦.៥ ស.ម. គ.ស ៥៥០_៦០០(?). ៤_ព្រះវិស្ណុចុងសម័យនគរភ្នំ. ម្ដុំវត្តភូ. ចម្លា[illegible]ភាពហ្សិត)

www.elibraryofcambodia.org

## ផែនរូបទី៥៤



១



២



៣

<u>រូបភាពទី ១_៣ :</u>

១_ព្រះសិវជិះលើគោ,ថ្ម រចនាបថភ្នំដា, បង្គោលនៃក្លោងទ្វារទីក្រុងអង្គរបុរី, សារមន្ទីរ ហ្គីមេ, ប៉ារីស, ព្រាហ្មបុរោហិត និង ព្រះហរិហរៈ, ជីផុត, អង្គរបុរី, ស.វ ទី៥_៦ គ.ស.



www.elibraryofcambodia.org

## ផែនរូបទី៥៥



១



៤ (ក,ខ)



២



៥



៣

**រូបភាពទី ១_៥ :**

១_កុដុ,ក្បាច់កំពូលប្រាសាទ, ឌីដុត, ២_យក្សពាក់ក្រសាល, អូរកែវ, កម្ពុជាក្រោម, ឥទ្ធិពលគុប្តៈ, ៣_ក្បាលយក្សពាក់ក្រសាល, អូរកែវ ឥទ្ធិពលគុប្តៈ, គ.ស ៦០០_៧០០, ៤_ក្រសាល, សំរិទ្ធ, ស្រុក អង្គរបូរី, តាកែវ ស.វ ទី៥_៦ គ.ស, ៥_កុដុ, ឌីដុត, អ៊ូថង, គ.ស ៥០០_៥៥០ កំពស់ ២៣,៨ស.ម



www.elibraryofcambodia.org



១



២



៣



៤

**<u>រូបភាពទី ១_៤ :</u>**

ចម្លាក់បរវតី ឬ ឧមា គ.ស ៥០០_៦០០ ១_ថ្ម សារមន្ទីរជាតិ, ២_ដីដុត, អង្គរបុរី, កំពស់ ៤៨ស.ម.បុរាណ (?) ៣_ថ្ម, អង្គរបុរី, កំពស់ ៣០ស.ម, ៤_សារមន្ទីរជាតិភ្នំពេញ



www.elibraryofcambodia.org



១



២



៣



៤

រូបភាពទី ១_៤ ៖

នាងបរវតី, ទុគ៌ា ឧមា, ឬ គ.ស ៦០០_៧០០, ១ ២ ព្រះនាងទុគ៌ា, ទួលពោធិ៍អាស្រោល, តាមប្តា, កំពង់ត្របែក, ព្រៃវែង កំពស់ ៥ស.ម, សារមន្ទីរជាតិ, ៣_ឧមាអង្គុយលើកំភ្លៅវិស្ណុ ជិះគោសំរិទ្ធ, សារមន្ទីរជាតិ, ទ្រង់ហ្សូវ, វិញឡុង, កម្ពុជាក្រោម។



www.elibraryofcambodia.org



១



២



៣



៤

<u>រូបភាពទី ១_៤ :</u>

១_ព្រះស្កន្ទ, ថ្ម, គ.ស ៥០០_៥៥០, កំពស់ ៣៥ស.ម, អយុធ្យា, ២_កីណរី, ដីដុត, គ.ស ៥០០_៥៥០, កំពស់ ២៣,៨ស.ម, អូរទង, សុផាន់បូរី, ៣_ទេពធីតា, ដីដុត, កំពស់ ២៦ស.ម ស្រីមហាពោធិ៍ បច្ចិមបូរី, ក្បាច់ដីដុត, [illegible]ធន, នគរបឋម, គ.ស ៥៥០_៦០០



www.elibraryofcambodia.org

## ផែនរូបទី៥៩


១


២


៣


៤


៥

<u>រូបភាពទី ១_៥ :</u>

១_យោគីសំរឹទ្ធ. អង្គរបុរី (ផ្ទះអ្នកស្រុក). ២_ឥសីដុត បុរាណ (?). ៣_ម្តាយ និង កូនសំរឹទ្ធ. អង្គរបុរី (សារមន្ទីរជាតិ ) កំពស់ ៨ស.ម. ៤_ម្តាយ[illegible] កូន សំរឹទ្ធ អ៊ូថង គ.ស ២០០_៤០០. សុផាន់បុរី. ៥_ប៉ូសេអ៊ីយ៉ុង. អូរកែវ សំរឹទ្ធ គ.ស ២០០_៤០០



www.elibraryofcambodia.org



១ ២ ៣

<u>រូបភាពទី ១_៣ :</u>

ព្រះសីវលិង្គ, ថ្ម,

១_សារមន្ទីរអង្គរបុរី, គ.ស ៥០០_៦០០,

២_វត្តគំនូរ, អង្គរបុរី, គ.ស ៤០០_៥០០,

៣_សម្បូរព្រៃគុក, គ.ស ៦០០_៦២០,



www.elibraryofcambodia.org



១ក



១ខ



២



៣

<u>**រូបភាពទី ១_៤ :**</u>

ព្រះសិវលិង្គ ថ្ម និង ដីដុត

១ និង ៤ : អង្គរបុរី គ.ស ៤៥០_៥០០,

២_អង្គរបុរី,

៣_ឆៃយ៉ា, សុរ៉ាតធានី, ថ្ម គ.ស ៤៥០_៥០០



www.elibraryofcambodia.org

## ផែនរូបទី៦២



១



៣



២



៤



៥



៦



៧



៨



៩



១០

<u>រូបភាពទី ១_១១ :</u>

ព្រះសិវលិង្គ និង ស្នានទ្រោនី, កែវ, ដីដុត, ស្រោបមាស អង្គរបុរី គ.ស ៥០០_៦០០ គេប់ខាត (រូបទី៣នៅសារមន្ទីរជាតិ )



www.elibraryofcambodia.org

## ផែនរូបទី៦៣


១


២


៣


៤

៥

៦

៧

៨

**<u>រូបភាពទី ១_៨ :</u>**

ស្ពានទ្រនាប់ ស.វ ទី៥_៦ គ.ស

១_៨ : ស្ពានទ្រនាប់, កែវស្ល, អង្គរបុរី



www.elibraryofcambodia.org

ផែនរូបទី៦៤




<u>រូបភាពទី ១_៧ :</u>

